សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ

គោលនយោបាយសារពើពន្ធ និង រូបិយវត្ថុ
FISCAL AND MONETARY POLICY

បណ្ឌិត សឺន សុទ្ធ
សាស្ត្រាចារ្យរងបណ្ឌិត ឆាយ គន្ធា

ឧបត្ថម្ភដោយ

CAMBODIA
RESEARCH CREATIVITY INNOVATION

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ

គោលនយោបាយសារពើពន្ធ និង រូបិយវត្ថុ

Fiscal and Monetary Policy

បណ្ឌិត សឺន សុទ្ធ
សាស្ត្រាចារ្យរងបណ្ឌិត ឆាយ គង្គា

២០២១

រក្សាសិទ្ធ

© ឆ្នាំ ២០២១

រក្សាសិទ្ធគ្រប់យ៉ាង

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំយុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា

ធំណាក់ធំនឧព័ត៌មាន:

អ្នកនិពន្ធ៖ បណ្ឌិត សឺន សុទ្ធ
ទូរស័ព្ទ៖ (+៨៥៥) ១២ ៧៨៨ ៩៧៧/(+៨៥៥) ៩៨ ៧៨៨ ៩៧៧
អ៊ីមែល៖ sonvisoth@gmail.com/webpage، economicstreet

©. 2021, Dr.Son Soth. All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition
Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:
Author: Dr. Son soth
Mobile phone: +855 98 788 977 / +855 12 788 977
Email: sonvisoth@gmail.com/webpage: economicstreet

បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានវិងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៌នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលធាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូជីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្តែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋនីដ៏ថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចនីដ៏ថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពស៊ប់ធ្លាក់។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការកែចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សូនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍នីដ៏ថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសូនឧស្សាហកម្មថាមពល និងឥន្ធនតីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសតឹការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកព័ត៌មាន និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៨៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរស័ព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំនីដ៏ថល និងមាតិកានីដ៏ថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មនីដ៏ថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកានីដ៏ថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកានីដ៏ថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំនីដ៏ថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាព ជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានជាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំនីដីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអក្សរកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលែលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាននីតិវិធីថ្នាលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ហានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការចោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជារួមគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.ត.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមស្រាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទួចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

សេចក្តីបញ្ជាក់
នៃមូលនិធិស្រាវជ្រាវ តំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ តំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ តំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរបកគំាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ តំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

ឧទ្ទិសកថា

កូនសូមឧទ្ទិសនូវអំណរអរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះវិញ្ញាណក្ខន្ធ លោកឪពុក **សឺន ណៃ** ដែលបានផ្តល់កំណើតឱ្យរូបកូន និងសតិបញ្ញា ភ្លឺថ្លា ឈ្លាសវៃ ដែលបានបីបាច់ថែរក្សារូបកូនកន្លងមក ជាពិសេសជាងនេះទៅទៀត ព្រមទាំងជីដូនជីតា បុព្វបុរសខ្មែរ អ្នកស្នេហាជាតិ ដែលបានបាត់បង់ជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ និងអស់លោកអ្នកប្រាជ្ញ បណ្ឌិត កវី បញ្ញវន្ត អ្នកនិពន្ធខ្មែរ ដែលបានបន្សល់ទុកនូវស្នាដៃ និងបទពិសោធន៍ល្អៗជាច្រើនឥតគណនាដល់កូនខ្មែរជំនាន់ក្រោយបានសម្រាប់សិក្សាស្រាវជ្រាវ។

ខ្ញុំសូមបួងសួងឱ្យវិញ្ញាណក្ខន្ធអស់លោកទាំងអស់បានទៅកើតនៅក្នុងសុគតិភពដែលជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន និងមានចំណេះវិជ្ជាខ្ពង់ខ្ពស់គ្រប់ៗជាតិ។

សេចក្តីថ្លែងអំណរគុណ

សៀវភៅ "គោលនយោបាយសារពើពន្ធ និងរូបិយវត្ថុ" នេះអាចប្រសូត្រចេញបានក៏ដោយសារតែមានការចូលរួម និងការផ្តល់វិភាគទានយ៉ាងធំធេងពីបណ្តាអ្នកវិទ្យាសាស្ត្រ និងឥស្សរជនដែលមានបទពិសោធន៍នៅក្នុងផ្នែកស្រាវជ្រាវកសិកម្មជាច្រើនរូប។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់ការពិនិត្យ និងផ្តល់ជាមតិល្អៗក្នុងការរៀបចំសៀវភៅនេះដោយ៖

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាអង្គភាពសាមី(សាកលវិទ្យាល័យភូមិន្ទកសិកម្ម)
- ឯកឧត្តម **សាន ឥន្ទ្រា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍
- សាស្ត្រាចារ្យរងបណ្ឌិត **ហួច ថាវរៈ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទសិកម្មកម្ម
- គណៈកម្មការត្រួតពិនិត្យមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងគណៈកម្មការត្រួតពិនិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយជ្រោមជ្រែងក្នុងការស្រាវជ្រាវ
- គណៈកម្មការត្រួតពិនិត្យ៖ លោកបណ្ឌិត ឆាំង ហ៊ុយ លោកបណ្ឌិត ម៉ក់ ពុទ្ធី លោកបណ្ឌិត លាប ប៉ូឡូ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត វង្ស ឌីណា លោក អេង លេង លោកស្រី ឆាយ ស្រីលីក្ខ លោកស្រី ហ៊ូ ផល្លា និងលោកស្រី ឆាយ ស្រីមុំ
- អ្នកផ្តល់យោបល់ ក៏ដូចជាអ្នកផ្តល់ឯកសារយោងទាំងភាសាជាតិ និងភាសាបរទេសនានា
- ក្រុមគ្រួសារជាទីស្រលាញ់របស់ខ្ញុំ ព្រមទាំងមិត្តភក្តិដែលបានជួយជ្រោមជ្រែងទាំងអស់

ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងឃ្លាប្រយោគ ការវាយអត្ថបទ ការរចនារូបភាព ដ្យាក្រាម និងក្រាហ្វិចមួយចំនួនតាមកម្មវិធីកុំព្យូទ័រសម្រាប់ជាឧទាហរណ៍នៅក្នុងការគណនា និងវិភាគទិន្នន័យនៅក្នុងវិធីសាស្ត្ររៀបចំការពិសោធន៍ផ្សេងៗ។

អារម្ភកថា

បញ្ហាសេដ្ឋកិច្ចគឺជាចំណោទបញ្ហា "**សង្គមជាតិគឺសង្គមសេដ្ឋកិច្ច**" សៀវភៅនេះបានរៀបរៀងឡើងដោយសម្អិតសម្អាងលើបញ្ហាសេដ្ឋកិច្ច សំដៅលើទិដ្ឋភាពទ្រឹស្តីគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុ ដោយផ្តើមចេញពីការវិភាគលើទ្រឹស្តីរូបិយវត្ថុទំនើបជាពិសេស។ ហេតុផលនៃការរៀបរៀងសៀវភៅនេះ ដោយសារតែអ្នករៀបរៀងបានយល់ឃើញថាប្រទេសកម្ពុជាបន្ទាប់ពីសង្គ្រាមស៊ីវិលអស់ជាច្រើនទសវត្សរ៍កន្លងមក ការចងក្រងសៀវភៅជាខេមរភាសាសម្រាប់អ្នកសិក្សាស្រាវជ្រាវមុខជំនាញសេដ្ឋកិច្ចនៅមានកម្រិត។ ហេតុនេះ អ្នករៀបរៀងនិពន្ធសៀវភៅនេះ បានខិតខំជ្រើសរើសសម្រិតសម្រាំងចងក្រងសៀវភៅជាខេមរភាសា ដោយបានដកស្រង់ចេញពីសៀវភៅ អត្ថបទ ខ្លឹមសារទ្រឹស្តី និងឯកសារភាសាបរទេសដ៏មានគុណតម្លៃខ្ពស់មកប្រែសម្រួលជាខេមរភាសាសម្រាប់អ្នកសិក្សាស្រាវជ្រាវដែលនិយមភាសាខ្មែរ។ ការរៀបរៀងស្នាដៃនេះគឺទាមទារពេលវេលា កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតីជាច្រើន ដើម្បីឱ្យស្នាដៃនេះ ចេលចេញជារូបរាងបាន។

ទន្ទឹមនឹងនេះ អ្នករៀបរៀងនិពន្ធសៀវភៅនេះ សុំការអធ្យាស្រ័យពីមិត្តអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនាក្នុងស្នាដៃនេះ ដូចជាកំហុសឆ្គងខាងអក្ខរាវិរុទ្ធ ដោយសារការពិនិត្យមិនបានគ្រប់ជ្រុងជ្រោយជាដើម។ ទន្ទឹមនឹងនេះ សូមថ្លែងអំណរគុណនូវការផ្តល់មតិកែម្អដើម្បីឱ្យស្នាដៃនេះកាន់តែមានគុណភាព ដើម្បីជាប្រយោជន៍ជាតិ និងសង្គមកម្ពុជារបស់យើងទាំងអស់គ្នា។

សៀវភៅនេះទៀតសោត គឺផ្តោតជាសំខាន់លើ "គោលនយោបាយសារពើពន្ធ និងរូបិយវត្ថុ" វិភាគលើគោលនយោបាយរបស់ធនាគារកណ្តាលដែលប្រើនូវឧបករណ៍គោលនយោបាយរូបិយវត្ថុ ដើម្បីឆ្លុះបញ្ចាំងពីគោលនយោបាយសេដ្ឋកិច្ចឱ្យមានស្ថិរភាពថ្លៃ កម្រិតនិកម្មភាពអតិបរមា និងកំណើនសេដ្ឋកិច្ចរយៈពេលវែង។

សូមឱ្យស្នាដៃនេះ បានជាជំនួយស្មារតីសម្រាប់លោកអ្នកអាន។

ថ្ងៃព្រហស្បតិ៍ ៦ រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២១

អ្នកនិពន្ធ

បណ្ឌិត សឺន សុទ្ធ

អ្នកនិពន្ធ



នាម និងគោត្តនាម ៖ **បណ្ឌិត សឺន សុទ្ធ**
អាសយដ្ឋាន ៖ ភូមិស្វាយឧត្តម សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ ភ្នំពេញ
ទីកន្លែងកំណើត ៖ ភូមិចាំងម៉ែ ឃុំប៉ៃលិន ស្រុករតនៈមណ្ឌល បាត់ដំបង
ស្ថាប័នការងារ ៖ អគ្គនាយកដ្ឋានពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឯកទេស ឬមុខជំនាញ ៖ សវនករពន្ធដារ

<u>ប្រវត្តិការសិក្សា៖</u>

- ២០២០-២០២២៖ កំពុងសិក្សាបន្តថ្នាក់ស្រាវជ្រាវក្រោយបណ្ឌិត
- ២០១៦-២០២០៖ បញ្ចប់ថ្នាក់បណ្ឌិតសេដ្ឋកិច្ច
- ២០០៣-២០០៥៖ បញ្ចប់ថ្នាក់អនុបណ្ឌិត
- ១៩៩៦-១៩៩៨៖ បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ
- ១៩៩៣-១៩៩៦៖ បញ្ចប់ថ្នាក់បរិញ្ញាប័ត្ររង
- ១៩៩២-១៩៩៣៖ សិក្សាថ្នាក់ត្រៀមមហាវិទ្យាល័យ
- ១៩៨៩-១៩៩២៖ ទទួលសញ្ញាប័ត្រទុតិយភូមិ

<u>បទពិសោធន៍ការងារ៖</u>

- ១៩៩៨-២០០០៖ បម្រើការងារនៅនាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ២០០០-២០១៤៖ បម្រើការងារនៅនាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ២០១៤-២០១៦៖ បម្រើការងារនៅសាខាពន្ធដារខណ្ឌ ឬស្សីកែវនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ២០១៦-២០២១៖ បម្រើការនៅសាខាពន្ធដារខណ្ឌដូនពេញនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

<u>បទពិសោធន៍បង្រៀនពីឆ្នាំ ២០០៩-២០២១៖</u>

- សាលាជាតិពន្ធដារ
- សាកលវិទ្យាល័យខេមរៈ
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (សាខាកំពង់ចាម)
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (ទីតាំងគោលបាត់ដំបង)
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (សាខាបន្ទាយមានជ័យ)
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (សាខាព្រះសីហនុ)

អ្នកនិពន្ធ



នាម និងគោត្តនាម ៖ សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គង្គា
(Assoc. Prof. CHHAY Kongkea, Ph.D.)

អាស័យដ្ឋាន ៖ ផ្ទះលេខ ២១១ ផ្លូវ ១១ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ស្ថាប័នការងារ ៖ មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

ឯកទេស ឬមុខជំនាញ ៖ បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចកសិកម្ម

ប្រវត្តិការសិក្សា៖

- 2003 - 2006: Ph.D. Degree in Economics, Major in Agricultural Economics Chonnam National University, Gwangju City, South Korea.
- 2001 - 2003: Master's Degree in Economics, Major in Agricultural Economics Chonnam National University, Gwangju City, South Korea.
- 1993 - 1998: Bachelor's Degree in Economics, Major in EnterpriseManagement Facultural of Law and Economics, Phnom Penh, Cambodia [Present: Royal university of Law and Economics (RULE)]
- 1993 - 1996: Diplôme de Baccalauréat en sciences économiques, Faculté de droit et des sciences économiques, Royaume du Cambodge.
- 1992 - 1993: Certificate of Preparatory Class, Institute of Economic Sciences.
- 1990 - 1992: Diplima Up-Grading of Psychogical Pedagogy, Major in Mathematic Battambang Psychogical Pedagogy School, Battamabng Province. (Present: National University of Management), Cambodia.
- 1990 - 1992: Diplima of Sinor Hight School, Battambang Secondary School, Battambang Province, Kingdom of Cambodia.

បទពិសោធន៍ការងារ៖

- ២០០៧ - បច្ចុប្បន្ន៖ ព្រឹទ្ធបុរសរង (Vice Dean) មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ព្រះរាជាណាចក្រកម្ពុជា
- ២០១២ - បច្ចុប្បន្ន៖ សាស្ត្រាចារ្យរង(Associate Professor)តាមអនុក្រឹត្យលេខ៥៤៤ អនក្រ.តក ស្តីពីការតែងតាំងឋានៈជាសាស្ត្រាចារ្យរងជូនមន្ត្រីរាជការ និងគ្រូបង្រៀនថ្នាក់ឧត្តមក្នុងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២
- 1998 - បច្ចុប្បន្ន៖ គ្រូបង្រៀនតាមសាកលវិទ្យាល័យនានា៖NUM, BBU, NIB, HRU, UME,

មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

ទំព័រ

សេចក្តីថ្លែងអំណរគុណ i
អារម្ភកថា ii
អ្នកនិពន្ធ iii
សេចក្តីបញ្ជាក់នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ iv
មាតិកា v
អក្សរកាត់អង់គ្លេស x
បញ្ជីគំនូសតាង និងក្រាហ្វិក xi

ជំពូកទី ១៖ ប្រវត្តិនៃសេដ្ឋកិច្ច(History Of Economic)

១.១-តើសេដ្ឋកិច្ចជាអ្វី(What Is Economics ?) ១
  ១.១.១-និយមន័យ(Definition) ១
  ១.១.២-ប្រវត្តិនៃម៉ាក្រូសេដ្ឋកិច្ច(History Of Macroeconomic) ៣
១.២-ការវិវត្តិសេដ្ឋកិច្ច(Economics Evolution) ៤
  ១.២.១-សេដ្ឋកិច្ចក្លាស៊ីក(Classical Economics) ៤
  ១.២.២-សេដ្ឋកិច្ចក្លាស៊ីកថ្មី(Neoclassical Economics) ៦
  ១.២.៣- សេដ្ឋកិច្ចបែបកេនស៍និយម(Keynes Economic) ៨
  ១.២.៤-សេដ្ឋកិច្ចថ្មីបែបកេនស៍(New-Keynesian Economic) ១០
  ១.២.៥- សេដ្ឋកិច្ចមីក្រូក្លាស៊ីកបែបថ្មី(New Classical MicrOECONoMic) ១១
១.៣-ការវិវត្តគំរូម៉ូដែលសេដ្ឋកិច្ច(Evolution Of Model´s Economic) ១៥
  ១.៣.១-គំរូម៉ូដែលក្លាស៊ីក(The Classical Paradigm) ១៥
  ១.៣.២-ទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក(Traditional Classical Idea) ១៥
  ១.៣.៣-ទ្រឹស្តីតម្រូវការសរុបនៃសេដ្ឋកិច្ចក្លាស៊ីក(Theory Of Aggregate Demand In The Traditional Classical) ១៦
  ១.៣.៤- គំរូទ្រឹស្តីនេអូក្លាស៊ីក(Neoclassical Model) ១៧

ជំពូកទី ២៖ លក្ខណៈវិនិច្ឆ័យនៃសារពើពន្ធ(Criteria Of Fiscal)

២.១-លក្ខណៈសម្គាល់នៃសារពើពន្ធ(Feature Of Fiscal) ១៩
  ២.១.១-ខ្លឹមសារនៃសារពើពន្ធ(Meaning Of Fiscal) ១៩

២.១.២-ខ្លឹមសារនៃចំណូលសារពើពន្ធ(Meaning Of Tax Revenue) ១៩
២.១.៣-ភាពយឺតនៃចំណូលសារពើពន្ធ(Elasticity Of Tax Revenue)..... ២១
២.២គោលការណ៍នៃសារពើពន្ធ-(Principles Of Fiscal) ២២
២.២.១-ប្រសិទ្ធភាពខាងសេដ្ឋកិច្ចនៃសារពើពន្ធ)Economy EfficIENCy Of Fiscal) ..២២
២.២.២-ភាពសាមញ្ញនៃរដ្ឋបាលសារពើពន្ធ (Simplicity Of Tax Administration)..... ២៤
២.២.៣-ភាពអាចបត់បែនបាននៃសារពើពន្ធ(Flexibility Of Fiscal)..... ២៥
២.២.៤-ភាពទទួលខុសត្រូវផ្នែកនយោបាយ ឬតម្លាភាពនៃសារពើពន្ធ
(Responsibility Politic/Transparency Of Fiscal) ២៦
២.២.៥-ភាពយុត្តិធម៌ និងសមធម៌នៃសារពើពន្ធ(Justice And Equity Of Fiscal)..... ២៦

ជំពូកទី ៣៖ ប្រព័ន្ធគ្រប់គ្រងនៃសារពើពន្ធ(Fiscal Management System)

៣.១ប្រព័ន្ធគ្រប់គ្រងនៃសារពើពន្ធ-(Fiscal Management System) ២៩
៣.១.១ប្រព័ន្ធនៃសារពើពន្ធ-(Fiscal System) ២៩
៣.១.២-ប្រព័ន្ធគ្រប់គ្រងនៃសារពើពន្ធ(Fiscal Management System)..... ៣១
៣.២-ប្រព័ន្ធរដ្ឋបាលនៃសារពើពន្ធ(Administrative System Of Fiscal)..... ៣៥
៣.២.១-រដ្ឋបាលសារពើពន្ធ(Tax Administration) ៣៥
៣.២.២-សារសំខាន់រដ្ឋបាលសារពើពន្ធ(Essential Of Tax Administration) ៤០

ជំពូកទី ៤៖ រចនាសម្ព័ន្ធនៃសារពើពន្ធ(Structural Of Fiscal)

៤.១-រចនាសម្ព័ន្ធនៃសារពើពន្ធ(Structural Of Fiscal) ៤៤
៤.១.១លក្ខណៈនៃសារពើពន្ធ-(Characteristics Of Fiscal) ៤៤
៤.១.២-ចំណាត់ថ្នាក់នៃសារពើពន្ធ(Classification Of Fiscal) ៤៦
៤.២-សន្ទស្សន៍នៃកម្លាំងសារពើពន្ធ(Fiscal Strength Index) ៥២
៤.២.១-សន្ទស្សន៍នៃសារពើពន្ធ(Fiscal Index)..... ៥២
៤.២.២-ចំណាត់ថ្នាក់សន្ទស្សន៍នៃសារពើពន្ធ(Fiscal Index Classification)..... ៥៣
៤.៣ការវិនិច្ឆ័យនៃសារពើពន្ធ-(Judgment Of Fiscal) ៥៥
៤.៣.១ការវិនិច្ឆ័យនៃ-វាយតម្លៃ(Judgment Of Evaluation)..... ៥៥
៤.៣.២ការវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធ-(Judgment Of Fiscal System) ៥៦

ជំពូកទី ៥៖ គោលនយោបាយសារពើពន្ធ(Fiscal Policy)

៥.១-និយមន័យ(Definition)..... ៦៦
៥.២-គោលនយោបាយសារពើពន្ធ(Fiscal Policy) ៦៧
៥.២.១-តើអ្វីជាគោលនយោបាយសារពើពន្ធ ?(What's Fiscal Policy ?) ៦៧

៥.២.២-ឧបករណ៍នៃគោលនយោបាយសារពើពន្ធ(Tools Of Fiscal Policy) ៧១
៥.២.៣-ប្រភេទនៃគោលនយោបាយសារពើពន្ធ (Types Of Fiscal Policy) ៧២
៥.២.៤-គោលបំណងនៃគោលនយោបាយសារពើពន្ធ (Objective: Fiscal PolICY) ...៧៣
៥.៣-ទិដ្ឋភាពទ្រឹស្តីគោលនយោបាយសារពើពន្ធ(Theory Of Fiscal Policy)..... ៧៥
៥.៣.១-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធអំឡុងវិបត្តិសេដ្ឋកិច្ច
(Effect of Fiscal Policy: Recessionary Gap) ៧៥
៥.៣.២-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើចំនុចសមតា
(Effects of Fiscal Policy On AD-AS Equilibrium) ៧៧
៥.៣.៣-ឥទ្ធិពលនៃគោលនយោបាយពង្រីកលើការផ្គត់ផ្គង់សរុប
(Effect of Fiscal Policy: Supply-Side) ៧៨
៥.៣.៤-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ(DisCRepTIONARY:
Close Recessionary Gap) ៧៩
៥.៤-គោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ(Discretionary Of Fiscal Policy) ៨0
៥.៤.១-គោលនយោបាយសារពើពន្ធពង្រីក(Expansionary Of Fiscal Policy) ៨១
៥.៤.២-ការបង្កើនចំណាយរបស់រដ្ឋាភិបាល(Increasing Government Spending) . ៨៤
៥.៤.៣-ការបន្ថយពន្ធ(Reduction Tax) ៨៥
៥.៤.៤-ការផ្គួបគ្នានៃការបង្កើនចំណាយរបស់រដ្ឋាភិបាល និងការបន្ថយពន្ធ (Combin-
ation Between Raise Government Spending and Reduce Tax) ៨៦
៥.៤.៥-គោលនយោបាយសារពើពន្ធបង្រួម(Contractionary Of Fiscal Policy) ៨៧
៥.៤.៦-ការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល
(Decreasing Government Spending) ៨៨
៥.៤.៧-ការដំឡើងពន្ធ(Increasing Taxes) ៨៩
៥.៤.៨-ការផ្គួបគ្នាការបន្ថយចំណាយរដ្ឋាភិបាល និងការដំឡើងពន្ធ(Combinated
Between Reduce Government SpENDing And Raising Taxes) ៨៩
៥.៥- គោលនយោបាយសារពើពន្ធអឆន្ទានុសិទ្ធិ
(Non-Discretionary of Fiscal Policy) ៩0
៥.៥.១-ស្ថិរភាពជាស្វ័យប្រវត្តិ(Automatic Stabilizers) ៩១
៥.៥.២-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើសេដ្ឋកិច្ច
(Effect of Economics Growth) ៩២
៥.៦-ឥទ្ធិពលរុញចេញ(Crowding-Out Effect) ៩៣
៥.៦.១-តើអ្វីជាឥទ្ធិពលរុញចេញ ?(What Is Crowding Out ?) ៩៤
៥.៦.២-ការវិភាគឥទ្ធិពលរុញចេញ(Analysis Crowding Out) ៩៧
៥.៦.៣-ការវាយតម្លៃទ្រឹស្តីរុញចេញ(Evaluating Of Crowding Out Theory) ៩៨

៥.៧-ឥទ្ធិពលគោលនយោបាយសារពើពន្ធមកលើសេដ្ឋកិច្ច
(Effect of Fiscal Policy on Economics) ៩៩
៥.៧.១-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើសេដ្ឋកិច្ចរយៈពេលវែង
(Impact of Fiscal Policy on Long-Term Economy) ៩៩
៥.៧.២-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើការផ្គត់ផ្គង់សរុប
(SuPPly-Side: Effects Of Fiscal Policy) ១០១
៥.៧.៣-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើការនាំចេញសុទ្ធ
(Net Export: Effects Of Fiscal Policy) ១០៥

ផ្នែកទី ៦៖ គោលនយោបាយរូបិយវត្ថុ (Monetary Policy)

៦.១-ប្រវត្តិសង្ខេបនៃរូបិយវត្ថុ (A Brief History Of The Definition Of Money) ១០៥
៦.១.១-សេចក្តីផ្តើម (Introduction) ១០៥
៦.១.២-ការបង្កើតរូបិយវត្ថុគឺជាអ្វី (What Is Money Creation?) ១០៧
៦.១.៣-យន្តការនាំឱ្យការបង្កើតរូបិយវត្ថុ
(Mechanisms Leading to Money Creation) ១០៨
៦.១.៤-ការបង្កើតរូបិយវត្ថុតាមរយៈបំណុល៖ (Creating Money Through Debt) ... ១០៩
៦.១.៥-តួគុណប្រាក់បញ្ញើធនាគារ)Deposit Multiplier(..... ១១០
៦.២ ការផ្គត់ផ្គង់រូបិយវត្ថុ (Money Supply) ១១២
៦.២.១-ការផ្គត់ផ្គងរូបិយវត្ថុ និងស្តុករូបិយវត្ថុ (Money Supply & Money Stock) ... ១១២
៦.២.២-តើអ្វីជាការផ្គត់ផ្គង់រូបិយវត្ថុ ? (What Is the Money Supply)? ១១៣
៦.២.៣-ហេតុអ្វីការផ្គត់ផ្គង់រូបិយវត្ថុមានសារៈសំខាន់?
(Why Is Money Supply Important)? ១១៤
៦.២.៤-តើអ្វីដែលកំណត់ការផ្គត់ផ្គង់រូបិយវត្ថុ (What's The Money Supply)? ១១៤
៦.៣-ការវាស់អតិផរណា (Measurement Inflation) ១១៦
៦.៣.១-អ្វីទៅជាអតិផរណា (What Is Inflation?) ១១៦
៦.៣.២-សន្ទស្សន៍ថ្លៃ (Price Index) ១១៧
៦.៤-គោលនយោបាយរូបិយវត្ថុ (Monetary Policy) ១២០
៦.៤.១-សេចក្តីផ្តើម (INTRODUCTION) ១២០
៦.៤.២-ទ្រឹស្តីគោលនយោបាយរូបិយវត្ថុ និង គោលនយោបាយសារពើពន្ធ
(DEFINITIONS OFMONETARY AND FISCAL POLICIES) ១២១
៦.៤.៣-កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ
(OBJECTIVE OF MONETARY POLICY) ១២២
៦.៤.៤-គោលនយោបាយរូបិយវត្ថុ (MONETARY POLICY) ១២៥

៦.៤.៥-សសរស្តម្ភនៃគោលនយោបាយរូបិយវត្ថុ
(QUOINS OF MONETARY POLICY) ១៣៧
៦.៥-ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ៖ អត្រាការប្រាក់ និងអតិផរណា (MONETARY POLICY: FROM INTEREST TO INFLATION) ១៣៩
៦.៦-ការវិនិយោគ(INVESTING) ១៤៣
សេចក្តីសន្និដ្ឋាន (Summary) ១៤៥

បណ្ណាល័យសារស្ត

បញ្ជីអក្សរកាត់ជាភាសាអង់គ្លេស

ពាក្យសរសេរកាត់	ការពន្យល់
C	: Consumption
G	: Government
I	: Investment
Y	: Income
T	: Taxes
AD	: Agggregate Supply
AS	: Aggravate supply
NX	: Net exports
WB	: world Bank
ADB	: Asian Development Bank
CPI	: Consumption price index
GDE	: Gross Domestic Expenditure
GDP	: Gross Domestic Product
GNP	: Gross National Product
IMF	: International Monetary Fund
MPC	: MARGINAL PROPENSITY TO CONSUME
MPS	: MARGINAL PROPENSITY TO SAVING
PPP	: Purchase Power Priority
WTO	: World trade organization
LRAS	: Long-run Aggregate Supply
OECD	: Operation Economics Committee Development
Rgdp	: Real Gross Domestic Product
SRAS	: Short-run Aggravate supply

តំណូសតាង និងក្រាហ្វិក

តំនូសតាងទី១៖ ប្រវត្តិនៃសេដ្ឋកិច្ច ១៣
តំនូសតាងទី២៖ គោលនយោបាយរបស់រដ្ឋាភិបាល ៧០
តំនូសតាងទី៣៖ ប្រភេទនៃគោលនយោបាយសារពើពន្ធ ៧៣
តំនូសតាងទី៤៖ គោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ ៨១
តំនូសតាងទី៥៖ ការអនុវត្តគោលនយោបាយសារពើពន្ធ ៨៣
តំនូសតាងទី៦៖ ឥទ្ធិពលរុញចេញ ៩៥
តំនូសតាងទី៧៖ តំនូសបំព្រួញឥទ្ធិពលរុញចេញ ៩៦
តំនូសតាងទី៨ បង្ហាញពី៖ កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ ១២៥
តំនូសតាងទី៩ បង្ហាញពី៖ គោលនយោបាយរូបិយវត្ថុ ១២៧
តំនូសតាងទី១០ បង្ហាញពី៖ យន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ ១៤០

ក្រាហ្វិកទី១៖ ឧបករណ៍គោលនយោបាយសារពើពន្ធ ៧២
ក្រាហ្វិកទី២៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធកំឡុងវិបត្តិសេដ្ឋកិច្ច ៧៧
ក្រាហ្វិកទី៣៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធត្រង់ចំនុចសមតា ៧៨
ក្រាហ្វិកទី៤៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីកលើការផ្គត់ផ្គង់សរុប ៧៩
ក្រាហ្វិកទី៥៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ ៨០
ក្រាហ្វិកទី៦៖ ការអនុវត្តគោលនយោបាយសារពើពន្ធពង្រីក ៨៧
ក្រាហ្វិកទី៧៖ ការអនុវត្តគោលនយោបាយសារពើពន្ធបង្រួម ៩០
ក្រាហ្វិកទី៨៖ ស្ថិរភាពស្វ័យប្រវត្តិ ៩១
ក្រាហ្វិកទី៩៖ ឥទ្ធិពលរុញចេញ ៩៤
ក្រាហ្វិកទី១០៖ វិភាគឥទ្ធិពលរុញចេញ ៩៧
ក្រាហ្វិកទី១១៖ ឥទ្ធិពលគោលនយោបាយសារពើពន្ធលើសេដ្ឋកិច្ចរយៈពេលវែង ១០០
ក្រាហ្វិកទី១២៖ ឥទ្ធិពលគោលនយោបាយសារពើពន្ធលើខ្សែកោងផ្គត់ផ្គង់សរុប ១០២
ក្រាហ្វិកទី១៣៖ ឥទ្ធិពលគោលនយោបាយសារពើពន្ធលើការនាំចេញសុទ្ធ ១០៣

ជំពូកទី ១

ប្រវត្តិនៃសេដ្ឋកិច្ច
HISTORY OF ECONOMICS

១.១- តើសេដ្ឋកិច្ចជាអ្វី(WHAT IS ECONOMICS ?)

១.១.១-និយមន័យ(DEFINITION)

ពាក្យសេដ្ឋកិច្ច (Economics) មកពីពាក្យក្រិចថាអិចកូណូម៉ូស (Ieko snomous)។ ម្យ៉ាងវិញទៀត ពាក្យអិចកូណូម៉ូស (Oikonomous) គឺមកពីពាក្យពីរម៉ាត់របស់ពាក្យអិចកូ (Oiko) ដែលមានន័យជាភាសាអង់គ្លេសថាគ្រួសារ (Household) និងណូម៉ូស (Nomous) ដែលមានន័យជាភាសាអង់គ្លេសថាការគ្រប់គ្រង (Management)។ ដូចនេះ បើយោងតាមទៅភាសាក្រិចពាក្យសេដ្ឋកិច្ច (Economics) មានន័យថាការគ្រប់គ្រងគ្រួសារ (The Management of Households) ។[១]

ប៉ុន្តែ បើយោងទៅតាមទស្សនាទានភាគច្រើនរបស់សេដ្ឋវិទូបានឱ្យនិយមន័យជាទូទៅថា សេដ្ឋកិច្ច (Economics) គឺជាវិទ្យាសាស្ត្រសង្គមដែលទាក់ទងទៅនឹងការប្រើប្រាស់ប្រភពធនធានខ្សត់កម្រ (Scarce Resources) ដើម្បីបំពេញនូវសេចក្តីពេញចិត្តអតិបរមានៃចំណង់ឥតព្រំដែនរបស់មនុស្ស។

សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រសង្កេត(Observation science) សម្រាប់ធ្វើការសម្រេចចិត្ត ដើម្បីធ្វើការពន្យល់ពីរឿងរ៉ាវអ្វីមួយក្នុងពិភពជាក់ស្តែង។ វិទ្យាសាស្ត្រសង្កេត (Observation science) គឺជាវិទ្យាសាស្ត្រដែលប្រមូលព័ត៌មាន (Togather the information) រួចយកព័ត៌មានដែលប្រមូលបានមកធ្វើការត្រួតពិនិត្យ (Examine the information) បន្ទាប់មកយកព័ត៌មានដែលពិនិត្យរួចមករៀបចំតាមលេខលំដាប់ (Order the information) ដើម្បីផ្តល់អាទិភាពថាតើព័ត៌មានណាត្រូវធ្វើមុន ហើយព័ត៌ មានណាត្រូវធ្វើតាមក្រោយ និងចុងក្រោយធ្វើបទបង្ហាញ (show or presence) ពីលទ្ធផលនៃការវិភាគព័ត៌មានទាំងនោះ ប្រាប់ម្ចាស់ទុនដើម្បីធ្វើការសម្រេចចិត្តក្នុងការងារឬកិច្ចការអ្វីមួយ។

សេដ្ឋកិច្ច (Economics) គឺជាការសិក្សាពីអត្តចរិកសកម្មភាពរបស់មនុស្សក្នុងការផលិត ការបែងចែក ការប្រើប្រាស់វត្ថុធាតុដើម ទំនិញនិងសេវាកម្មក្នុងពិភពជាក់ស្តែងនៃធនធានខ្សត់កម្រ។[២]

ទស្សន:ទូទៅសេដ្ឋកិច្ច (Economic) គឺជាការសិក្សាអំពីកត្តាផលិតកម្ម ការបែងចែក និងការប្រើប្រាស់ទំនិញនិងសេវាកម្ម នៅក្នុងសង្គមជាតិ។ សេដ្ឋកិច្ច គឺជាការសិក្សាអំពីរបៀបដែលមនុស្សធ្វើការជ្រើសរើស និងការបែងចែកនូវធនធានខ្សត់កម្រ ដើម្បីបំពេញសេចក្តីត្រូវការ និងសេចក្តីប៉ងប្រាថ្នា។ ន័យម្យ៉ាងទៀត សេដ្ឋកិច្ចគឺវិទ្យាសាស្ត្រនៃការសម្រេចចិត្ត ឬការជម្រើសដែលស្ថិតក្នុងស្ថានភាព

[១] N. Gregory Mainkiw,2012

[២] McConnell, 1993

ធនធានខ្សត់កម្រ។ តាមគំនិតភាគច្រើនគិតថា សេដ្ឋកិច្ចគឺមានទំនាក់ទំនងតែនឹងរូបិយវត្ថុតែប៉ុណ្ណោះ។ នោះវាជារឿងមិនពិត សេដ្ឋកិច្ចគឺការសិក្សាអំពីបុគ្គលិកលក្ខណៈរបស់បុគ្គល និងសង្គមជាតិទាំងមូលដែលមានទំនាក់ទំនងទៅនឹងធនធានខ្សត់កម្រ។[៣]

តើអ្វីជាធនធានខ្សត់កម្រ(Scarcity)?

ធនធានកម្រ គឺជាស្ថានភាពនៃភាពចង់បាន និងប្រភពធនធាន ដែលមានដែនកំណត់។ ធនធានខ្សត់កម្រ គឺសំដៅទៅលើធនធានសេដ្ឋកិច្ច ដែលខាងផ្នែកតម្រូវការធំជាងខាងផ្នែកការផ្គត់ផ្គង់។ ប្រសិនបើធនធានសេដ្ឋកិច្ច គ្មានដែនកំណត់ នោះវានឹងមិនមានបញ្ហាសេដ្ឋកិច្ចកើតឡើងឡើយ ហើយក៏គ្មានសេដ្ឋកិច្ចផងដែរ។ ដូច្នេះ ធនធានខ្សត់កម្រនេះ មានមិនគ្រប់គ្រាន់សម្រាប់តម្រូវការមនុស្សគ្រប់គ្នាទេ។ ហេតុនេះ ការសិក្សាពីធនធានខ្សត់កម្ររបស់សេដ្ឋកិច្ច ត្រូវបានជ្រើសរើសគឺជាបញ្ហាសេដ្ឋកិច្ច។

តើអ្វីជាជម្រើស(Choice)?

ដូចនេះ ធនធានសេដ្ឋកិច្ចមានដែនកំណត់ ហើយតម្រូវការគ្មានដែនកំណត់ បានបង្ខំឱ្យយើងធ្វើជម្រើស។ ជម្រើសនេះគឺជាបញ្ហាសេដ្ឋកិច្ចដែលជួយយើងធ្វើការជ្រើសរើសឱ្យទទួលបានភាពពេញចិត្តជាអតិបរមា។

ទន្ទឹមនឹងនេះ ការផ្តល់នូវនិយមន័យ"សេដ្ឋកិច្ច"របស់សេដ្ឋវិទូល្បីៗ មានដូចជា៖[៤]

ក) ពាក្យថា"ទ្រព្យសម្បត្តិប្រជាជាតិ"ឆ្នាំ១៧៧៦៖

តាមទស្សនៈសេដ្ឋវិទូជនជាតិស្កុតឡែនលោក អាដាម ស្មីត(Adam Smith) ជាបិតាសេដ្ឋវិទ្យាស៊ីកនិយម បានឱ្យនិយមន័យថា "សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីធនធានធម្មជាតិ និងបុព្វហេតុនៃទ្រព្យសម្បត្តិរបស់ប្រជាជាតិ" លោកបានសង្កត់ធ្ងន់ទៅលើកត្តាផលិតកម្ម និងកំណើនសេដ្ឋកិច្ចគឺជាប្រធានបទនៃសេដ្ឋកិច្ច។

ខ) ពាក្យថា"សុខមាលភាពសង្គម" ឆ្នាំ១៨៩០៖

តាមទស្សនៈមេដឹកនាំក្រុមសេដ្ឋកិច្ចក្លាស៊ីកថ្មីលោក អាល់ហ្វ្រេដ ម៉ាហ្សាល់(Alfred Marshall) បានឱ្យនិយមន័យសេដ្ឋកិច្ចថា "សេដ្ឋកិច្ច គឺជាការសិក្សាពីមនុស្សជាតិក្នុងអាជីវភាពធម្មតានៃជីវិត ដោយត្រួតពិនិត្យមើលពីសកម្មភាពបុគ្គល និងសង្គមជាតិ ដែលមានទំនាក់ទំនងយ៉ាងជិតស្និតបំផុតជាមួយការសម្រេចចិត្ត និងការប្រើប្រាស់សម្ភារៈចាំបាច់សម្រាប់សុខុមាលភាពសង្គម"។

គ) ពាក្យថា "កំណើនឬការអភិវឌ្ឍន៍" ឆ្នាំ១៩៤៨៖

តាមទស្សនៈលោកសាស្ត្រាចារ្យ ប៉ូល អេ.សាម៉ុលអែលសុន(Paul A. Samuelson) បានឱ្យនិយមន័យសេដ្ឋកិច្ចថា "សេដ្ឋកិច្ច គឺការសិក្សាអំពីរបៀបដែលមនុស្ស និងសង្គមជាតិ ជ្រើសរើសដោយការប្រើលុយឬមិនប្រើលុយ ដើម្បីប្រើប្រាស់ផលិតភាពធនធានខ្សត់កម្រ មានការប្រើប្រាស់ជំនួសនូវ

[៣] Macroeconomics theory

[៤] www.economicsworld.com

ទំនិញនិងសេវាផ្សេងៗ និងការបែងចែកទំនិញនិងសេវា សម្រាប់ការប្រើប្រាស់នាបច្ចុប្បន្ននិងអនាគត បណ្តាចំណោមមនុស្ស និងសង្គមជាតិផ្សេងគ្នា។ ជាពិសេសសេដ្ឋកិច្ចវិភាគលើការចំណាយថ្លៃដើម និង អត្ថប្រយោជន៍ ដើម្បីកែលំអគំរូនៃការបែងចែកធនធានខ្សត់កម្រ"។

ឃ) ពាក្យថា "ធនធានខ្សត់កម្រ" ឆ្នាំ១៩៣២៖

តាមទស្សនៈលោក លីអូណែល រ៉ូប៊ីន(Lionel Robbins) បានឱ្យនិយមន័យពាក្យសេដ្ឋកិច្ចថា "សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រដែលសិក្សាពីអាកប្បកិរិយារបស់មនុស្សជាមួយទំនាក់ទំនងនឹងការប្រើពាក្យ ថាចុងក្រោយ និងធនធានខ្សត់កម្រ"។

ង) ពាក្យថា "ជម្រើសឬការជ្រើសរើស" ឆ្នាំ២០១១៖

តាមទស្សនៈសាស្ត្រាចារ្យសេដ្ឋកិច្ចទំនើបលោក អេ.ស៊ី.ឌាស (A.C.Dhas) បានឱ្យនិយមន័យ សេដ្ឋកិច្ចថា "សេដ្ឋកិច្ច គឺការសិក្សាអំពីជម្រើសនៃការជ្រើសរើសដោយបុគ្គល ស្ថាប័ន សង្គម ប្រជាជាតិ ស្ថិតក្រោមស្ថានភាពធនធានខ្សត់កម្រ និងអតិរេក ឆ្ពោះទៅរកផលប្រយោជន៍អតិបរិមា និងតម្រូវការ ជាអត្ថប្រយោជន៍គ្មានដែនកំណត់របស់ពួកគេនាបច្ចុប្បន្ននិងនាអនាគត "សេដ្ឋកិច្ចត្រូវបានកំណត់ជារួម ថា" សិក្សាអំពីជម្រើសរបស់អ្នកទាំងអស់គ្នា ក្នុងការបង្កើនអត្ថប្រយោជន៍ផលិតកម្ម និងការប្រើប្រាស់ ធនធានខ្សត់កម្រ និងអតិរេកសម្រាប់តម្រូវការនាបច្ចុប្បន្ន និងនាអនាគត"។

រហូតមកដល់បច្ចុប្បន្ននេះ ការពិភាក្សាពីនិយមន័យពាក្យថា "សេដ្ឋកិច្ច" នៅតែបន្តមានលក្ខណៈ ស្មុគស្មាញដដែល។ មានទស្សនៈសេដ្ឋវិទូជាច្រើនមានភាពចង្អៀតចង្អល់ខ្វែងគំនិតគ្នាទាក់ទងលក្ខ ណៈជាក់ស្តែងនៃបញ្ហាសេដ្ឋកិច្ច។ ការពិភាក្សាលើពាក្យថាសេដ្ឋកិច្ច និងបាតុភូតសេដ្ឋកិច្ចជាអ្វីនោះ? ខាងលើនេះជានិយមន័យ "សេដ្ឋកិច្ច" ត្រូវបានពន្យល់បកស្រាយដោយសេដ្ឋវិទូល្បីចំនួន៥រូបសំខាន់ៗ តាំងពីសម័យកាលសេដ្ឋកិច្ចក្លាស៊ីកចាស់ សេដ្ឋកិច្ចក្លាស៊ីកថ្មី សេដ្ឋកិច្ចកេនស៍ និងសេដ្ឋកិច្ចកេនស៍ទំនើប។

ការកំណត់និយមន័យសេដ្ឋកិច្ច កាន់តែមានលក្ខណៈប្រសើរឡើង គឺស្ថិតក្នុងសម័យកាលរបស់ សេដ្ឋវិទូលោក អាល់ហ្វ្រេដ ម៉ាហ្សាល(Alfred Marshall)។ ទោះបីជានិយមន័យសេដ្ឋកិច្ចរបស់លោក អាល់ហ្វ្រេដ ម៉ាហ្សាល មិនទាន់មានភាពច្បាស់លាស់នៅឡើយក៏ដោយក្តី។ ហេតុនេះ បញ្ហានិយមន័យ "សេដ្ឋកិច្ច" នៅតែបន្តឱ្យនិយមន័យជាបន្តបន្ទាប់។

១.១.២-ប្រវត្តិនៃម៉ាក្រូសេដ្ឋកិច្ច(HISTORY OF MACROECONOMIC)

តើម៉ាក្រូសេដ្ឋកិច្ចគឺជាអ្វី?

ពាក្យថាម៉ាក្រូសេដ្ឋកិច្ចមានន័យថា គឺជាការសិក្សាអំពីបាតុភូតសេដ្ឋកិច្ចទាំងមូល។ ម្យ៉ាងទៀត ម៉ាក្រូសេដ្ឋកិច្ច គឺជាការសិក្សាអំពីទំហំសេដ្ឋកិច្ច ឬការប្រមូលផ្តុំសេដ្ឋកិច្ចសរុបទាំងស្រុង។ មានដូចជា ប្រាក់ចំណូលជាតិសរុប រូបិយវត្ថុសរុប កម្រិតតម្លៃ អត្រាអនិកម្មភាព និងកំណើនសេដ្ឋកិច្ចជាដើម។

សរុបជារួមម៉ាក្រូសេដ្ឋកិច្ច គឺការសិក្សាអំពីរបៀបដែលធនធានខ្សត់កម្រ ត្រូវបានប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចទាំងមូល ឬបាតុភូតសេដ្ឋកិច្ចទាំងមូល។ ជាទូទៅ ម៉ាក្រូសេដ្ឋកិច្ចបានផ្តោតលើការសិក្សាលើអថេរជាច្រើនមានអថេរសំខាន់ៗដែលតែងតែប្រទះឃើញក្នុងការសិក្សាពិភាក្សាទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច មានដូចជា៖

- ផលិតផលក្នុងស្រុកសរុប(Gross Domestic Product)
- អតិផរណា(Inflation)
- ការប្រាក់(Interest)
- អត្រាប្តូរប្រាក់(Exchange rate) និង
- អនិកម្មភាព(Unemployment)

ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច បានចាប់កំណើតនាឆ្នាំ ១៩៣៦ បោះពុម្ពផ្សាយដោយសេដ្ឋវិទូលោក ចន មេណាដ កេនស៍ ទ្រឹស្តីរួមស្តីពី[5] "អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ"។ ក្នុងអំឡុងពេលមានមហាវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ គឺជាបរាជ័យខាងបញ្ញារបស់អ្នកសេដ្ឋកិច្ច ដែលសិក្សាលើទ្រឹស្តីវដ្តអាជីវកម្ម។ ពេលនោះទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចត្រូវបានជំនួស គឺអ្នកសេដ្ឋកិច្ចជនជាតិអង់គ្លេសដែលមានទស្សនៈផ្លាស់ប្តូរទ្រឹស្តីក្លាស៊ីករបស់លោក អាដាម ស្មីត។ ការអនុវត្តជាក់ស្តែងនៃទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល គួរតែត្រូវបង្កើនតម្រូវការដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ បើតាមរយៈលោកកេនស៍មានជំនឿថា តម្រូវការសរុបរបស់អ្នកប្រើប្រាស់ គឺជាកត្តាចម្បងនៅក្នុងសេដ្ឋកិច្ចឱ្យជំរុញកំណើន។ ជាលទ្ធផល ទ្រឹស្តីនេះត្រូវបានគាំទ្រដល់គោលនយោបាយសារពើពន្ធ។ លោកកេនស៍បានសង្កត់ធ្ងន់ទៅលើតម្រូវការដ៏មានប្រសិទ្ធភាពដែលគេហៅថា "តម្រូវការសរុប" ដោយលោកកេនស៍បានបន្ថែមថាកម្រិតនិកម្មភាពពឹងផ្អែកលើតម្រូវការដែលមានប្រសិទ្ធភាព។ ប្រសិទ្ធភាពនៃតម្រូវការ គឺជាទិន្នផលជាតិសរុបទាំងមូល។ សរុបជារួម ទិន្នផលជាតិសរុបបានបង្កើតប្រាក់ចំណូល។ ដូច្នេះ កម្រិតនិកម្មភាព ពឹងផ្អែកលើតម្រូវការសរុបជាលទ្ធផល ត្រូវបានកំនត់ដោយតម្រូវការលើការប្រើប្រាស់របស់គ្រួសារ និងការវិនិយោគ។ ស្ថាបនិកទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចរូបនេះថា មិនត្រឹមតែបានកំណត់ពីភាពមិនត្រឹមត្រូវនៃសេដ្ឋកិច្ចទាំងពីរផ្នែក (ខ្វះខាត និងអតិរេក) តែប៉ុណ្ណោះទេ។ ប៉ុន្តែថែមទាំងបានចង្អុលបង្ហាញពីសមីការសេដ្ឋកិច្ច៖ (Y = AD = C + I + G + NX) ជារូបមន្តរួមនៃទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចទាំងមូល។ នេះគឺជាគោលគំនិតនៃគោលនយោបាយសារពើពន្ធក្នុងការគ្រប់គ្រងលើការចំណាយរបស់រដ្ឋាភិបាល និងការកម្រិតពន្ធដែលមានចលករសេដ្ឋកិច្ចសំខាន់ៗចំនួន៤ខាងលើ។

១.២-ការវិវត្តិសេដ្ឋកិច្ច(ECONOMICS EVOLUTION)

១.២.១-សេដ្ឋកិច្ចក្លាស៊ីក(CLASSICAL ECONOMICS)

[5] Keynes general theory

បើតាមទស្សនៈលោក អាដាម ស្មីត(Adam Smith) ស្តីពីទ្រឹស្តីសេដ្ឋកិច្ចបុរាណ(បិតាក្លាស៊ីកនិយម)បានចាត់ទុកថាសេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រដែលទាក់ទងនឹង "ទ្រព្យសម្បត្តិ" ។ ក្រុមសេដ្ឋវិទូទាំងនោះបានយល់ថាទ្រព្យសម្បត្តិមិនត្រឹមតែជាមធ្យោបាយសេដ្ឋកិច្ចតែប៉ុណ្ណោះទេ ប៉ុន្តែគ្មានព្រំដែនបញ្ចប់នោះឡើយ។ ហេតុដូច្នេះ សេដ្ឋកិច្ចគឺការសិក្សាអំពីផលិតកម្ម និងការចែកចាយទ្រព្យសម្បត្តិ(ធនធាន)សម្រាប់ពួកគេ។

ក្រុមសេដ្ឋកិច្ចក្លាស៊ីក គឺជាពាក្យទូលំទូលាយមួយ ដែលសំដៅទៅលើសាលាគំនិតសេដ្ឋកិច្ចសម្រាប់ការសិក្សាស្រាវជ្រាវលើទ្រឹស្តីសេដ្ឋកិច្ចនាសតវត្សរ៍ទី ១៨ និង១៩។ សេដ្ឋវិទូក្លាស៊ីកភាគច្រើនបានសិក្សាលើទ្រឹស្តីរបស់សេដ្ឋវិទូជនជាតិស្កុតឡែន អាដាម ស្មីត ដែលជាអ្នកបង្កើតទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីកនេះឡើង។ មានអ្នកប្រាជ្ញដូចជា Spanish Scholastics និង Prench physiocrats បានឯកភាពលើទ្រឹស្តីនៃសេដ្ឋកិច្ចក្លាស៊ីករបស់លោក អាដាម ស្មីត។ ការចូលរួមចំណែក គួរឱ្យកត់សម្គាល់ចំពោះសេដ្ឋកិច្ចក្លាស៊ីករួមមានដូចជាលោក David Ricardo, លោក Thomas Malthus, លោក Anne Robert Jacques Turgot, លោក John Stuart Mill, លោក Jean-Baptiste Say និងលោក Eugen Bohm von Bawerk ជាដើម។

ទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក ត្រូវបានបង្កើតឡើងដ៏មានឥទ្ធិពលយ៉ាងខ្លាំង បន្ទាប់ពីកំណើតនៃរបបមូលធននិយមរបស់លោកខាងលិច។ សាលាគំនិតសេដ្ឋកិច្ចក្លាស៊ីកដែលលេចធ្លោនាសតវត្សរ៍ទី ១៨ និង ១៩ ទ្រឹស្តីនេះបានជំរុញឱ្យបណ្តាប្រទេសដែលបានគ្រប់គ្រងប្រទេសតាមរបបរាជានិយម អាស្រ័យលើរបបលទ្ធិប្រជាធិបតេយ្យមូលធននិយមជាមួយនឹងអំណាចផ្ទាល់របស់ខ្លួន។ បិតាសេដ្ឋវិទូក្លាស៊ីកលោក អាដាម ស្មីត នាក្នុងអំឡុងឆ្នាំ ១៧៧៦ បានបោះពុម្ពផ្សាយសៀវភៅមានដែលចំណងជើងថា "ទ្រព្យសម្បត្តិរបស់ប្រជាជាតិ" បង្ហាញពីការរីកចម្រើនលេចធ្លោបំផុតមួយក្នុងទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក។ វិវរណៈរបស់គាត់ផ្តោតទៅលើពាណិជ្ជកម្មសេរីដែលគេហៅថា "បាតដៃអរូបិយ" ដែលជាទ្រឹស្តីដំបូងស្តីពីការផ្គត់ផ្គង់ និងតម្រូវការនៅក្នុងស្រុក និងអន្តរជាតិ។ ទ្រឹស្តីនេះ គឺមានកម្លាំងទ្វេដង និងការប្រកួតប្រជែងគ្នា រវាងលំនឹងសមតានៃតម្រូវការ និងផលិតកម្ម (ការផ្គត់ផ្គង់)។ លោកអាដាម ស្មីត បានជំរុញពាណិជ្ជកម្ម នៅក្នុងស្រុកដែលនាំឱ្យតម្លៃកាន់តែមានប្រសិទ្ធភាព និងសមហេតុផលក្នុងទីផ្សារផលិតកម្ម ដោយផ្អែកលើការផ្គត់ផ្គង់ និងតម្រូវការ។

សេដ្ឋកិច្ចក្លាស៊ីក បានធ្វើនិយ័តកម្មដោយខ្លួនឯងតាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍទីផ្សារមូលធននិយម នោះជាមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចក្លាស៊ីក។ មុនពេលការរីកចម្រើនសេដ្ឋកិច្ចក្លាស៊ីកសេដ្ឋវិទូភាគច្រើនបានអនុវត្តតាមប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាល ដោយបានប្រើអំណាចពីថ្នាក់លើចុះមកក្រោម។ សេដ្ឋវិទូក្លាស៊ីកល្បីៗជាច្រើន រួមទាំងលោក អាដាម ស្មីត និងលោក ទូហ្គត បានបង្កើតនូវទ្រឹស្តីរបស់ពួកគេជំនួសដោយគោលនយោបាយគាំពារនិយម និងគោលនយោបាយអតិផរណារបស់ពួកពាណិជ្ជករអឺរ៉ុប។ ទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសេដ្ឋកិច្ចសេរីខាងផ្នែកនយោបាយនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី។

ទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក គឺទ្រឹស្តីសេដ្ឋកិច្ចបែបបុរាណ ត្រូវបានបង្កើតបន្ទាប់ពីកំណើតនៃរបបមូលធននិយមរបស់លោកខាងលិច និងបដិវត្តឧស្សាហកម្ម។ សេដ្ឋវិទូក្លាស៊ីក បានព្យាយាមប្រឹងប្រែងជាលើកដំបូងបំផុតក្នុងការពន្យល់ពីការងារសេដ្ឋកិច្ច ត្រូវធ្វើក្នុងរបបមូលធននិយម។ សេដ្ឋវិទូក្លាស៊ីកដំបូងគេបានបង្កើតទ្រឹស្តីនៃកម្រិតថ្លៃ ការផ្គត់ផ្គង់ តម្រូវការ និងការបែងចែក។ រាល់ការជ្រៀតជ្រែករបស់រដ្ឋាភិបាលត្រូវបានច្រានចោលជាមួយនឹងការផ្លាស់ប្តូរទីផ្សារដែលគេហៅថា "Lasses-faire" ឬ "Let it be"។

ទោះបីជាយ៉ាងណា គំនិតរបស់សេដ្ឋវិទូក្លាស៊ីក ពុំមានលក្ខណៈឯកភាពគ្រប់ជ្រុងជ្រោយទាំងស្រុងលើជំនឿ ឬការយល់ដឹងអំពីទីផ្សារសេរីរបស់ពួកគេឡើយ។ ទោះបីជាមានគំនិតរួមគ្នាគួរឱ្យកត់សម្គាល់ក្នុងសេដ្ឋកិច្ចបែបបុរាណភាគច្រើនក៏ដោយ។ មានគំនិតភាគច្រើនអនុគ្រោះដល់ពាណិជ្ជកម្ម និងការប្រកួតប្រជែងសេរីក្នុងចំណោមកម្មករ និងអាជីវកម្ម។ សេដ្ឋវិទូបុរាណ ចង់ធ្វើការផ្លាស់ប្តូរឱ្យឆ្ងាយពីរចនាសម្ព័ន្ធសង្គមដែលជាមូលដ្ឋានក្នុងវណ្ណៈ ក្នុងការបំពេញតម្រូវការនៃផលប្រយោជន៍។

ការធ្លាក់ចុះឥទ្ធិពលនៃទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីករបស់ អាដាម ស្មីធ ដែលមានការផ្លាស់ប្តូរយ៉ាងខ្លាំងនាទសវត្សឆ្នាំ១៨៨០ និងឆ្នាំ ១៨៩០ ប៉ុន្តែទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក នៅតែជាទ្រឹស្តីស្នូលនៃសេដ្ឋកិច្ចក្លាស៊ីកដដែល។ ពេលនោះក៏មានការសរសេរឡើងវិញនូវទ្រឹស្តីក្លាស៊ីកបែបថ្មី បង្កើតឡើងដោយជនជាតិអាឡឺម៉ង់ជាសាលាគំនិតសេដ្ឋកិច្ចក្លាស៊ីកបែបថ្មី។ ក៏ប៉ុន្តែទ្រឹស្តីសេដ្ឋកិច្ចរបស់ ម៉ាក្សស៊ាន (Marxian) បានចូលរួមចំណែកក្នុងរយៈពេលខ្លី ចំពោះទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីកនិយមតែប៉ុណ្ណោះ។

១.២.២-សេដ្ឋកិច្ចក្លាស៊ីកថ្មី (NEOCLASSICAL ECONOMICS)

តើអ្វីទៅជាទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីកថ្មី (Neoclassical economic)?

ទ្រឹស្តីនៃសេដ្ឋកិច្ចក្លាស៊ីកថ្មី គឺជាវិធីសាស្ត្រសិក្សាពីសេដ្ឋកិច្ចដោយផ្តោតលើទំនិញ និងសេវា ទិន្នផលជាតិសរុប និងការបែងចែកប្រាក់ចំណូលនៅក្នុងទីផ្សារតាមរយៈការផ្គត់ផ្គង់ និងតម្រូវការ។

តាមទស្សនៈរបស់លោក អាល់ហ្វ្រេដ ម៉ាហ្សាល់(Alfred Marshall) ស្តីពីសេដ្ឋកិច្ចក្លាស៊ីកថ្មី ដែលលោកជាប្រធានក្រុមសេដ្ឋកិច្ចក្លាស៊ីកថ្មី បានចាត់ទុកថា "សុខុមាលភាពលើសម្ភារៈ" គឺជាប្រធានបទសំខាន់នៃសេដ្ឋកិច្ច។ ពួកសេដ្ឋកិច្ចក្លាស៊ីកថ្មី បានចាត់ទុកថាសុខុមាលភាពមនុស្ស និងទ្រព្យសម្បត្តិសម្ភារៈ គឺជាមធ្យោបាយដើម្បីសម្រេចបានសុខុមាលភាពសង្គម។ តាមគំនិតរបស់លោក អាល់ហ្វ្រេដ ម៉ាហ្សាល់ (Alfred Marshall) បានបង្វែរបញ្ហារបស់សេដ្ឋកិច្ចពីទ្រព្យសម្បត្តិទៅសុខុមាលភាពសង្គមមនុស្សជាតិវិញ។ លោក អាល់ហ្វ្រេដ ម៉ាហ្សាល់ (Alfred Marshall) គឺជាបិតាសេដ្ឋកិច្ចក្លាស៊ីកបែបថ្មី (Neoclassical)។ លោកជាសេដ្ឋវិទូអង់គ្លេស(១៨៤២-១៩២៤) ដែលទទួលបានរង្វាន់ណូបែលសេដ្ឋកិច្ចនិយមស្តីពីទ្រឹស្តីជារួមដែលផ្តោតលើការផ្គត់ផ្គង់ (Supply) និងតម្រូវការ (Demand) ដែលជាកម្លាំងជំរុញផលិតកម្ម កម្រិតថ្លៃ និងការប្រើប្រាស់ទំនិញនិងសេវា។ ទ្រឹស្តីនេះ បានផុសចេញឡើងប្រហែលឆ្នាំ ១៩០០ ដើម្បីប្រកួតប្រជែងជាមួយនឹងទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីករបស់លោក អាដាម ស្មីត ដែលគាត់ជាបិតាសេដ្ឋកិច្ចក្លាស៊ីកនិយម។

សេដ្ឋវិទូលោក អាល់ហ្វ្រេដ ម៉ាហ្សាល បានកំណត់និយមន័យសេដ្ឋកិច្ចថា "គឺជាការសិក្សារបស់មនុស្សក្នុងអាជីវកម្មធម្មតាជីវិតរស់នៅ"។ ទស្សនៈសេដ្ឋកិច្ចរបស់លោកមានក្តណៈមិនច្បាស់លាស់ ប៉ុន្តែគេអាចបញ្ជាក់ពីនិយមន័យនៃសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់លាស់ជាងនេះ បានកំណត់ថា "សេដ្ឋកិច្ចទាក់ទងផលិតកម្ម (Production) ការបែងចែក (Distribution) និងការប្រើប្រាស់ (Consumption) ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ "សេដ្ឋកិច្ចគឺជាការសិក្សាអំពីរបៀបដែលផលិតកម្ម ត្រូវបានរៀបចំដើម្បីបំពេញតម្រូវការ និងចំណង់របស់មនុស្ស"។

លោក អាល់ហ្វ្រេដ ម៉ាហ្សាល ជាអ្នកបង្កើតក្រាហ្វិកស្តង់ដារស្តីពីការផ្គត់ផ្គង់ និងតម្រូវការដោលើកដំបូងបង្អស់ បានបង្ហាញពីមូលដ្ឋានគ្រឹះទាក់ទងរវាងខ្សែកោងការផ្គត់ផ្គង់ និងខ្សែកោងតម្រូវការលំនឹងសមតាទីផ្សារដាក់ស្តែងរវាងកម្រិតបរិមាណ និងកម្រិតថ្លៃ ដែលទាក់ទងនឹងការផ្គត់ផ្គង់ និងតម្រូវការ គឺជាច្បាប់នៃម៉ាជីណាស់អ៊ុយធីលីធី (law of marginal utility)។

មានមតិតវ៉ាគ្នាយ៉ាងស្វិតស្វាញចំពោះទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក បានលេចចេញឡើង នាទសវត្សរ៍ឆ្នាំ ១៩៣០ និងឆ្នាំ១៩៤០ ជាមួយទស្សនៈរបស់គណិតវិទូអង់គ្លេស ចន មេណាដ កេនស៍។ លោក កេនស៍ គឺជាសិស្សរបស់ Alfred Marshall និងជាមនុស្សជំនិតរបស់លោក Thomas Maltus។ សេដ្ឋវិទូរូបនេះ បានតស៊ូមតិចំពោះតួនាទីរបស់រដ្ឋាភិបាលក្នុងកិច្ចការគ្រប់គ្រងសេដ្ឋកិច្ច។ តាមលោក ចន មេណាដ កេនស៍ កាន់តែពេញនិយមជាមួយនឹងអ្នកនយោបាយអង់គ្លេស និងអាមេរិក។ បន្ទាប់ពី វិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ និងសង្គ្រាមលោកលើកទី២ លោកកេនស៍បានជំនួសទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក និងសេដ្ឋកិច្ចនេអូក្លា-ស៊ីក ឱ្យរួមក្លាយជាទ្រឹស្តីសេដ្ឋកិច្ចគំរូទំនើប បានលេចធ្លោក្នុងចំណោមបណ្តារដ្ឋាភិបាលនានាលើពិភពលោក។

បញ្ហាប្រឈមកាន់តែខ្លាំងក្លាឡើងរវាងទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក និងទ្រឹស្តីសេដ្ឋកិច្ចកេនស៍ នាទសវត្សរ៍ឆ្នាំ១៩៣០ និងឆ្នាំ១៩៤០ តាមរយៈសំណេរទ្រឹស្តីរបស់លោក ចន មេណាដ កេនស៍។ លោក កេនស៍ បានគិតថាសេដ្ឋកិច្ចទីផ្សារសេរីមានទំនោរកការប្រើប្រាស់ (Consumption) និងចំណាយ (Spending)។ លោកបានហៅបញ្ហានេះថាជាបញ្ហាសេដ្ឋកិច្ចដ៏សំខាន់បំផុត ហើយលោកបានកំណត់ថា អត្រាការប្រាក់ខ្ពស់ជាបញ្ហាស្លាប់រស់ដែលទាក់ទិននឹងចំណង់ចំណូលចិត្តរបស់បុគ្គលសម្រាប់ការសន្សំ(Saving) ហើយលោកក៏បានជំទាស់ទៅនឹងទ្រឹស្តីសេដ្ឋកិច្ចទីផ្សារសេរីរបស់ពួកសេដ្ឋវិទូក្លាស៊ីកផងដែរ។

ការវិវត្តទ្រឹស្តីនៃសេដ្ឋកិច្ចឈានដល់សម័យកាលរបស់លោក លីអូណែល រូប៊ីន (Lion Robbins) ការឱ្យនិយមន័យសេដ្ឋកិច្ច ត្រូវបានប្រើយ៉ាងទូលំទូលាយ និងកាន់តែច្បាស់លាស់ឡើង ដោយលោកបានពន្យល់ថា "សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីឥរិយាបទរបស់មនុស្ស ដែលជាប់ទាក់ទងនឹងធនធានមនុស្សបានប្រើក្នុងវិធីផ្សេងៗគ្នា"។ ទស្សនៈរបស់លោក លីអូណែល រូប៊ីន(Lion Robbins)នៃការគិតបែបទំនើប បានភ្ជាប់មកជាមួយពាក្យអក្សរសាស្ត្រសេដ្ឋកិច្ច បានពន្យល់ពី "សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីឥរិយាបថរបស់មនុស្ស ដែលជាប់ទាក់ទងនឹងធនធានដែលមនុស្សបានប្រើក្នុងវិធីផ្សេងៗគ្នា"។ លោកបានបញ្ជាក់ថាកត្តាធំពីរសំខាន់ គឺការលេចចេញបញ្ហាសេដ្ឋកិច្ច និងប្រធានបទ

សេដ្ឋកិច្ច និងមានអត្ថិភាពនៃសេចក្តីត្រូវការរបស់មនុស្សគ្មានដែនកំណត់ និងធនធានខ្សត់កម្រ។ តម្រូវការរបស់មនុស្សជាច្រើន គឺត្រូវបានបំពេញចិត្តតាមរយៈធនធានខ្សត់កម្រសេដ្ឋកិច្ច ដែលមាននៅលើផែនដីនេះ។ ដូច្នេះ គាត់បានបន្ថែមប្រធានបទនៃសេដ្ឋកិច្ចឆ្ពោះទៅរកការសិក្សាអំពីរបៀបដែលសង្គម ឬបុគ្គលប្រើប្រាស់ធនធានមានកំណត់របស់ពួកគេ ដើម្បីបំពេញនូវតម្រូវការគ្មានដែនកំណត់។ ចំណែកខ្លឹមសារបាតុភូតសេដ្ឋកិច្ច ក្នុងនោះរួមមានកម្រិតថ្លៃ រូបិយវត្ថុ ផលិតកម្ម និងទីផ្សារជាដើម អាចត្រូវបានចាត់ទុកថាបណ្តាលមកពីលទ្ធផលនៃភាពកម្រ ឬវិធីដែលមនុស្សព្យាយាមដោះស្រាយពីបញ្ហាភាពកម្រនេះ។ ទស្សនៈរបស់លោក លីអូណែល រ៉ូប៊ីន បានពន្យល់ថា "សេដ្ឋកិច្ច" គឺមានគោលបំណងចាប់យកតែលក្ខណៈពិសេសដែលកើតមានជាលក្ខណៈធម្មតាចំពោះសេដ្ឋកិច្ច ត្រូវបានគេស្គាល់ថាជា"បញ្ហាសេដ្ឋកិច្ច" បង្ហាញអំពីទស្សនៈដ៏ច្បាស់លាស់មួយ មានភាពចង្អៀតនៅឡើយដែលទាក់ទិននឹងលក្ខណៈជាក់ស្តែងនៃបញ្ហាសេដ្ឋកិច្ច។ ឧទាហរណ៍៖ តើហេតុអ្វីនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រៀបចំគោលនយោបាយ ដើម្បីកាត់បន្ថយអនិកម្មភាពដ៏ធំ ត្រូវបានគេមើលឃើញថា មានពាក់ព័ន្ធនឹងជម្រើសក្នុងការប្រើប្រាស់ធនធានខ្សត់កម្រ? បញ្ហានេះ ត្រូវបានចំអកឡកឡឺយនឹងទ្រឹស្តីរបស់លោក លីអូណែល រ៉ូប៊ី ទ្រឹស្តីរបស់លោកត្រូវបានបញ្ចប់ត្រឹមឆ្នាំ ១៩៣២ នាក្នុងអំឡុងពេលមហាវិបត្តិសេដ្ឋកិច្ចសកល។ ហើយការកំណត់និយមន័យសេដ្ឋកិច្ចឡើងវិញ មានលក្ខណៈប្រសើរជាងទ្រឹស្តីរបស់លោក លីអូណែល រ៉ូប៊ីន ដោយសេដ្ឋវិទូជនជាតិអង់គ្លេស គឺលោក អាល់ហ្វ្រេដ ម៉ាហ្សាល់ បានកំណត់និយមន័យសេដ្ឋកិច្ចថា "គឺការសិក្សារបស់មនុស្សនៅក្នុងអាជីវកម្មធម្មតាជីវិតរស់នៅ"។

១.២.៣-សេដ្ឋកិច្ចបែបកេនស៍និយម(KEYNES ECONOMIC)

តើអ្វីទៅជាគំរូសេដ្ឋកិច្ចបែបកេនស៍និយម(Keynes)?

លោកកេនស៍ ជាសេដ្ឋវិទូដែលមានឥទ្ធិពលយ៉ាងខ្លាំងក្នុងសម័យកាលរបស់គាត់។ លោកមានឪពុកជាសាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យ Cambridge ក៏ជាអ្នកស្រាវជ្រាវការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងនយោបាយផងដែរ។ លោក កេនស៍ បានយកចិត្តទុកដាក់សិក្សាពីបញ្ហារូបិយវត្ថុ ហើយស្នាដៃដ៏ល្បីរបស់លោកកេនស៍ គឺជាទ្រឹស្តីរួម "អនិកម្មភាព អត្រាការប្រាក់ និង រូបិយវត្ថុ" ត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៣៦។ ហើយតាមរយៈស្នាដៃនេះ បានធ្វើឱ្យរបត់ទ្រឹស្តីរបស់ក្លាស៊ីកនិយម (បដិវត្តន៍កេសន៍) បង្ហាញអំពីភាពចាំបាច់ក្នុងការធ្វើអន្តរាគមន៍របស់រដ្ឋាភិបាល ចំពោះដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចរបស់លោកកេនស៍ ចង់វាយប្រហារចំពោះមុខលើទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក ចង់បង្ហាញទស្សនៈរបស់គាត់ស្តីពីទិន្នផលជាតិសរុប និងនិកម្មភាពពេញលេញ។ គោលបំណងចម្បងនៃទ្រឹស្តី គឺដើម្បីពន្យល់ពីកម្រិតការងារ វានឹងកើតមានឡើងនៅពេលណាមួយឱ្យដល់សេដ្ឋវិទូក្លាស៊ីក រួមមានដូចជា Adam Smith, David Ricardo, J.S. Mill, Alfred Marshall និងលោក Pihou។ ទ្រឹស្តីនៃម៉ាក្រូសេដ្ឋកិច្ចរបស់លោកកេនស៍ មានឥទ្ធិពលលើសេដ្ឋកិច្ចក្លាស៊ីក ខណៈពេលសេដ្ឋកិច្ចក្លាស៊ីក បានបរាជ័យក្នុងការពន្យល់ពីមូលហេតុនៃការធ្លាក់ចុះសេដ្ឋកិច្ចដ៏អាក្រក់បំផុត នាចន្លោះឆ្នាំ(១៩២៩-១៩៤១)។

សេដ្ឋវិទូលោក ចន មេណាដ កេនស៍ បានតស៊ូមតិសម្រាប់តួនាទីគ្រប់គ្រងរបស់រដ្ឋាភិបាលលូកដៃចូលក្នុងកិច្ចការសេដ្ឋកិច្ច ដែលធ្វើឱ្យគាត់កាន់តែពេញនិយម ជាមួយនឹងអ្នកនយោបាយអង់គ្លេស និងអាម៉េរិក។ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចដ៏អាក្រក់ និងសង្គ្រាមលោកលើកទី២ បន្ទាប់មកលោកកេនស៍ បានជំនួសទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីកដែលជាវិទ្យាសាស្ត្រសេដ្ឋកិច្ចសង្គម ឱ្យក្លាយជាគំរូម៉ូដែលតែមួយបានលេចធ្លោក្នុងចំណោមរដ្ឋាភិបាលនានាលើពិភពលោក។ ការផ្លាស់ប្តូរទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីក គឺជាសកម្មភាពសេដ្ឋកិច្ចសកលជាក់ស្តែង។

លោកកេនស៍ បានអះអាងថានៅក្នុងសេដ្ឋកិច្ចទីផ្សារ ដើម្បីជម្នះឧបសគ្គបានលើបញ្ហានិកម្មភាពរដ្ឋាភិបាលត្រូវមានគោលនយោបាយរូបិយវត្ថុសកម្មមួយ ដែលលើកទឹកចិត្តដល់តម្រូវការសរុប។ ពាក់ព័ន្ធកង្វះខាតសេដ្ឋកិច្ចទីផ្សារ និងតួនាទីរបស់រដ្ឋាភិបាល គាត់បានគូសបញ្ជាក់បន្ថែមថា "រដ្ឋត្រូវធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ចតាមរយៈគោលនយោបាយសារពើពន្ធ សម្រាប់ផ្តល់ការលើកទឹកចិត្តដល់តម្រូវការទើបអាចដោះស្រាយបញ្ហានិកម្មភាពបាន"។

អំឡុងឆ្នាំ១៩៣៦ សេដ្ឋវិទូជនជាតិអង់គ្លេស ចន មេណាដ កេនស៍ បានបោះពុម្ពផ្សាយនូវទ្រឹស្តីរួម "អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ" ហើយត្រូវបានគេស្គាល់ថាជា"ទ្រឹស្តីទូទៅ"។ លោក កេនស៍ បានលើកជាទ្រឹស្តីថាការកើនឡើងនូវទម្រង់នៃការចំណាយរបស់រដ្ឋាភិបាល គឺដើម្បីប្រយុទ្ធប្រឆាំងទៅនឹងកម្លាំងធ្លាក់ចុះរបស់សេដ្ឋកិច្ច (Recessionary force)។ នៅក្នុងអំឡុងពេលនៃវិបត្តិសេដ្ឋកិច្ច លោកកេនស៍ បានលើកឡើងថារដ្ឋាភិបាលអាចប្រើអំណាចដើម្បីជំរុញការចំណាយរបស់រដ្ឋ និងកម្រិតពន្ធ ដែលរដ្ឋាភិបាលមានឥទ្ធិពលលើការចំណាយក្នុងសេដ្ឋកិច្ច ដើម្បីរុញច្រានតម្រូវការសរុបឱ្យរំកិលទៅរកខាងស្តាំ។

ការចំណាយរបស់រដ្ឋាភិបាល បានជំរុញឱ្យសេដ្ឋកិច្ចងើបឡើងវិញ តាមរយៈការជួលកម្លាំងពលកម្មរបស់មនុស្សឱ្យធ្វើការងារលើវិស័យសាធារណៈ ដែលពួកគេមានតម្រូវការចាំបាច់ ដោយមិនប្រកួតប្រជែងជាមួយវិស័យឯកជន។ ហើយនិយោជិតទាំងនេះ នឹងមានការចំណាយនូវប្រាក់ចំណូលរបស់ពួកគេឡើងវិញ សកម្មភាពផលិតកម្មនឹងដំណើរការឡើងវិញចំពោះបញ្ហានេះ។ លោកកេនស៍ គូសបញ្ជាក់ទៀតថាការកើនឡើងការចំណាយរបស់រដ្ឋាភិបាល នឹងនាំមកនូវការកើនឡើងនូវតម្រូវការសរុបចំពោះទំនិញនៅលើសេដ្ឋកិច្ចទីផ្សារ។

ភស្តុតាងជាក់ស្តែងនៃសង្គ្រាមលោកលើកទី២ នៃទ្រឹស្តីរបស់លោកកេនស៍។ ប្រជាជាតិនានាលើពិភពលោក បានជំរុញបង្កើនការចំណាយរបស់រដ្ឋាភិបាល ហើយរដ្ឋាភិបាល បានបញ្ជាឱ្យបង្កើតនូវកម្លាំងប្រដាប់អាវុធ។ ការកើនឡើងនូវការចំណាយរបស់រដ្ឋាភិបាល បានមើលឃើញកំណើនការងារពលកម្ម និងកើនឡើងនូវតម្រូវការទំនិញនិងសេវាក្នុងសេដ្ឋកិច្ច។ ជាការពិត សង្គ្រាមលោកលើកទី២ ត្រូវបានគេទទួលស្គាល់ថា បានពាំនាំអឺរ៉ុបឱ្យចេញផុតពីវិបត្តិសេដ្ឋកិច្ច។

មុនពេលមានវិបត្តិសេដ្ឋកិច្ចដ៏ធំ រដ្ឋាភិបាលទូទាំងពិភពលោក បានអនុវត្តតាមគោលនយោបាយ Lassesz-faire ឬ Let it be។ វិធីសាស្ត្រសេដ្ឋកិច្ចនេះ ផ្អែកលើការបង្រៀនរបស់បិតាសេដ្ឋវិទូក្លាស៊ីកមានដូចជា អាដាម ស្មីត និង អាល់ហ្វ្រេដម៉ាសាល់ជាដើម។ ពួកសេដ្ឋវិទូក្លាស៊ីកនិយម ជឿជាក់លើ

អំណាចនៃបាតដៃអរូបិយ (invisible hand) សេដ្ឋកិច្ចទីផ្សារ។ ពួកសេដ្ឋវិទូក្លាស៊ីកនិយម បានផ្តល់យោបល់ថារដ្ឋាភិបាលមិនគួរជ្រៀតជ្រែកចូលកិច្ចការងារសេដ្ឋកិច្ចនោះទេ ព្រោះថាការជ្រៀតជ្រែកណាមួយក្នុងទីផ្សារនោះ មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ ក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ភាពជាប់គាំងទីផ្សារភាគហ៊ុននាឆ្នាំ១៩២៩ ដែលនាំឱ្យមានវិបត្តិសេដ្ឋកិច្ចបណ្តាលមកពីតម្រូវការសេដ្ឋកិច្ចទាប រួមទាំងកំណើនអនិកម្មភាព។ ទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីកនិយម មិនអាចផ្តល់នូវដំណោះស្រាយណាមួយចំពោះវិបត្តិដ៏អាក្រក់នោះបានឡើយ។

សរុបជារួម រាល់អ្វីដែលបានលើកឡើងដោយលោកកេនស៍ សុទ្ធសឹងជាការសម្លឹងមើលលើព្រឹត្តិការណ៍សេដ្ឋកិច្ចបាតុភូតទាំងមូល និងមានលក្ខណៈខុសប្លែកពីសេដ្ឋវិទូជំនាន់មុនៗ។ អ្វីៗដែលគាត់បាននិយាយនៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ គឺជាទស្សនាទានថ្មីស្រឡាង និងស្ថិតនៅក្នុងប្រធានបទរបស់ម៉ាក្រូសេដ្ឋកិច្ចទ្រឹស្តីស្តីពី "អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ"។

១.២.៤-សេដ្ឋកិច្ចថ្មីបែបកេនស៍ (NEW-KEYNESIAN ECONOMIC)

តើទ្រឹស្តីសេដ្ឋកិច្ចកេនស៍បែបថ្មី គឺជាអ្វី?

ពាក្យថាទ្រឹស្តី "សេដ្ឋកិច្ចកេសន៍ថ្មីបែប" បានណែនាំមកដោយលោក Michael Parkin ក្នុងអំឡុងឆ្នាំ១៩៨២។ ការប្រើប្រាស់ពាក្យនេះជាលើដំបូងបំផុត "Neo-Keynesian economic" នៅក្នុងអត្ថបទមួយរបស់លោក Ball, Mankiw, និងលោក Romer នៅឆ្នាំ១៩៨៨។ ពាក្យថា "New" ត្រូវបានជំនួសដោយពាក្យ "Neo" ដើម្បីសម្គាល់ពាក្យថា "Neoclassiacl Synthesis Keynesian Economics" (ពាក្យនេះបានប្រើដោយលោក Samuelson និងសេដ្ឋវិទូដទៃទៀត) បង្ហាញថាវាជាទឡ្ហីករណ៍ប្រឆាំងនឹងសេដ្ឋកិច្ចសម័យថ្មី។

សេដ្ឋកិច្ចកេសន៍ថ្មីបែប គឺជាសាលាគំនិតនៃសិក្សាទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចនាសម័យទំនើប ដែលបន្តឆ្លុះបញ្ចាំងពីគំនិតរបស់លោកកេនស៍(ចាស់)។ លោក កេនស៍ បានសរសេរទ្រឹស្តីរួម "អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ" នាទសវត្សឆ្នាំ១៩៣០ ហើយទ្រឹស្តីរបស់គាត់មានឥទ្ធិពលក្នុងចំណោមអ្នកសិក្សាសេដ្ឋកិច្ច និងអ្នកគោលនយោបាយរហូតដល់ទសវត្សរ៍ឆ្នាំ១៩៦០ ។

ទោះបីជាយ៉ាងណា នាទសវត្សរ៍ឆ្នាំ១៩៧០ អ្នកសេដ្ឋវិទូថ្មីៗ ដូចជា Robert Lucas, លោក Thomas J. Sargent, និងលោក Robert Barro បានចោទជាសំនួរពីការបង្រៀនជាច្រើនអំពីបដិវត្តន៍សេដ្ឋកិច្ចរបស់លោកកេសន៍។ ក្រោមស្លាកពាក្យថា "New Keynesian" ដែលពិពណ៌នាអំពីអ្នកសេដ្ឋកិច្ចទាំងនោះក្នុងទសវត្សរ៍ឆ្នាំ១៩៨០ បានឆ្លើយតបតនឹងការរិះគន់សេដ្ឋកិច្ចក្លាស៊ីកថ្មីជាមួយនឹងការកែសម្រួលជាតុដើម។ ការងាររបស់ពួកគេ ត្រូវបានគេស្គាល់ថាជាការសំយោគសេដ្ឋកិច្ចក្លាស៊ីកថ្មី (Neo-classical) និងបង្កើតគំរូសេដ្ឋកិច្ចដែលបានបង្កើតជាគំនិតស្នូលនៃសេដ្ឋកិច្ច (Neo-Keynesian)។ គំនិតទាំងនេះ បានគ្របដណ្តប់លើសេដ្ឋកិច្ចមេ (Mainstream) រយៈពេលក្រោយសង្គ្រាម និងទទួលឥទ្ធិពលពីទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច នាទសវត្សរ៍ឆ្នាំ១៩៥០, ១៩៦០ និង ១៩៧០ ។

តើអ្វីជាភាពខុសគ្នារវាងសេដ្ឋកិច្ចកេនស៍ និងសេដ្ឋកិច្ចថ្មីបែបកេនស៍(New-Keynesian)?

- គន្លឹះសំខាន់របស់ទ្រឹស្តីកេនស៍មើលមិនឃើញថា សេដ្ឋកិច្ចទីផ្សារមិនអាចស្តារឡើងវិញដោយឯកឯងទេ។
- ទ្រឹស្តីសេដ្ឋកិច្ចនេអូកេនស៍(Neokeynesian)ដោយផ្តោតលើកំណើនសេដ្ឋកិច្ច និងស្ថិរភាពជាជាងនិកម្មភាពពេញលេញ។

ទ្រឹស្តីសេដ្ឋកិច្ចនេអូកេនស៍ បានកំណត់ថា សេដ្ឋកិច្ចទីផ្សារមិនមានការគ្រប់គ្រងដោយខ្លួនឯង (Self-regulating)ឡើយ។ សេដ្ឋវិទូកេនស៍បែបថ្មី បានជឿជាក់ថាសេដ្ឋកិច្ចទីផ្សារនឹងកែខៃដោយខ្លួនឯងមិនអាចទៅរួចនោះទេ។ ការធ្លាក់ចុះសេដ្ឋកិច្ច អាចនឹងកើតឡើងដោយសារតែការបរាជ័យនៃការសម្របសម្រួល។ សេដ្ឋកិច្ចកេនស៍បែបថ្មី គឺជាសាលានៃគំនិតសេដ្ឋកិច្ចបែបទំនើប បានផ្តល់គំនិតទៅលើអាជីវកម្មមិនអាចផ្លាស់ប្តូរថ្លៃរបស់ពួកគេបានឆាប់រហ័សនោះទេ។

<u>សំយោគសេដ្ឋកិច្ចកេនស៍ទំនើប៖</u>

ទ្រឹស្តីសេដ្ឋកិច្ចកេនស៍ទំនើបរបស់លោក Abba Lerner នៅក្នុងអំឡុងឆ្នាំ(១៩៤៤-១៩៥១) គឺជាមនុស្សដំបូងដែលបានស្វែងយល់ពីប្រព័ន្ធសេដ្ឋកិច្ចកេនស៍ទំនើបដែលសិក្សាពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រដ្ឋាភិបាល។

សេដ្ឋកិច្ចកេសន៍ទំនើប គឺជាសាលានៃគំនិតសេដ្ឋកិច្ចសិក្សាលើទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចដែលបានព្យាយាមផ្តល់មូលដ្ឋានគ្រឹះពីមីក្រូសេដ្ឋកិច្ច សម្រាប់សេដ្ឋកិច្ចកេនស៍ទំនើប។ ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច បានឆ្លើយតបទៅនឹងការរិះគន់ដោយអ្នកប្រកាន់ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចបែបថ្មី។

- មានសេដ្ឋវិទូភាគច្រើន ជឿជាក់ថាការឡើងចុះសេដ្ឋកិច្ចរយៈពេលខ្លីជាលទ្ធផលនៃទិន្នផលជាតិសរុប និងកម្រិតនិកម្មភាព វាបង្ហាញពីអត្រាគម្លាតពីធម្មជាតិ ដែលគម្លាតទាំងនេះកើតឡើងដោយសារតែប្រាក់ឈ្នួល (Wages) និងកម្រិតថ្លៃ(Price level) វានៅជាប់ជាមួយគ្នា។
- ការស្រាវជ្រាវរបស់សេដ្ឋវិទូកេនស៍ទំនើប បានព្យាយាមពន្យល់ពីភាពជាប់លាប់នៃប្រាក់ឈ្នួលនិងកម្រិតថ្លៃ ដោយពិនិត្យមើលទ្រឹស្តីមីក្រូសេដ្ឋកិច្ចនៃការកែតម្រូវកម្រិតថ្លៃ។

<u>ទ្រឹស្តីសេដ្ឋកិច្ចកេនស៍ទំនើប៖</u>

- ទីផ្សារមិនអាចកែសម្រួលបានលឿន ដូចការរំពឹងទុកសមមូយនោះឡើយ
- ការអន្តរាគមន៍របស់រដ្ឋាភិបាល នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះខ្លាំង
- រដ្ឋាភិបាល គួរតែជានាថាទីផ្សារដំណើរការទៅយ៉ាងរលូនតាមដែលអាចធ្វើទៅបានតាមរយៈគោលនយោបាយមីក្រូសេដ្ឋកិច្ច។

១.២.៥- សេដ្ឋកិច្ចមីក្រូក្លាស៊ីកបែបថ្មី(NEW CLASSICAL MICROECONOMIC)

តើសេដ្ឋកិច្ចមីក្រូក្លាស៊ីកបែបថ្មី គឺជាអ្វី?

សេដ្ឋកិច្ចមីក្រូក្លាស៊ីកបែបថ្មីជួនកាលគេហៅជាសាមញ្ញថា "New classical economics" គឺជាសាលានៃគំនិតសេដ្ឋកិច្ចនៃទ្រឹស្តីមីក្រូសេដ្ឋកិច្ចបែបថ្មីដែលបានបង្កើតការវិភាគលើក្របខ័ណ្ឌទ្រឹស្តីសេដ្ឋកិច្ចក្លាស៊ីកថ្មី(គំរូចាស់)។ ជាពិសេសទ្រឹស្តីនេះ សង្កត់ធ្ងន់លើសារៈសំខាន់នៃមូលដ្ឋានគ្រឹះយ៉ាង

ម៉ត់ចត់ ដោយផ្អែកលើមីក្រូសេដ្ឋកិច្ចដោយមានការរំពឹងទុកដ៏សមហេតុផលមួយ(Rational expectations)។

គំរូមីក្រូសេដ្ឋកិច្ចក្លាស៊ីកសម័យថ្មីនេះ បានបង្កើតឡើងចុងសតវត្សរ៍ទី ១៩ ផ្អែកលើការបោះពុម្ពផ្សាយសៀវភៅដោយលោក William Stanley Jevons, លោក Carl Menger និងលោក Leon Walras។ ទ្រឹស្តីនេះផ្តោតលើសេដ្ឋកិច្ចក្លាស៊ីកបែបថ្មី រួមបញ្ចូលជាមួយនឹងគោលការណ៍មូលដ្ឋានគ្រឹះសេដ្ឋកិច្ចរបស់លោកកេនស៍(គំរូចាស់)។ មីក្រូសេដ្ឋកិច្ចក្លាស៊ីកបែបថ្មី ខិតខំដើម្បីផ្តល់មូលដ្ឋានគ្រឹះមីក្រូសេដ្ឋកិច្ចសម្រាប់ការវិភាគម៉ាក្រូសេដ្ឋកិច្ច។ ការណ៍នេះ គឺផ្ទុយពីសាលានៃគំនិតសេដ្ឋកិច្ចកេនស៍ទំនើបដែលជាដៃគូប្រជែងរបស់ខ្លួនបានប្រើប្រាស់មីក្រូហិរញ្ញវត្ថុ ដូចជាភាពជាថ្លៃដើម និងការប្រកួតប្រជែងមិនល្អឥតខ្ចោះរបស់ទីផ្សារ ដើម្បីបង្កើតនូវគំរូម៉ាក្រូសេដ្ឋកិច្ចស្រដៀងនឹងទ្រឹស្តីនេអូកេនស៍ដែរ។

ក្នុងវិស័យសេដ្ឋកិច្ច មីក្រូហិរញ្ញវត្ថុគឺជាឥរិយាបទមីក្រូសេដ្ឋកិច្ចរបស់ភ្នាក់ងារម្នាក់ៗ ដូចជាភ្នាក់ងារគ្រួសារ ឬភ្នាក់ងារអាជីវកម្ម ដែលជាទ្រឹស្តីសេដ្ឋកិច្ចមូលដ្ឋាន។ ម៉ាក្រូសេដ្ឋកិច្ចជំបូងបំផុត រួមមានគំរូរបស់កេនស៍នាពេលថ្មីៗនេះ ដែលមានមូលដ្ឋានលើសម្មតិកម្មពីទំនាក់ទំនងរវាងបរិមាណសរុប មានដូចជាផលិតកម្មសរុប (Aggregate production) មាននិកម្មភាព (Employment) ការប្រើប្រាស់ (Consumption) និងការវិនិយោគ(Investment)។ អ្នករិះគន់ និងអ្នកគាំទ្រលើម៉ូដែលម៉ាក្រូសេដ្ឋកិច្ចក្លាស៊ីកថ្មីទាំងនេះ មិនបានយល់ស្របពីទំនាក់ទំនងសរុបរួម(Aggregate)ស្របនឹងគោលការណ៍នៃមីក្រូសេដ្ឋកិច្ចទេ។ ក្នុងអំឡុងពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ មានអ្នកសេដ្ឋវិទូម៉ាក្រូសេដ្ឋកិច្ច បានព្យាយាមបញ្ចូលគ្នានូវគំរូមីក្រូសេដ្ឋកិច្ចនៃឥរិយាបទគ្រួសារ និងអាជីវកម្ម ដែលមានទំនាក់ទំនងរវាងអថេរម៉ាក្រូសេដ្ឋកិច្ច។ បច្ចុប្បន្ននេះ មានគំរូម៉ូដែលម៉ាក្រូសេដ្ឋកិច្ចជាច្រើនតំណាងឱ្យទ្រឹស្តីផ្សេងៗគ្នា ត្រូវបាន ទទួលដោយការប្រមូលផ្តុំម៉ូដែលមីក្រូសេដ្ឋកិច្ច។ ក្រុមសេដ្ឋវិទូ បានសាកល្បងសិក្សាលើទិន្នន័យម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ច។ ការសិក្សាអំពីមីក្រូហិរញ្ញវត្ថុ កំពុងតែទទួលបានប្រជាប្រិយភាពសូម្បីតែការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗនេះ រួមមានការគ្រប់គ្រងប្រតិបត្តិការ និងការសិក្សាគម្រោងជាដើម។

លោក Robert Lucas បានបង្កើតម៉ូដែល "ការរំពឹងទុកដ៏សមហេតុផល" សម្រាប់ការអភិវឌ្ឍន៍និងអនុវត្តទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចនៃការរំពឹងទុកដ៏សមហេតុផល ដែលជាសម្មតិកម្មនៃអេកូណូមេទ្រីក។ លោក Robert Lucas បានរកឃើញថាបុគ្គលម្នាក់ៗនឹងបញ្ឈប់ (Offset) លទ្ធផលដែលបានគ្រោងទុកនៃគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុ ដោយធ្វើការសម្រេចចិត្តខាងសេដ្ឋកិច្ចឯកជន ផ្អែកលើបទពិសោធន៍កន្លងមក និងលទ្ធផលដែលបានរំពឹងទុក។ ទ្រឹស្តី"ការរំពឹងទុកដ៏សមហេតុផល" បានបង្ហាញថា រូបវន្តបុគ្គលពឹងផ្អែកលើការសម្រេចចិត្តលើហេតុផលព័ត៌មានរបស់ពួកគេ និងបទពិសោធន៍កន្លង មក។ អ្នកសេដ្ឋកិច្ចប្រើទ្រឹស្តីសមាមាត្រការរំពឹងទុក ដើម្បីពន្យល់ពីកត្តាសេដ្ឋកិច្ចដែលបានរំពឹងទុក ដូចជាអត្រាអតិផរណា និងអត្រាការប្រាក់។ លោក Robert Lucas បានលើកឡើងថា ប្រសិនបើ(ដូចដែលត្រូវបានសន្មតថាក្នុងមីក្រូសេដ្ឋកិច្ច)ក្នុងសេដ្ឋកិច្ច គឺមានការរំពឹងទុកសមហេតុសមផល។ បន្ទាប់មក មានការផ្លាស់ប្តូរដែលមិននឹកស្មានដល់ ចំពោះការផ្តត់ផ្តង់រូបិយវត្ថុ មានឥទ្ធិពលលើទិន្នផល

និងនិកម្មភាព បើមិនដូច្នោះទេប្រជាជនគ្រាន់តែកំណត់ប្រាក់ឈ្នួល និងតម្រូវការថ្លៃឈ្នួល តាមការរំពឹងទុករបស់ពួកគេពីអតិផរណានាពេលអនាគតឆាប់ៗនេះ។

ទ្រឹស្តីសេដ្ឋកិច្ចរបស់លោក Edward C. Prescott (១៩៤០)៖ សេដ្ឋវិទូជនជាតិអាមេរិក គាត់គឺឥស្សរជនសំខាន់ម្នាក់នៅក្នុងទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច ជាពិសេសទ្រឹស្តីវដ្តអាជីវកម្ម។ នៅក្នុងឆ្នាំ(២០០៤) លោក Edward Christian Prescott និងលោក Finn Kydland បានទទួលរង្វាន់ណូបែលដែលបានបោះពុម្ពផ្សាយទ្រឹស្តី "Ahead of Business Cycle Measurement"។ លោក Prescott និងលោក Kydland បានសរសេរអត្ថបទរបស់ពួកគេជឿថាអាជីវកម្មដែលតម្រូវការដ៏គួរឱ្យតក់ស្លុត ដូចជាការដួលរលំនៃទំនុកចិត្តរបស់អតិថិជនមានន័យថា គោលនយោបាយរូបិយវត្ថុអាចដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យវដ្តអាជីវកម្មមានភាពរលូន និងកាត់បន្ថយវិបត្តិទាំងនោះបាន។


<u>ទស្សន:សេដ្ឋកិច្ចក្លាស៊ីកនិយម៖</u>

ទ្រឹស្តីសេដ្ឋកិច្ចលំនឹងសមតា (Eqilibrium) កើតមានឡើង ពេលដែលបរិមាណការផ្គត់ផ្គង់សរុបគឺស្មើគ្នាបរិមាណតម្រូវការសរុប (Aggregate demand)។

ហេតុអ្វីបានជាសេដ្ឋវិទូក្លាស៊ីកគិតថាដំណើរសេដ្ឋកិច្ចនឹងកែខៃទីផ្សារដោយខ្លួនឯង (Self-correcting)? ហេតុអ្វីមិនតម្រូវឱ្យមានតួនាទីរបស់រដ្ឋាភិបាលក្នុងសេដ្ឋកិច្ច? តើទស្សន:ពួកក្លាស៊ីកស្តីពីចំណូលសុទ្ធ(Net income) កម្រិតនិកម្មភាព(Employment) ទីផ្សារពលកម្ម(Market labor) ការសន្សំ(Saving) និងការវិនិយោគមានអ្វីខ្លះ? តើតួនាទីរបស់រូបិយវត្ថុក្នុងសេដ្ឋកិច្ចយ៉ាងដូចម្តេច? ហេតុអ្វីបានជាពួកសេដ្ឋវិទូក្លាស៊ីក ជឿជាក់ថា គោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុនឹងមិនមានការប្រែប្រួលកម្រិតទិន្នផលជាតិសរុប(National income) និងកម្រិតការងារ។ ហេតុអ្វីខ្សែកោងផ្គត់ផ្គង់សរុប (Aggregate Supply) គឺត្រូវបញ្ឈរ?

ពួកសេដ្ឋវិទូក្លាស៊ីកជឿជាក់ថា គោលនយោបាយរូបិយវត្ថុ៖ មានទំទាក់ទំនងគ្នាយ៉ាងពិតប្រាកដរវាងការផ្គត់ផ្គង់ និងកម្រិតថ្លៃ។ ប្រសិនបើមានការផ្លាស់ប្តូរការផ្គត់ផ្គង់រូបិយវត្ថុនោះ ការផ្លាស់ប្តូរនេះនឹងជះឥទ្ធិពលដោយផ្ទាល់ទៅលើតម្រូវការសរុប។

តំនូសតាងទី១៖ ប្រវត្តិនៃសេដ្ឋកិច្ច



ការផ្លាស់ប្តូរតម្រូវការសរុប មានផលប៉ះពាល់ដល់ផលិតផលក្នុងស្រុកសរុបពិត និងនិកម្មភាព។ ប្រសិនបើមានការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុធំជាងអត្រាកំណើនសេដ្ឋកិច្ច ជាលទ្ធផល វានឹងកើនឡើងនៃកម្រិតថ្លៃផងដែរ។ ក្លាស៊ីកនិយមក៏ជឿជាក់ដែរថា សេដ្ឋកិច្ចនឹងកែខ្លួនដោយខ្លួនឯង ដូច្នេះ ប្រសិនបើមានអតុល្យភាពណាមួយនៅក្នុងកម្រិតថ្លៃតម្រូវការសរុប ឬការផ្គត់ផ្គង់សរុប សេដ្ឋកិច្ចនឹងវិលត្រឡប់ទៅរកលំនឹងវិញ។ គំរូសេដ្ឋកិច្ចដែលទទួលគំនិតនៃសេដ្ឋកិច្ច មុនទ្រឹស្តីសេដ្ឋវិទូរបស់ លោក កេនស៍។ ការសន្មត់ថាកម្រិតថ្លៃ និងកម្រិតប្រាក់ឈ្នួល ត្រូវសម្របទៅនឹងទីផ្សារឱ្យបានច្បាស់លាស់ ហើយគោលនយោបាយរូបិយវត្ថុ មិនមានឥទ្ធិពលលើអថេរពិតប្រាកដ ដូចជាទិន្នផលសេដ្ឋកិច្ច និងនិកម្មភាពឡើយ។

សេដ្ឋវិទូក្លាស៊ីកជឿជាក់ថាផ្នែកការផ្គត់ផ្គង់ មានសារសំខាន់ជាជាងផ្នែកតម្រូវការ។ គំរូសេដ្ឋកិច្ចបែបក្លាស៊ីកបង្ហាញថា សេដ្ឋកិច្ចមាននិកម្មភាពពេញលេញគ្រប់កម្រិតនៃទិន្នផលសេដ្ឋកិច្ច។ ដូច្នេះ ការផ្គត់ផ្គង់សរុប គឺអ័ក្សបញ្ឈរ។ នេះមានន័យថារាល់ការកើនឡើង ឬថយចុះនៃតម្រូវការការសរុបនាំឱ្យតម្លៃកាន់តែខ្ពស់ឬទាប ប៉ុន្តែទិន្នផលសេដ្ឋកិច្ចនៅតែដដែល។

<u>ទស្សន:សេដ្ឋកិច្ចកេនស៍និយម៖</u>

គំរូសេដ្ឋកិច្ចកេនស៍និយមបានសន្មតថា គឺជាតម្រូវការនឹងបង្កើតការផ្គត់ផ្គង់ដោយខ្លួនឯង ដរាបណាកម្រិតអនិកម្មភាព កម្រិតថ្លៃ និងកម្រិតប្រាក់ឈ្នួល មានភាពតឹងរឹងតែក្នុងសេដ្ឋកិច្ចរយៈពេលខ្លី។ សេដ្ឋកិច្ចកេនស៍និយមជឿជាក់ថាផ្នែកតម្រូវការ មានសារសំខាន់ជាងផ្នែកការផ្គត់ផ្គង់។ លោកកេនស៍ បានធ្វើការតស៊ូមតិសម្រាប់ការចំណាយរបស់រដ្ឋាភិបាល និងការកាត់បន្ថយពន្ធ ដើម្បីជំរុញតម្រូវការ និងទាញគោលដៅសេដ្ឋកិច្ចចេញពីវិបត្តិ។ លោកកេនស៍ ត្រូវបានគេចាត់ទុកថាទ្រឹស្តី "តម្រូវការ"ដែលផ្តោតលើការផ្លាស់ប្តូរសេដ្ឋកិច្ចរយៈពេលខ្លី។ តាមទ្រឹស្តីរបស់លោកកេនស៍ អត្រាអនិកម្មភាពពឹងផ្អែកលើតម្រូវការដែលមានប្រសិទ្ធភាព។ ប្រសិទ្ធភាពតម្រូវការ ជាលទ្ធផលនៃទិន្នផលសេដ្ឋកិច្ច។ ទិន្នផលសេដ្ឋកិច្ច បង្កើតប្រាក់ចំណូល។ ដូច្នេះ អត្រាអនិកម្មភាពពឹងផ្អែកលើតម្រូវការសរុប ជាលទ្ធផលត្រូវបានកំណត់ដោយតម្រូវការលើការប្រើប្រាស់ និងតម្រូវការវិនិយោគ។ លោក បានជឿជាក់ថារាល់ការផ្លាស់ប្តូរការផ្គត់ផ្គង់រូបិយវត្ថុ នឹងប៉ះពាល់ដល់អត្រាការប្រាក់ (Interest rates)។ នៅគ្រាដែលអត្រាការប្រាក់ ត្រូវបានរងផលប៉ះពាល់តម្រូវការសរុប ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរអត្រាការប្រាក់។ ការផ្លាស់ប្តូរណាមួយក្នុងគោលនយោបាយរូបិយវត្ថុ គឺមានឥទ្ធិពលទៅលើការផ្គត់ផ្គង់រូបិយវត្ថុ។

ដូច្នេះការសិក្សាពីប្រវត្តិគំនិតសេដ្ឋកិច្ច ឬប្រវត្តិសេដ្ឋកិច្ច គឺផ្តោតជាសំខាន់ទៅលើអ្វីដែលបានកើតឡើងនៅក្នុងគំនិតសេដ្ឋកិច្ច ខណៈពេលដែលមានសេដ្ឋវិទូជាច្រើន មានការយល់ឃើញខុសគ្នា និងមានការពន្យល់ខុសគ្នាដោយអន្លើ។ ការសិក្សាប្រវត្តិគំនិតនៃសេដ្ឋកិច្ច មិនវិនិច្ឆ័យថាតើគំនិតសេដ្ឋកិច្ចរបស់សេដ្ឋវិទូ ឬបញ្ញាវន្តណាមួយត្រូវ ឬណាមួយខុសឡើយ។ ផ្ទុយទៅវិញ គឺគ្រាន់តែបង្ហាញអំពីដំណើរការវិវត្ត និងការប្រែប្រួលនូវគំនិតនៃសេដ្ឋកិច្ចដែលមានជាយូរលង់មកហើយ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវអំពីគំនិតនៃសេដ្ឋកិច្ច ឬប្រវត្តិនៃសេដ្ឋកិច្ច ដើម្បីធ្វើការសិក្សាពិភាក្សាវែកញែកឱ្យដាច់ថាតើនរណាខ្លះជាសេដ្ឋវិទូ ឬប្រវត្តិវិទូជាដើម ដើម្បីជៀសវាងការភ័ន្តច្រឡំ។

១.៣-ការវិវត្តគំរូម៉ូដែលសេដ្ឋកិច្ច(THE EVOLUTION OF MODEL´S ECONOMIC)

១.៣.១-គំរូម៉ូដែលក្លាស៊ីក(THE CLASSICAL PARADIGM)

ក្រុមនៃគំរូម៉ូដែលរបស់ក្លាស៊ីក គឺស្របទៅនឹងក្របខណ្ឌលំនឹងសមតាទូទៅរបស់គំរូម៉ូដែលរបស់ Walrasian ហើយបានសន្មត់ថាទីផ្សារបង្កើតប្រាក់ឈ្នួល និងថ្លៃឈ្នួលពលកម្មសម្រាប់ទំនិញនីមួយៗ នៅក្នុងកម្រិតនៃតម្រូវការ និងការផ្គត់ផ្គង់មានលក្ខណៈស្មើគ្នា (ជម្រះទីផ្សារ)។ មានទីផ្សារមួយគឺជាទីផ្សារកម្លាំងពលកម្ម ដែលបានបោសសម្អាត វាបានបញ្ជាក់ថារាល់កម្មករដែលមានបំណងផ្គត់ផ្គង់កម្លាំងពលកម្មតាមរយៈប្រាក់ឈ្នួលដែលមានស្រាប់នឹងមាននិកម្មភាពពេញលេញ ហើយប្រាក់ឈ្នួលនីមួយៗ នឹងអាចផ្តល់ការងារដល់កម្មករទាំងអស់ដែលខ្លួនចង់បានតាមរយៈប្រាក់ឈ្នួលដែលមានឱ្យដល់ទីផ្សារ។[៦]

[៦] In the short-run of the classical models, with errors in expectations, market clearance can imply a level of employment different from the full-employment (long-run equilibrium) level.

ស្ថានភាពនេះនៅក្នុងបរិបទនៃការវិភាគរយៈពេលវែងត្រូវបានគេស្គាល់ថាជា "ការងារពេញលេញ" ដូច្នេះ សញ្ញាណសម្គាល់នៃគំរូម៉ូដែលរបស់ក្លាស៊ីក គឺថានៅក្នុងលំនឹងសមតាសម្រាប់រយៈពេលវែងពួកគេបានបង្ហាញពីនិកម្មភាពពេញលេញ។[៧] ទោះយ៉ាងណាក៏ដោយយើងមើលឃើញពីការសង្កត់ធ្ងន់របស់ពួកក្លាស៊ីកលើការសម្អាតទីផ្សាការងារដែលមានផលប៉ះពាល់ដល់លំនឹងសមតានេះច្រើនតែត្រូវបានគេបញ្ចោញ និងនិយាយដូចជាវា គឺជាការសន្មតដែលមិនត្រូវបានម៉ត់ចត់ទេ។

១.៣.២-ទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក(TRADITIONAL CLASSICAL IDEA)

"វិធីសាស្ត្របែបបុរាណ(ក្លាស៊ីក)" ត្រូវបានលើកឡើងក្នុងសៀវភៅនេះ សម្រាប់ទស្សនៈខុសៗគ្នាបន្តិចបន្តួចស្តីពីការប្រែប្រួលសេដ្ឋកិច្ចនាពាក់កណ្តាលសតវត្សរ៍ទី ១៨ រហូតដល់ការចេញផ្សាយទ្រឹស្តីទូទៅរបស់លោកកេនស៍នៅក្នុងឆ្នាំ ១៩៣៦ ។ ក្នុងវិសាលភាពគួរឱ្យកត់សម្គាល់ពីទស្សនៈទាំងនេះ ត្រូវបានសាយភាយផ្លាស់ប្តូរក្នុងចំណោមអ្នកនិពន្ធទៅតាមពេលវេលា។ ក្នុងករណីណាក៏ដោយ ក៏ពុំមានកែបង្រួមអត្ថន័យទាំងស្រុងទេ ទោះបីជាមានការទទួលស្គាល់តាមទ្រឹស្តីរួមរបស់លោកកេសន៍ក៏ដោយ។ ឥឡូវនេះ ពួកគេបានចាត់ទុកដូចជាមានគំរូម៉ូដែលកែបង្រួមគ្នាមួយ។ យើងអាចហៅសេចក្តីថ្លែងការណ៍រួមដ៏តូចចង្អៀតនៃទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក មិនត្រូវបានគេនិយាយថាជាគំរូម៉ូដែលបង្រួមរួម សូម្បីតែក្នុងអំឡុងពេលរុងរឿងរបស់គំរូម៉ូដែលនេះក្នុងកំឡុងសតវត្សរ៍ទី ១៩ និងដើមសតវត្សរ៍ទី២០ ក៏ដោយ ប៉ុន្តែគំនិតរបស់វាត្រូវបានបញ្ចូលក្នុងគំរូម៉ូដែលក្លាស៊ីកនិយមបែបថ្មី។

សមាសធាតុពីរនៃគំរូម៉ូដែលក្លាស៊ីកទាក់ទងដោយផ្ទាល់នឹងសេដ្ឋកិច្ចរូបិយវត្ថុ គឺជាទ្រឹស្តីបរិមាណរូបិយវត្ថុសម្រាប់កម្រិតថ្លៃ និងទ្រឹស្តីមូលនិធិដែលអាចកម្ចីបានកម្រិតអត្រាការប្រាក់។ ទ្រឹស្តីនិកម្មភាព គឺជាការវិភាគលើទីផ្សារការងារ (ពលកម្ម) និងរួមបញ្ចូលសម្មតិកម្មថាមានលំនឹងសមតាទីផ្សារដែលបានបង្ហាញថានិកម្មភាពពេញលេញ ដូច្នេះទស្សនៈសេដ្ឋវិទូក្លាស៊ីក ពុំមានទ្រឹស្តីនៃអនិកម្មភាព ឬបប្រែបម្រួលការងារលើបម្រែបម្រួលសរុបក្នុងកម្រិតជំណើរការសេដ្ឋកិច្ចសម្រាប់រយៈពេលវែងនោះទេ។ ដូច្នេះវាពុំមានទ្រឹស្តីនៃគម្លាតនៃអនិកម្មភាព និងទិន្នផលសរុបពីកម្រិតការងារពេញលេញរបស់ពួកគេឡើយ។

ទោះយ៉ាងណា សមាសធាតុផ្សំមួយទៀតនៃគំនិតបុរាណបែបក្លាស៊ីក គឺពន្យល់អំពីវដ្តអាជីវកម្មរបស់វា ដែលអនុញ្ញាតឱ្យមានសកម្មភាពសេដ្ឋកិច្ចក្នុងការឆ្លើយតបរបស់សេដ្ឋកិច្ចទៅនឹងវិបត្តិសេដ្ឋកិច្ចជាក់ស្តែង ដូច្នេះការពន្យល់បែបនេះពិតជាបានបង្វែរទិសដៅពីនិកម្មភាពពេញលេញ។ វិធីសាស្ត្របែបបុរាណខ្វះការធ្វើសមាហរណកម្មលើទ្រឹស្តីមីក្រូសេដ្ឋកិច្ច និងជាលទ្ធផលការងារផ្អែកលើលទ្ធផលនៃការពន្យល់ពីវដ្តអាជីវកម្មក៏ដូចជាការលាយបញ្ចូលគ្នារវាងទ្រឹស្តីបរិមាណ និងទ្រឹស្តីមូលនិធិដែលអាចខ្ចីប្រាក់បាន។ សរុបជារួម ខណៈពេលដែលវិធីសាស្ត្រនេះ មានសមាសធាតុជាច្រើននៃទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច វាខ្វះក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរួមបញ្ចូលគ្នា។ វាក៏ខ្វះការព្យាបាលជាក់លាក់នៃតម្រូវការសរុបសម្រាប់ទំនិញ

[៧] The difference between an assumption of full employment and one that is an implication of the equilibrium state is that the former rules out the studies of the properties of the system when it is in disequilibrium; the latter does not necessarily do so. In addition, the former can rule out a distinction between short-run and long-run equilibrium.

ដែលបច្ចុប្បន្នមាននៅក្នុងទំនាក់ទំនងខ្សែកោង IS ជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃម៉ាក្រូសេដ្ឋកិច្ចបច្ចុប្បន្ន។

១.៣.៣-ទ្រឹស្តីតម្រូវការសរុបនៃសេដ្ឋកិច្ចក្លាស៊ីក (THEORY OF AGGREGATE DEMAND IN THE TRADITIONAL CLASSICAL)

ពុំមានទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចជាក់លាក់តាមគំរូម៉ូដែលរបស់ពួកក្លាស៊ីកឡើយ វាមិនបានបញ្ចូលជាទ្រឹស្តីសម្រាប់ការកំណត់តម្រូវការសរុបសម្រាប់ទំនិញ(រូបិយវត្ថុ)ទេ។[៨] ផ្ទុយទៅវិញវិធីសាស្ត្រនេះ បានសិក្សាលើទីផ្សារលើទំនិញនីមួយៗដាច់ដោយឡែកពីគ្នានៅក្នុងលក្ខខណ្ឌមីក្រូសេដ្ឋកិច្ច ពោលគឺទាក់ទងនឹងការវិភាគលើតម្រូវការ និងការផ្គត់ផ្គង់។[៩] ជំនួសឱ្យទ្រឹស្តីនៃតម្រូវការសរុបសម្រាប់ទំនិញទាំងស្រុង វិធីសាស្ត្របែបបុរាណតាមបែបជាក់លាក់ ប៉ុន្តែកាន់តែច្បាស់ជាងនេះទៅទៀតត្រូវបានដោះស្រាយតាមច្បាប់របស់ (Say's law) ដែលបានបញ្ជាក់ថាការផ្គត់ផ្គង់សរុបបង្កើតបានទំនិញ (តែងតែបានចូលរួម) តាមតម្រូវការរបស់ខ្លួន ដូច្នេះទ្រឹស្តីដាច់ដោយឡែកពីតម្រូវការសរុបមិនចាំបាច់ ឬទាមទារជាក់លាក់ទេ។

Say's law មាននៅគ្រប់ទីកន្លែងក្នុងការវិភាគដែលផ្តល់ដោយសេដ្ឋវិទូជាច្រើននៅសម័យកាលបុរាណ។ ក្នុងចំណោមច្បាប់ផ្សេងទៀត វាត្រូវបានចារទុកដោយលោក Adam Smith នៅសតវត្សរ៍ទី ១៨ និងដើមសតវត្សរ៍ទី១៩ ដែលរួមមានលោក David Ricardo នៅពាក់កណ្តាលសតវត្សរ៍ទី១៩ និងលោក Alfred Marshall នៅចុងសតវត្សរ៍ទី ១៩។ បើទោះយ៉ាងណា Say's law មិនមានសុពលភាពសម្រាប់សេដ្ឋកិច្ចរូបិយវត្ថុដែលមានទំនិញជា (រូបិយវត្ថុនិងកាស) និងមូលបត្របំណុលសម្រាប់ហេតុផលជាច្រើននៅក្នុងសេដ្ឋកិច្ចនោះទេ។

ក្នុងចំណោមទ្រឹស្តីទាំងនោះ គឺថានៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុ; អ្នកលក់ទំនិញទាំងអស់មិនមែនជាអ្នកទិញទំនិញដោយស្វ័យប្រវត្តិនោះទេ ព្រោះតែផ្នែកមួយប្រាក់ចំណូលរបស់អ្នកលក់ ត្រូវបានរក្សាទុកដែលអាចត្រូវបានរាប់បញ្ចូលជារូបិយវត្ថុ ឬសញ្ញាប័ណ្ណ (រួមបញ្ចូលទាំងប្រាក់បញ្ញើសន្សំក្នុងធនាគារ) ច្រើនជាងការប្តូរទៅជាការចំណាយលើទំនិញ(រូបិយវត្ថុ)។

<u>កំណត់ចំណាំ</u>៖ ទ្រឹស្តីទំនើបនៃតម្រូវការសរុប មិនត្រូវរាប់បញ្ចូលក្នុង Say's law នោះទេ។ ដូច្នេះវាមិនមែនជាផ្នែកមួយនៃម៉ាក្រូសេដ្ឋកិច្ចទំនើបទៀតឡើយ។

១.៣.៤- គំរូទ្រឹស្តីនេអូក្លាស៊ីក(NEOCLASSICAL MODEL)

សម្រាប់ "គំរូម៉ូដែលរបស់នេអូក្លាស៊ីក" គឺជាឈ្មោះថ្មីដែលត្រូវបានផ្តល់ឱ្យប្រើឡើងវិញនៃគំនិតសេដ្ឋកិច្ចរបស់ក្លាស៊ីក (បុរាណ) ដែលបានផ្តល់គំរូម៉ូដែលថ្មីឡើងវិញ និងបានរកឃើញក្នុងដំណាក់កាលចុងក្រោយនៃទ្រឹស្តីទូទៅក្នុងក្របខ័ណ្ឌបង្រួមរួមទ្រឹស្តីជាថ្មី។ ក្របខណ្ឌគំរូម៉ូដែលរបស់នេអូក្លាស៊ីក គឺជា

[៨] The analysis of aggregate demand requires the concept of the multiplier, which was propose only in the 1930s.

[៩] The analysis of aggregate demand requires the concept of the multiplier, which was proposed only in the 1930s.

ការវិភាគលើក្របខ័ណ្ឌសមីការខ្សែកោង IS-LM ។ សម្រាប់ការសិក្សាស្រាវជ្រាវឡើងវិញ រួមមានការពន្លឿនការគិតគូរពីទ្រឹស្តីក្លាស៊ីក ដូចជាពាក្យថា"ទ្រព្យសម្បត្តិ/ពីហ្គូ" និងផលប៉ះពាល់ទៅលើតុល្យភាពពិតលើតម្រូវការទំនិញ ដូចជាការបន្ថែមធាតុថ្មីនៃតម្រូវការប្រជុំយប្រថានចំពោះរូបិយវត្ថុ និងការវិភាគយ៉ាងជាក់លាក់នៃទីផ្សារទំនិញក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច។

លើសពីនេះទៀត ធាតុខ្លះនៃគំនិតសេដ្ឋកិច្ចក្លាស៊ីក ដូចជាទ្រឹស្តីបរិមាណរូបិយវត្ថុ ជាទ្រឹស្តីមូលនិធិឱ្យខ្ចីប្រាក់ និងច្បាប់របស់សាយ (Say's law) និងភាពចែកដាច់ពីគ្នារវាងភាពជាក់ស្តែងនៃសេដ្ឋកិច្ច និងសេដ្ឋកិច្ចរូបិយវត្ថុ ត្រូវបានគេបោះបង់ចោលនៅក្នុងដំណើរការបង្វិលប្រាក់។ ជាលទ្ធផលនៃគំរូម៉ូដែលក៏ខុសគ្នាពីគំនិតបែបបុរាណតាមរយៈការធ្វើសមាហរណកម្មម៉ាក្រូសេដ្ឋកិច្ចដែរ។ គំរូម៉ូដែលបែបបុរាណ ជាទូទៅត្រូវបានបដិសេធចោលភាគច្រើននៃវិជ្ជាជីវៈសេដ្ឋកិច្ច ពីទសវត្សរ៍ឆ្នាំ១៩៤០ ដល់ឆ្នាំ ១៩៧០ បើទោះបីជាវានៅតែបន្តកើតមាន ដូចជាការដាក់បញ្ចូលក្នុងការសិក្សាវិភាគនេះក៏ដោយ។

បើទោះយ៉ាងណា ការកែលម្អគំរូម៉ូដែលសេដ្ឋកិច្ចក្លាស៊ីកឡើងវិញ និងការបន្ថែមលើគំរូម៉ូដែលសេដ្ឋកិច្ចក្លាស៊ីកនៅតែបន្តធ្វើក្នុងទសវត្សរ៍ទាំងនេះ។ គំរូម៉ូដែលដ៏លេចធ្លោនៅក្នុងទសវត្សរ៍ទាំងនេះ គឺជាគំរូម៉ូដែលរបស់លោកកេនស៍។ បើទោះបីជា គំរូម៉ូដែលថ្មីបានរើបឡើងវិញនៅក្នុងទសវត្សឆ្នាំ ១៩៧០ ក៏ដោយ ហើយចាប់តាំងពីពេលនោះមកបានយកទម្រង់គំរូម៉ូដែលផ្សេងៗគ្នា។ ទាំងនេះ គឺជាមនោគមវិជ្ជាសេដ្ឋកិច្ចនៅក្នុងឆ្នាំ ១៩៧០ តាមគំរូបុរាណបែបទំនើប និងគំរូបុរាណបែបថ្មី។

ការកំណត់បទដ្ឋានវិភាគលើរូបិយវត្ថុ គឺថាធនាគារកណ្តាលអនុវត្តការគ្រប់គ្រងសេដ្ឋកិច្ច ដោយពិនិត្យលើការផ្តត់ផ្តង់រូបិយវត្ថុសរុប (aggregate supply)។ ក្នុងករណីនេះ ការវិភាគលើតម្រូវការរូបិយវត្ថុសរុប (aggregate demand) ត្រូវបានគេហៅថាខ្សែកោង៖ IS–LM ។ ការវិភាគលើទីផ្សាររូបិយវត្ថុ បង្កើតបានសមីការខ្សែកោង IS ។ ទោះយ៉ាងណាក៏ដោយ ប្រភេទនៃសេដ្ឋកិច្ចខ្លះ ការគ្រប់គ្រងអត្រាការប្រាក់ អាចជាមធ្យោបាយមួយក្នុងការគ្រប់គ្រងតម្រូវការរូបិយវត្ថុសរុបច្រើនជាងការផ្តត់ផ្តង់រូបិយវត្ថុសរុប។ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍មួយចំនួនរួមទាំងសហរដ្ឋអាមេរិក កាណាដា និងអង់គ្លេស បច្ចុប្បន្ននេះ ហាក់ដូចជាពឹងផ្អែកកាន់តែខ្លាំងលើអត្រាការប្រាក់ជាជាងការផ្តត់ផ្តង់លុយសរុប ដែលជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុជាចម្បង។[90]

សម្រាប់សេដ្ឋកិច្ចប្រទេសរបស់ពួកគេ ការវិភាគលើខ្សែកោង LM ពុំសូវសមស្របនោះទេ។ ផ្ទុយទៅវិញ ការវិភាគលើខ្សែកោង IRT(interest rate target) ដែលបន្ថែមលើខ្សែកោង IS កំណត់តម្រូវការរូបិយវត្ថុសរុបនៅក្នុងគំរូវិភាគ។ ការវិភាគលើខ្សែកោង IS–LM និង IS–IRT ត្រូវបានបង្ហាញលម្អិតក្នុងជំពូកទី ១៣ នៃសៀវភៅចំណងជើង "សេដ្ឋកិច្ចរូបិយវត្ថុ" ។ ប្រសិនបើធនាគារកណ្តាលកំណត់អត្រាការប្រាក់ជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុហួសហេតុពេក ដែលមានគោលបំណងផ្តត់ផ្តង់បរិមាណរូបិយវត្ថុសរុបទៅតាមអត្រាការប្រាក់នោះដែរ។ ធនាគារកណ្តាល អាចធ្វើឱ្យមានការផ្លាស់ប្តូរសមស្របទៅតាមមូលដ្ឋានរូបិយវត្ថុ ដោយការស្ម័គ្រចិត្ត ឬអនុញ្ញាតិឱ្យធនាគារពាណិជ្ជកម្ម អាចខ្ចីលុយពី

[90] This is also so for the European Central Bank, which claims to treat the interest rate as its primary monetary policy instrument but also monitors monetary aggregates.

ធនាគារកណ្តាលបាន។ ក្នុងករណីនេះ ការផ្តត់ផ្តង់រូបិយវត្ថុបានក្លាយទៅជារឿងមិនល្អសម្រាប់សេដ្ឋកិច្ច។

ជំពូកទី ២

លក្ខណៈវិនិច្ឆ័យនៃសារពើពន្ធ

CRITERIA OF FISCAL

២.១-លក្ខណៈសំគាល់នៃសារពើពន្ធ(FEATURE OF FISCAL)

២.១.១-ខ្លឹមសារនៃសារពើពន្ធ(MEANING OF FISCAL)

សារពើពន្ធ[99] គឺជាវិភាគទានមានលក្ខណៈជាកាតព្វកិច្ចតាមច្បាប់កំណត់ ដែលអ្នកជាប់ពន្ធទាំងរូបវន្តបុគ្គលនិងទាំងនីតិបុគ្គល ដែលមានកាតព្វកិច្ចត្រូវបង់ជូនរដ្ឋ។ សារពើពន្ធ គឺមានលក្ខណៈចាប់

[99] Define: Taxation

បង្ខំ មិនអាស្រ័យទៅលើការស្ម័គ្រចិត្ត ដូចជាការផ្តល់អំណោយនោះទេ។ ហើយរាល់ការបង់ពន្ធនីមួយៗ ពុំមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងបរិមាណទំនិញសាធារណៈជាក់លាក់ឡើយ ដែលត្រូវតែផ្តត់ផ្តង់ឱ្យអ្នកជាប់ពន្ធម្នាក់ៗនោះដែរ។[១២] លក្ខណៈបង្ខំនៃសារពើពន្ធ មានមូលដ្ឋានមកពីបាតុភូតនៃការប្រើប្រាស់សេរី ពាក់ព័ន្ធទៅនឹងការចូលរួមវិភាគទានក្នុងការផលិត ឬការប្រើប្រាស់ទំនិញ និងសេវាសាធារណៈ។ ភាពមិនអាចដកចេញបាន និងភាពមិនអាចប្រជែងបាន របស់ទំនិញសាធារណៈបណ្តាលឱ្យមានអ្នកប្រើប្រាស់សេរី ដែលមានលទ្ធភាពប្រើប្រាស់ទំនិញ និងសេវាសាធារណៈ។ ហេតុនេះហើយទើប មានអ្នកគេចវេសពីកាតព្វកិច្ចបង់វិភាគទានពន្ធ។ ដើម្បីដោះស្រាយបញ្ហានេះ សារពើពន្ធគឺជាមធ្យោបាយមួយសម្រាប់ធ្វើហិរញ្ញប្បទានដល់នូវការផ្តត់ផ្តង់ទំនិញ និងសេវាសាធារណៈ ហើយត្រូវមានលក្ខណៈជាកាតព្វកិច្ច ដោយមិនឈរលើគោលការណ៍ស្ម័គ្រចិត្តនោះឡើយ។ បើតាមរយៈលោក Collender មាន ទស្សនៈថាពន្ធគឺ ឧបករណ៍បង្អាក់ទឹកចិត្តដល់សកម្មភាពបង្កដែលឱ្យមានផលប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចខាងក្រៅ។[១៣] ពន្ធត្រូវបានគេប្រើប្រាស់ជាឧបករណ៍សម្រាប់គោលនយោបាយសេដ្ឋកិច្ច ដើម្បីសម្រេចបាននូវការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច នៅពេលដែលវដ្តសេដ្ឋកិច្ចមានការកើនឡើងឬថយចុះ ក្នុងកម្រិតមួយខុសពីគោលដៅសេដ្ឋកិច្ច[១៤] ដើម្បីលើកទឹកចិត្តឬបង្អាក់ទឹកចិត្តដល់វិស័យណាមួយ និងកាត់បន្ថយវិសមភាពប្រាក់ចំណូល និងទ្រព្យសម្បត្តិ។

២.១.២-ខ្លឹមសារនៃចំណូលសារពើពន្ធ (MEANING OF TAX REVENUE)

ហេតុផលចម្បងការយកពន្ធ គឺការកេណ្ឌប្រមូលចំណូលពន្ធសម្រាប់ធ្វើហិរញ្ញប្បទានឱ្យបានគ្រប់គ្រាន់ដល់សកម្មភាពវិស័យសាធារណៈ ដោយមិនបង្កឱ្យមានផលប៉ះពាល់ដល់កម្រិតអតិផរណា។ ចំណូលពន្ធ ក៏ពុំមែនជាប្រភពចំណូលជាតិតែមួយគត់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការចំណាយសាធារណៈទេ។ ប៉ុន្តែចំណូលពន្ធក៏បានផ្តល់ហិរញ្ញប្បទានតាមរយៈការឱ្យខ្ចីពីធនាគារកណ្តាល និងបណ្តាលឱ្យមានអតិផរណាធ្ងន់ធ្ងរដែរ ដូចជាមាននៅក្នុងបទពិសោធន៍ប្រវត្តិសាស្ត្រពីវិបត្តិអតិផរណានៅប្រទេសអាឡឺម៉ងនាទសវត្សរ៍១៩២០ជាដើម[១៥] ឬការឱ្យខ្ចីពីទីផ្សារហិរញ្ញវត្ថុនៅក្នុងស្រុកក៏អាចបណ្តាលឱ្យមានបញ្ហាចំពោះការចំណាយសេវាសាធារណៈមិនបានការ ដែលមិនអាចធ្វើឱ្យវិនិយោគមានការកើនឡើង ហើយការទទួលជំនួយបរទេសអាចមានលក្ខណៈមិនទៀងទាត់។ ដូចនេះ ចំណូលសារពើពន្ធបានក្លាយជាមធ្យោបាយមួយដ៏រឹងមាំ និងសមស្របមួយ ដើម្បីសម្រេចបាននូវគោលដៅសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋាភិបាល។ ក្នុងទិដ្ឋភាពទ្រឹស្តីនៃសារពើពន្ធ ធ្វើឱ្យខាតបង់ដល់សុខុមាលភាពសង្គមតាមរយៈការកំណត់បន្ទុកពន្ធលើសដែលកើតមានឡើង ពេលណាអ្នកជាប់ពន្ធបង្ខំចិត្តគេចវេសបន្ទុកពន្ធលើសនេះ ដោយផ្តោតទៅលើសកម្មភាពដែលជាបន្ទុកពន្ធស្រាល។ ឧទាហរណ៍ ដើម្បីកាត់បន្ថយបន្ទុក

[១២] http://www.blackslawdictionary.com(2002)

[១៣] Colander David C.(2006); Economics, 6th edition, McGraw-hill, Irwin, Boston.p.421-432

[១៤] Tax:(proportional income tax)

[១៥] Rudiger Dornbusch (1985); stopping hyperinflation: lessons from the German inflation, experience of the 1920, NBER working paper series, working paper No.1675, USA.

ពន្ធលើសនេះ ប្រព័ន្ធនៃសារពើពន្ធភាគច្រើនកំណត់អត្រាពន្ធឱ្យខ្ពស់ ចំពោះប្រភេទទំនិញដែលមានតម្រូវការពុំសូវមានលក្ខណៈរួញលូតនោះ ប្រសិនបើប្រៀបធៀបទៅនឹងទំនិញដែលមានតម្រូវការ និងមានលក្ខណៈរួញលូតជាង។ ដូច្នេះប្រព័ន្ធនៃសារពើពន្ធអាចជួយបង្កាមិនឱ្យមានបន្ទុកពន្ធលើសឬការខាតបង់សុខុមាលភាព ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទំនិញជំនួស ខណៈពេលដែលថ្លៃទំនិញត្រូវកើនឡើងបន្ទាប់ពីយន្តការប្រមូលពន្ធ។[១៦] តាមរយៈលោក Campbell និងលោក Standley បានអះអាងថាជាទូទៅប្រសិនបើតម្រូវការ និងការផ្គត់ផ្គង់កាន់តែមានលក្ខណៈរួញលូតនោះ ការខាតបង់ប្រសិទ្ធភាពតាមរយៈពន្ធកាន់តែមានប្រសិទ្ធភាពខ្ពស់ផងដែរ។[១៧] ហើយផលប៉ះពាល់នៃសារពើពន្ធមកលើសង្គមជាតិ ក៏មានផលប៉ះពាល់ដោយផ្ទាល់តាមរយៈការបង់ពន្ធឱ្យដល់រដ្ឋាភិបាល ការខាតបង់អតិរេករបស់អ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ និងការចំណាយរបស់រដ្ឋាភិបាលក្នុងការប្រមូលពន្ធ និងការទូទាត់បំណុលពន្ធ។ ចំពោះអត្ថប្រយោជន៍សារពើពន្ធ គឺផលចំណេញរបស់សង្គមដែលកើតចេញពីការផ្គត់ផ្គង់ទំនិញ និងសេវាពីសំណាក់រដ្ឋាភិបាលតាមរយៈការបំពេញនូវតួនាទីរបស់ខ្លួនក្នុងសេដ្ឋកិច្ចទីផ្សារ។[១៨]

មានអ្នកស្រាវជ្រាវជាច្រើន មានទស្សនៈដូចគ្នាថា ចំណូលសារពើពន្ធ គឺជាប្រភពចំណូលដ៏ចាំបាច់សម្រាប់បំពេញមុខងាររបស់រដ្ឋាភិបាលមានដូចជា៖

១. ការបង្កើតនូវប្រពន្ធ័នៃសារពើពន្ធ និងវិធាននានាប្រកបដោយសង្គតិភាព
២. ការជំរុញនូវការប្រកួតប្រជែងទីផ្សារប្រកបដោយយុត្តិធម៌
៣. ការកែតម្រូវនូវភាពបញ្ចេញខាងក្រៅ
៤. ការធានានូវស្ថិរភាព និងកំណើនសេដ្ឋកិច្ច
៥. ការផ្គត់ផ្គង់ទំនិញនិងសេវាសាធារណៈ
៦. ការកែតម្រូវលទ្ធផលទីផ្សារ[១៩]

សារពើពន្ធ គឺមានអត្ថិភាពជាចម្បង សម្រាប់ការប្រមូលកៀរគរចំណូលជាតិ ដើម្បីផ្តល់នូវហិរញ្ញប្បទានដល់ប្រតិបត្តិការរបស់រដ្ឋាភិបាល។ ករណីចំណូលសារពើពន្ធ មិនគ្រប់គ្រាន់នាំឱ្យមានឱនភាពថវិកាជាតិលើកលែងតែករណីរដ្ឋាភិបាល អនុវត្តនូវគោលនយោបាយការលើកទឹកចិត្តសារពើពន្ធ សម្រាប់រយៈពេលខ្លីដើម្បីការកែលម្អស្ថានភាពសេដ្ឋកិច្ច។ ជាទូទៅឱនភាពថវិកាជាតិធ្វើឱ្យមានផលវិបាកម៉ាក្រូសេ-ដ្ឋកិច្ចច្រើនយ៉ាង ដូចជាការរុញច្រានការវិនិយោគវិស័យឯកជន និងកំណើនអតិផរណា និងអតុល្យភាពជញ្ជីងទូទាត់ជាដើម។[២០] ដូច្នេះ បង្កឱ្យមានឱនភាពថវិកាទាមទារឱ្យមានការគ្រប់គ្រងឱ្យបានល្អទាំងផ្នែកការចំណាយ និងទាំងផ្នែកចំណូលនៃថវិកា។ បើសិនចំណូលសារពើពន្ធ មិនអាចកើតឡើងដើម្បីឆ្លើយតបនឹងកំណើនតម្រូវការហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទំនិញ និងសេវាសាធារណៈទេ

[១៦] Jha raghbendra (1998); modern public economics, New York, Routledge

[១៧] Cambell R. McConell and standley L. Brue (2008); Economics principles, problems, and policies; 17th Edition, McGraw-hill, International Edition Boston.

[១៨] Rudiger et.al., (2004); Macroeconomics, ninth edition, McGrow-hill, international edition, Singapore.

[១៩] Thomas A. Caret and rousell M. Rhine (2006); on the size & growth of government, martin Feldstein (1996); how big should government be? NBER working paper series, working papers 5868,USA.

[២០] K.Alex Chrystal and Daniel L. Thornton (1986); the macroeconomics effects of the deficit spending: A Review, federal reserve bank of st.louis Nov-Dec1986.

នោះ។ ដូចនេះរដ្ឋាភិបាលត្រូវកាត់បន្ថយចំណាយថវិកា និងពិនិត្យលទ្ធភាពបង្កើនអត្រាពន្ធ ឬកែប្រែរចនាសម្ព័ន្ធសារពើពន្ធឡើងវិញ។ ដូច្នេះ ប្រព័ន្ធនៃសារពើពន្ធល្អបង្កើតឱ្យមានចំណូលសារពើពន្ធគ្រប់គ្រាន់ សម្រាប់បម្រើឱ្យការចំណាយរបស់រដ្ឋាភិបាល។ ទោះបីជាអត្រាកំណើនចំណូលសារពើពន្ធប្រទេសនីមួយៗ មានសន្ទុះមិនស្មើគ្នាក៏ដោយតាមធម្មតាអត្រាកំណើនចំណូលសារពើពន្ធ ត្រូវមានកម្រិតប្រហាក់ប្រហែលគ្នានឹងអត្រាកំណើនសេដ្ឋកិច្ច លើកលែងតែករណីរដ្ឋាភិបាលចង់កែប្រែទំហំនៃចំណូលពន្ធ។

២.១.៣-ភាពយឺតនៃចំណូលសារពើពន្ធ (ELASTICITY OF TAX REVENUE)

ភាពរួញលូតនៃប្រាក់ចំណូលសារពើពន្ធ បានវាស់វែងអំពីល្បឿននៃកំណើនចំណូលសារពើពន្ធធៀបទៅនឹងល្បឿននៃកំណើនសេដ្ឋកិច្ចជាតិ។ ពោល គឺជាបម្រែបម្រួលភាគរយចំណូលសារពើពន្ធ ចែកនឹងបម្រែបម្រួលជាភាគរយផលិតផលក្នុងស្រុកសរុប ឬសក្តានុពលមូលដ្ឋានពន្ធ។ ភាពរួញលូតសារពើពន្ធ គឺសំដៅទៅលើសន្ទុះនៃកំណើនចំណូលសារពើពន្ធ ដោយពុំមានការកែប្រែគោលនយោបាយសារពើពន្ធ។ ប្រសិនបើ ភាពរួញលូតនោះស្មើនឹង0 (សូន្យ) មានន័យថាចំណែកជាភាគរយចំណូលសារពើពន្ធ ក្នុងផលិតផលក្នុងស្រុកសរុប គឺមានទំហំថេរ។ បើសិនភាពរួញលូតមានទំហំធំជាង១(មួយ) បង្ហាញថាចំណូលនៃសារពើពន្ធកើនឡើង ក្នុងសន្ទុះមួយលឿនជាងប្រាក់ចំណូលសរុប។ ភាពរួញលូតនៃសារពើពន្ធចំណុះទៅនឹងរចនាសម្ព័ន្ធសារពើពន្ធ។ ភាពរួញលូតនៃពន្ធលើប្រាក់ចំណូលបុគ្គល អាស្រ័យទៅនឹងលក្ខណៈការកើនឡើងអត្រាពន្ធតាមកំណើនប្រាក់ចំណូល ព្រមទាំងការកម្រិតនៃការលើកលែងពន្ធលើប្រាក់ចំណូល។ ពន្ធលើការប្រើប្រាស់ ច្រើនមានលក្ខណៈរួញលូតជាង កាលណាពន្ធប្រភេទនេះគ្របដណ្តប់លើទំនិញនិងសេវា ដែលកំពុងលូតលាស់ឆាប់រហ័ស ហើយពន្ធនេះត្រូវបានគេគណនាគិតជាភាគរយនៃថ្លៃលក់ដូចជាអាករលើតម្លៃបន្ថែមជាដើម។ ពន្ធលើទ្រព្យសម្បត្តិ អាចឡើងបានឆាប់រហ័សកាលណាទ្រព្យសម្បត្តិគណនាបានពេញលេញត្រឹមត្រូវ។ បើតាមធម្មតាកំណើនចំណូលសារពើពន្ធ មានសន្ទុះយឺតនៅពេលសេដ្ឋកិច្ចមានការធ្លាក់ចុះ និងមានសន្ទុះលឿននៅពេលសេដ្ឋកិច្ចមានការកើនឡើង។ ដូចគ្នានេះផងដែរ លក្ខណៈរួញលូតនៃប្រាក់ចំណូលសារពើពន្ធភាគច្រើនបានកើនឡើងនៅពេលសេដ្ឋកិច្ចបានកើនឡើង ហើយភាពរួញលូតពន្ធលើប្រាក់ចំណេញ អាស្រ័យកាន់តែខ្លាំងទៅនឹងការកើនឡើង ឬការថយចុះនៃសេដ្ឋកិច្ច។ តាមបណ្តាប្រទេសដែលពឹងផ្អែកខ្លាំងលើ ចំណូលពន្ធលើធនធានធម្មជាតិដូចជា ប្រេងឥន្ធនៈ និងរ៉ែជាដើម។ អាចប្រឈមមុខនឹងការប្រែប្រួលចំណូលសារពើពន្ធដែលបណ្តាលមកពីការប្រែប្រួលកម្រិតនៃថ្លៃ និងតម្រូវការធនធានទាំងនេះ។[២១] ដូច្នេះ ប្រព័ន្ធសារពើពន្ធមួយដែលមានមូលដ្ឋានទូលាយអាចធានាស្ថិរភាពនៃចំណូលសារពើពន្ធ។

២.២-គោលការណ៍នៃសារពើពន្ធ(PRINCIPLES OF FISCAL)

[២១] Robin boadway and frunk flatters(1993); the taxation of natural resources principles&policy issues, policy research wok=rking papers, public economics, WPS 1210, World bank, Washington D.C.

បិតាសេដ្ឋវិទូសម័យបុរាណលោក អាដាមស្មីត(ADAM SMITH) បានលើកឡើងថាប្រព័ន្ធនៃសារពើពន្ធមួយល្អ ត្រូវមានលក្ខណសម្បត្តិមួយចំនួន គឺត្រូវឆ្លុះបញ្ចាំងអំពីសមត្ថភាពបង់ពន្ធត្រូវមានប្រសិទ្ធភាពខាងផ្នែករដ្ឋបាល និងមិនធ្វើឱ្យរំខានដល់សេដ្ឋកិច្ច[២២] ហើយគោលការណ៍នេះមានបច្ចុប្បន្នភាពរហូតដល់សព្វថ្ងៃ។

មានការទទួលស្គាល់ជាទូទៅថា ប្រព័ន្ធនៃសារពើពន្ធល្អ ត្រូវតែមានលក្ខណៈសម្បត្តិ៥យ៉ាង៖

១) ប្រសិទ្ធភាពខាងសេដ្ឋកិច្ចនៃសារពើពន្ធ

២) ភាពសាមញ្ញនៃសារពើពន្ធ

៣) ភាពដែលអាចបត់បែនបានសារពើពន្ធ

៤) ភាពទទួលខុសត្រូវផ្នែកនយោបាយឬតម្លាភាពនៃសារពើពន្ធ និង

៥) ភាពយុត្តិធម៌ឬសមធម៌នៃសារពើពន្ធ។[២៣]

២.២.១-ប្រសិទ្ធភាពខាងសេដ្ឋកិច្ចនៃសារពើពន្ធ(ECONOMY EFFICIENCY OF FISCAL)

ប្រព័ន្ធនៃសារពើពន្ធល្អ មិនត្រូវធ្វើឱ្យរំខានដល់សកម្មភាពសេដ្ឋកិច្ច ហើយត្រូវប្រើប្រាស់ដើម្បីលើកស្ទួយប្រសិទ្ធភាពសេដ្ឋកិច្ច។ ប្រព័ន្ធនៃសារពើពន្ធភាគច្រើន គឺកែប្រែថ្លៃទីផ្សារតាមរយៈនេះធ្វើឱ្យមានការរារាំងស្ទះដល់ដំណើរប្រព្រឹត្តិទៅនៃតួនាទីរបស់ថ្លៃ ដើម្បីផ្តល់ព័ត៌មានសម្រាប់អ្នកចូលរួមកម្មវិធីទីផ្សារ និងប្រសិទ្ធភាពនៃការវិភាជន៍ធនធានត្រូវបានប្រែប្រួល។ ផលប៉ះពាល់សេដ្ឋកិច្ចនៃសារពើពន្ធមានយ៉ាងច្រើន[២៤] ពន្ធគឺមធ្យោបាយមួយនៃការផ្ទេរធនធានពីវិស័យឯកជនមកវិស័យសាធារណៈ។ ក្នុងន័យនេះពន្ធមិនមែនបណ្តាលឱ្យមានផលប៉ះពាល់ក្នុងន័យសេដ្ឋកិច្ចនោះទេ។ ប៉ុន្តែផលប៉ះពាល់សេដ្ឋកិច្ចនៃសារពើពន្ធនឹងកើតមានឡើងកាលណាធនធានដែលត្រូវបានប្រើប្រាស់ បើទោះបីជាគោលបំណងឯកជនឬសាធារណៈក្តី មិនអាចសម្រេចបានប្រសិទ្ធភាពពេញលេញតាមរយៈពន្ធ។ ប្រព័ន្ធសារពើពន្ធ មានឥទ្ធិពលដល់ការកែប្រែការសម្រេចចិត្តរបស់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ហើយក៏អាចធ្វើឱ្យថយចុះនូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានសេដ្ឋកិច្ចផងដែរ។ ដូចជាពន្ធលើប្រាក់បៀវត្ស និងពន្ធលើប្រាក់ឈ្នួល ធ្វើឱ្យមានការ លើកទឹកចិត្តសម្រាប់ការងារថយចុះ។ ពន្ធលើប្រាក់បៀវត្សវិស័យក្នុងប្រព័ន្ធ អាចធ្វើឱ្យមានការទាក់ទាញសម្រាប់ស្វែងរកការងារខាងវិស័យក្រៅប្រព័ន្ធ។ ពន្ធលើការប្រើប្រាស់នេះ អាចបង្អាក់ទឹកចិត្តដល់បំពេញការងារ ពីព្រោះថាពន្ធលើការចំណាយអាចធ្វើឱ្យចំនួននៃពេលវេលា ដែលត្រូវធ្វើការសម្រាប់ទំនិញ និងសេវា លើទីផ្សារមានការកើនឡើង។ ដោយសារតែពន្ធមិនត្រូវបានកំណត់លើតម្លៃ ហេតុនេះពន្ធប្រភេទនេះ អាចបង្អាក់ទឹកចិត្តដល់ការប្រើប្រាស់ទំនិញ ឬសេវាកម្មនោះ។ ប្រភេទពន្ធលើប្រាក់

[២២] Adam Smith (1976); an inquiry into the natural and causes of the wealth of nations, vol.III, willain Clowes and sons London, Digitalized by google.

[២៣] Joseph E. stiglitz (2000); Economics of public sector, third edition, w.w. norton company, Inc., USA.p.456-475

[២៤] Joseph E. stiglitz (2000); Economics of public sector, third edition, w.w. norton company, Inc., USA.p.452.

ចំណូលនេះ អាចធ្វើឱ្យប្រែប្រួលបរិមាណ និងប្រាក់សន្សំ។[២៥] ការមិនទាន់យកពន្ធលើប្រាក់ចំណូលពីការវិនិយោគលើមូលបត្រសង្គហធន ដរាបណាអ្នកវិនិយោគមិនទាន់លក់មូលបត្រនោះ អាចជំរុញឱ្យវិនិយោគិនរក្សាទុកមូលបត្រនោះរយៈពេលវែង។ តាមរយៈការស្រាវជ្រាវជាច្រើន បានបង្ហាញថាប្រព័ន្ធនៃសារពើពន្ធ ត្រូវបានប្រើប្រាស់ដើម្បីការទាក់ទាញលើការវិនិយោគទុនពីបរទេស ដើម្បីលើកទឹកចិត្តវិនិយោគក្នុងវិស័-យ ឬតំបន់អាទិភាពណាមួយ។[២៦] ចំណែកឯពន្ធលើប្រាក់ចំណេញសាជីវកម្ម អាចមានឥទ្ធិពលលើរចនាសម្ព-ន្ធដើមទុន ឬភាគលាភ។ ឧទាហរណ៍ បើសិនភាគលាភ គឺជាបំណុលពន្ធរបស់ភាគទុនិកនោះ ជំរុញឱ្យមានការរក្សាទុកប្រាក់ចំណេញមិនបែងចែកច្រើន។ បើសិន ការប្រាក់លើបំណុលបំពេញដើមទុន ត្រូវបានកាត់ចេញពីមូលដ្ឋានគិតពន្ធ ចំណែកឯភាគលាភមិនត្រូវបានកាត់ចេញពីមូលដ្ឋានគិតពន្ធទេនោះក្រុមហ៊ុនអាចនឹងមានទំនោរបង្កើនការខ្ចីប្រាក់ ដើម្បីបំពេញដើមទុនច្រើនជាងការផ្សព្វផ្សាយប័ណ្ណភាគហ៊ុន។[២៧]

ក្រៅពីនេះ ផលប៉ះពាល់សេដ្ឋកិច្ចនៃសារពើពន្ធ នឹងកើតមានឡើងតាមរយៈការចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងសារពើពន្ធ។[២៨]

ទី១) ការប្រមូលពន្ធ ទាមទារឱ្យមានការចំណាយ អាស្រ័យទៅនឹងប្រភេទពន្ធ ការចំណាយជាក់ស្តែងរបស់រដ្ឋបាលសារពើពន្ធ សម្រាប់ការប្រមូលពន្ធនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ គិតជាមធ្យមមានកម្រិតប្រមាណ ១%(ភាគរយ)នៃចំណូលសារពើពន្ធសរុប និងមានកម្រិតច្រើនជាងនេះ នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។[២៩] ការចំណាយរបស់អ្នកជាប់ពន្ធទាក់ទងទៅនឹងការអនុលោមតាមបទប្បញ្ញត្តិ ដូចជាការចំណាយលើអ្នកបិទបញ្ជីសារពើពន្ធជាដើម។[៣០]

ទី២) រវាងរដ្ឋបាលសារពើពន្ធ និងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ គឺមានអន្តរកម្មទៅវិញទៅមកអ្នកជាប់ពន្ធមានកាតព្វកិច្ច ត្រូវបង្ហាញព័ត៌មានកាន់តែច្រើនការចំណាយអនុលោមតាមបទប្ប-ញ្ញត្តិក៏មានកាន់តែច្រើន។ ប៉ុន្តែការចំណាយផ្សេងៗរបស់រដ្ឋបាលសារពើពន្ធក៏មានកាន់តែតិចដែរ។ ការចំណាយរដ្ឋបាលសារពើពន្ធ និងចំណាយអនុលោមភាពតាមបទប្បញ្ញត្តិ ក៏អាចកើតឡើងព្រមគ្នាដែរ។ ក្នុងករណី ដែលការធ្វើទំនើបកម្មរបស់រដ្ឋបាលសារពើពន្ធទាមទារព័ត៌មានកាន់តែច្រើនពីអ្នកជាប់ពន្ធ និងត្រូវតែធ្វើសវនកម្មឱ្យបានច្បាស់លាស់។

ទី៣) ក៏ត្រូវចំណាយអនុលោមភាពតាមបទប្បញ្ញត្តិផងដែរ។ ឧទាហរណ៍ និយោជក អាចកាត់ទុកពន្ធលើប្រាក់បៀវត្សរបស់និយោជិត ហើយធនាគារត្រូវផ្តល់ព័ត៌មានទៅឱ្យអាជ្ញាធរពន្ធដារ ឬ

---

[២៥] Bergheim Douglas (2000); Taxation and saving, NBER working paper series, working paper 7061.

[២៦] Policy brief (2008), tax effects on foreign direct investment, OECD. Ruud A. de Mool and sjef ederveen (2001).

[២៧] Thiess Buettner and others (2007); taxation and capital structure choice-evidence from a panel of German multinationals, CEsifo working paper No.1841 category1: public finance, Gernany

[២៨] Robert W. McGee(2007); tax administration costs in transition economics and OECD. A comparative study, Andrea's school of business working paper.

[២៩] Mann Arthur J.(2002)Estimating the administrative costs of taxation. A Methodology with application to the case of Guatemala, Dec tech system, Arlington

[៣០] Hijathula A.J. and jeff pope (2008); exploring the relationship between tax compliance costs and compliance issues in Malaysia, journal of applies law and policy, Australia. Sebastian Eichfelder and Diskussionsbetrage des Fachbereichs wirtchaftawissenschaft de freien universitet Betriebswirts chaftliche reihe 2009/03, berlin.

ត្រូវផ្ទេរប្រាក់ចំណូលពន្ធចូលទៅក្នុងគណនីរបស់ធនាគារដ្ឋាភិបាលជាដើម។ ជាញឹកញយ ការចំណាយអនុលោមតាមបទប្បញ្ញត្តិមានកម្រិតច្រើនដងលើសពីការចំណាយរបស់រដ្ឋបាលសារពើពន្ធ។ [៣១]

ហេតុនេះទើបមានប្រទេសនានា តែងតែព្យាយាមអភិវឌ្ឍប្រព័ន្ធសារពើពន្ធរបស់ខ្លួន ដើម្បីបន្ទាបឱ្យបានអប្បបរមានូវការខាតបង់ប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងចំណាយផ្សេងៗតាមរយៈសារពើពន្ធ។

២.២.២-ភាពសាមញ្ញនៃរដ្ឋបាលសារពើពន្ធ (SIMPLICITY OF TAX ADMINISTRATIVE)

រដ្ឋបាលសារពើពន្ធមានគោលដៅធ្វើឱ្យសារពើពន្ធមានលក្ខណៈងាយស្រួលយល់ និងងាយស្រួលអនុលោមតាម ហើយរដ្ឋបាលសារពើពន្ធត្រូវបានអនុវត្ត និងគ្រប់គ្រងប្រកបដោយលក្ខណៈបច្ចេកទេស និងយុត្តិធម៌។ ភាពសាមញ្ញរដ្ឋបាលសារពើពន្ធមានន័យថា ធ្វើឱ្យរចនាសម្ពន្ធ័នៃសារពើពន្ធមានលក្ខណៈសាមញ្ញ និងងាយស្រួល ជាគន្លឹះនៃការកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាល និងការចំណាយអនុលោមភាពតាមបទប្បញ្ញត្តិសារពើពន្ធ។ តាមរយៈលោក Gleen បានបញ្ជាក់ថា ភាពសាមញ្ញនៃសារពើពន្ធនេះ ត្រូវបានគ្របដណ្តប់លើប្រព័ន្ធនៃសារពើពន្ធច្បាប់ និងបទប្បញ្ញត្តិ និងការអនុវត្តតាមវិធានសារពើពន្ធ។[៣២] ភាពសាមញ្ញប្រព័ន្ធសារពើ និងរចនាសម្ព័ន្ធនៃសារពើពន្ធ សំដៅលើការកាត់បន្ថយចំនួនសារពើពន្ធជាមួយនឹងការជ្រើសរើសទីកន្លែងងាយស្រួល ដើម្បីប្រមូលពន្ធ និងទូទាត់បំណុលពន្ធ។

ភាពសាមញ្ញនៃច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធមានន័យថា ច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ត្រូវបានរៀបចំឱ្យមានលក្ខណៈអាចយល់បានពេញលេញ និងកាត់បន្ថយការលើកលែងពន្ធ និងអាករ។ ភាពសាមញ្ញនៃការអនុវត្តវិធានសារពើពន្ធ តម្រូវឱ្យមានការប្រើប្រាស់បទប្បញ្ញត្តិសារពើពន្ធ និងផ្តល់ព័ត៌មានច្បាស់លាស់ដោយផ្ទាល់លើវិស័យ ឬក្រុមអ្នកជាប់ពន្ធនីមួយៗ។ សុខដុមនីយកម្មប្រព័ន្ធនៃសារពើពន្ធគ្រប់កម្រិត គឺកត្តាមួយចាំបាច់ដើម្បីចៀសវាងការយកពន្ធស្ទួនគ្នា។ មានអ្នកជំនាញជាច្រើនបានស្នើសុំឱ្យមានការបង្កើតក្រុមសារពើពន្ធ ដើម្បីធ្វើជាមធ្យោបាយដល់ការសម្របសម្រួលនូវវិធាន និងបទប្បញ្ញត្តិសារពើពន្ធ។[៣៣] ជាញឹកញាប់អ្នកជាប់ពន្ធ ពុំអាចអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធដោយសារតែមិនយល់ដឹងការងារនេះ ឬត្រូវការចំណាយពេលវេលា និងធនធានហិរញ្ញវត្ថុជាច្រើនសម្រាប់អនុលោមតាមច្បាប់។[៣៤] ការកែប្រែប្រព័ន្ធសារពើពន្ធ ឬការអនុវត្តន៍ប្រព័ន្ធថ្មីតែងតែធ្វើឱ្យមាន

---

[៣១] Arindam Des-Guptas (2004a); tax compliance costs and non-filing Behavior, Institute of public finance and policy, working paper 04/5, India. Arindam Des-Guptas (2004b); the compliance costs of the personal income tax India, 2000-2001: preliminary estimates, excerpted and condensed from a report on company compliance costs of the personal income Tax in: Chattopadhyay, s. and A. Des-Guptas (2002);" the compliance costs of the personal income tax and it Determinants", Mimeo, new Delhi: NIPFP. Available at http://www.planing commi-sion.nic.in/reports.

[៣២] Gleen P. Jenkins and Edwin N. forclem (1993); enhancing voluntary compliance by reducing compliance costs: A taxpayer service Approach, Harvard university

[៣៣] Victor thuronyi (eds) (1996); tax law design and drafting, volume 1, international monetary fund, Washington D.C. chapter1.

[៣៤] Victor thuronyi (eds)(1996) ; tax law Desigh and drafting , Volume 1, international Monetary Fund, Washington D.C. chapter 1.

កំ-ណើនការចំណាយដើម្បីអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធនៅក្នុងដំណាក់កាលដំបូង។[៣៥] សម្រាប់វិនិយោគិនប្រព័ន្ធសារពើពន្ធមួយប្រកបដោយស្ថិរភាព គឺជាផ្នែកមួយយ៉ាងសំខាន់នៃបរិយាកាសវិនិយោគ ហើយការចំណាយដើម្បីទូទាត់បំណុលពន្ធ គឺផ្នែកមួយដើម្បីចំណាយប្រតិបត្តិការអាជីវ-កម្ម។ ភាពស្មុគស្មាញនៃប្រព័ន្ធសារពើពន្ធធ្វើឱ្យមានបន្ទុកការចំណាយ និងផលប៉ះពាល់ផ្សេងៗ។

ការចំណាយសម្រាប់ការអនុលោមតាមបទប្បញ្ញត្តិធ្វើឱ្យថយចុះធនធានផ្នែកឯកជន និងចំណូលថវិកាជាតិ ក៏មិនអាចកើតឡើងតាមរយៈនេះដែរ។

ការស្រាវជ្រាវខ្លះបានបង្ហាញថា បន្ទុកចំណាយសម្រាប់អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ត្រូវបានកាត់បន្ថយកាលណាក្រុមហ៊ុនមួយមានទំហំកាន់តែធំ ហើយបន្ទុកចំណាយនេះកាន់តែកើនឡើងកាលណាក្រុមហ៊ុនមួយនោះ បានឈានចូលទៅក្នុងទីផ្សារអន្តរជាតិ។[៣៦]

២.២.៣-ភាពអាចបត់បែនបានៃសារពើពន្ធ (FLEXIBILITY OF FISCAL)

រចនាសម្ព័ន្ធនិងអត្រាពន្ធ ត្រូវបានកែប្រែដោយគ្មានឧបសគ្គធ្ងន់ធ្ងរ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលលក្ខណៈសេដ្ឋកិច្ច និងនយោបាយ គឺលក្ខណៈសម្គាល់នៃភាពអាចបត់បែនបាននៃសារពើពន្ធ។ ដូចបានបង្ហាញខាងលើនេះ សារពើពន្ធគឺជាផ្នែកមួយនៃស្ថិរភាពស្វ័យប្រវត្តិ (Authomatic stabilizer) ភាពអាចបត់បែនបានទៅតាមកម្រិតចំណូលសារពើពន្ធទៅតាមឧបអាជីវកម្ម ឬកម្រិតនៃសកម្មភាពសេដ្ឋកិច្ច។ ភាពដែលអាចបត់បែនបាននៃសារពើពន្ធច្រើនតែមានកម្រិត ដោយសារកត្តានយោបាយដែលទាមទារឱ្យមានការជជែកវែកញែកជាច្រើន ហើយក៏ធ្វើឱ្យមានការកែប្រែ និងការអនុវត្តច្បាប់ថ្មីដែលមានការយឺតយ៉ាវដែរ។

២.២.៤-ភាពទទួលខុសត្រូវផ្នែកនយោបាយ ឬតម្លាភាពនៃសារពើពន្ធ (RESPONSIBILITY POLITIC/TRANSPARENCY OF FISCAL)

ប្រព័ន្ធនៃសារពើពន្ធ ត្រូវបានរៀបចំឱ្យមានតម្លាភាព ដើម្បីបង្ហាញឱ្យច្បាស់លាស់អំពីបន្ទុករបស់អ្នកជាប់ពន្ធ និងអត្ថប្រយោជន៍ផ្សេងៗដែលអាចទទួលបាន។ តម្លាភាពនៃសារពើពន្ធ ទាមទារឱ្យមានការរៀបចំក្របខ័ណ្ឌគតិយុត្តិសារពើពន្ធ ដែលអាចចៀសវាងលក្ខណៈស្មុគស្មាញខ្លាំងពេក ព្រមទាំងទប់ស្កាត់កុំឱ្យមន្ត្រីពន្ធដារមានឆន្ទានុសិទ្ធិខ្លាំងពេក។ នីតិវិធីរដ្ឋបាលពន្ធនិងបទប្បញ្ញត្តិសារពើពន្ធនានាក្រៅពីមានលក្ខណៈច្បាស់លាស់ និងភាពសាមញ្ញភាព ត្រូវតែបើកចំហដោយគ្មានការលាក់លៀមសម្រាប់អ្នកជាប់ពន្ធឡើយ។ រចនាសម្ព័ន្ធនៃសារពើពន្ធ ត្រូវមានលក្ខណៈទទួលខុសត្រូវផ្នែកនយោបាយ ត្រូវបានកែប្រែតាមរយៈសេចក្តីព្រាងច្បាប់ពន្ធ បន្ទាប់ពីរដ្ឋាភិបាល យកនូវសេចក្តីព្រាង

---

[៣៥] Jeff pope (2004); the compliance costs of taxation in Australia and tax simplification: the issues, chapter 4, Australian journal of management, 18,1, June 1993, the university of new south wales. Clemens fuest and other (2006); does tax simplification yield more equity and efficiency? an empirical analysis for Germany, finanzwissenschaftiche diskussionsbeitrage Nr. 06-05 center for public Economics, university of cologne

[៣៦] Blumenthal M.and sreurod B. J. (1995); implication cost of taxing foreign-source income: its magnitude, Determinants, and policy implication, international tax and public finance 2:37-53 (1995) 9,1995 kluwer Academic publishers.

ច្បាប់នេះមកប្រជុំពិភាក្សាដោយមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយពីតួអង្គផ្សេងៗ ជាពិសេសអ្នកជាប់ពន្ធតែម្តង។ ហើយមានករណីខ្លះ អត្រាកំណើនពន្ធលើប្រាក់ចំណូល មានអត្រាពន្ធកើនតាមលំដាប់ពុំមែនជាលទ្ធភាពនៃការកែប្រែច្បាប់នោះទេ។

ដោយសារតែប្រព័ន្ធនៃសារពើពន្ធ មិនត្រូវបានសម្របជាមួយនឹងអតិផរណា។ ដូច្នេះ អតិផរណាមានកម្រិតខ្ពស់ ជាមូលដ្ឋានគិតពន្ធសម្រាប់ប្រាក់ចំណូលក៏ត្រូវកើនឡើងផងដែរ។

២.២.៥-តាពយុត្តិធម៌ និងសមធម៌នៃសារពើពន្ធ(JUSTICE AND EQUITY OF FISCAL)

សារពើពន្ធ គឺជាឧបករណ៍នយោបាយមួយ សម្រាប់ដកហូតធនធានពីផ្នែកឯកជន ដោយឈរលើគោលការណ៍ប្រសិទ្ធភាព និងការកាត់បន្ថយចំណាយរដ្ឋបាល។ តាពយុត្តិធម៌នៃប្រព័ន្ធសារពើពន្ធ សំដៅទៅលើការរៀបចំនូវវិធាន និងបទប្បញ្ញត្តិសារពើពន្ធមួយ មិនបង្កឱ្យមានឧត្តមភាពដល់ក្រុមអ្នកជាប់ពន្ធមួយ ច្រើនជាងក្រុមអ្នកជាប់ពន្ធមួយទៀត ដែលអាចកើតមានឡើងតាមរយៈការចន្លោះប្រហោងនៃការលើកទឹកចិត្តដែលមិនសមស្របទៅនឹងការកេងបន្លំក្នុងការអនុវត្តន៍ច្បាប់សារពើពន្ធ។ តាពយុត្តិធម៌សារពើពន្ធសំដៅទៅលើគោលការណ៍សមធម៌នៃសារពើពន្ធដែលមានពីរយ៉ាងគឺ៖

១) សមធម៌នៃសារពើពន្ធតាមខ្សែផ្តេក តម្រូវឱ្យអ្នកជាប់ពន្ធ ដែលមានស្ថានភាពសេដ្ឋកិច្ច ស្រដៀងគ្នាត្រូវតែបង់ពន្ធក្នុងបរិមាណដូចគ្នា។

២) សមធម៌នៃសារពើពន្ធតាមខ្សែឈរ ទាមទារឱ្យអ្នកជាប់ពន្ធដែលមានប្រាក់ចំណូលខ្ពស់ត្រូវជាប់អត្រាពន្ធម៉ាហ្សីណាល់កាន់តែខ្ពស់។

លទ្ធផលការស្រាវជ្រាវមួយបានបង្ហាញថា នៅក្នុងប្រព័ន្ធសារពើពន្ធសមធម៌ទាំងពីរនេះ មិនមានភាពងាយស្រួលសម្រាប់ការអនុវត្តបានយ៉ាងពេញលេញឡើយ។[៣៧] ជាក់ស្តែងពន្ធលើប្រាក់ចំណូលអាចតម្រូវទៅតាមសមធម៌តាមខ្សែដេកបាន លុះត្រាតែបុគ្គលម្នាក់ៗមានសមត្ថភាព និងមានប្រាក់ចំណូលតែមួយប្រភេទដូចគ្នា និងសារពើពន្ធត្រូវបានកំណត់លើមូលដ្ឋាននៃសមត្ថភាពបុគ្គលម្នាក់ៗ ដែលរកចំណូលបាន (ពុំមែនលើកម្រិតជាក់ស្តែងប្រាក់ចំណូលទេ) ទើបធនធានដែលបានយកពន្ធមានសមធម៌សម្រាប់អ្នកមានស្ថានភាពដូចគ្នាបាន។ គោលការណ៍នៃសមធម៌តាមខ្សែដេក ក៏ពុំបានត្រួតពិនិត្យមើលឱកាសទទួលបានអត្ថប្រយោជន៍នៃសេវាសាធារណៈ ដែលរដ្ឋាភិបាលបានផ្តត់ផ្តង់ទៅឱ្យក្រុមអ្នកជាប់ពន្ធផ្សេងៗទៀតដែរ។ រីឯការអនុវត្តន៍គោលការណ៍សមធម៌តាមខ្សែឈរក៏នៅមិនទាន់មានសុក្រឹត្យដែរ។

ជាទូទៅ អត្រាពន្ធលើប្រាក់ចំណូលតែងតែកើនឡើងទៅតាមកម្រិតនៃប្រាក់ចំណូល។ ក៏ប៉ុន្តែមានករណីជាច្រើន បានផ្តល់នូវលទ្ធភាពឱ្យមានការលើកលែងពន្ធឬការកាត់កងចេញពីមូលដ្ឋានបង់ពន្ធ។ ជាទូទៅ ការកំណត់ពន្ធភាគច្រើនពឹងផ្អែកលើគោលការណ៍នៃសមត្ថភាពបង់ពន្ធតាមរយៈនេះ អ្នកមាន

[៣៧] *Richard M. Bird and Eric M. (2003); introduction to tax policy Design and Development, Draft prepared for a course on practical issues of tax policy in Developing countries, word Bank, April 28-may 1, 2003. P,19-23. Paul van den Noord Christopher heady (2001); surveillance of tax policies, A synthesis of finding in Economics surveys, OECD Economics Department working paper, No.303, OECD publishing.*

ចំណូលខ្ពស់តែងតែមានសមត្ថភាពគ្រប់គ្រាន់ជាងអ្នកដែលមានចំណូលទាប ដើម្បីចូលរួមវិភាគទានសម្រាប់ធ្វើហិរញ្ញប្បទានដល់ប្រតិបត្តិការចំណាយរបស់រដ្ឋាភិបាល។

សូមបញ្ជាក់ដែរថា ក្រៅពីគោលការណ៍នៃសមត្ថភាពបង់ពន្ធ ប្រព័ន្ធសារពើពន្ធបានអនុវត្តគោលការណ៍មួយទៀត គឺគោលការណ៍អត្ថប្រយោជន៍។ គោលការណ៍អត្ថប្រយោជន៍មានលក្ខណៈដូចជាគោលការណ៍ទីផ្សារដែរ គឺបុគ្គលណាដែលទទួលបានអត្ថប្រយោជន៍ពីទំនិញឬសេវាកម្ម ហើយបុគ្គលនោះត្រូវតែបង់ពន្ធនិងអាករ តាមចំនួនចាំបាច់មួយសម្រាប់ការផ្គត់ផ្គង់ទំនិញឬសេវា។ ឧទាហរណ៍ ពន្ធដែលពឹងផ្អែកលើគោលការណ៍នៃអត្ថប្រយោជន៍ ដូចជាតម្លៃបន្ថែមលើផលិតផលតេលសិលា ត្រូវបានកំណត់យកសម្រាប់បញ្ជូនទៅក្នុងមូលនិធិថែទាំ និងជួសជុលផ្លូវថ្នល់។

បញ្ហាយុត្តិធម៌សារពើពន្ធមួយទៀត គឺថ្លឹងថ្លែងលើការប្រើប្រាស់ និងការយកពន្ធលើប្រាក់ចំណូលដូចជាប្រាក់ពន្ធ មានប្រភពមកពីធនធានរបស់បុគ្គលទៅចូលរួមចំណែកក្នុងសកម្មភាពសេដ្ឋកិច្ច ហើយការប្រើប្រាស់ គឺជាការដកហូតរបស់បុគ្គលចេញពីផលិតផលសរុបរបស់សង្គម។ តាមរយៈនេះធ្វើឱ្យមានសេចក្តីសន្និដ្ឋានបានថា បើសិនចង់ឱ្យសង្គមបន្តការលូតលាស់ គឺត្រូវផ្តោតលើការយកពន្ធលើការប្រើប្រាស់ច្រើនជាជាងការយកពន្ធលើប្រាក់ចំណូល។ ម៉្យាងវិញទៀត ពន្ធប្រាក់ចំណូលលើបុគ្គលតែងតែប្រែប្រួលទៅតាមអាយុកាលរស់នៅរបស់ពួកគេ។ ដូចនេះ គួរតែប្រើប្រាស់យកលើការចំណាយលើការប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់កំណត់ពន្ធ ដើម្បីអនុលោមតាមគោលការណ៍សមត្ថភាពបង់ពន្ធឱ្យបានល្អជាងលើគោលការណ៍ការយកពន្ធលើប្រាក់ចំណូល។

មានទស្សនៈខ្លះទៀត បានផ្តោតលើការយកពន្ធលើទ្រព្យសម្បត្តិច្រើនជាងការយកពន្ធលើប្រាក់ចំណូលបានបង្ហាញឧទាហរណ៍ថាបើសិនបុគ្គលម្នាក់រកប្រាក់ចំណូលបាន ១០០លានរៀល ហើយចាយបាន១លានរៀល បុគ្គលនោះមានសមត្ថភាពបង់ពន្ធខ្ពស់ជាងបុគ្គលម្នាក់ទៀតដែលរកប្រាក់ចំណូលបាន១លានរៀល ហើយចាយបានតែ១លានរៀល។ មូលដ្ឋានពន្ធលើការប្រើប្រាស់ បុគ្គលទាំងពីរត្រូវទទួលរងនូវបន្ទុកពន្ធស្មើគ្នា ប៉ុន្តែមូលដ្ឋានពន្ធលើប្រាក់ចំណូលបុគ្គលទី១ត្រូវតែជាប់ពន្ធច្រើនជាង។ ការណ៍នេះ ដោយសារពន្ធលើប្រាក់ចំណូលក៏ដូចជាពន្ធលើការប្រើប្រាស់មិនបានកំណត់ពន្ធលើការសន្សំរបស់បុគ្គលទេ។ ដូច្នេះ គួរតែប្រើប្រាស់ពន្ធលើការប្រើប្រាស់សម្រាប់យកពន្ធលើការចំណាយ និងពន្ធលើទ្រព្យសម្បត្តិសម្រាប់យកពន្ធលើការសន្សំវិញ។[៣៨]

គណៈកម្មាធិការសហភាពអឺរ៉ុបបានយល់ឃើញថា ជាទូទៅបន្ទុកសារពើពន្ធត្រូវបានចែករំលែកទៅតាមគោលការណ៍សមត្ថភាពបង់ពន្ធ។ ការអនុវត្តន៍គោលការណ៍នេះ សំដៅជាពិសេសទៅលើពន្ធលើប្រាក់ចំណូលរបស់បុគ្គល។ ចំណែកឯពន្ធលើប្រាក់ចំណេញ អាចជួបការលំបាក ដើម្បីកំណត់ថាតើការមិនសម្រេចបានប្រាក់ត្រូវជាប់ពន្ធដែរឬទេ? បើទោះបីជា តាមរយៈគោលការណ៍សមត្ថភាពបង់ពន្ធតម្រូវឱ្យប្រាក់ចំណេញខ្ពស់ត្រូវជាប់អត្រាពន្ធខ្ពស់ក៏ដោយ។[៣៩] ក៏ប៉ុន្តែច្បាប់សារពើពន្ធតាមប្រទេសខ្លះ

[៣៨] Richard M. Bird and Eric M. (2003); introduction to tax policy Design and Development, Draft prepared for a course on practical issues of tax policy in Developing countries, word Bank, April 28-may 1, 2003. P,16-17.

[៣៩] *European commission (2004); General tax principles, common consolidated corporate Tax Base Working Group, (CCCTb WG), working Document, CCCTB/WP/001Rev 1/doc/en, Brussels.*

បានអនុញ្ញាតឱ្យមានការកាត់កងតាមរយៈយោងការខាតបង់ទៅមុខបាន។ សរុបមក ពន្ធមានឥទ្ធិពលលើសមធម៌តាមវិធីច្រើនយ៉ាង។ គោលការណ៍សមធម៌តាមខ្សែដេកនេះ អាចមិនអនុវត្តបានពេញលេញចំពោះបុគ្គលដែលមានស្ថានភាពដូចគ្នា។ ចំពោះអ្នកទទួលទានស្រាត្រូវទទួលរងបន្ទុកពន្ធធ្ងន់ធ្ងរជាងអ្នកទិញលំនៅដ្ឋាន ឬអ្នកមានប្រាក់ចំណូលជាប្រាក់ថ្លៃឈ្នួល ឬប្រាក់បៀវត្ស ដែលអាចជាប់ពន្ធច្រើនជាងអ្នកមានប្រភពចំណូលពីវិស័យកសិកម្ម ឬភាគលាភ។ រីឯគោលការណ៍ សមធម៌តាមខ្សែឈរ ពន្ធអាចមានលទ្ធភាពខុសគ្នាទៅលើការបែងចែកប្រាក់ចំណូលទៅតាមរយៈការកំណត់ពន្ធលើអ្នកមានក្នុងកម្រិតមួយច្រើនជាងអ្នកក្រ។

ជំពូកទី ៣

ប្រព័ន្ធគ្រប់គ្រងនៃសារពើពន្ធ

FISCAL MANAGEMENT SYSTEM

៣.១-ប្រព័ន្ធគ្រប់គ្រងនៃសារពើពន្ធ (FISCAL MANAGEMENT SYSTEM)

៣.១.១-ប្រព័ន្ធនៃសារពើពន្ធ (FISCAL SYSTEM)

ប្រព័ន្ធនៃសារពើពន្ធ គឺជាប្រព័ន្ធមួយផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលអនុវត្តនយោបាយសារពើពន្ធតាមមធ្យោបាយដ៏មានប្រសិទ្ធភាព។ ប្រព័ន្ធនៃសារពើពន្ធនេះ គឺបញ្ចូលនូវការអភិវឌ្ឍន៍ការបង្កើននូវសមត្ថ-ភាព និងកេណ្ឌប្រមូលចំណូលពន្ធឱ្យបានធនល្មម និងសម្រេចឱ្យបានប្រសិទ្ធភាពសេដ្ឋកិច្ច ការធានាបាននូវសមធម៌ ភាពចម្រុះសារពើពន្ធឱ្យបានសមស្រប ភាពសាមញ្ញ និងភាពស័ក្តិសិទ្ធិនៃរដ្ឋបាលសារពើពន្ធ ព្រមទាំងតម្លាភាព គណនេយ្យភាព និងភាពស័ក្តិសិទ្ធិនៃសារពើពន្ធ មិនមែនចំពោះតែម្យ៉ាង

ការ តាក់តែងរចនាសម្ព័ន្ធនៃគោលនយោបាយសារពើពន្ធតែប៉ុណ្ណោះទេ។ ប៉ុន្តែ វាក៏ចំណុះទៅនឹងភាពស័ក្តិសិទ្ធិនៃរដ្ឋបាលសារពើពន្ធផងដែរ។ បន្ទាប់ពីរដ្ឋាភិបាលកំណត់ឱ្យបានសមស្របនូវនយោបាយសារពើពន្ធរួចហើយ។ រដ្ឋបាលសារពើពន្ធ មានតួនាទីជាគន្លឹះក្នុងការធានាឱ្យបាននូវការអនុវត្តន៍ប្រកបដោយស័ក្តិសិទ្ធិនយោបាយនេះ ដើម្បីសម្រេចបានគោលដៅ។ ការរៀបចំប្រព័ន្ធសារពើពន្ធ តែងតែរាប់បញ្ចូលនូវបញ្ហាតម្លាភាព និងអភិបាលកិច្ចនៃប្រព័ន្ធសារពើពន្ធ។ ច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ព្រមទាំងលិខិតដ្ឋានផ្សេងៗ ដូចជាឯកសារពន្យល់ជាដើមត្រូវបានផ្តល់លទ្ធភាពឱ្យសាធារណជនអាចស្វែងរកបាននឹងមានបច្ចុប្បន្នភាព។ សៀវភៅណែនាំរបស់មូលនិធិរូបិយវត្ថុអន្តរជាតិស្តីពីតម្លាភាពនៃសារពើពន្ធ បានគូសបញ្ជាក់ថាវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ត្រូវតែផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យអ្នកជាប់ពន្ធបានជ្រួតជ្រាប និងប្រតិកម្មឆ្លើយតបឱ្យបានត្រឹមត្រូវ។ នៅក្នុងការប្រើឆន្ទានុសិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការអនុវត្តច្បាប់ ក៏ដូចជាការចរចារអំពីបំណុលពន្ធរវាងមន្ត្រីពន្ធ និងអ្នកជាប់ពន្ធ ពុំមែនជាវិធានទូទៅនោះឡើយ។ ប៉ុន្តែនេះជាបាតុភូតនៃភាពកង្វះខាតនៃតម្លាភាពដែលជាឱកាសនៃអំពើពុករលួយ។[៤០]

ការកែប្រែប្រព័ន្ធនៃសារពើពន្ធមានន័យថា កំណែទម្រង់សារពើពន្ធ។ ជាទូទៅលទ្ធផលនៃការអនុវត្តកំណែទម្រង់សារពើពន្ធ ត្រូវបានវាយតម្លៃតាមលក្ខណៈសម្បត្តិបីយ៉ាង[៤១]៖

១-គោលបំណងនៃកំណែទម្រង់

២-វិសាលភាពនៃកំណែទម្រង់

៣-ដំណើរការនៃកំណែទម្រង់

គោលបំណងនៃកំណែទម្រង់សារពើពន្ធមានដូចជា៖

- ការបង្កើនចំណូលសារពើពន្ធ
- សាមញ្ញកម្មនៃប្រព័ន្ធសារពើពន្ធដោយមិនទាក់ទងនឹងការបង្កើតចំណូលសារពើពន្ធ
- ធានាបានសមធម៌ចំពោះមុខសញ្ញាមួយចំនួននៅក្នុងវិសាលភាពខ្សែដេក និងខ្សែឈរ
- ការកាត់បន្ថយរបាំងសារពើពន្ធដើម្បីសម្រេចបានការវិភាជន៍ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់
- ការជំរុញឱ្យមានលំហូរធនធានឆ្ពោះទៅរកវិស័យអទិភាពមួយចំនួន

កំណត់ទម្រង់សារពើពន្ធ មានលក្ខណៈទូលំទូលាយដោយគ្រប់ដណ្តប់ទៅលើប្រភពចំណូលជាច្រើនប្រភេទ ហើយជាញឹកញាប់ទាក់ទងទៅនឹងការអនុម័តច្បាប់ ឬបទប្បញ្ញត្តិសារពើពន្ធថ្មីៗមួយចំនួន ឬក៏មានករណីខ្លះកំណែទម្រង់សារពើពន្ធមានគោលដៅកែតម្រូវនូវសមភាពសំខាន់ៗមួយ ឬពីរនៃប្រព័ន្ធសារពើពន្ធប៉ុណ្ណោះ។ ការស្រាវជ្រាវជាច្រើនបានបង្ហាញលទ្ធផលថាកំណែទម្រង់សារពើពន្ធភាគច្រើនផ្តោតលើការពង្រឹងប្រព័ន្ធសារពើពន្ធទាំងមូល ក្នុងនោះដែរមានស្ថាប័នសម្រាប់សារពើពន្ធ និង

[៤០] IMF (2007); Manual on fiscal transparency; international monetary fund, fiscal Affairs Department Washington D. C. p.24-27

[៤១] Vahram stepanyan (2003); Reforming Tax system: Experience of the Baltic, Russia, and other countries of the former soviet union; IMF working paper, WP/03/173, Washington D. C.p6.

អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ឬក៏អាចសំដៅលើការប្រែប្រួលនយោបាយសារពើពន្ធ ដោយផ្តោតទៅលើមូលដ្ឋានសារពើពន្ធ និងរចនាសម្ព័ន្ធនៃអត្រាពន្ធ និងអាករក៏មានផងដែរ។[៤២] ការវាយតម្លៃកម្រិតជោគជ័យនៃកំណែទម្រង់សារពើពន្ធ មិនទាក់ទងទៅនឹងគោលបំណងបង្កើតចំណូលសារពើពន្ធ ដូចជាគោលដៅសមធម៌ កំណើនសេដ្ឋកិច្ច ភាពសាមញ្ញ និងប្រសិទ្ធភាពនៃវិភាជធនធាន តែងតែជួបនូវការលំបាក ដោយសារមិនអាចវាស់វែងបានងាយស្រួល។ ដូច្នេះ បានជាការវិភាគអំពីឥទ្ធិពលនៃកំណែទម្រង់សារពើពន្ធច្រើនតែផ្តោតលើការវាយតម្លៃនៃសមត្ថភាពបង្កើន និងកៀរគរប្រមូលចំណូលសារពើពន្ធវិញ។

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានលើកឡើងថាប្រព័ន្ធនៃសារពើពន្ធ គួរគប្បីមានលក្ខណៈសម្បត្តិល្អៗមួយចំនួនគឺ៖[៤៣]

- ពឹងផ្អែកកាន់តែច្រើនទៅលើពន្ធនិងអាករ ជាពិសេសអាករលើការប្រើប្រាស់ដែលមានមូលដ្ឋានជាទូទៅ ដូចជាអាករលើតម្លៃបន្ថែមដែលមានអត្រាឯកភាពតែមួយ និងចៀសវាងការលើកលែងអាករពិសេសលើផលិតផលតេលសិលា កេសដ្ឋៈស្រវឹង ផលិតផលថ្នាំជក់ និងប្រភេទអាករមួយចំនួនតូចនៃទំនិញប្រណិត។
- មិនពឹងផ្អែកលើពន្ធគយ និងពន្ធនិងអាករពីការនាំចេញ បានធ្វើឱ្យរាំងស្ទះដល់សមត្ថភាពប្រគួតប្រជែងជាលក្ខណៈអន្តរជាតិ។
- បន្ទាបពន្ធនិងអាករ នាំចូលឱ្យដល់កម្រិតអប្បបរមា។
- ការយកពន្ធលើប្រាក់ចំណូលបុគ្គល គួរគប្បីមានលក្ខណៈរដ្ឋបាលសាមញ្ញជាមួយការអនុញ្ញាតឱ្យមានការកាត់កងតិចតួចមានអត្រាពន្ធសមល្មម សម្រាប់ប្រាក់ចំណូលខ្ពស់ និងកំណត់កម្រិតកម្ពស់ប្រាក់ចំណូល ដែលមិនត្រូវជាប់កាតព្វកិច្ចពន្ធឱ្យបានសមល្មមសម្រាប់ការលើកលែងកាតព្វកិច្ចពន្ធ អ្នកមានប្រាក់ចំណូលទាប ព្រមទាំងការអនុវត្តពន្ធកាត់ទុក។
- កំណើនអត្រាពន្ធលើប្រាក់ចំណេញឱ្យមានកម្រិតពីមធ្យមទៅទាប។

ចំពោះអត្រាពន្ធខ្ពស់បំផុត សម្រាប់ពន្ធលើប្រាក់ចំណេញ គួរគប្បីកំណត់ឱ្យមានកម្រិតប្រហាក់ប្រហែលជាមួយនឹងអត្រាពន្ធសម្រាប់ប្រាក់ចំណូលបុគ្គល ដែលមានកម្រិតខ្ពស់បំផុត។ ជាមួយគ្នានេះ រំលស់និងសំវិធានធន សម្រាប់ការចំណេញពុំមែនជាសាច់ប្រាក់ គួរគប្បីអនុវត្តឱ្យបានដូចគ្នា ចំពោះគ្រប់ផ្នែកសេដ្ឋកិច្ចទាំងអស់ព្រមទាំងកាត់បន្ថយការលើកទឹកចិត្តសារពើពន្ធ ចំពោះផ្នែកអាទិភាពផ្សេងៗឱ្យនៅត្រឹមកម្រិតតិចតួច។

៣.១.២-ប្រព័ន្ធគ្រប់គ្រងនៃសារពើពន្ធ (FISCAL MANAGEMENT SYSTEM)

[៤២] Emran M. S. and joseph E. Stiglitz (2002); on selective indirect Tax reefrom in developing countries; Stafford university, and Columbia university. Khalil Zadeh-S. et al. (1991); tax reform in developing countries; finance and development, June 1991, 28, 2, ABI/INFORM Global. P.44-46

[៤៣] Parthasrathi shome (edited) (1995); Tax policy Handbook; international Monetary fund, fiscal Affairs department, Washington D. C.

នយោបាយសារពើពន្ធ អាចឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធសេដ្ឋកិច្ច សមត្ថភាពគ្រប់គ្រងចំណូលសារពើពន្ធ តម្រូវការសេវាសាធារណៈនឹងលទ្ធភាពកៀរគរប្រមូលនូវធនធានពីប្រភពផ្សេងទៀតរបស់ប្រទេសនោះ មានដូចជាប្រេងកាត ឬជំនួយអភិវឌ្ឍជាដើម។ លើសពីនេះមានកត្តាសំខាន់ដទៃទៀត ដែលមានឥទ្ធិពលដល់នយោបាយសារពើពន្ធ ដូចជាវប្បធម៌សារពើពន្ធ ព្រមទាំងជំនឿទុកចិត្តរវាងអ្នកជាប់ពន្ធ និងរដ្ឋាភិបាលរបស់ខ្លួន។[៤៤] នៅប្រទេសកំពុងអភិវឌ្ឍន៍នយោបាយសារពើពន្ធ មានលក្ខណៈជាសិល្បៈនៃលទ្ធភាពជាជាងការអនុវត្តទ្រឹស្តី និងបទដ្ឋានទូទៅ។ ប្រទេសទាំងនេះ ជួបប្រទះនឹងបញ្ហាប្រឈមធំៗមួយចំនួន ក្នុងការប្រឹងប្រែងរៀបចំប្រព័ន្ធសារពើពន្ធ និងនយោបាយសារពើពន្ធមួយមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ ដោយយសារតែ៖

១. វិស័យកសិកម្ម និងវិស័យក្រៅប្រព័ន្ធគ្របដណ្តប់មួយផ្នែកធំក្នុងសកម្មភាពសេដ្ឋកិច្ច ហើយការទូទាត់ភាគច្រើនប្រព្រឹត្តទៅតាមរយៈសាច់ប្រាក់ ដោយសារគ្មានការកត់ត្រាក្នុងបញ្ជីគណនេយ្យទេ។[៤៥] ដូចជាពលករកម្រទទួលបានប្រាក់ឈ្នួលទៀងទាត់ ហើយក៏កម្រមានលទ្ធភាពទិញទំ-និញ និងសេវានៅតាមហាងទំនើបដែរ។ ការបង់ពន្ធតាមរបបពិត (របបស្ម័យប្រកាស) ជាលទ្ធភាពយកពន្ធលើប្រាក់ចំណូលអាជីវកម្ម និងពន្ធលើការប្រើប្រាស់ ដើម្បីប្រាក់ចំណូលសារពើពន្ធនៅមានកម្រិតនៅឡើយ។

២. កង្វះធនធានមនុស្ស កង្វះមធ្យោបាយ និងកង្វះថវិកា សម្រាប់ចំណូលសារពើពន្ធ កង្វះសមត្ថ-ភាពរបស់អ្នកជាប់ពន្ធ ក្នុងការកាន់កាប់បញ្ជីការគណនេយ្យបណ្តាលឱ្យប្រព័ន្ធនៃសារពើពន្ធ ត្រូវបានរៀបចំតាមជម្រើសមួយ អាចអនុវត្តតាមស្ថានភាពជាក់ស្តែងច្រើនជាងការរៀបចំឱ្យមានលក្ខណៈទំនើប និងប្រសិទ្ធភាព។

៣. ទិន្នន័យស្ថិតិ និងព័ត៌មានមិនគ្រប់គ្រាន់ ធ្វើឱ្យមានឧបសគ្គដល់ការវាយតម្លៃអំពីផលប៉ះពាល់នៃការកែប្រែនយោបាយសារពើពន្ធ។

៤. វិសមភាពសេដ្ឋកិច្ចទៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មានកម្រិតមួយខ្ពស់ជាងសមភាពតាមប្រទេសជឿនលឿន។ សន្ទស្សន៍ជីនី នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំមានកម្រិត ០,៥ ឬច្រើនជាងនេះ។[៤៦]

វិសមភាពនេះមានឥទ្ធិពល២យ៉ាង មកលើនយោបាយសារពើពន្ធ៖

១) បង្កើនចំណូលសារពើពន្ធពីក្រុមអ្នកមានប្រាក់ចំណូលខ្ពស់ ត្រូវជាប់ពន្ធក្នុងកម្រិតសមាមាត្រខ្ពស់ជាង បើធៀបនឹងក្រុមអ្នកមានប្រាក់ចំណូលទាបជាង។

[៤៤] Frey B. S. and feld L. P. (2002); deterrence and Morele in Taxation; CESifo working paper No. 760, Switzerland.

[៤៥] Schneider fried rich (2002); size and Measurement of the informal economy in 110 countries around the world; paper presented at a workshop of Australia National Tax center, ANU, Canberra, Australia, July 17, 2002

[៤៦] LIO (2008); world of work report 2008, income inequalities in the Age of financial GlobaliZation, international labour organization (ILO), published by the international instituefor labour stidies (IILS), Switzerland. P. 8-14.

២) អំណាចសេដ្ឋកិច្ច និងអំណាចនយោបាយច្រើនប្រមូលផ្តុំនៅក្នុងក្រុមអ្នកមានប្រាក់ចំណូលខ្ពស់តាមរយៈកំណែទម្រង់សារពើពន្ធនេះអាចធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ក្រុមអ្នកមានប្រាក់ចំណូលខ្ពស់ អាចប្រឈមមុខប្រតិកម្ម ឬពុំអាចប្រព្រឹត្តទៅបានទេ។ ដូច្នេះ ទើបពន្ធលើប្រាក់ចំណូលបុគ្គល និងពន្ធលើទ្រព្យសម្បត្តិ ឬពន្ធលើដីធ្លី ពុំសូវបានអនុវត្តហ្មត់ចត់។

នយោបាយសារពើពន្ធមួយដែលល្អនិងសមស្រប តម្រូវឱ្យមានការបន្ទាបពន្ធឱ្យដល់កម្រិតអប្បបរមា និងមិនមានផលប៉ះពាល់ពីការយកពន្ធនិងអាកររនោះ។[៤៧] បទពិសោធន៍ បានបង្ហាញថាមានវិធានការចំនួនបី ដើម្បីបន្ទាបផលប៉ះពាល់នេះ[៤៨]៖

វិធានទី១៖ការពង្រីកមូលដ្ឋានពន្ធ (Expansion of tax base)

ការកាត់បន្ថយពន្ធការលើកលែងពន្ធ និងការបញ្ចូលអ្នកមិនបង់ពន្ធ មកក្នុងបណ្តាកាតព្វកិច្ចសារពើពន្ធ គឺជាវិធីមួយសម្រាប់គ្រប់គ្រងចំណូលសារពើពន្ធ ករណីមូលដ្ឋានសារពើពន្ធ បានសន្មត់ថាឥតមានការប្រែប្រួល។ ប៉ុន្តែមូលដ្ឋានសារពើពន្ធពុំមានស្ថិរភាពវាអាចប្រែប្រួលកើនឡើងឬថយចុះ អាស្រ័យទៅនឹងរបៀបដែលជាបន្ទុកសារពើពន្ធក្នុងការប្រមូលចំណូលពន្ធ។ ឧទាហរណ៍ សារពើពន្ធអាចលើកទឹកចិត្តឬបង្អាក់ទឹកចិត្តវិស័យក្នុងប្រព័ន្ធបាន ការប្រើប្រាស់ឧបករណ៍នយោបាយសារពើពន្ធសម្រាប់កែតម្រូវកំណើនសេដ្ឋកិច្ចតាមវិធីច្រើនយ៉ាង។ អ្នកជំនាញសារពើពន្ធជាច្រើន បានមានទស្សនៈថាមូលដ្ឋានពន្ធត្រូវពង្រីកឱ្យបានទូលំទូលាយ ជាពិសេសពន្ធលើការប្រើប្រាស់មានលក្ខណៈល្អជាងពន្ធលើប្រាក់ចំណូលការលើកទឹកចិត្តសារពើពន្ធ គួរតែកាត់បន្ថយឱ្យមកនៅត្រឹមកម្រិតតិចតួចបំផុត ត្រូវតែប្រឹងប្រែងប្រមូលពន្ធចំពោះសកម្មភាពវិស័យក្រៅប្រព័ន្ធ។ ពង្រីកឱ្យបានទូលាយមូលដ្ឋានពន្ធលើការប្រើប្រាស់ ទោះបីជាមានការបង្អាក់ទៅដល់ឆន្ទៈការងារខ្លះក៏ដោយ ក៏ពន្ធប្រភេទនេះមានផលប៉ះពាល់ក្នុងកម្រិតតិចតួចដល់ការប្រើប្រាស់ទំនិញនិងសេវា។ ប្រសិនបើទំនិញនិងសេវាទាំងអស់ ឬភាគច្រើនលើសលុបត្រូវបានបញ្ចូលឱ្យជាប់កាតព្វកិច្ចសារពើពន្ធក៏ដោយ។ មានទំនិញមួយចំនួនតូច ដូចជាផលិតផលថ្នាំជក់ កេសដ្ឋៈស្រវឹង និងផលិតផលតេលសិលាជាដើម ត្រូវបានជាប់ពន្ធតាមអត្រាពន្ធមួយខ្ពស់ជាងទំនិញនិងសេវាដទៃទៀត។ ទិដ្ឋភាពទ្រឹស្តី ដើម្បីកាត់បន្ថយការខាតបង់ប្រសិទ្ធភាពអត្រាពន្ធខុសៗគ្នា បានកំណត់សម្រាប់ទំនិញនិងសេវានីមួយៗ ដែលក្នុងនោះអត្រាខ្ពស់ត្រូវកំណត់សម្រាប់ទំនិញនិងសេវា ដែលអ្នកទិញពុំសូវឬមិនកែប្រែឥរិយាបទតាមរយៈបន្ទុកពន្ធ។ ដើម្បីអនុវត្តនយោបាយសារពើពន្ធរបៀបនេះ តម្រូវឱ្យក្តាប់ព័ត៌មានឱ្យបានច្រើនគ្រប់គ្រាន់អំពីការកែប្រែឥរិយាបទសេដ្ឋកិច្ច តាមរយៈជាប់កាតព្វកិច្ចក្នុងកម្រិតខុសគ្នានេះ។ លើសពីនេះគោលនយោបាយនេះពុំបានគិតគូរទៅដល់បញ្ហារដ្ឋបាល និងសមធម៌នោះទេ។ ដូច្នេះ បានជាក្នុងការអនុវត្តជាក់ស្តែងគេនិយមប្រើអត្រាពន្ធឯកភាព

[៤៧] will martin and James E. Anderson et al. (2005); costs of Taxation and the benefits of public goods: the role of income Effects; Boston college Department of Economics.

[៤៨] Richard M. Bird and Eric M. Zolt (2007); Tax policy in Emerging countries; University of Toronto and UCLA, ITP paper 0707, Canada. P. 11-12.

ឱ្យបានទូលំទូលាយជំនួសនូវការអនុវត្តវិស័យពន្ធខុសៗគ្នាច្រើន សម្រាប់ទំនិញនិងសេវាប្រើប្រាស់ផ្សេងៗ។

ការពង្រឹងមូលដ្ឋានសារពើពន្ធឱ្យបានទូលំទូលាយ ពុំមែនសុទ្ធតែល្អនៅគ្រប់ករណីនោះទេ។ ដូចជាអាករលើតម្លៃបន្ថែមនៅតាមប្រទេសមួយចំនួន ពុំបានលើកលែងពន្ធចំពោះទំនិញនិងសេវាកម្មសំខា-ន់ៗដែលបានបម្រើឱ្យសេចក្តីត្រូវការរបស់អ្នកក្រីក្រនោះទេ។ ដូចជាប្រទេសចាមៃកាមានការលើកលែងលើមុខទំនិញចំនួនប្រាំមុខ គេអាចកាត់បន្ថយបន្ទុកអាករលើតម្លៃបន្ថែមបានពាក់កណ្តាលសម្រាប់អ្នកមានប្រាក់ចំណូលទាបមានចំនួន ៤០ភាគនៃចំនួនអ្នកមានសរុប។[៤៩] ក៏ប៉ុន្តែមានអ្នកស្រាវជ្រាវខ្លះមានទស្សនៈថាជាទូទៅការកំណត់អត្រាពន្ធ គឺប្រសើរជាងការលើកលែងពន្ធ។

នយោបាយសារពើពន្ធ មានគោលដៅជំរុញកំណើនសេដ្ឋកិច្ច បានផ្តោតលើការកាត់បន្ថយការចំណាយក្នុងប្រតិបត្តិការវិស័យក្នុងប្រព័ន្ធ និងមិនធ្វើឱ្យសម្បទានសារពើពន្ធដល់សកម្មភាពសេដ្ឋកិច្ចវិស័-យក្រៅប្រព័ន្ធ។ អ្នកឯកទេសខ្លះ មានទស្សនៈថាសាមញ្ញកម្ម និងភាពងាយស្រួលប្រព័ន្ធនៃសារពើពន្ធអាចជួយទប់ស្កាត់ពុំឱ្យមានសហគ្រាសវិស័យក្នុងប្រព័ន្ធ ស្វែងរកឱកាសចាកចេញរកវិស័យក្រៅប្រព័ន្ធវិញ ហើយជួយលើកទឹកចិត្តដល់ការពង្រីកខ្លួនរបស់សហគ្រាសដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មវិស័-យក្នុងប្រព័ន្ធ។[៥០] ជាទូទៅការលើកលែងពន្ធ ពុំមែនជាវិធានការល្អប្រសើរសម្រាប់នយោបាយសារពើពន្ធទេ។ ការលើកលែងពន្ធ គឺជាវិធានការសារពើពន្ធ ត្រូវបានប្រើសម្រាប់តែការទាក់ទាញការវិនិយោគនិងសម្រាប់វិស័យសេដ្ឋកិច្ចឬតំបន់មួយចំនួនប៉ុណ្ណោះ។ ប៉ុន្តែបទពិសោធន៍បានបង្ហាញថា មានករណីជាច្រើនការលើកលែងពន្ធ ពុំបានទាក់ទាញការវិនិយោគប្រកបដោយគុណភាព និងមានផលិតភាពនោះទេ។ ប៉ុន្តែបែរជាបង្កើតឱកាសគេចពន្ធតាមវិធីផ្សេងៗ និងធ្វើឱ្យការងាររដ្ឋបាលសារពើពន្ធកាន់តែស្មុគស្មាញ និងធ្វើឱ្យបាត់បង់តម្លាភាព។[៥១] ជាលទ្ធផលនៃការស្រាវជ្រាវរបស់លោក Theodore បានបង្ហាញថាការលើកលែងពន្ធ គឺជាទម្រង់ឧបត្ថម្ភធនមួយដែលច្រើនតែផ្តល់ការលើកលែងពន្ធលើការនាំចូល(អាករជាតុចូល) ដូចជាវត្ថុធាតុដើម ទំនិញអន្តរការី និងទំនិញមូលធនផ្សេងៗ។ តាមរយៈនេះធ្វើឱ្យការផ្សារភ្ជាប់ផលិតកម្មនៃសង្វាក់ផលិតកម្មវិលជុំ(Backward linkages)ត្រូវបានរាំងស្ទះ។[៥២]

វិធានទី២៖ការបន្ទាបអត្រាពន្ធ (Reducing tax rates)

ជាទូទៅ ការបង្កើតចំណូលសារពើពន្ធ អាចប្រព្រឹត្តទៅបានតាមវិធី ៣យ៉ាងៈ

- ការបង្កើនអត្រាពន្ធ
- ការពង្រីកមូលដ្ឋានពន្ធ

[៤៩] Richard M. Bird and Eric M. Zolt (2007); Tax policy in Emerging countries; University of Toronto and UCLA, ITP paper 0707, Canada. P. 11-12.

[៥០] Chattopadhyay S. and Das-Gupta A. (2002); the income Tax compliance cost of Indian corporation; national institute of public finance and policy, New Delhi.

[៥១] Bruce Blolnick (2004); Effectiveness and economic impact of Tax incentives in the SADC region; Technical Report, submitted to USAID/RCDA, SADC Tax subcommittee, SADC trade, industry, finance and investment directorate, submitted by Nathan-MSI Group under contract No, PCE-I-00-98-00016-00, p. 3-20.

[៥២] Theodore H. Moran (2001); parental supervision: the new paradigm for foreign Direct investment and Development; policy Analyses in international Economics, United Kingdom.

- ការកែលម្អរដ្ឋបាលសារពើពន្ធ។

ការបង្កើនអត្រាពន្ធនៅក្នុងប្រព័ន្ធសារពើពន្ធ គឺជាវិធីមួយដែលក្នុងទិដ្ឋភាពនយោបាយពុំសូវចោទជាបញ្ហាធំដុំទេ។ ប៉ុន្តែនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ច គឺជាដំណោះស្រាយមួយធ្វើឱ្យខាតបង់ប្រសិទ្ធភាពសេដ្ឋកិច្ច។ នៅក្នុងទ្រឹស្តីទំនាក់ទំនងរវាងអត្រាពន្ធ និងចំណូលសារពើពន្ធ ត្រូវបានបង្ហាញតាមរយៈខ្សែកោង(Laffer)។[៥៣] មូលដ្ឋាននេះ ការកែប្រែអត្រាពន្ធមានឥទ្ធិពលពីរយ៉ាងនៅក្នុងទិសដៅដូចគ្នា លើចំណូលសារពើពន្ធដែលឥទ្ធិពលទី១៖ មានលក្ខណៈជាគណិតសាស្ត្រ ពោលគឺប្រែប្រួលជាភាគរយនៃអត្រាពន្ធបណ្តាលឱ្យមានការប្រែប្រួលភាគរយស្របគ្នានូវចំណូលសារពើពន្ធ ដែលមានទំនាក់ទំនងផ្ទុយគ្នាជា មួយនឹងការបង្កើន ឬការបន្ថយអត្រាពន្ធ។ នេះមានន័យថា ការបង្កើនអត្រាពន្ធនឹងធ្វើឱ្យចំណូលសារពើពន្ធថយចុះ ហើយការបន្ថយអត្រាពន្ធធ្វើចំណូលសារពើពន្ធកើនឡើង។ ការបន្ទាបអត្រាពន្ធ គឺជាការលើកទឹកចិត្តដល់ការវិនិយោគ (ពីព្រោះប្រាក់ចំណូលក្រោយបង់ពន្ធនឹងកើនឡើង) ធ្វើឱ្យមានកំណើនផលិតភាពសេដ្ឋកិច្ច ហើយជាលទ្ធផលចំណូលសារពើពន្ធនឹងកើនឡើង បើទោះបីជា អត្រាពន្ធបន្ទាបក៏ដោយ។ រីឯការបង្កើនអត្រាពន្ធ ដោយគ្មានការពង្រីកមូលដ្ឋានពន្ធ អាចធ្វើឱ្យមូលដ្ឋានពន្ធមួយផ្នែកអាចនឹងកៀសចេញទៅខាងក្រៅប្រទេសបាន គួបផ្សំជាមួយភាពគ្មានប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធដែលចំណូលសារពើពន្ធពុំអាចកើនឡើងបាននោះ។ កំណើនអត្រាពន្ធ អាចធ្វើឱ្យមានប៉ះពាល់ដល់ធនធានចល័ត (មូលធននិងកម្លាំងពលកម្ម) ព្រមទាំងតួអង្គសេដ្ឋកិច្ចនានា ដូចជាអ្នកវិនិយោគបរទេសជាដើម។

ជាមួយគ្នានេះដែរ វិសមភាពតាមខ្សែឈរ អាចកើនឡើងដោយសារតែ អ្នកជាប់កាតព្វកិច្ចពន្ធមួយចំនួនត្រូវបង់ពន្ធ រីឯអ្នកខ្លះទៀតមានលទ្ធភាពគេចពន្ធបាន ហើយក្នុងករណីដែលអត្រាពន្ធកើនឡើងមិនស្មើគ្នានោះ ក៏អាចធ្វើឱ្យវិសមភាពតាមខ្សែដេកកើនឡើងបានដែរ។

វិធានទី៣៖ការបង្ក្រួមពន្ធ និងអាករលើផលិតកម្ម (Contraction tax and production tax)

ពន្ធនិងអាករលើផលិតកម្ម ដូចជាពន្ធលើប្រាក់ចំណេញ និងពន្ធលើចំណូលពីការលក់ទំនិញ (Sale Tax)ជាដើម (ការលើកលែងអាករលើតម្លៃបន្ថែម) អាចធ្វើឱ្យរាំងស្ទះដល់ប្រសិទ្ធភាពផលិតកម្ម ពីព្រោះពន្ធប្រភេទនេះ អាចមានផលប៉ះពាល់ដល់ការជ្រើសរើសផលិតកម្ម ការប្រែប្រួលកម្មវិធីផលិតកម្ម និងការកែប្រែទ្រង់ទ្រាយគតិយុត្តិរបស់ក្រុមហ៊ុន។ ជាទូទៅ សារពើពន្ធគឺជាយន្តការមួយសម្រាប់ផ្ទេរធនធានពីផ្នែកឯកជនទៅវិស័យសាធារណៈ។ ប៉ុន្តែទន្ទឹមគ្នានេះ សារពើពន្ធក៏បណ្តាលឱ្យមានការចំ-ណាយលើសេដ្ឋកិច្ចផងដែរ ធ្វើឱ្យមានការខាតបង់នូវការប្រើប្រាស់ធនធានសម្រាប់គោលដៅតាមបទប្បញ្ញត្តិ ឬគេចវេសកាតព្វកិច្ចសារពើពន្ធ គឺជាការចំណាយ ឬខាតបង់ខាងសេដ្ឋកិច្ច។ ការណ៍នេះមានន័យថាការបង្កើនអត្រាពន្ធធ្វើឱ្យថយចុះនូវសមត្ថភាពសេដ្ឋកិច្ចក្នុងការផ្គត់ផ្គង់ទំនិញ និងសេវា

[៥៣] Arthur B. Laffer (2004); the Laffer curve: past, present, and future; Backgrounder, published by the heritage foundation, No. 1765, June 1 2004, Washington D. C.

កម្មផ្សេងៗដែលសង្គមចង់ធ្វើឱ្យមានការប្រែប្រួលកម្រិតថ្លៃ តាមរយៈនេះបណ្តាលឱ្យមានការប្រែប្រួលការសម្រេចចិត្តក្នុងការធ្វើការងារការសន្សំ និងការវិនិយោគ។[៥៤]

៣.២-ប្រព័ន្ធរដ្ឋបាលនៃសារពើពន្ធ(ADMINISTRATIVE SYSTEM OF FISCAL)

៣.២.១-រដ្ឋបាលសារពើពន្ធ(TAX ADMINISTRATION)

រដ្ឋបាលសារពើពន្ធ គឺជាកត្តាចម្បងសម្រាប់អនុវត្តនូវនយោបាយសារពើពន្ធឱ្យមានប្រសិទ្ធភាព។ នយោបាយសារពើពន្ធល្អប្រសើរនឹងមានសារប្រយោជន៍ កាលណានយោបាយសារពើពន្ធ ត្រូវបានអនុវត្តប្រកបដោយភាពស័ក្តិសិទ្ធិ។ ដូចនេះ ក្នុងការរៀបចំនូវគោលនយោបាយសារពើពន្ធ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ដល់វិសាលភាពរដ្ឋបាលសារពើពន្ធឱ្យបានហ្មត់ចត់។[៥៥] របបសារពើពន្ធខុសៗគ្នាទាមទារឱ្យមានការរៀបចំនូវប្រភេទនៃរដ្ឋបាលសារពើពន្ធខុសៗគ្នាដែរ។ គោលនយោបាយសារពើពន្ធមិនត្រឹមតែមានឥទ្ធិពលលើការចំណាយរដ្ឋបាលសារពើពន្ធតែប៉ុណ្ណោះទេ។ ប៉ុន្តែនយោបាយសារពើពន្ធក៏ទាក់ទងទៅនឹងការរៀបចំអង្គការចាត់តាំងនៃរដ្ឋបាលសារពើពន្ធនេះផងដែរ។ កម្រិតសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធ គឺជាកត្តាគន្លឹះមួយក្នុងការរៀបចំប្រព័ន្ធសារពើពន្ធ។ លោក Mika បានអះអាងថាក្នុងន័យជាក់ស្តែងរដ្ឋបាលសារពើពន្ធ គឺជានយោបាយសារពើពន្ធ[៥៦] ពោលគឺត្រូវមានការធានាឱ្យបានសមាហរណកម្មនៃបញ្ហារដ្ឋបាលសារពើពន្ធក្នុងការរៀបចំនូវនយោបាយសារពើពន្ធ។ ឧទាហរណ៍សាមញ្ញកម្មនៃច្បាប់សារពើពន្ធ ជាគោលបំណងមួយដ៏សំខាន់នៃការកំណែទម្រង់សារពើពន្ធ តែងតែពាក់ព័ន្ធទៅនឹងរដ្ឋបាលសារពើពន្ធ។ ជាទូទៅសម្រាប់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធទាំងមូលជាសមត្ថកិច្ចទទួលខុសត្រូវរបស់អង្គភាពសារពើពន្ធនានា ត្រូវបានបែងចែកទៅតាមប្រភេទសារពើពន្ធ ដូចជារដ្ឋបាលគ្រប់គ្រងប្រព័ន្ធនៃរដ្ឋបាល គ្រប់គ្រងអាករលើតម្លៃបន្ថែម នៅតាមបណ្តាប្រទេសជាច្រើនត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលគយនិងរដ្ឋបាលពន្ធដារ។ ហើយចំណូលសារពើពន្ធប្រភេទខ្លះ ត្រូវបានបែងចែកសមត្ថកិច្ចគ្រប់គ្រងរវាងរដ្ឋបាលសារពើពន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ ដូច្នេះ ការកែប្រែនយោបាយសារពើពន្ធ ត្រូវបានគាំទ្រដោយការកែប្រែសមត្ថកិច្ចរដ្ឋបាលសារពើពន្ធ។[៥៧]

ការបង្កើនចំណូលសារពើពន្ធលើមូលដ្ឋាននៃរដ្ឋបាលសារពើពន្ធដដែល គឺជាវិសាលភាពមួយនៃភារកិច្ចរបស់រដ្ឋបាលសារពើពន្ធ ហើយកម្រិតចំណូលសារពើពន្ធគឺគ្រាន់តែជាលក្ខខណ្ឌចាំបាច់ក្នុងការវាយតម្លៃអំពីសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធតែប៉ុណ្ណោះ។ ប៉ុន្តែតាមលក្ខខណ្ឌគ្រប់គ្រាន់នៃប្រសិទ្ធភាពរបស់រដ្ឋបាលសារពើពន្ធ តម្រូវឱ្យមានការគិតគូពីកម្រិតនៃការចំណាយក្នុងការប្រមូលចំណូលសារ

[៥៤] Alex Robson (2007); No free lunch: the costs of Taxation; the New Zealand Business Round table, Washington, New Zealand.

[៥៥] Brid, Richard M. Zolt, Eric M. (2003); introduction to tax policy design and development; a draft prepares for a course on practical issues of tax policy in development countries, Word Bank, April 28 may 1, 2003.

[៥៦] Casanegra de jantscher, Mika (1986); problems of Administering a Value-Added Tax in developing countries; IMF working paper No.86/15

[៥៧] Wayne thirst (1991); Lessons from Tax Reform. An Overview; the working paper series, the bank's policy Research, and External Affairs complex, the world bank, WPS 576, Washington D.C.

ពើពន្ធថែមទៀត។[៥៨] វិធីសាស្ត្រនៃសារពើពន្ធត្រូវបានប្រមូល និងឥទ្ធិពលនៃចំណូលសារពើពន្ធទៅលើសមធម៌ និងនិរន្តភាពរបស់រដ្ឋាភិបាល និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក៏មានសារៈសំខាន់ដូចគ្នាទៅនឹងប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធដែរ។ ក្រៅពីនេះ ចំណាយរបស់ផ្នែកឯកជន និងសាធារណៈទាក់ទងទៅនឹងរដ្ឋបាលសារពើពន្ធ គឺមានវិសាលភាពជំរុញការអនុវត្តតាមបទប្បញ្ញត្តិសារពើពន្ធតាមរយៈការអនុវត្តតាមន៍របស់រដ្ឋបាលសារពើពន្ធច្រើនជាងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ តាមរយៈរដ្ឋបាលសារពើពន្ធមានតួនាទីអកម្មជាអ្នកទទួលប្រាក់ពន្ធនិងអាករ។

បុរេលក្ខខណ្ឌនៃការកែទម្រង់រដ្ឋបាលសារពើពន្ធ គឺការរៀបចំឱ្យប្រព័ន្ធសារពើពន្ធមានលក្ខណៈសាមញ្ញដើម្បីធានាឱ្យបានថាប្រព័ន្ធនេះ អាចត្រូវបានអនុវត្តប្រកបដោយភាពស័ក្តិសិទ្ធិ ជាពិសេសនៅក្នុងបរិយាកាសនៃការមិនសូវអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ ពុំមែនឆ្លុះបញ្ចាំងតែម្យ៉ាងអំពីកម្រិតនៃភាពស័ក្តិសិទ្ធិរបស់រដ្ឋបាលសារពើពន្ធប៉ុណ្ណោះទេ។ មនសិការរបស់អ្នកជាប់ពន្ធ មានចំពោះកាតព្វកិច្ចសារពើពន្ធចំពោះរដ្ឋាភិបាល ព្រមទាំងកត្តាសង្គមផ្សេងៗទៀត ក៏មានឥទ្ធិពលផងដែរលើភាពស័ក្តិសិទ្ធិនៃរដ្ឋបាលសារពើពន្ធ។ មនសិការសារពើពន្ធ កើតមានឡើងនៅក្នុងក្របខ័ណ្ឌនៃកត្តាសង្គមមួយចំនួន ដូចជាកម្រិតនៃការឱ្យតម្លៃលើការគេចវេសពន្ធ ការយល់ឃើញអំពីភាពត្រឹមត្រូវ ស្ថិរភាព និងភាពពេញលេញនៃរចនាសម្ពន្ធ៍សារពើពន្ធការឱ្យតម្លៃទៅលើសមត្ថភាពនឹងភាពស្របច្បាប់របស់រដ្ឋាភិបាល ព្រមទាំងទំនុកចិត្តចំពោះប្រសិទ្ធភាពនៃការប្រើប្រាស់ចំណូលសារពើពន្ធនៅក្នុងការអភិវឌ្ឍន៍។ ជាទូទៅ គោលនយោបាយសាធារណៈរបស់រដ្ឋាភិបាល ពាក់ព័ន្ធនឹងកត្តាសង្គមទាំងនេះ អាចមានឥទ្ធិពលដល់មនសិការសារពើពន្ធរបស់អ្នកជាប់ពន្ធ ព្រមទាំងកម្រិតនៃការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធរបស់អ្នកជាប់ពន្ធ។ ជួនកាល ការអនុវត្តពិន័យនិងទោសទណ្ឌ ដោយគ្មានការលើកលែង អាចជួយជំរុញដល់ការអនុលោមតាមបទប្បញ្ញត្តិដោយស្ម័គ្រចិត្តថែមមួយកម្រិតទៀត។[៥៩]

លទ្ធផលនៃការស្រាវជ្រាវមួយចំនួនបានបង្ហាញថាកំណើនភាពស្មុគស្មាញនៃប្រព័ន្ធសារពើពន្ធធ្វើឱ្យមានផលប៉ះពាល់លើរដ្ឋបាលសារពើពន្ធ និងការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ។[៦០] ឧទាហរណ៍ ពន្ធលើប្រាក់ចំណូលធ្វើឱ្យប្រព័ន្ធសារពើពន្ធមានលក្ខណៈស្មុគស្មាញច្រើនជាងពន្ធលើការប្រើប្រាស់ជាមួយនឹងការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ។ សាមញ្ញកម្មប្រព័ន្ធសារពើពន្ធ គឺមានភាពចាំបាច់ប៉ុន្តែមិនគ្រប់គ្រាន់ក្នុងការជួយកាត់បន្ថយការចំណាយរបស់អ្នកជាប់ពន្ធក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធនោះឡើយ។ នៅក្នុងទិដ្ឋភាពសេដ្ឋកិច្ច ភាពស្មុគស្មាញសារពើពន្ធ អាចត្រូវកំណត់តាមរយៈការចំណាយ ចំពោះការងារការិយាធិបតេយ្យក្នុងការគណនាប្រាក់ពន្ធ និងការបង្វែរប្រាក់ពន្ធ ព្រមទាំងការបង្វែរវិភាគទានជានាវ៉ាប់រងសង្គមកិច្ចទៅអាជ្ញាធរមាន

[៥៨] Arthur J… Mann (2002); Estimating the administrative costs of taxation: A Methodology with Application to the case of Guatemala: Detach systems, Arlington, VA

[៥៩] Bird, Richard M. (2004); Administrative Dimensions of tax Reform; Asia-pacific tax bulletin, international, March 2004, pp. 134-150. Pp.134-150.

[៦០] Jeff pope (1993); the compliance costs of taxation in Australia and tax simplification: the issues; Australian Journal of Management, 18,1, June 1993, @ the university of New south wales, pp. 69-90. Khud J. Muck (2007); tax-trariff reform with costs of tax administrative; international tax and public finance, volume 15, number 6, DOI: 10.1007/s10797-007-9042-z, pp. 647-667. Pp. 69-90.

សមត្ថកិច្ច។[៦១] បើតាមលោក Kopezuk បង្ហាញថាភាពស្មុគស្មាញនៃប្រព័ន្ធសារពើពន្ធ បានបង្កលក្ខ-ណៈឱ្យមានឱកាសបិតបាំងប្រាក់ចំណូលពន្ធ ដើម្បីកុំឱ្យជាប់កាតព្វកិច្ចពន្ធអាចបង្កើននូវភាវនីយភាពនៃការធ្វើឱ្យអ្នកជាប់ពន្ធ ជានាបំណុលពន្ធមិនបានត្រឹមត្រូវដោយអចេតនា ដោយសារវិធានការជំរុញការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ រមែងជួបការលំបាកនៅក្នុងការញែកចេញពីគ្នារវាងអ្នកជាប់ពន្ធដែលមានចេតនា និងអចេតនាបំភ្លៃបំណុលពន្ធ។[៦២] ដូច្នេះភាពស្មុគស្មាញនៃសារពើពន្ធ អាចកាត់បន្ថយភាពស័ក្តិសិទ្ធិនៃយុទ្ធនាការជំរុញការអនុលោមសារពើពន្ធ ដូចជាការតាមដាន ឬផាកពិន័យជាដើម។

ការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ ត្រូវបានចាត់ទុកថាជាបន្ទុកសេដ្ឋកិច្ច ដោយសារតែហេតុផលបីយ៉ាង៖

១. ការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ ធ្វើឱ្យថយចុះធនធានផ្នែកឯកជន ដោយពុំបានធ្វើឱ្យកើនឡើងនូវចំណូលថវិការបស់រដ្ឋាភិបាលទេ។ ដូច្នេះ វាជាការខាតបង់ធនធានសេដ្ឋកិច្ច។

២. បទពិសោធន៍បានបង្ហាញថាបន្ទុកសេដ្ឋកិច្ចនៃការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធថយចុះជាមួយនឹងទំហំសហគ្រាស[៦៣] និងកើនឡើងទៅនឹងការចូលក្នុងទីផ្សារអន្តរជាតិ។[៦៤] តាមរយៈនេះ ធ្វើឱ្យមានផលប៉ះពាល់ដល់ការប្រកួតប្រជែងរបស់សហគ្រាសធុនតូចនិងមធ្យម និងធ្វើឱ្យថយចុះនូវឱកាសចូលទៅកាន់ទីផ្សារអន្តរជាតិរបស់សហគ្រាសទាំងនោះ។

៣. ការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិ ស្តីពីសារពើពន្ធមានទំនាក់ទំនងជាមួយនឹងកម្រិតនៃការអនុលោមច្បាប់។ បើការអនុលោមតាមមានកម្រិតទាបនោះឱកាសសម្រាប់គេចវេសកាតព្វកិច្ចសារពើពន្ធមានកម្រិតខ្ពស់។[៦៥]

ក្នុងទិដ្ឋភាពរដ្ឋបាលធុរកិច្ច បន្ទុកចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធរបស់ផ្នែកឯកជន គឺមិនចំណុះតែម្យ៉ាងទៅនឹងការរៀបចំនិងការអនុវត្តរបស់ប្រព័ន្ធសារពើពន្ធទេ។ ប៉ុន្តែក៏ចំណុះនឹងយុទ្ធសាស្ត្រនៃការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធរបស់អ្នកជាប់ពន្ធផងដែរ។ អ្នកជាប់ពន្ធអាចប្រើប្រាស់កម្មវិធីកុំព្យូទ័រឬបណ្តាញអ៊ីនធឺណេតឬជួលក្រុមហ៊ុនបម្រើសេវាប្រឹក្សាផ្នែកពន្ធដារឱ្យជួយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធបាន។ ការស្រាវជ្រាវខ្លះ បានលើកឡើងថាការចំណាយក្នុងការទូទាត់សេវាប្រឹក្សាផ្នែកសារពើពន្ធ គួរតែត្រូវទទួលការអនុញ្ញាតឱ្យកាត់កងចេញពីមូលដ្ឋានគិតពន្ធ

[៦១] OECD (2009); Taxing Wages; paris. Available at: www.oecd.org/ctp/taxingwages.

[៦២] Wojcech kopezuk (2006) Tax implication and tax compliance: An economics perspective; in max B. sawicky (editor) 2006; bridging the tax gap: Addressing the crisis in federal tax administration; Economics policy institute, Washington D. C.

[៦៣] OECD (Eds) (2001); Business view on red tape: administrative and regulatory burdens on small and medium enterprises, Paris: OECD

[៦៤] Blumenthal, M. and slemrod J. (1995); the compliance cost of taxing foreign-source of income: its magnitude, determinants and policy implication, international Tax and public Finance, 2, 37-53. P. 37-53.

[៦៥] Brian erard and chih-chin Ho (2003); explaining the U.S. income Tax compliance continuum; journal of tax research, Vol. 1, No. 2. Available at SSRN: http//ssrn.com/abstract=643942

ហើយរដ្ឋាភិបាលអាចឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែល្អថែមទៀត រវាងក្រុមហ៊ុនបម្រើសេវាប្រឹក្សាផ្នែកសារពើពន្ធ និងផ្នែកឯកជនដែលជាប់កាតព្វកិច្ចពន្ធ។[៦៦] បើយោងតាមទស្សនៈរបស់លោក Cedric ពន្យល់ថា ការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ គឺការចំណាយរបស់អ្នកជាប់ពន្ធសម្រាប់បំពេញកាតព្វកិច្ចតាមតម្រូវការរបស់ច្បាប់សារពើពន្ធ និងអាជ្ញាធរសារពើពន្ធ។ ការចំណាយនេះ គឺជាការចំណាយបន្ថែមទៅលើប្រាក់ពន្ធជាក់ស្តែងដែលត្រូវទូទាត់។[៦៧] ប៉ុន្តែការចំណាយនេះ ក៏ជាបន្ទុករបស់អ្នកជាប់ពន្ធមួយចំនួនទៀតមានតួនាទីសម្រួលដល់ការផ្ទេរធនធាន(ប្រាក់ពន្ធ)ពីផ្នែកឯកជន ទៅឱ្យរដ្ឋាភិបាលផងដែរ ដូចជានិយោជកទទួលខុសត្រូវក្នុងការកាត់ទុកប្រាក់ពន្ធកាត់ទុកពីការប្រាក់ របស់អ្នកផ្ញើប្រាក់ជាដើម។ ជាទូទៅ ការចំណាយនៅក្នុងប្រព័ន្ធសារពើពន្ធមានច្រើនសណ្ឋាន រួមមានការខាតបង់សុខុមាលភាពថ្លៃដើម ឱកាសការប៉ះពាល់ខាងផ្លូវចិត្ត ដល់ការចំណាយលើការប្រមូលចំ-ណូលសារពើពន្ធការចំណាយរបស់រដ្ឋាភិបាល ការចំណាយលើការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ ការចំណាយលើការគេចវេសកាតព្វកិច្ចសារពើពន្ធ ការមិនបានបង់ពន្ធ រួមទាំងការខាតបង់នៃប្រសិទ្ធភាពសេដ្ឋកិច្ច។[៦៨]

ប្រព័ន្ធនៃសារពើពន្ធ ដែលបង្កលក្ខណៈដល់ការសម្របសម្រួលការងាររបស់រដ្ឋបាលសារពើពន្ធ គឺមានលក្ខណៈសម្បត្តិសំខាន់ៗមួយចំនួន រួមមានប្រភេទពន្ធមានចំនួនតិចតួច អត្រាពន្ធមានកម្រិតតិច សម្រាប់ប្រភេទពន្ធនីមួយៗពុំសូវមានការលើកលែងពន្ធ និងមានមូលដ្ឋានពន្ធទូលាយ។ មូលដ្ឋាននេះ ប្រព័ន្ធនៃសារពើពន្ធអាចធ្វើឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រង និងសម្រេចបានការអនុលោមតាមបទប្បញ្ញត្តសារពើពន្ធនៅក្នុងកម្រិតមួយខ្ពស់។[៦៩] ប្រភេទពន្ធ មានចំនួនតិចធ្វើឱ្យខាតបង់ប្រសិទ្ធភាពសេដ្ឋកិច្ច និងការចំណាយក្នុងរដ្ឋបាលសារពើពន្ធមានកម្រិតទាប។ អត្រាពន្ធមានចំនួនតិច ដូចជាករណីពន្ធលើទំនិញជាដើម អាចកាត់បន្ថយបាននូវការមិនអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ តាមរយៈការកែប្រែចំណាត់ថ្នាក់បន្ទុកពន្ធនិងអាករផ្សេងៗ។[៧០] អត្រាពន្ធកើនឡើងជាមួយនឹងកម្រិតប្រាក់ចំណេញអាចជំរុញឱ្យសហគ្រាសបំបែកអង្គភាពខ្លួន ឬរក្សាទុកទំហំរបស់ខ្លួនឱ្យមានកម្រិតមួយមិនធំពេកដើម្បី សម្រួលបន្ទុកពន្ធបណ្តាលឱ្យរាំងស្ទះដល់ឱកាសប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពតាមវិមាត្រនៃសេដ្ឋកិច្ច។ ប្រព័ន្ធនៃសារពើពន្ធ មានការលើកលែងពន្ធច្រើន(ដើម្បីសម្រេចគោលដៅផ្សេងៗ ក្រៅពីចំណូលថវិកាជាតិ) ធ្វើឱ្យការចំណាយក្នុងរដ្ឋបាលសារពើពន្ធមានកម្រិតខ្ពស់ ហើយរដ្ឋបាលសារពើពន្ធកាន់តែមានលក្ខណៈស្មុគស្មាញ។ ការលើកលែងពន្ធ(ក្រៅពីធ្វើឱ្យមូលដ្ឋានសារពើពន្ធរួញថយ

---

[៦៦] Sebastian E. and Michael s. (2009); Tax compliance costs: A business administration perspective; diskussionsbeitrage des fachbereichs wirtchaftswissenachaft der freien university berlin, betriebswirtschaftliche reich 2009/03, berlin

[៦៧] Sendford, cedric (1995); improving the Methodologies; in: sandford, cedric (ed); Tax compliance costs Measurement and policy; Bath, U.K. fiscal publication in association with the institute for fiscal studies.

[៦៨] Joel slemrod and shlomo yitzhaki (1995); the costs of Taxation and the marginal costs of Funds; IMF working paper No. 95/83, WP/9583-EA, Washington D.C.

[៦៩] Silvani, carlos, and Katherine baer (1997); Designing a Tax Administration Reform strategy: Experience and guidelines; IMF working paper, WP/97/30, Washington, D. C.

[៧០] Fissban, Raymond and stand-in weir (2004); tax rates and tax evidence from missing imports in china; journal of political economy 112(2): 471-96 taipan K. starker (2003); improving tax compliance in evildoing countries via self-assessment systems – what could bang lades learn from Japan? international bureau of fiscal document ation (IBFD), Asia-pacific tax bulletin vol. 9, No. 6 June 2003.

ចុះ គឺ បង្កើនវិសមាសភាព និងខូចថ្លៃ) បណ្តាលឱ្យមានប្រព្រឹត្តិកម្មខុសគ្នា ចំពោះអ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធត្រូវការព័ត៌មានកាន់តែច្រើន ដើម្បីបង្កើននូវឱកាសដល់ការរៀបចំរបាយការណ៍ពន្ធ មិនត្រឹមត្រូវ និងធ្វើឱ្យការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធពីសំណាក់អ្នកជាប់ពន្ធ និងតតិយជន កាន់តែស្មុគស្មាញឡើង។ ជាទូទៅសម្បទានពន្ធសម្រាប់បម្រើឱ្យគោលដៅក្រៅពីចំណូលថវិការដ្ឋជាច្រើន តែត្រូវបានប្រើប្រាស់ក្នុងករណីកម្រ ហើយត្រូវបានជ្រើសរើសមុខសញ្ញាដោយប្រយ័ត្នប្រយែងផងដែរ។ ក្រោយពីបានប្រៀបធៀបភាពស័ក្តិសិទ្ធិជាមួយនឹងមធ្យោបាយផ្សេងទៀតមានគោលបំណងដូចគ្នា ដូចជាការចំណាយថវិការដ្ឋ ការឧបត្ថម្ភធន ឬនិយ័តកម្មផ្សេងៗទៀត។

អ្នកសេដ្ឋកិច្ចខ្លះបានកំណត់ថា ការសម្រេចចិត្តពីសាមញ្ញកម្មនៃប្រព័ន្ធនៃសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ តម្រូវឱ្យមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក) ការរៀបចំច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធឱ្យមានលក្ខណៈសាមញ្ញបំផុតតាមអាចធ្វើបាន

ខ) ប្រព័ន្ធនៃសារពើពន្ធមានលក្ខណៈទូទៅ ដោយមានករណីលើកលែងពន្ធការកាត់កងពន្ធ និងការបញ្ចុះពន្ធដ៏តិចតួច

គ) ប្រព័ន្ធនៃសារពើពន្ធ មិនត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅសេដ្ឋកិច្ចច្រើនពេកទេ

ឃ) ប្រព័ន្ធនៃសារពើពន្ធ ត្រូវបានឃ្លាំមើលចំពោះប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិឱ្យបានជាប្រចាំ

ង) រដ្ឋបាលសារពើពន្ធ មានភារកិច្ចប្រមូលផ្តុំការប្រមូលចំណូលពន្ធលើប្រភពសារពើពន្ធ និងការយកចិត្តទុកដាក់ដល់ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណនៃលេខកូដសារពើពន្ធ។

ច) ព័ត៌មានសម្រាប់គោលដៅសារពើពន្ធ មិនត្រូវប្រមូលច្រើនហួសពីសមត្ថភាពគ្រប់គ្រង ឬកែច្នៃរបស់រដ្ឋបាលសារពើពន្ធ

ឆ) ជំរុញឱ្យមានការកត់ត្រា និងរក្សាទុកនូវរបាយការណ៍សារពើពន្ធរបស់អ្នកជាប់ពន្ធ

ជ) ផ្តោតលើការអនុវត្តរបបស្វ័យប្រកាសធ្វើជាគោលដៅរយៈពេលវែង។[៧១]

រដ្ឋបាលសារពើពន្ធ មានវិសាលភាពគ្របដណ្តប់ទាំងវិស័យសាធារណៈ និងវិស័យឯកជន ក្នុងនោះរួមមាន ក្រសួងសាមីដែលគ្រប់គ្រងចំណូលថវិការដ្ឋ អាជ្ញាធរ ឬ(អគ្គ)នាយកដ្ឋានសវនកម្មឯករាជ្យស្ថាប័នប្រឆាំងអំពើពុករលួយ អង្គការនីតិប្បញ្ញត្តិតតិយជន ដែលទទួលបានបទបញ្ជាឱ្យប្រមូលពន្ធ ដូចជាធនាគារអ្នកកាត់ទុកប្រាក់ពន្ធផ្សេងៗ តុលាការ មជ្ឈនត្តការនគរបាល ក្រុមហ៊ុនបម្រើសេវាបិទបញ្ជីទូទាត់បំណុលពន្ធ និងសហគមន៍អ្នកជាប់ពន្ធ។ ក្នុងករណី អ្នកជាប់ពន្ធមានសុចរិតភាព និងមានចំណេះដឹងគ្រប់គ្រាន់ក្នុងការទូទាត់បំណុលពន្ធនោះ រដ្ឋបាលសារពើពន្ធមានភារកិច្ចធ្វើឱ្យងាយស្រួលក្នុងការបង់ពន្ធដល់អ្នកជាប់ពន្ធ។ ជាទូទៅ ដោយសារតែអ្នកជាប់ពន្ធទាំងអស់ ពុំមែនសុទ្ធតែជាអ្នកសុចរិត និងមិនមានចំណេះដឹងគ្រប់គ្រាន់ក្នុងការបង់ពន្ធ ដូច្នេះរដ្ឋបាលសារពើពន្ធមានគោលដៅចម្បងក្នុងការអប់រំអ្នកជាប់ពន្ធអំពីសារពើពន្ធ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ដើម្បីជួយអ្នកជាប់ពន្ធសុចរិតឱ្យអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ និងជួយជំរុញឱ្យអ្នកគេចវេសពន្ធឱ្យអនុលោមតាមបទ

[៧១] Silvani, carlos, and Katherine baer (1997); designing a tax administration reform strategy: Experience and guidelines: IMF working paper, WP/97/30, Washington, D. C.

ប្បញ្ញត្តិសារពើពន្ធ។ តាមនេះរដ្ឋបាលនៃសារពើពន្ធ មានតួនាទីការកិច្ចទទួលខុសត្រូវក្នុងការអប់រំ និងការផ្តល់នូវពត៌មាន ចំពោះអ្នកជាប់ពន្ធសម្រួល និងបម្រើសេវាជូនអ្នកជាប់ពន្ធ និងជំរុញឱ្យមានការបង់ពន្ធឱ្យរដ្ឋាភិបាលស្របទៅនឹងការកំណត់ដូចមានចែងក្នុងច្បាប់សារពើពន្ធ។ ដូច្នេះ រដ្ឋបាលសារពើពន្ធពុំមែនមាន តួនាទីត្រឹមតែ ការកេណ្ឌប្រមូលចំណូលសារពើពន្ធឱ្យបានច្រើនទៅតាមច្បាប់បានកំណត់នោះទេ ប៉ុន្តែត្រូវអនុវត្តនូវតួនាទីរបស់ខ្លួនដោយមានផលប៉ះពាល់ដល់សង្គមតិចតួចបំផុត។

ភាពស័ក្តិសិទ្ធិនៃរដ្ឋបាលសារពើពន្ធទាមទារឱ្យមានការរៀបចំនូវបរិស្ថានមួយ សម្រាប់ប្រជាពលរដ្ឋដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធដោយស្ម័គ្រចិត្ត។ ចំណែកឯប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធវិញ គឺតម្រូវឱ្យរដ្ឋបាលសារពើពន្ធអនុវត្តការកិច្ចរបស់ខ្លួនដោយមានការចំណាយក្នុងការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ និងផលប៉ះពាល់សង្គមក្នុងកម្រិតអប្បបរមា។[៧២] ប្រព័ន្ធសារពើពន្ធក្នុងពិភពលោកមាននិន្នាការវិវត្តឆ្ពោះទៅរកប្រព័ន្ធស្វ័យប្រកាសតាមរយៈនេះអ្នកជាប់ពន្ធ ជាអ្នកកំណត់ធ្វើនូវរបាយការណ៍អំពីបំណុលពន្ធរបស់ខ្លួន ហើយទូទាត់បំណុលពន្ធនេះឱ្យបានគ្រប់ចំនួនដោយពុំចាំបាច់មានការបង្ខិតបង្ខំពីអាជ្ញាធរសារពើពន្ធ។ របបស្វ័យប្រកាសនេះ អាចនឹងសម្រេចបាននូវការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធបានល្អ កាលណាយន្តការជំរុញឱ្យមានការអនុលោមតាមបទប្បញ្ញត្តិនៃសារពើពន្ធមានដូចជាការផាកពិន័យត្រូវបានអនុវត្តដោយតឹងរឹងហើយអ្នកជាប់ពន្ធមានជំនឿថាករណីមិនអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធនោះប្រាកដជាប្រឈមនឹងការផាកពិន័យដោយចៀសមិនរួច។

៣.២.២-សារសំខាន់រដ្ឋបាលសារពើពន្ធ

(ESSENTIAL OF TAX ADNIMISTRATIVE)

តួនាទីភារកិច្ចរបស់រដ្ឋបាលសារពើពន្ធ មិនមែនផ្តោតតែម្យ៉ាងទៅលើការជំរុញឱ្យមានការអនុ-លោមតាមបទប្បញ្ញត្តិសារពើពន្ធនោះទេ ថែមទាំងផ្តោតទៅលើការអប់រំ និងណែនាំឱ្យប្រជាពលរដ្ឋបំពេញកាតព្វកិច្ចសារពើពន្ធផងដែរ។ មុខងាររបស់រដ្ឋបាលសារពើពន្ធ និងសកម្មភាពរបស់រដ្ឋបាលសារ-ពើពន្ធអាចចែកជា៖

ក. ការចុះបញ្ជីអ្នកជាប់ពន្ធ ក្នុងការធ្វើបច្ចុប្បន្នកម្មនៃបញ្ជីនេះ ដោយកំណត់លេខកូដរបស់អ្នកជាប់ពន្ធ និងតាមដានរាល់អ្នកជាប់ពន្ធ ដែលមិនទាន់ចុះបញ្ជី។

ខ. ការផ្តល់សេវាដល់អ្នកជាប់ពន្ធ ដែលមានការអប់រំអ្នកជាប់ពន្ធ តាមរយៈសិក្ខាសាលា និងការផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗ សម្រួលដល់ការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធដោយស្ម័គ្រចិត្ត និងបែបបទបង់ពន្ធ

គ. ការទូទាត់បំណុលពន្ធនិងការសងពន្ធត្រឡប់ទៅវិញ។

[៧២] Bird Richard M. (2003); Administrative dimension of tax reform; roman school of management, ITP paper 0302, Toronto. P. 10.

ឃ. ការឃ្លាំមើលអ្នកកាត់ទុកពន្ធ និងភ្នាក់ងារប្រមូលពន្ធ ដើម្បីប្រាក់ពន្ធបានបង្វែរមកឱ្យរដ្ឋាភិ-បាលបានគ្រប់ចំនួននិងទៀងទាត់។

ង. ការប្រមូលព័ត៌មាន ទាក់ទងនឹងចម្លងការដែលអាចជាប់ពន្ធ ជាពិសេសអាចពឹងផ្អែកលើប្រភពព័ត៌មាន ដែលអាចស្វែងរកបានពីសំណាក់ភាគីទី៣ ដូចជាគ្រឹះស្ថានហិរញ្ញវត្ថុទី ភ្នាក់ងាររបស់រដ្ឋាភិបាលក្រុមហ៊ុនជើងសារនិងរដ្ឋាភិបាលបរទេសជាដើម។

ច. ប្រតិបត្តិការស្រាវជ្រាវតាមរយៈការជាវនូវព័ត៌មានអំពីប្រភពសំខាន់ៗ ការវិភាគអំពីករណីគេចពន្ធការតាមដានអ្នកជាប់ពន្ធ ស្ថិតក្នុងករណីសង្ស័យ និងការស្រាវជ្រាវរកកស្តុតាងផ្សេងៗ ពាក់ព័ន្ធនឹងបញ្ហាសារពើពន្ធ។

ឆ. វិភាគហានិភ័យ និងការកំណត់មុខសញ្ញា សម្រាប់ធ្វើអធិការកិច្ចសវនកម្មនិងស៊ើបអង្កេត។

ជ. ការតឹងទារបំណុលពន្ធ។

ឈ. ការត្រួតពិនិត្យការបោះពុម្ព និងការប្រើប្រាស់វិក្កយបត្រ សម្រាប់អាករលើតម្លៃបន្ថែម។

ញ. ការងារនីតិកម្ម ដូចជាការរៀបចំសេចក្តីព្រាង ធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិ និងការ ប្តឹងទៅតុលាការជាដើម។[៧៣]

ច្បាប់ និងនយោបាយសារពើពន្ធ គឺជាមូលដ្ឋានសម្រាប់កេណ្ឌប្រមូលបំណុលពន្ធនិងអាករ ប៉ុន្តែចំនួនជាក់ស្តែងនៃពន្ធនិងអាករ ដែលបង់ក្នុងរតនាជាតិរបស់រដ្ឋាភិបាល គឺអាស្រ័យមួយផ្នែកធំទៅនឹងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិរបស់រដ្ឋបាលសារពើពន្ធ។ ជាមួយគ្នានេះ គុណភាពនៃរដ្ឋបាលសារពើពន្ធ ក៏មានឥទ្ធិពលដល់បរិយាកាសវិនិយោគ និងការអភិវឌ្ឍន៍របស់វិស័យឯកជនផងដែរ។[៧៤] សហគ្រាស មានគោលបំណងវិនិយោគមិនត្រឹមតែគិតគូអំពីប្រព័ន្ធ និងគោលនយោបាយសារពើពន្ធតែប៉ុណ្ណោះទេ។ ប៉ុន្តែក៏ផ្តោតការយកចិត្តទុកដាក់ដល់ដំណើរប្រព្រឹត្តទៅរបស់ប្រព័ន្ធ និងគោលនយោបាយសារពើពន្ធដែរ។ រដ្ឋបាលសារពើពន្ធដែលខ្វះគណនេយ្យភាព និងខ្វះតម្លាភាពអាចបង្អាក់ទឹកចិត្តដល់វិនិយោគ។ កង្វះសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធ ក្នុងការជំរុញការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធធ្វើឱ្យក្រុមហ៊ុនដែលគោរពច្បាប់គ្មានឧត្តមភាពប្រកួតប្រជែង ជាមួយក្រុមហ៊ុនដែលមានឱកាសចៀសវាង ឬគេចវេសកាតព្វកិច្ចពន្ធ ក្នុងនោះជាពិសេសក្រុមហ៊ុនដែលធ្វើប្រតិបត្តិការវិស័យក្រៅប្រព័ន្ធ។ តាមរយៈនេះក្រុមហ៊ុនអាចរារែកក្នុងការចូលរួមក្នុងវិស័យក្នុងប្រព័ន្ធ។ លោក Fieldsted បានបកស្រាយថា រដ្ឋ-បាលសារពើពន្ធគឺជាស្ថាប័នសាធារណៈមួយដែលងាយនឹងប្រឈមអំពើពុករលួយផ្សេងៗ អាចនឹងប៉ះពាល់ដល់ចំណូលរដ្ឋាភិបាលបង្កការលំបាកដល់អ្នកជាប់ពន្ធ និងជំរុញឱ្យមាន

[៧៣] Jit B. S. Gill (2000); A Diagnostic framework for revenue administration; word techhical paper No. 472, the world bank, Washington, D. C.

[៧៤] The world Bank (2005); world development report 2005: A Batter investment climate for everyone: Washington D.C. p. 106-111.

ឥរិយាបថមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ។[៧៥] ជាសូចនាករសំខាន់ៗមួយចំនួនត្រូវបានជ្រើសរើសមកបង្ហាញដូចខាងក្រោម៖[៧៦]

១. ចំណូលសារពើពន្ធសរុបដោយធៀបនឹងផលិតផលក្នុងស្រុកសរុប គឺជាសូចនាករតំណាងឱ្យសម្ភាធសារពើពន្ធ។ ក្នុងករណីសេដ្ឋកិច្ចមានកម្រិតអភិវឌ្ឍប្រហាក់ប្រហែលគ្នា និងរចនាសម្ព័ន្ធសារពើពន្ធដូចគ្នានោះ សូចនាករនេះអាចត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបអំពីកម្រិតនៃភាពស័ក្តិសិទ្ធិរបស់រដ្ឋបាលសារពើពន្ធរវាងប្រទេសនីមួយៗ។ ការវាយតម្លៃសូចនាករនេះ គេគួរគប្បីមានការប្រុងប្រយ័ត្នផងដែរ ពីព្រោះការកេណ្ឌប្រមូលចំណូលសារពើពន្ធនៅតាមប្រ-ទេសនីមួយៗ គឺអាចអាស្រ័យទៅនឹងកម្រិតនៃការចំណាយ និងលទ្ធភាពដែលអាចស្វែងរក មូលនិធិបានពីប្រភពផ្សេងទៀត ក្រៅពីចំណូលសារពើពន្ធ។ ក្រៅពីនេះ ចំណែកដ៏ធំក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងសេដ្ឋកិច្ចនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ អាចធ្វើឱ្យទិន្នន័យស្តីពីផលិតផលក្នុងស្រុកសរុបមានលក្ខណៈមិនសូវច្បាស់លាស់ទេ។ ទោះបីយ៉ាងណា ទិន្នន័យសេរីសម្រាប់ រយៈពេលវែងស្តីពីផលធៀបរវាងចំណូលសារពើពន្ធ និងផលិតផលក្នុងស្រុកសរុប ដោយសារតែមានការកែតម្រូវជាមួយនឹងការប្រែប្រួលនៃអត្រាពន្ធ និងមូលដ្ឋានសារពើពន្ធអាចជាសូចនាករមួយដ៏សំខាន់សម្រាប់កំណត់ពីការវិវត្តន៍នៃស័ក្តិសិទ្ធិរបស់រដ្ឋបាលសារពើពន្ធ។

២. ចំណូលសារពើពន្ធជាក់ស្តែង ធៀបទៅចំណូលសារពើពន្ធប៉ាន់ស្មាន ក្នុងផែនការថវិកាជាតិ គឺជាសូចនាករមួយបានបង្ហាញពីសមត្ថភាពនៃរដ្ឋបាលសារពើពន្ធ ការសម្រេចបានតាមគោលដៅចំណូលសារពើពន្ធដែលបានកំណត់នៅក្នុងផែនការថវិកាជាតិ។

៣. គម្លាតចំណូលសារពើពន្ធ គឺជាសូចនាករមួយបានបង្ហាញអំពីសក្តានុពលនៃចំណូលសារពើពន្ធដែលត្រូវបានប្រមូលក្នុងក្របខណ្ឌនយោបាយសារពើពន្ធបច្ចុប្បន្ន ដោយប្រៀបធៀបនឹងលទ្ធផលជាក់ស្តែង និងការកៀរគរប្រមូលចំណូលសារពើពន្ធ។ គម្លាតនេះ គឺជាការបាត់បង់ចំណូលសារពើពន្ធ ដែលអាចបណ្តាលមកពីការមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ នឹងការគេចវេសកាតព្វកិច្ចពន្ធឆ្លុះបញ្ចាំងពីភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពរដ្ឋបាលសារពើពន្ធ។

៤. ចំណូលប្រាក់ពន្ធដែលត្រូវបានបង់ដោយស្ម័គ្រចិត្តធៀបនឹងចំណូលប្រាក់ពន្ធសរុបត្រូវបានប្រ-មូល គឺសូចនាករមួយបានបង្ហាញឱ្យឃើញអំពីកម្រិតនៃជោគជ័យរបស់រដ្ឋបាលសារពើពន្ធ ក្នុងការសម្រួលដល់អ្នកជាប់ពន្ធដោយស្ម័គ្រចិត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធ ដើម្បី

[៧៥] Odd-helge fjeldstad (2005); corruption in tax administration: lessons from institutional reform in Uganda; CMF working paper, WP 2005: 10, Norway

[៧៦] OEDC (2009); Tax administration in EODC and selected Non-OEDC countries: comparative information series (2008); prepared by the forum on Tax administration, centre for Tax policy and administration.

ជួយជំរុញឱ្យអ្នកជាប់ពន្ធចូលរួមមកបង់ពន្ធដើម្បីចៀសវាងការផាកពិន័យ ដោយគ្មានការលើកលែងក្នុងករណីដែលអ្នកជាប់ពន្ធគេចវេសកាតព្វកិច្ចពន្ធ។

៥.ចំណូលសារពើពន្ធ បានត្រូវប្រមូលបន្ថែមធៀបនឹងចំណូលស្វ័យប្រកាសប្រាក់ពន្ធដែលត្រូវបានធ្វើសវនកម្ម បង្ហាញពីកម្រិតជោគជ័យរបស់រដ្ឋបាលសារពើពន្ធនៅក្នុងការតាមដាននូវការលាក់កំបាំងបំណុលពន្ធ។

៦.ការប្រមូលប្រាក់ពន្ធពុំទាន់បានទូទាត់ធៀបនឹងប្រាក់ពន្ធដែលបានទូទាត់ឆ្លុះបញ្ចាំងអំពីសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធ ក្នុងការតឹងទារបំណុលពន្ធ។

៧.ការចំណាយក្នុងការប្រមូលចំណូលសារពើពន្ធ គឺជាផលធៀបក្នុងការចំណាយថវិកាជាតិជាប្រចាំ ចំពោះរដ្ឋបាលសារពើពន្ធ និងការប្រមូលចំណូលសារពើពន្ធសរុប។ សូចនាករនេះបានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធក្នុងការប្រើប្រាស់ធនធានរបស់ខ្លួនសម្រាប់ប្រមូលចំណូលសារពើពន្ធ។

៨.ការយល់ឃើញរបស់អ្នកជាប់ពន្ធ ជាលទ្ធផលនៃការអង្កេតជាប្រចាំស្តីពីសុចរិតភាព ភាពជឿទុកចិត្តបាន ភាពត្រឹមត្រូវ ការជួយសម្រួល និងប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធ។
សូចនាករនេះ មានសារសំខាន់ក្នុងការផ្តល់ព័ត៌មាន ដល់ការកែទម្រង់រដ្ឋបាលសារពើពន្ធ។

ជំពូកទី ៤
រចនាសម្ព័ន្ធនៃសារពើពន្ធ
STRUCTURAL OF FISCAL

៤.១-រចនាសម្ព័ន្ធនៃសារពើពន្ធ(STRUCTURAL OF FISCAL)

៤.១.១-លក្ខណៈនៃសារពើពន្ធ(CHARACTERISTICS OF FISCAL)

រដ្ឋាភិបាលទាំងឡាយ តែងតែប្រើប្រាស់ប្រព័ន្ធសារពើពន្ធ ដើម្បីកេណ្ឌប្រមូលចំណូលសម្រាប់ធ្វើ ហិរញ្ញប្បទានដល់ការចំណាយរបស់ខ្លួនដែលមានចំណែកពី ១០ភាគរយ ទៅដល់ ៤០ភាគរយ នៃផលិ-តផលក្នុងស្រុកសរុប។ ជាទូទៅ ចំណែកចំណាយថវិការបស់រដ្ឋាភិបាលនៃផលិតផលក្នុងស្រុក សរុប មាននិន្នាការកើនឡើងជាមួយនឹងកំណើនប្រាក់ចំណូលសម្រាប់បុគ្គលម្នាក់ៗ។ ដូច្នេះ ការ ចំណាយថវិ-ការបស់រដ្ឋាភិបាល គឺទំហំដ៏ធំធេងដែលធ្វើឱ្យការយកពន្ធនិងអាករ គឺជាកម្មវត្ថុដ៏សំខាន់ បំផុតនៃសកម្មភាពរបស់រដ្ឋាភិបាល។ ជាប្រវត្តិសាស្ត្រ រដ្ឋាភិបាលពឹងផ្អែកជាចម្បងលើធនធានពីរ ប្រភេទ ដើម្បីប្រមូលធនធានពីមនុស្សក្នុងសង្គមដែលខ្លួនបានត្រួតត្រា ដើម្បីគោលដៅលើការចំណាយ របស់រដ្ឋាភិបាល និងកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការចំណាយលើប្រាក់បៀវត្សមន្ត្រីរាជការដែល បម្រើការងារក្នុងវិស័-យសេវាសាធារណៈ វិស័យយោធា និងព្រមទាំងចំណាយផ្សេងៗជាច្រើនប្រភេទ ទៀត ដែលមានលក្ខណៈចំណាយចរន្ត និងលក្ខណៈចំណាយមូលធន។ លោក Mick បានបង្ហាញពី ប្រភពមួយចំនួនជាសារសំខាន់នៃប្រព័ន្ធសារពើពន្ធដែលមានការវិវត្តតាមដំណាក់កាលផ្សេងៗគ្នាជាប្រវ ត្តិសាស្ត្រ។

១. ការផ្តល់អាជ្ញាប័ណ្ណ(ដូចជាការផ្ទេរមរតក និងការលក់អចលនទ្រព្យ) អាជីវកម្មខ្នាតតូច ការធ្វើ អាជីវកម្មព្រៃឈើ ការប្រើប្រាស់ប្រព័ន្ធតុលាការ និងការបញ្ជាក់ជាផ្លូវការលើលិខិតស្នាមផ្សេងៗ ការផ្តល់នូវគោរម្យងារ (ដូចជាស្តេចក្រាញ់ ឬឧកញ៉ាជាដើម) និងការផ្តល់តួនាទីនៅក្នុងវិស័យ ស៊ីវិល និងយោធា។ បច្ចុប្បន្ននេះ ចំណូលពន្ធប្រភពនេះភាគច្រើន បានបាត់បង់ចំណុចសំ-ខាន់របស់ខ្លួនជាបន្តបន្ទាប់ក្នុងចំណូលថវិកាជាតិ។ ប៉ុន្តែពន្ធប្រថាប់ត្រា និងកម្រៃជើងសារដែ-លបានមកពីការផ្តល់អាជ្ញាប័ណ្ណ នៅតែជាប្រភពចំណូលដ៏សំខាន់សម្រាប់ថវិកាជាតិដដែល។

២. ចំណូលលាភការពីការបោះពុម្ពប្រាក់ ដែលរដ្ឋាភិបាលទទួលបានភាពផ្តាច់មុខរបស់ខ្លួនក្នុង ការចេញផ្សាយរូបិយវត្ថុ។ ជាគោលការណ៍ទូទៅ រូបិយវត្ថុតំណាងឱ្យឥណទេយ្យ ឬសិទ្ធទា យកចំពោះអ្នកចេញផ្សាយ។ ក៏ប៉ុន្តែ ជាក់ស្តែងមួយផ្នែកធំនៃឥណទេយ្យនេះមិនត្រូវបានអនុវត្ត ពិតប្រាកដ។ ករណីខ្លះរដ្ឋាភិបាលបានផ្សាយចេញក្រដាសប្រាក់លើសពីសេចក្តីត្រូវការក្នុងសេដ្ឋ កិច្ច ដើម្បីបានចំណេញលាភការពីការបោះពុម្ពប្រាក់ ឬដើម្បីបំពេញហិរញ្ញប្បទានដល់ឱ នភាពថវិកាជាតិក្នុងរយៈពេលខ្លី ដែលបណ្តាលឱ្យមានអតិផរណាក្នុងកម្រិតមួយដែលមិនអាច គ្រប់គ្រងបាន។ រយៈពេលជាង៣ទសវត្សរ៍ចុងក្រោយនេះ រដ្ឋាភិបាលភាគច្រើនបានប្តេជ្ញាអនុ វត្តនូវគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ក្នុងគោលបំណងធានាឱ្យបានស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ចសម្រាប់រយៈពេលវែង។ ដូច្នេះ លាភការបានមកពីការបោះពុម្ពផ្សាយក្រដាកប្រាក់ លែងមានសារសំខាន់សម្រាប់ជើរតួនាទីធ្វើជាប្រភពចំណូលថវិកាជាតិទៀតហើយ។

៣.ចំណូលរដ្ឋាភិបាលទទួលបានពីសិទ្ធិផ្តាច់មុខ ក្នុងការគ្រប់គ្រងផលិតកម្ម និងការជួញដូរ ទំនិញប្រើប្រាស់មួយចំនួន មានដូចជា អំបិល ស្រា និងបារី ជាដើម។ ប្រភពចំណូលប្រភេទ នេះ មានកម្រិតកាន់តែស្តួចស្តើងធៀបទៅនឹងប្រភពចំណូលផ្សេងទៀត ជាមួយនឹងការ អភិវឌ្ឍន៍សេដ្ឋ-កិច្ច និងបើកចំហរសេដ្ឋកិច្ច។

៤.ចំណូលពីទ្រព្យសម្បត្តិរបស់រដ្ឋ ជាពិសេសការផ្តល់ដីសម្បទានសង្គមកិច្ចដល់វិស័យកសិកម្ម និងឧស្សាហកម្ម ដូចជាចំណូលសហគ្រាសសាធារណៈក្នុងការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត អាជីវកម្មកំពង់ផែ ការដឹកជញ្ជូនតាមផ្លូវរថភ្លើង ការបម្រើសេវាប្រៃសណីយ៍ និងទូរគមនាគមន៍ជាដើម។ រហូតដល់ពេលបច្ចុប្បន្នប្រភពចំណូលនេះ បានថយចុះយ៉ាងឆាប់រហ័សតាមរយៈឯកជនភាវូប-នីយកម្ម។

៥.ចំណូលពីការគ្រប់គ្រងការនាំចេញកសិផលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដូចជាកាកាវ កាហ្វេ តែ កប្បាស និងស្ករជាដើម។ ប្រភពចំណូលនេះ បានថយចុះសារសំខាន់របស់ខ្លួន តាមរយៈ ការផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីលើកស្ទួយការនាំចេញផលិតផលកសិកម្ម។

៦.ចំណូលរដ្ឋាភិបាល បានកេណ្ឌប្រមូលតាមរយៈពន្ធនិងអាករ គឺកម្មសិទ្ធិរបស់រដ្ឋដូចជាសួយសារ និងកម្រៃជើងសារផ្សេងៗ ព្រមទាំងការធ្វើអាជីវកម្មលើប្រេងឥន្ធនៈ ឧស្ម័ន និងរ៉ែផ្សេងៗ។ ប្រទេសដែលខ្សត់ធនធានរ៉ែមួយចំនួនដូចជា តៃវ៉ាន់ ជប៉ុន កូរ៉េខាងត្បូង និងសឹង្ហបុរីជាដើម។ បានខិតខំអភិវឌ្ឍសមត្ថភាពខ្លួន បានប្រកបដោយជោគជ័យក្នុងការផលិតនាំចេញទំនិញ និងសេវាកម្ម មានលក្ខណៈប្រកួតប្រជែងលើទីផ្សារអន្តរជាតិ តាមរយៈនេះអាចពង្រីកបានសក្តានុ-ពលចំណូលពន្ធបានយ៉ាងឆាប់រហ័ស។

៧.ចំណូលទទួលបានពីហិរញ្ញប្បទានសហប្រតិបត្តិការ និងឧបត្ថម្ភធនផ្សេងៗទៀតពីសំណាក់បណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មានប្រាក់ចំណូលទាប ដែលចំណូលប្រភេទនេះកំពុងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើហិរញ្ញ-ប្បទានដល់ការចំណាយសម្រាប់ការអនុវត្តន៍គម្រោងអភិវឌ្ឍសំខាន់ៗរបស់ខ្លួន។

៨.ការយកពន្ធដ៏ទូលំទូលាយពីប្រជាពលរដ្ឋ និងសហគ្រាស ជាពិសេសពន្ធលើប្រាក់ចំណូល ពន្ធលើការកាន់កាប់កម្មសិទ្ធិករ ពន្ធលើមូលធន ពន្ធលើប្រាក់បៀវត្ស ពន្ធលើពាណិជ្ជកម្ម អន្តរជាតិ ពន្ធលើការស្នាក់នៅ ពន្ធលើការផ្ទេរមរតក និងអាករលើផលរបរ អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន។ ពន្ធនិងអាកប្រភេទនេះ គឺជាប្រភពចំណូលដ៏ចម្បងជាងគេសម្រាប់រដ្ឋាភិបាលភាគច្រើន លើកលែងរដ្ឋាភិបាលមួយចំនួនតូចដៃ

លពឹងផ្អែកលើប្រភពចំណូលពីការនាំចេញធនធានធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់ ឬពីជំនួយអន្តរជាតិជាដើម។

៤.១.២-ចំណាត់ថ្នាក់នៃសារពើពន្ធ(CLASSIFICATION OF FISCAL)

ប្រព័ន្ធនៃសារពើពន្ធ បានរៀបចំចំណាត់ថ្នាក់ទៅតាមគោលការណ៍ផ្សេងៗ៖

គោលការណ៍ទី១៖ មូលដ្ឋានពន្ធនិងអាករ

ក) ប្រាក់ចំណូល ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណេញជាដើម។

ខ) ចំណូលមូលធន ត្រូវជាប់ពន្ធលើប្រាក់ចំណេញពីមូលធន កើតមានឡើងតាមរយៈការជួញដូរមូលបត្រ និងការប្រាក់ និងពន្ធលើការផ្ទេរមរតកជាដើម។

គ) ការប្រើប្រាស់ ត្រូវជាប់ពន្ធតាមរយៈការនូវទិញទំនិញនិងសេវា ដើម្បីប្រើប្រាស់ផ្សេងៗ ដូចជាពន្ធគយ អាករលើតម្លៃបន្ថែម និងអាករពិសេសលើទំនិញនិងសេវាមួយចំនួនជាដើម។

គោលការណ៍ទី២៖ ពន្ធផ្ទាល់និងពន្ធប្រយោល

ពន្ធផ្ទាល់ គឺបានកំណត់យកដោយផ្ទាល់ចំពោះបុគ្គលដែលត្រូវជាប់ពន្ធ។ រីឯពន្ធប្រយោលជាបន្ទុករបស់អ្នកជាប់ពន្ធលើបុគ្គល ឬអង្គភាពផ្សេងទៀតខុសពីបុគ្គល ឬអង្គភាពដែលជាប់ពន្ធនិងអាករ បានប្រមូលពីអ្នកជាប់បំណុលពន្ធនិងអាករ ដោយបុគ្គលឬអង្គភាពនោះដែលមានកាតព្វកិច្ចត្រូវបង្វែរប្រាក់ពន្ធ និងអាករទៅឱ្យរដ្ឋបាលពន្ធ។

ពន្ធផ្ទាល់បានចែកចេញជា៖

ក) ពន្ធលើប្រាក់ចំណូល

ខ) ពន្ធលើប្រាក់ចំណេញរបស់សហគ្រាស

គ) ពន្ធលើប្រាក់ចំណេញពីមូលធន

ឃ) ពន្ធលើការផ្ទេរមរតក។

ចំពោះពន្ធប្រយោលមានដូចជា អាករលើតម្លៃបន្ថែម និងអាករលើផលរបរ ពន្ធគយ និងអាកពិសេសលើទំនិញ និងសេវាមួយចំនួនជាដើម។

គោលការណ៍ទី៣៖ គិតតាមបរិមាណនិងគិតជាភាគ

ដោយគិតតាមបរិមាណប្រាក់ពន្ធ បានកំណត់ជាទឹកប្រាក់ ក្នុងចំនួនមួយជាក់លាក់លើមូលដ្ឋាននៃបរិមាណទំនិញដែលត្រូវជាប់ពន្ធ។ ឧទាហរណ៍ដូចជា ពន្ធលើថ្នាំជក់ ឬផលិតផលគេលសិលា ត្រូវកំណត់យកទៅតាមទម្ងន់ទំនិញទាំងនោះ។ ពន្ធគិតជាភាគរយ បានកំណត់ជាភាគរយនៃតម្លៃ ឬកម្រិតនៃមូលដ្ឋានពន្ធ ដូចជាពន្ធលើប្រាក់ចំណូល ត្រូវជាប់បន្ទុកពន្ធក្នុងអត្រាចន្លោះពី ១០ភាគរយ ទៅដល់ ៤០ភាគរយ អាស្រ័យទៅនឹងកម្រិត និងប្រភេទនៃប្រាក់ចំណូល។

គោលការណ៍ទី៤៖ ការបែងចែកបន្ទុកពន្ធតាមរយៈអត្រាពន្ធ

ក) ការកើនឡើងតាមកំណើននៃមូលដ្ឋានពន្ធធ្វើឱ្យអត្រាពន្ធម៉ាហ្សីណាល់មានកម្រិតខ្ពស់ជាងអត្រាពន្ធមធ្យម

ខ) សមាមាត្រ ពោលគឺមានចំណែកមួយថេរនៃកម្រិតមូលដ្ឋានពន្ធ ហើយធ្វើឱ្យអត្រាពន្ធមធ្យមមានកម្រិតខ្ពស់ជាងអត្រាពន្ធម៉ាហ្សីណាល់។ គួរបញ្ជាក់ថាអត្រាពន្ធម៉ាហ្សីណាល់ គឺជាផលធៀបរវាងការប្រែប្រួលនៃប្រាក់ពន្ធ និង ការប្រែប្រួលនៃប្រាក់ចំណូល ហើយអត្រាពន្ធមធ្យមគឺជាផលធៀបរវាងប្រាក់ពន្ធសរុប និងប្រាក់ចំណូលសរុប។

អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (OECD) បានបង្កើតបទដ្ឋានដ៏ច្បាស់លាស់មួយនៅក្នុងការរៀបចំចំណាត់ថ្នាក់ពន្ធនិងអាករ ដោយបានបែងចែកប្រភេទពន្ធនិងអាករ ជាក្រុមធំៗចំនួន ៦ប្រភេទគឺ៖

១) ពន្ធលើប្រាក់ចំណូល(ប្រាក់ចំណេញ) និងប្រាក់ចំណេញពីមូលធន

២) វិភាគទានពន្ធលើសុវត្ថិភាពសង្គមកិច្ច

៣) ពន្ធលើប្រាក់បៀវត្ស ពន្ធប្រាក់ចំណូលពីកម្លាំងពលកម្ម និងពន្ធលើទ្រព្យសម្បត្តិ

៤) ពន្ធលើទំនិញនិងសេវា (ដូចជាអាកររលើតម្លៃបន្ថែម និងអាករពិសេសជាដើម)

៥) ពន្ធលើការប្រើប្រាស់ទំនិញឬពន្ធលើការអនុញ្ញាតឱ្យប្រើប្រាស់ទំនិញឬពន្ធលើការអនុញ្ញាតឱ្យធ្វើសកម្មភាព

៦) ពន្ធនិងអាកររផ្សេងៗ។

ចំណែកឯមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានរៀបចំចំណាត់ថ្នាក់ពន្ធនិងអាករ ស្រដៀងគ្នានឹងបទដ្ឋានរបស់អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច(OECD)ផងដែរ។

សមាសភាពសារពើពន្ធ គឺកត្តាមួយយ៉ាងសំខាន់នៃការរៀបចំនូវគោលនយោបាយសារពើពន្ធ។

ទី១-បញ្ហាតុល្យភាពរវាងពន្ធលើការប្រើប្រាស់ ដូចជាអាកររលើតម្លៃបន្ថែម និងអាករពិសេស មានមូលដ្ឋានទូលំទូលាយ និងពន្ធលើប្រាក់ចំណូលលើកម្លាំងពលកម្ម និងមូលធន។ នេះបទពិសោធន៍តាមបណ្តាប្រទេសអភិវឌ្ឍន៍ បានបង្ហាញថាប្រទេសដែលពឹងផ្អែកលើចំណូលពន្ធលើការប្រើប្រាស់មាននិន្នាការសន្សំបានច្រើនជាង និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាង ប្រទេសដែលពឹងផ្អែកលើចំណូលពន្ធប្រភេទផ្សេង។ ចំពោះពន្ធលើប្រាក់ចំណូលបុគ្គល ទោះបីជាអាចផ្តល់នូវលទ្ធភាពចំគោលដៅបានល្អជាងក្នុងការអនុវត្តន៍ប្រព័ន្ធនៃសារពើពន្ធមួយដែលមានសមធម៌ក៏ដោយ។ ក៏ប៉ុន្តែ ប្រភេទពន្ធលើការប្រើប្រាស់ អាចជាវិធីមួយស័ក្តិសិទ្ធិច្រើនជាងក្នុងការជួយដល់អ្នកជាប់ពន្ធដែលពុំសូវមានសមត្ថភាពក្នុងការបង់ពន្ធ។

ទី២-ការពឹងផ្អែកលើចំណូលពន្ធគយធៀបទៅនឹងចំណូលពន្ធលើការប្រើប្រាស់ក្នុងស្រុកមាននិន្នាការថយចុះជាលំដាប់។

ទី៣-ការពឹងផ្អែកកាន់តែខ្លាំងលើពន្ធប្រយោល ជាពិសេសអាកររលើតម្លៃបន្ថែម និងការកាត់បន្ថយការពឹងផ្អែកលើពន្ធលើពាណិជ្ជកម្មអន្តរជាតិ។

ជាទូទៅ រចនាសម្ព័ន្ធសារពើពន្ធមាននិន្នាការវិវត្តទៅតាមលក្ខណៈដូចតទៅ៖

ក) បណ្តាប្រទេសនានា បានកាត់អត្រាពន្ធលើប្រាក់ចំណូលលើបុគ្គលមួយផ្នែកនៅក្នុងគោលបំណងដើម្បីកែលម្អបរិយាកាសទីផ្សារពលកម្មឱ្យមានលក្ខណៈអនុគ្រោះពន្ធ និងមួយផ្នែកទៀតជាលទ្ធ

ផលកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលមូលធន ដើម្បីឆ្លើយតបទៅនឹងសម្ពាធសកលភាវូបនីយកម្ម។ បើតាមរយៈអត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុតនៃប្រាក់ចំណូលលើបុគ្គល ត្រូវបានបញ្ចុះក្នុងកម្រិតមួយគួរឱ្យគត់សម្គាល់។ ប៉ុន្តែជាមួយគ្នានេះ ចំណែកជាភាគរយនៃចំណូលពីពន្ធលើប្រាក់ចំណូលបុគ្គលធៀបទៅនឹងផលិតផលក្នុងស្រុកសរុបតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានកើនឡើង។ ផ្ទុយទៅវិញ ពន្ធលើប្រាក់ចំណូលបុគ្គល ត្រូវបានថយចុះនៅតាមបណ្តាប្រទេសជាសមាជិកនៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចទ្វីបអឺរ៉ុប។ នៅក្នុងតំបន់អឺរ៉ុបកណ្តាល និងបាល់ទិច ដោយសារតែផលវិបាកនៃការបន្ទាបអត្រាពន្ធលើប្រាក់ចំណូលសហគ្រាស ធ្វើឱ្យមានការរំលែកមូលដ្ឋានពន្ធលើប្រាក់ចំណូលបុគ្គលទៅជាពន្ធលើប្រាក់ចំណូលសហគ្រាសវិញ។

នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រចនាសម្ព័ន្ធនៃអត្រាពន្ធលើប្រាក់ចំណូលបុគ្គលបានរៀបចំសម្រាប់បម្រើឱ្យគោលដៅនយោបាយសំដៅធានាឱ្យបាននូវសមធម៌សង្គម និងការទទួលបាននូវការគាំទ្រខាងផ្នែកនយោបាយ។ មូលដ្ឋាននេះ ភាគរយនៃប្រាក់ចំណូលប្រចាំឆ្នាំ គឺមានចំនួនច្រើនតាមលំដាប់ថ្នាក់ និងកម្រិតប្រាក់ចំណូលដែលត្រូវជាប់អត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុត គឺនៅមានចំនួនកម្រិតទាបបើសិនប្រៀបធៀបទៅនឹងប្រទេសអភិវឌ្ឍន៍។

យោងតាមការស្រាវជ្រាវរបស់លោក Vito និងលោក Howell ប្រសិទ្ធភាពនៃការអនុវត្តអត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុត គឺនៅមានកម្រិតទាបដោយសារប្រព័ន្ធសារពើពន្ធ បានផ្តល់នូវលទ្ធភាពឱ្យមានការកាត់កងជាច្រើនចេញពីមូលដ្ឋានបង់ពន្ធព្រមទាំងការកំណត់អត្រាពន្ធទាប ចំពោះប្រាក់ចំណូលលើទ្រព្យសកម្មហិរញ្ញវត្ថុ។

ម៉្យាងទៀត ភាគរយនៃប្រាក់ចំណូលបុគ្គលប្រចាំឆ្នាំតាមប្រទេសកំពុងអភិវឌ្ឍន៍ គឺមានកម្រិតខ្ពស់រាប់សិបដង បើធៀបទៅនឹងប្រាក់ចំណូលគិតជាមធ្យមភាគសម្រាប់ម្នាក់ៗដែលធ្វើឱ្យករណីជាប់ពន្ធលើប្រាក់ចំណូលបុគ្គលក្នុងអត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុតមានចំនួនតិចតួច។ នៅតាមបណ្តាប្រទេសជាច្រើន ប្រព្រឹត្តកម្មសារពើពន្ធសម្រាប់ប្រាក់ចំណូលក្នុងវិស័យហិរញ្ញវត្ថុនៅជួបការលំបាក ដោយសារតែលក្ខណៈពិសេសនៃឧស្សាហកម្មហិរញ្ញវត្ថុ។ ជាឧទាហរណ៍ ការប្រាក់ត្រូវជាប់ពន្ធកាត់ទុកក្នុងអត្រាមួយដ៏ទាប បើសិនធៀបនឹងអត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុតសម្រាប់ប្រាក់ចំណូលលើបុគ្គល និងប្រាក់ចំណូលសហគ្រាស ចំណែកពន្ធលើការបែងភាគលាភច្រើនតែជាប់បន្ទុកពន្ធស្ងួនទៀតផង។

ខ) អត្រាពន្ធលើប្រាក់ចំណូលសហគ្រាសមាននិន្នាការធ្លាក់ចុះក្នុងកម្រិតសាកលក្នុងរយៈកាលជាងមួយទសវត្សរ៍ចុងក្រោយ។ ទោះបីជាការកាត់បន្ថយអត្រាពន្ធនេះ មានសន្ទុះមិនស្មើគ្នានៅតាមតំបន់នៅតាមប្រទេសផ្សេងៗគ្នាក៏ដោយ។ នៅតាមបណ្តាប្រទេសជាសមាជិកអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនៅអឺរ៉ុប អត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុត សម្រាប់ចំណូលលើសហគ្រាសនៅក្នុងឆ្នាំ២០០៩ នៅប្រទេសអៀឡង់ដ៍មានកម្រិតស្មើនឹង ១២.៥ភាគរយ នៅប្រទេសជប៉ុន និងសហរដ្ឋអាម៉េរិក អត្រាពន្ធនេះដែលមានកម្រិតស្មើនឹង ៤០ភាគរយ នៅប្រទេសបារាំង ៣៣ ភាគរយ។ល។ ការកាត់បន្ថយអត្រាពន្ធនេះ បានធ្វើឡើងជាមួយនឹងការពង្រីកមូលដ្ឋានពន្ធតាមរយៈការរឹតបន្តឹងចំពោះការកាត់កងការចំណាយ ដូចជាការកាត់កងនូវការខាតបង់ និងការកាត់បន្ថយនូវការចំណាយការប្រាក់

ជាដើម ព្រមទាំងការលើកលែងពន្ធមួយចំនួន តាមរយៈនេះការរំលែកពីមូលដ្ឋានពន្ធលើប្រាក់ចំណូលសហគ្រាសបានកើនឡើង។ ក្រៅពីនេះ ការរំលែកពីមូលដ្ឋានអ្នកជាប់ពន្ធពីមូលដ្ឋានពន្ធលើប្រាក់ចំណូលបុគ្គលមកមូលដ្ឋានពន្ធលើប្រាក់ចំណូលសហគ្រាសវិញ ព្រមទាំងការកែដុះដាលនៃវិស័យឯកជនចូលវិស័យក្នុងប្រព័ន្ធវិញ។ ជាពិសេសផ្នែកសេវាកម្ម និងរកប្រាក់ចំណេញឱ្យបានប្រសើរជាងមុន របស់វិស័យហិរ-ញ្ញវត្ថុ គឺកត្តារួមផ្សំយ៉ាងសំខាន់ក្នុងការបង្កើននូវលទ្ធភាពបន្ថែមចំណូលពន្ធលើប្រាក់ចំណូលសហគ្រាស។ នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន មូលដ្ឋានគិតពន្ធលើប្រាក់ចំណូលសហគ្រាសបានគិតជាមធ្យមភាគប្រមាណ ១៥ភាគរយ នៃចំណូលសារពើពន្ធសរុបបានរួមចុះទន្ទឹមគ្នានឹងការបន្ទាបអត្រាពន្ធប្រភេទនេះ។ បើតាមរយៈចំណូលពន្ធលើប្រាក់ចំណូលសហគ្រាសបានថយចុះ(បន្ទាប់ពីការកើនឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដែលសេដ្ឋកិច្ចតាមប្រទេសភាគច្រើនបានកើនឡើងគួរឱ្យកត់សម្គាល់) ដោយសារកំណើតតំបន់ពាណិជ្ជកម្មសេរី និងការលើកទឹកចិត្តសារពើពន្ធ។ ចំពោះប្រទេសមានការនាំចេញប្រេងឥន្ធនៈ មានលទ្ធភាពធ្វើអាជីវកម្មលើធនធានធម្មជាតិ ចំណូលពន្ធលើប្រាក់ចំណូលសហគ្រា-សមាននិន្នាការកើនឡើងជាលំដាប់។ គួរបញ្ជាក់ថា ទិដ្ឋភាពសារពើពន្ធក្នុងការសម្រេចចិត្តរបស់សហ គ្រាសវិនិយោគ គឺមិនចំណុះឱ្យតែម៉្យាងនឹងអត្រាពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឡើយ ក៏ប៉ុន្តែរបៀបកំណត់មូលដ្ឋានពន្ធក៏មានសារសំខាន់ណាស់ដែរ។ មូលដ្ឋានពន្ធលើប្រាក់ចំណូលសហគ្រាស ត្រូវបានកំណត់ខុសៗគ្នាទៅតាមរបបសារពើរបស់ប្រទេសនានា។ ដូច្នេះ អត្រាពន្ធតែម៉្យាងពុំមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទាក់ទាញការវិនិយោគនោះទេ។ មូលដ្ឋានគិតពន្ធលើប្រាក់ចំណូលសហគ្រាស អាចប្រែប្រួលអាស្រ័យនឹងរបៀបការកំណត់សុំវិធានធនសម្រាប់ការលើកទឹកចិត្តសារពើពន្ធផ្សេងៗគ្នា សម្រាប់វិនិ-យោគវិធីសាស្ត្រនៃការវាយតម្លៃសន្និធិទំនិញ និងការកម្រិតពន្ធ ចំពោះលំហូរទំនិញឆ្លងកាត់ព្រំប្រទល់ប្រទេសជាដើម។

គ) រយៈកាលជាង ២ទសវត្សរ៍កន្លងមកនេះ រចនាសម្ព័ន្ធសារពើពន្ធ បានវិវឌ្ឍតាមរយៈកំណើនចំណូលសារពើពន្ធដែលពឹងផ្អែកលើការចំណាយប្រើប្រាស់ដែលគេហៅថា"ពន្ធប្រយោល" ជាពិសេសតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ ការពឹងផ្អែកកាន់តែខ្លាំងទៅនឹងចំណូលពន្ធប្រយោលនេះ គឺជាលទ្ធផលថយចុះនូវចំណូលពន្ធលើពាណិជ្ជកម្មអន្តរជាតិ។ ម៉្យាងវិញទៀតការផ្តោតយកពន្ធលើការប្រើប្រាស់គឺឆ្លើយតបទៅនឹងកំណើនការប្រកួតប្រជែងសារពើពន្ធដែលឆ្លងកាត់ព្រំប្រទល់ប្រទេស ចំពោះលទ្ធភាពចល័តបាននៃមូលដ្ឋានពន្ធ ពីព្រោះពន្ធលើការប្រើប្រាស់ ពុំសូវមានលក្ខណៈចល័តបានដូចពន្ធលើមូលធនទេ។ ពន្ធលើការប្រើប្រាស់(ពន្ធប្រយោល) ត្រូវបានកំណត់លើការទិញឬលក់ទំនិញ និងសេវាកម្ម (រាប់បញ្ចូលទាំងសេវាពលកម្មដែរ) ដូចជាអាករលើផលរបរ អាករពិសេស អាករលើតម្លៃបន្ថែម និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ។ ចំណែកឯពន្ធលើប្រាក់ចំណូល(ពន្ធផ្ទាល់) ត្រូវបានកំណត់ទៅលើប្រាក់ឈ្នួលឬបៀវត្ស និងអត្ថប្រយោជន៍បន្ថែមផ្សេងៗព្រមទាំងចំណូលពីការសន្សំ និងការវិនិយោគ រួមមានពន្ធលើប្រាក់ចំណូលបុគ្គល និងពន្ធលើប្រាក់ចំណូលសហគ្រាស។ ចំពោះអាករលើតម្លៃបន្ថែម ត្រូវបានអនុវត្តជាបន្តបន្ទាប់យ៉ាងឆាប់រហ័សក្នុងកម្រិតសាកល។ នៅអឺរ៉ុបការអនុវត្តន៍អាករលើតម្លៃបន្ថែម ត្រូវបានចាត់ទុកថា ជាបុរេលក្ខខណ្ឌមួយនៃសមាជិកភាពរបស់សហគមន៍អឺរ៉ុប។ តាម

បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ការរៀបចំនិងការអនុវត្តន៍កំណែទម្រង់សារពើពន្ធបានទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីសំណាក់អង្គការហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗជាពិសេសមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ មកម្ល៉េះ អាករលើតម្លៃបន្ថែម ត្រូវបានដាក់ឱ្យអនុវត្តក្រោមលក្ខខណ្ឌកម្មវិធីកែតម្រូវនូវរចនាសម្ព័ន្ធ និងគោលនយោបាយស្តីរការពារនីយកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក។ អាករលើតម្លៃបន្ថែម បានក្លាយចំណុចកណ្តាលនៃការកេណ្ឌប្រមូលចំណូលសារពើពន្ធដោយចាត់ទុកថា វាជាមធ្យោបាយដ៏សក្តិសិទ្ធិសម្រាប់បង្កើនចំណូលសារពើពន្ធ និងការកែលម្អប្រសិទ្ធភាពសេដ្ឋកិច្ច។ ប្រទេសមួយចំនួន បានអនុវត្តប្រកបដោយជោគជ័យក្នុងការបង្កើនចំណូលសារពើពន្ធ នៅតាមបណ្តាប្រទេសមួយចំនួនដូចជា ប្រេស៊ីល ឥណ្ឌូនេស៊ី និងម៉ាឡាវីជាដើម។ ក៏ប៉ុន្តែតាមប្រទេសជាច្រើនទៀតនៅមានឧបសគ្គ ឬដោយសារប្រសិទ្ធភាពរដ្ឋបាលសារពើពន្ធនៅមានកម្រិត។ អាករលើតម្លៃបន្ថែម ត្រូវបានទទួលរងការទិទៀនថា ធ្វើឱ្យអ្នកប្រើប្រាស់ចុងក្រោយជាប់បន្ទុកពន្ធកាន់តែខ្លាំង ដែលធ្វើឱ្យវិសមភាពកើនឡើងជាមួយនឹងការសម្រេចចិត្តគោលនយោបាយក្នុងការជ្រើសរើសចំនួនអត្រាពន្ធ និងកម្រិតអត្រាពន្ធ សម្រាប់អាករលើតម្លៃបន្ថែម ព្រមទាំងនីតិវិធីរដ្ឋបាល ដែលត្រូវសងត្រលប់វិញនូវអាករលើតម្លៃបន្ថែម និងកម្មវិធីចុះបញ្ជីជាដើម។ តាមរយៈនេះធ្វើឱ្យមានបន្ទុកចំណាយរដ្ឋបាលសារពើពន្ធ និងការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិអាករលើតម្លៃបន្ថែមដ៏ច្រើន។ បើតាមការអះអាងរបស់លោក Bird អត្រាពន្ធសម្រាប់អាករលើតម្លៃបន្ថែម គួរត្រូវបានរៀបចំជាអត្រាឯកភាព ដើម្បីកាត់បន្ថយការចំណាយរដ្ឋបាល និងចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិសំដៅលើកកម្ពស់ប្រសិទ្ធភាពការប្រមូលចំណូលពន្ធនិងអាករគ្រប់ប្រភេទ។

អាករលើតម្លៃបន្ថែមត្រូវបានអភិវឌ្ឍ និងបានដាក់ឱ្យអនុវត្តមុនគេនៅប្រទេសបារាំងឆ្នាំ១៩៥៣ ហើយក្រោយមក ត្រូវបានឆ្លងរាលដាលទៅផ្នែកផ្សេងៗនៃទ្វីបអឺរ៉ុប គឺមានលក្ខណៈសមស្របទៅតាមកម្រិតជឿនលឿននៃរដ្ឋបាលសារពើពន្ធនៅតាមប្រទេសអភិវឌ្ឍន៍ទាំងនោះ។ ចំពោះប្រទេសកំពុងអភិ-វឌ្ឍន៍ បានគ្រប់ដណ្តប់ទៅដោយវិស័យក្រៅប្រព័ន្ធដ៏ធំធេង ហើយបង្កលក្ខណៈងាយស្រួលដល់ការចៀសវាងកាតព្វកិច្ចជាប់អាករលើតម្លៃបន្ថែម គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការពង្រីកមូលដ្ឋានពន្ធរបស់ខ្លួន។ លោក Auriol និងលោក Warlters មានទស្សនៈថាការយកពន្ធលើទំនិញ និងសេវាលើការប្រើប្រាស់ និងធាតុចូលជាអន្តរការី ត្រូវបានប្រើប្រាស់នៅក្នុងវិស័យក្រៅប្រព័ន្ធដែលអាចនឹងមានប្រសិទ្ធភាពជាងការបង្កើតពន្ធនៅក្នុងវិស័យក្នុងប្រព័ន្ធ។

ឃ) សេរីភាវូបនីយកម្មពាណិជ្ជកម្មអន្តរជាតិ បានប្រព្រឹត្តទៅជាមួយការកាត់បន្ថយអត្រាពន្ធគយនៅតាមបណ្តាប្រទេសនានា នៅក្នុងក្របខណ្ឌជាទ្វេភាគី និងពហុភាគី។ និន្នាការនេះ បណ្តាលឱ្យប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ត្រូវបានប្រឈមនឹងការធ្លាក់ចុះចំណូលពន្ធគយ ហើយត្រូវការប្រឹងប្រែងធ្វើកំណែទម្រង់សារពើពន្ធ ដើម្បីពង្រឹងសមត្ថភាពកេណ្ឌប្រមូលចំណូលសារពើពន្ធតាមរបបផ្ទៃក្នុង ដូចជាអាករលើតម្លៃបន្ថែម និងពន្ធលើប្រាក់ចំណូលជាដើម។ លទ្ធផលនៃការស្រាវជ្រាវរបស់លោក Thomas និងលោក Michel បានធ្វើការជ្រើសរើសប្រទេសចំនួន ១១១ ធ្វើជាសំណាក់គំរូបានបង្ហាញថាក្រុមប្រទេសដែលមានប្រាក់ចំណូលខ្ពស់ មានសមត្ថភាពបង្កើនចំណូលក្នុងស្រុកបានពេ

ញលេញ សម្រាប់ប៉ះប៉ូវការធ្លាក់ចុះចំណូលពន្ធលើពាណិជ្ជកម្មអន្តរជាតិ ក្រុមប្រទេសដែលមានប្រាក់ចំណូលមធ្យមមានលទ្ធភាពបង្កើនចំណូលក្នុងស្រុកបានពី ៤០សេន ទៅដល់ ៤៥សេន។ ចំពោះការបាត់បង់ចំណូលពន្ធលើពាណិជ្ជកម្មអន្តរជាតិចំនួន១ដុល្លារ។ ក្រុមប្រទេសមានប្រាក់ចំណូលទាប ចំណុះយ៉ាងខ្លាំងនឹងចំណូលពន្ធពីពាណិជ្ជកម្មអន្តរជាតិ មានសមត្ថភាពបង្កើននូវប្រាក់ចំណូលនៅក្នុងស្រុកបានយ៉ាងច្រើនត្រឹមតែ៣០សេន តែប៉ុណ្ណោះ។ ចំពោះការបាត់បង់ចំណូលពន្ធពីពាណិជ្ជកម្មអន្តរជាតិចំនួន១ដុល្លារ តាមរយៈការបង្កើនរបបពន្ធផ្ទៃក្នុង។ ចំពោះសមត្ថភាពប៉ះប៉ូវខុសៗគ្នា នូវការបាត់បង់នៃចំណូលពន្ធពីពាណិជ្ជកម្មអន្តរជាតិ គឺដោយសាររដ្ឋបាលសារពើពន្ធមានកម្រិតទន់ខ្សោយតាមបណ្តាប្រទេសមានប្រាក់ចំណូលទាប ហើយពុំទាន់មានការអភិវឌ្ឍន៍សមត្ថភាពឱ្យបានទាន់ពេលវេលា ក្នុងការពង្រឹងការប្រមូលចំណូលពន្ធតាមរបបពន្ធផ្ទៃក្នុង។ ជាមួយគ្នានេះដែរ សក្តានុពលមូលដ្ឋានពន្ធ ជាពិសេសសម្រាប់ពន្ធលើប្រាក់ចំណូលនៅតាមបណ្តាប្រទេសមានប្រាក់ចំណូលទាបនៅមានកម្រិតតិចតួច ពីព្រោះសេដ្ឋ-កិច្ចគ្របដណ្តប់ដោយសកម្មភាពជីវប្រព្រឹត្តជាច្រើនចំណែកឯវិស័យកសិកម្មវិញជាកសិដ្ឋានតូចតាចមានចំនួនច្រើននៅក្នុងសេដ្ឋកិច្ច។ ចំពោះក្រុមប្រទេសដែលមានប្រាក់ចំណូលខ្ពស់ និងមធ្យមវិញ មានសមត្ថភាពបង្កើនប្រាក់ចំណូលតាមរបបពន្ធផ្ទៃក្នុងតាមរយៈការបង្កើនចំណូលពន្ធលើការប្រើប្រាស់ និងពន្ធផ្តាល់ទាំងព្រមគ្នា។ សរុបជារួមមក ការវិវត្តរចនាសម្ព័ន្ធនៃសារពើពន្ធ គឺជាកត្តាមួយដ៏សំខាន់នៅក្នុងការរៀបចំនូវគោលនយោបាយកែទម្រង់សារពើពន្ធ។

តាមការស្រាវជ្រាវរបស់លោក Keen Simone បានបង្ហាញថាចំណូលសារពើពន្ធអាចលើសពីនេះទៅទៀត តាមរយៈសេរីភាវូបនីយកម្មអន្តរជាតិ និងតាមរយៈការលុបបំបាត់ចោលនូវការលើកលែងពន្ធ ការបន្ធាបអត្រាពន្ធគយ និងកែលម្អនីតិវិធីគយ ដែលធ្វើឱ្យមានកំណើនលំហូរពាណិជ្ជកម្ម។

ចំពោះវិស័យរ៉ែការស្រាវជ្រាវបានបង្ហាញថា លទ្ធផលមិនដូចគ្នាទេអំពីឥទ្ធិពលរបស់វិស័យទាំងនេះមកលើចំណូលសារពើពន្ធ។ គួរកត់សម្គាល់ថា ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការគ្រប់គ្រងចំណូលសារពើពន្ធ គឺចំណុះទៅនឹងកត្តាសំខាន់ផ្សេងទៀតជាច្រើន។ ដូចមានបង្ហាញ នៅក្នុងបទពិសោធន៍នៃការអនុវត្តគម្រោងឥណទានសម្រាប់កំណែទម្រង់ប្រព័ន្ធសារពើពន្ធរបស់ធនាគារពិភពលោក ដែលបានចំណាយមូលនិធិជាង ៨ ពាន់លានដុល្លារ។ នាទសវត្សរ៍ឆ្នាំ១៩៩០ នៅក្នុងនោះមានការពង្រឹងនូវ ស្ថាប័ន និងកសាងសមត្ថភាពអភិបាលកិច្ចវិស័យសាធារណៈ ជាពិសេសរដ្ឋបាលសារពើពន្ធ។ ជាមួយគ្នានេះដែរការស្រាវជ្រាវរបស់លោក Gupta បានបង្ហាញពីលទ្ធផលគួរឱ្យទុកចិត្តថាការពឹងផ្អែកការយកពន្ធលើទំនិញនិងសេវា ធ្វើឱ្យចំណូលសារពើពន្ធមានកម្រិតទាប ពីព្រោះពន្ធនិងអាករលើទំនិញ និង សេវាគឺមានលក្ខណៈជាពន្ធប្រយោល ហើយចរិតថយចុះជាលំដាប់(Regressive character)នៃពន្ធ ប្រភេទនេះ ធ្វើឱ្យមានកំណើនវិសមភាពនៃការបែងចែកប្រាក់ចំណូល និងអាចបណ្តាលឱ្យថយចុះនូវមូលដ្ឋានពន្ធ។ ផ្ទុយទៅវិញ ការពឹងផ្អែកខ្លាំងលើការយកពន្ធលើប្រាក់ចំណូល ជាពិសេសពន្ធលើប្រាក់ចំណេញពីមូលធន (ដោយសារតែពន្ធប្រភេទនេះ មានលក្ខណៈកើនឡើងជាលំដាប់ និងកំណើនប្រាក់ ចំណេញ) ធ្វើឱ្យចំណែកនៃចំណូលសារពើពន្ធនៅក្នុងផលិតផលក្នុងស្រុកសរុបមាននិន្នាការកើន ឡើង។

៤.២-សន្ទស្សន៍នៃកម្លាំងសារពើពន្ធ(FISCAL STRENGTH OF INDEX)

៤.២.១-សន្ទស្សន៍នៃសារពើពន្ធ(FISCAL INDEX)

សន្ទស្សន៍នៃកម្លាំងសារពើពន្ធ គឺជាអនុបាតនៃចំណែកសារពើពន្ធជាក់ស្តែងធៀបទៅនឹងចំណែកសារពើពន្ធប៉ាន់ស្មាន (សក្តានុពលសារពើពន្ធ) ក្នុងផលិតផលក្នុងស្រុកសរុប។ បើសិនសន្ទស្សន៍នេះមានទំហំធំជាង១ មានន័យថាកម្លាំងសារពើពន្ធមានកម្រិតខ្ពស់ បានបង្ហាញថាប្រទេសមួយដែលប្រើប្រាស់មូលដ្ឋានពន្ធបានល្អប្រសើរសម្រាប់បង្កើនចំណូលសារពើពន្ធ។ ផ្ទុយទៅវិញ បើសន្ទស្សន៍មានទំហំតូចជាង១ មានន័យថាកម្លាំងសារពើពន្ធមានកម្រិតទាប ហើយបង្ហាញថាប្រទេសមានសក្តានុពលសម្រាប់បង្កើនប្រាក់ចំណូលសារពើពន្ធ។

តាមរយៈទស្សនៈរបស់លោក Muagrave ការប្រើប្រាស់សន្ទស្សន៍នេះ ធ្វើជារង្វាស់មួយសម្រាប់ប្រៀបធៀបជាលក្ខណៈអន្តរជាតិ អំពីលទ្ធផលការគ្រប់គ្រងចំណូលសារពើពន្ធរវាងប្រទេសនានា អាចនឹងមានលក្ខណៈសមស្របទាល់តែប្រភេទនីមួយៗមានលក្ខណៈស្រដៀងគ្នាក្នុងទិដ្ឋភាពនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងកម្រិតនៃប្រាក់ចំណូល។ ការប្រើប្រាស់សន្ទស្សន៍នេះ គឺមានលក្ខណៈសាមញ្ញ និងងាយស្រួលក្នុងការផ្តល់ព័ត៌មានពីនិន្នាការក្នុងកម្រិតពិភពលោកពីសមត្ថភាព និងលទ្ធភាពប្រមូលសារពើពន្ធរបស់ប្រទេសនីមួយៗក៏ពិតមែន។ ប៉ុន្តែការណ៍នេះ មិនអាចឆ្លុះបញ្ចាំងបានពិតប្រាកដអំពីសមត្ថភាពសារពើពន្ធរបស់ប្រទេសនីមួយៗទេ ដោយសារស្ថានភាពខុសៗគ្នា នៅតាមបណ្តាប្រទេសនីមួយៗ ដូចជាស្ថានការវិវត្តនៃប្រជាសាស្ត្រ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចជាដើម។ ដូច្នេះ ធ្វើឱ្យអនុបាតចំណូលសារពើពន្ធធៀបទៅនឹងផលិតផលក្នុងស្រុកសរុប អាចផ្តល់នូវទំហំមួយមិនច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការប្រៀបធៀបនឹងការវាយតម្លៃពីសក្តានុពល ក៏ដូចជាកម្លាំងសារពើពន្ធរវាងប្រទេសនានា។

ការប៉ាន់ស្មានពីសក្តានុពលសារពើពន្ធ តែងតែជួបការលំបាកជាច្រើនដោយសារគុណភាពប្រព័ន្ធប្រមូលទិន្នន័យស្ថិតិនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ នៅមានកម្រិតទាបដែលជាហេតុបណ្តាលឱ្យមានការវាស់វែងពីអថេរមិនច្បាស់លាស់ជាមួយគ្នានេះដែរ គឺទំនាក់ទំនងរវាងអថេរមិនអាស្រ័យអាចត្រូវបានបកស្រាយខុសពីភាពជាក់ស្តែង។ ក្រៅពីគុណភាព និងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប ជាមូលដ្ឋានសម្រាប់កំណត់នូវសក្តានុពល និងកម្លាំងសារពើពន្ធ តែតែងមានស្ថានភាពនិងការវិវត្តខុសគ្នាតាមសេដ្ឋកិច្ចនីមួយៗ និងកំណត់សក្តានុពលសារពើពន្ធរបស់ប្រទេសមួយ ត្រូវបានពឹងផ្អែកជាដំបូងលើការប៉ាន់ស្មានពីអថេរមិនអាស្រ័យមួយចំនួន មានឥទ្ធិពលលើចំណូលសារពើពន្ធដោយពុំបានឆ្លុះបញ្ចាំងពីកម្រិតនៃសម្ពាធនយោបាយ ក្នុងការឆ្លើយតបនឹងតម្រូវការចំណាយសាធារណៈ ព្រមទាំងឆន្ទៈនយោបាយក្នុងការប្រមូលចំណូលសារពើពន្ធ។ បើសិនប្រៀបធៀបសន្ទស្សន៍នៃកម្លាំងសារពើពន្ធរបស់ប្រទេសមួយ ឬជាសន្ទស្សន៍មធ្យមរបស់ប្រទេសមួយដែលនៅមានកម្រិត។

ការអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា មិនអាចបង្ហាញបានទាំងស្រុងពីសមត្ថភាពការគ្រប់គ្រងចំណូលសារពើពន្ធរបស់ប្រទេសនីមួយៗបាននោះទេ។ ប៉ុន្តែបើយោងតាមទស្សនៈរបស់លោក Chelliah ថាវាអាចផ្តល់ព័ត៌មានចាំបាច់អំពីលទ្ធភាព និងវិសាលភាពនៃការបង្កើតប្រាក់ចំណូលសារពើពន្ធដែរ។ តាម

ទស្សនៈលោក Tuan បានបញ្ជាក់ថាសន្ទស្សន៍នៃកម្លាំងសារពើពន្ធ គឺពុំអាចជំនួសឱ្យការសិក្សាគ្រប់ជ្រុងជ្រោយអំពីបញ្ហាសារពើពន្ធនៅក្នុងទំនាក់ទំនងផ្ទាល់ជាមួយនឹងតម្រូវការ និងសមាភាពនៃចំណាយសាធារណៈព្រមទាំងលក្ខខណ្ឌស្ថាប័នរបស់ប្រទេសនីមួយៗបានទេ។

មានការស្រាវជ្រាវជាច្រើន អំពីសន្ទស្សន៍នៃកម្លាំងសារពើពន្ធ ត្រូវបានធ្វើឡើងដោយអ្នកឯកទេសខាងសារពើពន្ធ តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ មកម្ល៉េះ។ លោក Chelliah បានជ្រើសរើសសំណាកគំរូចំណូលពន្ធចំនួន ៤៧ ប្រទេស យកបានមកសិក្សាអំពីចំណែកនៃសារពើពន្ធក្នុងផលិតផលក្នុងស្រុកសរុបពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧១ ដោយបានរួមបញ្ចូលអថេរមិនអាស្រ័យសំខាន់ៗមួយចំនួន បានរកឃើញថាជាទូទៅប្រទេសដែលមានចំណែកសារពើពន្ធខ្ពស់នៅក្នុងផលិតផលក្នុងស្រុកសរុបច្រើនតែមានសន្ទស្សន៍នៃកម្លាំងសារពើពន្ធខ្ពស់ដែរ ប៉ុន្តែមានករណីលើកលែងច្រើនគួរឱ្យកត់សម្គាល់ផងដែរ។ សន្ទស្សន៍នេះបានប្រែប្រួលតាមប្រទេសខ្លះ បើសិនប្រៀបធៀបនឹងលទ្ធផលស្រាវជ្រាវកាលពីគ្រាមុនៗ។ ការស្រាវជ្រាវរបស់លោក Tanzi លើសំណាកគំរូមានចំនួន ៨៦ ប្រទេស បានបង្ហាញពីទំនាក់ទំនងវិជ្ជមានរវាងចំណែកចំណូលសារពើពន្ធនៃផលិតផលក្នុងស្រុកសរុបពិត និងកម្រិតប្រាក់ចំណូលសម្រាប់ម្នាក់ៗ។ ក្រោយមកទៀត លោកបានរៀបចំស្រាវជ្រាវលើសំណាកគំរូមានចំនួន ៨៣ ប្រទេស សម្រាប់រយៈកាលពីឆ្នាំ១៩៧៨ ដល់ឆ្នាំ១៩៨៨ ហើយបានបង្ហាញពីទំនាក់ទំនងរវាងអថេរទាំងពីរនេះបានចុះខ្សោយ ដោយសារតែឥទ្ធិពលនៃកត្តាផ្សេងៗទៀតដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចមានតម្រូវការថវិកាជាតិសម្រាប់សងបំណុល និងការផ្លាស់ប្តូរចនាសម្ព័ន្ធសេដ្ឋកិច្ច។ សក្តានុពលសារពើពន្ធ (ចំណូលសារពើពន្ធប៉ាន់ស្មានធៀបនឹងផលិតផលក្នុងស្រុកសរុប) និងចំណូលសារពើពន្ធជាក់ស្តែងធៀបនឹងផលិតផលក្នុងស្រុកសរុប(GDP)។ តាមរយៈនេះ បានកំណត់សន្ទស្សន៍នៃកម្លាំងសារពើពន្ធនៅតាមប្រទេសនីមួយៗ

៤.២.២-ចំណាត់ថ្នាក់សន្ទស្សន៍នៃសារពើពន្ធ(FISCAL OF INDEX CLASSIFICATION)

បើយោងតាមលទ្ធផលនៃការស្រាវជ្រាវក្រុមអ្នកសេដ្ឋកិច្ចទាំងនេះ បានរៀបចំបញ្ចូលប្រទេសទាំងអស់ (ពឹងផ្អែកលើលទ្ធផលនៃការប្រមូលចំណូលពន្ធជាក់ស្តែង និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធ) ទៅតាមចំណាត់ថ្នាក់មាន៤ក្រុម៖

- ក្រុមប្រទេសទី១៖ ដែលមានចំណូលសារពើពន្ធជាក់ស្តែងទាប និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធមានកម្រិតទាប។
- ក្រុមប្រទេសទី២៖ ដែលមានចំណូលសារពើពន្ធជាក់ស្តែងទាប និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធកម្រិតខ្ពស់។
- ក្រុមប្រទេសទី៣៖ ដែលមានចំណូលសារពើពន្ធជាក់ស្តែងខ្ពស់ និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធមានកម្រិតទាប។

- ក្រុមប្រទេសទី៤៖ ដែលមានចំណូលសារពើពន្ធជាក់ស្តែងមធ្យមកម្រិតខ្ពស់ឡើងទៅ និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធកម្រិតទាប។

ក្រុមប្រទេសទី១៖ ភាគច្រើនលើសលុបជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (លើកលែងសហរដ្ឋអាមេរិក និង កូរ៉េខាងត្បូង) មានចំណូលសារពើពន្ធជាក់ស្តែងប្រៀបធៀបនឹងផលិតផលក្នុងស្រុកសរុបទាប និងមានសន្ទស្សន៍នៃកម្លាំងសារពើពន្ធកម្រិតទាប។ មានប្រទេសខ្លះដូចជា កាំមឺរូន និង ម៉ាដាហ្គាសកាជាដើម គឺនៅចំណុះខ្លាំងទៅនឹងជំនួយបរទេស មានប្រទេសជាច្រើនមានការលើកទឹកចិត្តសារពើពន្ធដ៏ស្មុគស្មាញជាច្រើន ដែលបានធ្វើឱ្យរួញចុះនូវបរិមាណពន្ធ ហើយបានបង្កើនឱ្យមាននូវភាពចន្លោះប្រហោងសម្រាប់ការគេចវេសពន្ធ ធ្វើឱ្យមជ្ឈដ្ឋានសាធារណៈមានទស្សនៈអវិជ្ជមាន ចំពោះភាពយុត្តិធម៌ប្រព័ន្ធសារពើពន្ធ និងបង្កើតឱ្យមានឱកាសនូវអំពើពុករលួយ។ របបសារពើពន្ធ ស្មុគស្មាញរួមផ្សំនឹងសមត្ថភាពខ្សោយនៃរដ្ឋបាលសារពើពន្ធធ្វើឱ្យប្រទេសជាច្រើនសម្រេចបានចំណូលសារពើពន្ធទាប និងការចំណាយកាន់តែខ្ពស់នៅក្នុងរដ្ឋបាលសារពើពន្ធ នៅក្នុងការអនុលោមបទប្បញ្ញត្តិសារពើពន្ធ។ ករណីនេះ កំណែទម្រង់សារពើពន្ធ គួរតែត្រូវបានផ្តោតលើទិសដៅការបង្កើនការប្រមូលចំណូលសារពើពន្ធ។ គោលនយោបាយសារពើពន្ធ អាចតម្រង់ទិសដៅរកការពង្រីកមូលដ្ឋានពន្ធការធ្វើសនិទានកម្មនៃរច-នាសម្ព័ន្ធសារពើពន្ធ ជាពិសេសប្រព័ន្ធការលើកទឹកចិត្តសារពើពន្ធ និងការពង្រីកការអនុវត្តអាករលើតម្លៃបន្ថែម។

ក្រុមប្រទេសទី២៖ ភាគច្រើន គឺជាប្រទេសដែលមានប្រាក់ចំណូលមធ្យម និងខ្ពស់សម្រេចបាននូវការប្រមូលចំណូលសារពើពន្ធជាក់ស្តែងធៀបទៅនឹងផលិតផលក្នុងស្រុកសរុបកម្រិតមួយខ្ពស់ និងសន្ទ-ស្សន៍នៃកម្លាំងសារពើពន្ធកម្រិតខ្ពស់។ ហេតុនេះប្រទេសទាំងនោះ មានលទ្ធភាពចង្អៀតក្នុងការលើកកម្ពស់ចំណូលសារពើពន្ធបន្ថែមទៀត។ ចំណូលសារពើពន្ធជាក់ស្តែងខ្ពស់ និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធខ្ពស់នៅតាមប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដូចជា អាល់ហ្សេរី ប្រេស៊ីល ប៊ុលហ្គារី និងម៉ុងហ្គោលីជាដើម ពុំមានន័យថារចនាសម្ព័ន្ធសារពើពន្ធ និងរដ្ឋបាលសារពើពន្ធរបស់ប្រទេសទាំងនោះ សម្រេចបាននូវលទ្ធផលល្អប្រសើរតាមរយៈប្រតិបត្តិការអន្តរជាតិនៅឡើយទេ។ ប្រព័ន្ធសារពើពន្ធរបស់ប្រទេសទាំងនោះ ត្រូវការកំណែទម្រង់ច្រើនទៀតដោយសារតែកត្តាពន្ធសម្រាប់អាករលើតម្លៃបន្ថែមមានចំនួនច្រើន ហើយនៅមានការកាត់កង និងលើកលែងពន្ធជាច្រើន សម្រាប់ពន្ធលើប្រាក់ចំណូលបុគ្គល និងពន្ធលើប្រាក់ចំណូលសហគ្រាស។ ការបង្កើនចំណូលសារពើពន្ធបន្ថែមពុំមែនជាអាទិភាពគោលនយោបាយកំណែទម្រង់របស់ក្រុមប្រទេសទាំងនោះទេ។

ក្រុមប្រទេសទី៣៖ ការគ្របដណ្តប់លើចំនួនប្រទេសតិចតួច ហើយប្រទេសភាគច្រើនជាប្រទេសដែលមានកម្រិតអភិវឌ្ឍន៍តិចតួច។ របបសារពើពន្ធរបស់ប្រទេសភាគច្រើន មិនសូវមានស្ថិរភាព និងរដ្ឋបាលសារពើពន្ធនៅខ្សោយ។ ចំណូលសារពើពន្ធជាក់ស្តែងមានកម្រិតទាប ប៉ុន្តែមានសន្ទស្សន៍នៃកម្លាំងសារពើពន្ធកម្រិតខ្ពស់ តាមរយៈជំរុញការប្រមូលពន្ធលើពាណិជ្ជកម្មអន្តរជាតិ ឬការកំណត់ពន្ធខ្ពស់សម្រាប់សកម្មភាពសេដ្ឋកិច្ចវិស័យក្នុងប្រព័ន្ធដែលជាញឹកញាយធ្វើឱ្យមានការបង្អាក់ទឹកចិត្តទៅដល់វិស័យក្នុងប្រព័ន្ធ និងការវិនិយោគ ដូចករណីប្រទេស អ៊ូហ្គានដា ជាដើម។ នៅតាមប្រទេសខ្លះ អត្រា

ពន្ធសម្រាប់ប្រភេទពន្ធមួយចំនួនត្រូវបានបង្កើតឡើង ប៉ុន្តែពុំមានប្រសិទ្ធភាពពេញលេញ ដោយសារតែការលើកលែងពន្ធច្រើន និងការអនុវត្តអត្រាពន្ធសូន្យ ដូចជាអាករលើតម្លៃបន្ថែម។ ដូច្នេះ វិធានការកំណែទម្រង់សារពើពន្ធសម្រាប់រយៈពេលខ្លី អាចផ្តោតលើការធ្វើសន្និទានកម្មនយោបាយសារពើពន្ធ និងនីតិវិធីរដ្ឋបាលសារពើពន្ធ ដើម្បីកាត់បន្ថយការចំណាយក្នុងការអនុវត្តតាមបទប្បញ្ញត្តិសារពើពន្ធ និងដើម្បីលើកទឹកចិត្តដល់វិស័យក្នុងប្រព័ន្ធ ព្រមទាំងការលុបបំបាត់នូវឧបសគ្គសារពើពន្ធ សម្រាប់ការនាំចូល និងប្រតិបត្តិការរបស់សហគ្រាស។ សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង អាទិភាពនៃកំណែទម្រង់សារពើពន្ធអាចផ្តោតលើការពង្រីកមូលដ្ឋានពន្ធ និងការពង្រីកដំណើរការសារពើពន្ធ។

ក្រុមប្រទេសទី៤៖ ភាគច្រើន គឺជាប្រទេសដែលមានប្រាក់ចំណូលពីមធ្យមកម្រិតខ្ពស់ឡើងទៅ។ ប្រទេសទាំងនេះ មានសក្តានុពលខ្ពស់សម្រេចបានចំណូលសារពើពន្ធជាក់ស្តែងខ្ពស់ ប៉ុន្តែមានសន្ទស្សន៍នៃកម្លាំងសារពើពន្ធកម្រិតទាប ដែលអាចឆ្លុះបញ្ចាំងពីនយោបាយក្នុងការកម្រិតទំហំសារពើពន្ធ។ រចនាសម្ព័ន្ធសារពើពន្ធរបស់ប្រទេសទាំងនោះ អាចត្រូវបានកែលម្អតាមរយៈការកាត់បន្ថយពន្ធនិងអាករទៅលើកត្តាផលិតម្ម។ ជាពិសេស ការបង្កើនពន្ធដែលមានមូលដ្ឋានពន្ធទូលាយ ពោលគឺជាពន្ធប្រយោលដូចជាពន្ធលើចំណាយការប្រើប្រាស់ជាដើម។ រចនាសម្ព័ន្ធសារពើពន្ធ អាចឱ្យមានការសន្និដ្ឋានជាទូទៅបានថាប្រទេសដែលមានចំណូលសារពើពន្ធជាក់ស្តែងទាប និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធ គឺនៅមានលទ្ធភាពទូលាយក្នុងការបង្កើតនូវចំណូលសារពើពន្ធជាក់ស្តែងទាប និងសន្ទស្សន៍នៃកម្លាំងសារពើពន្ធមានកម្រិតខ្ពស់ គឺនៅសល់លទ្ធភាពតិចតួចក្នុងរយៈពេលខ្លីក្នុងការបង្កើនចំណូលសារពើពន្ធ លើកលែងតែប្រទេសនោះ បង្ខំចិត្តបង្កើនការចំណាយសម្រាប់រដ្ឋបាលសារពើពន្ធអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធព្រមទាំងបង្កាក់ទឹកចិត្តដល់វិស័យក្នុងប្រពន្ធ័ជាដើម។

៤.៣-ការវិនិច្ឆ័យនៃសារពើពន្ធ (JUDGMENT OF FISCAL)

៤.៣.១-ការវិនិច្ឆ័យនៃការវាយតម្លៃ (JUDGMENT OF EVALUATION)

គោលបំណងនៃការវាយតម្លៃ និង ប្រៀបធៀបជាលក្ខណៈអន្តរជាតិពីប្រព័ន្ធនៃសារពើពន្ធ មានរដ្ឋាភិបាលមួយចំនួន អង្គការអន្តរជាតិ និងទីភ្នាក់ងារផ្តល់នូវជំនួយបរទេសសំខាន់ៗ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក បានខិតខំព្យាយាមរៀបចំលក្ខខណ្ឌវិនិច្ឆ័យមួយឱ្យមានលក្ខណៈជាបទដ្ឋានអន្តរជាតិ សម្រាប់តំណាងឱ្យប្រតិបត្តិករល្អក្នុងការគ្រប់គ្រងចំណូលសារពើពន្ធ។ លោក Barbone បានរៀបចំ "ក្របខណ្ឌសម្រាប់និទស្សន៍ពីភាពទន់ខ្សោយប្រព័ន្ធនៃសារពើពន្ធ" បានពឹងផ្អែកលើបទពិសោធន៍នៃលទ្ធផលការអនុវត្តន៍នូវគម្រោងកំណែទម្រង់សារពើពន្ធនៅតាមប្រទេសជាច្រើន ដែលបានផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក។ នៅក្នុងក្របខណ្ឌនេះ បានបង្ហាញអំពីការកំណត់គោលនយោបាយនៃគណនេយ្យភាព និងការផ្តល់សេវាតាមលទ្ធភាពសមត្ថភាព និងស្ថាប័នរបស់ប្រព័ន្ធសារពើពន្ធរវាងប្រទេសផ្សេងៗគ្នា។ តាមរយៈលោក Jit បានលើកឡើងនូវក្របខណ្ឌសម្រាប់ការវាយតម្លៃរដ្ឋបាលសារពើពន្ធ បានផ្តោតលើការប្រព្រឹត្តទៅនៃ ដំណើការ និងបរិយាកាសនានាដែលសារពើពន្ធត្រូវបានបំពេញតាមតួនាទីរបស់ខ្លួន។

ប៉ុន្តែពុំបានផ្តោតលើការរៀបចំបទដ្ឋានសម្រាប់ឱ្យមានការប្រៀបធៀបជាលក្ខណៈអន្តរជាតិនោះទេ។ ទោះបីជា បានរៀបចំក្របខណ្ឌសម្រាប់វាយតម្លៃលទ្ធផលនៃកំណែទម្រង់សារពើពន្ធ និងរដ្ឋបាលសារពើពន្ធដោយបានប្រើប្រាប់សូចនាករសំខាន់ៗ ពាក់ព័ន្ធទៅនឹងលទ្ធផលចំណូលសារពើពន្ធ សមត្ថភាព និង ស្ថាប័ននៃរដ្ឋបាលសារពើពន្ធ និងឧបសគ្គផ្សេងៗក៏ដោយ។

ធនាគារពិភពលោក បានបង្កើតគេហទំព័រមួយមានចំណងជើងថា "នយោបាយនិងរដ្ឋបាលសារពើពន្ធ" សម្រាប់វាយតម្លៃនូវការអនុវត្តគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ ដោយបានបង្ហាញពីបញ្ហាស្ថាប័ន និងប្រភពឯកសារមួយចំនួន។ ប៉ុន្តែ វាពុំបានបង្កើតគោលដៅដែលអាចវាស់វែងបានសម្រាប់ធ្វើការប្រៀបធៀបជាលក្ខណៈអន្តរជាតិ។ សហគមអឺរ៉ុប បានរៀបចំសេចក្តីព្រៀងផែនការមេស្តីពីប្រព័ន្ធនៃសារពើពន្ធ ដើម្បីផ្តល់ជាគោលការណ៍ណែនាំដល់ប្រទេសដែលចង់ចូលជាសមាជិករៀបចំរដ្ឋបាលសារពើពន្ធឱ្យបានសមស្របទៅនឹងសូចនាករមួយចំនួន ប៉ុន្តែក៏ពុំបានកំណត់អំពីទិន្នន័យជាក់លាក់សម្រាប់សូចនាកនីមួយៗនោះទេដែលធ្វើឱ្យការវាយតម្លៃ និងការប្រៀបធៀបអំពីលទ្ធផលជាលក្ខណៈអន្តរជាតិជួបការលំបាក។

លក្ខខណ្ឌវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធ គឺជាឧបករណ៍មួយសម្រាប់វាយតម្លៃលទ្ធផល និងធាតុចូលនៃប្រព័ន្ធសារពើពន្ធព្រមទាំងដំណើរការ និងការរៀបចំរដ្ឋបាលសារពើពន្ធតាមរយៈការប្រៀបធៀបនូវសូចនាករជាក់លាក់នីមួយៗដែលត្រូវបានកំណត់ឡើងធ្វើជាតំណាងឱ្យស្តង់ដារអន្តរជាតិ សម្រាប់ប្រតិបត្តិក្នុងការវាយតម្លៃប្រព័ន្ធសារពើពន្ធ។ លក្ខខណ្ឌវិនិច្ឆ័យនីមួយៗ អាចត្រូវបានប្រើប្រាស់សម្រាប់តាមដានដំណើរការអនុវត្តកិច្ចការកំណែទម្រង់ និងទំនើបកម្មនៃប្រព័ន្ធសារពើពន្ធពីគ្រាមួយទៅគ្រាមួយទៀត។ លើសពីនេះ លក្ខខណ្ឌវិនិច្ឆ័យក៏មានមុខងារជាឧបករណ៍សម្រាប់ប្រៀបធៀបនូវក្របខ័ណ្ឌ និងលទ្ធផលនៃការអនុវត្តរបស់ប្រព័ន្ធសារពើពន្ធរវាងប្រទេសនីមួយៗផងដែរ។

៤.៣.២-ការវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធ (JUDGMENT OF FISCAL SYSTEM)

លក្ខខណ្ឌវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធ ត្រូវបានចាប់ផ្តើមធ្វើការអភិវឌ្ឍន៍តាំងពីពាក់កណ្តាលទស-វត្សរ៍ឆ្នាំ១៩៩០ ជាពិសេសនៅតាមប្រទេសមួយចំនួន នៅអាមេរិកឡាទីន ដោយបានប្រើប្រាស់នូវសូចនា-ករសំខាន់ៗមួយចំនួន តាមរយៈបទពិសោធន៍ដែលទទួលបានពីអ្នកស្រាវជ្រាវមុនៗ។ លោក Gallagher បានរៀបចំលក្ខខណ្ឌវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធមួយដែលមានបញ្ចូលនូវសូចនាករជាក់លាក់ជាច្រើន។

ក) រចនាសម្ព័ន្ធ និងលទ្ធផលសារពើពន្ធដែលជាលក្ខខណ្ឌវិនិច្ឆ័យចម្បងនៃប្រព័ន្ធសារពើពន្ធ ត្រូវបានវាស់វែងតាមរយៈសូចនាករដូចខាងក្រោម៖

១. ចំនួននៃប្រភេទសារពើពន្ធ (ដែលបទដ្ឋានអន្តរជាតិបានកំណត់ប្រភេទពន្ធចំនួន៦) ដែលគ្របដណ្តប់ ៧៥ភាគរយ នៃចំណូលសារពើពន្ធសរុប។ សូចនាកនេះ មានគោលបំណងបង្ហាញអំពីលក្ខណៈប្រមូលផ្តុំ ឬលក្ខណៈបំបែកនៃប្រព័ន្ធសារពើពន្ធ។ បើប្រព័ន្ធសារពើពន្ធពឹងផ្អែកលើប្រភពចំណូលកាន់តែចង្អៀតឬតិចនោះ ហានិភ័យការប្រែប្រួលចំណូលសារពើពន្ធនឹងមានកម្រិតកាន់តែខ្ពស់ ហើយការប៉ាន់ស្មានពីលទ្ធផលនៃការប្រមូលចំណូលពន្ធ

សម្រាប់គ្រាខាងមុខ អាចជួបបញ្ហាប្រឈមកាន់តែខ្លាំង។ ឧទាហរណ៍ ចំណូលដែលទទួលបានពីអាជីវកម្មប្រេងឥន្ធនៈមានចំណែក ៧០ភាគរយ នៃចំណូលរបស់រដ្ឋាភិបាលនៅបណ្តាប្រទេសមួយចំនួននៅអាហ្វ្រិក និងមជ្ឈឹមបូព៌ា ហើយចំណូលនេះតែងតែងាយចុះគួរឱ្យកត់សម្គាល់ជាញឹកញយ។ ក៏ប៉ុន្តែ ប្រព័ន្ធនៃសារពើពន្ធមួយ ពឹងផ្អែកទៅលើចំណូលពីប្រភពពន្ធច្រើនប្រភេទពេកអាចធ្វើឱ្យមានបន្ទុកច្រើនដល់រដ្ឋបាលសារពើពន្ធក្នុងការគ្រប់គ្រង និងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធ។

២.មូលដ្ឋានពន្ធទូលាយ និងការលើកលែងពន្ធមានកម្រិត ពោលគឺប្រព័ន្ធសារពើពន្ធត្រូវគ្របដណ្តប់ទៅលើគ្រប់វិស័យទាំងអស់នៃសកម្មភាពសេដ្ឋកិច្ចលើកលែងពន្ធនិងអាករ ដែលជាបន្ទុករបស់រដ្ឋកាត់កងនឹងអភ័យឯកសិទ្ធិផ្សេងៗ ត្រូវបានកាត់បន្ថយឱ្យនៅសល់តិចតួចបំផុតតាមដែលអាចធ្វើទៅបាន។

៣.ភាគរយនៃអ្នកជាប់ពន្ធ (លក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិបានកំណត់ ៥ ភាគរយ) ដែលមានចំណែក ៧៥ភាគរយ នៃចំណូលសារពើពន្ធសរុប។ សូចនាករនេះដែរចង់បង្ហាញថា បើសិនភាគរយនេះមានទំហំកាន់តែតូចនោះ ភាពងាយរងគ្រោះនៃប្រព័ន្ធសារពើពន្ធមានកម្រិតកាន់តែខ្ពស់ កាលណាស្ថានភាពសេដ្ឋកិច្ចរបស់អ្នកជាប់បន្ទុកពន្ធទាំងនេះប្រែប្រួល។ ជាទូទៅមានអ្នកជាប់ពន្ធមួយចំនួនប៉ុណ្ណោះ ភាគច្រើនជាក្រុមហ៊ុនធំៗ ដែលបានរួមចំណែកធំធេងក្នុងចំណូលពន្ធរបស់ប្រទេសនីមួយៗ ជាពិសេសសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារតែរដ្ឋបាលសារពើពន្ធពិបាកនឹងកេណ្ឌប្រមូលនៅក្នុងវិស័យមួយចំនួន ដូចជាវិស័យកសិកម្ម និងវិស័យក្រៅប្រព័ន្ធជាដើម ក្រៅពីនេះមានករណីលើកលែងពន្ធជាច្រើនទៀត។

៤.អត្រាពន្ធមានចំនួនតិចតួច គឺជាសមាសធាតុមួយសម្រាប់បង្ហាញពីរចនាសម្ព័ន្ធសារពើពន្ធល្អ ពីព្រោះអត្រាពន្ធមានចំនួនច្រើនពេកអាចបង្កឱ្យមានឱកាសគេចពន្ធ ហើយធ្វើឱ្យរដ្ឋបាលសារពើពន្ធមានលក្ខណៈស្មុគស្មាញ។ ជាពិសេសពន្ធលើប្រាក់ចំណេញរបស់សហគ្រាស និងពន្ធលើប្រាក់ចំណូលបុគ្គល គួរគប្បីមានចំនួនអត្រាពន្ធតិចតួច ក្នុងករណីអាករលើតម្លៃបន្ថែមគួរតែអនុវត្តអត្រាពន្ធឯកភាពតែមួយឬពីរប៉ុណ្ណោះទើបជាការប្រសើរ។

៥.អត្រាពន្ធសម្រាប់អាករលើតម្លៃបន្ថែម ត្រូវបានកំណត់តាមរយៈលក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិស្ថិតក្នុងរង្វង់អត្រាឯកភាព ១៦ ភាគរយ។ ទោះបីយ៉ាងណា ពុំបានតម្រូវយកតាមអត្រាពន្ធប្រទេសណាមួយក៏ដោយ ក៏ប៉ុន្តែលក្ខខណ្ឌវិនិច្ឆ័យ បានផ្តោតលើការអនុវត្តអត្រាពន្ធឯកភាពតែមួយសម្រាប់ទំនិញ និងសេវាទាំងអស់លើកលែងតែអាករលើការនាំចេញ ដែលអាចជាប់អត្រាពន្ធសូន្យភាគរយ (0%) បានន័យថាបើសិនផលិតផលមួយត្រូវនាំចេញ ហើយអ្នកនាំចេញត្រូវបានទទួលត្រឡប់មកវិញនូវអាករលើតម្លៃបន្ថែម ដែលគេបានបង់នៅក្នុងដំណាក់កាលផលិតកម្មមុន ការនាំចេញរបស់គេ។

៦. ពន្ធប្រយោល គិតជាភាគរយនៃចំណូលសារពើពន្ធសរុប (ជាលក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិបានកំណត់ ៥០ភាគរយ) គឺសូចនាករមួយសម្រាប់បង្ហាញអំពីលក្ខណៈពឹងផ្អែកនៃរចនាសម្ព័ន្ធសារពើពន្ធ ប៉ុន្តែពុំមានការកំណត់ជាក់លាក់ថា ភាគរយពន្ធប្រយោលក្នុងចំណូលសារពើពន្ធត្រូវមានកម្រិតណាទើបបានល្អទេ។ ប៉ុន្តែជាទូទៅ ប្រទេសដែលមានប្រាក់ចំណូលខ្ពស់ច្រើនគឺមានចំណែកជាភាគរយនៃពន្ធផ្ទាល់នៃចំណូលសារពើពន្ធមានកម្រិតខ្ពស់ ចំណែកឯប្រទេសក្រីក្រចំណូលពន្ធប្រយោលមានសមាមាត្រភាគរយខ្ពស់នៅក្នុងចំណូលសារពើពន្ធសរុប។

៧. ការប្រមូលអាករលើពន្ធបន្ថែមគិតជាភាគរយនៃចំណូលសារពើពន្ធសរុប (លក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិបានកំណត់៥ភាគរយ) បង្ហាញពីសារសំខាន់នៃអាករលើតម្លៃបន្ថែមជាប្រភេទពន្ធមានមូលដ្ឋានទូលាយនៅក្នុងប្រពន្ធ័សារពើពន្ធ។ តាមបទដ្ឋានអន្តរជាតិនៃអាករលើតម្លៃបន្ថែម អាចមានចំណែកប្រមាណ ៣៥ភាគរយ នៃចំណូលសារពើពន្ធសរុប។

៨. អនុបាតនៃចំណូលសារពើពន្ធជាក់ស្តែងធៀបនឹងផលិតផលក្នុងស្រុកសរុប គឺលក្ខខណ្ឌវិនិច្ឆ័យមួយសម្រាប់វាស់វែងពីសមត្ថភាពបង់ពន្ធ និងប្រមូលពន្ធរបស់ប្រទេសមួយដែលបានបង្ហាញនៅខាងលើ។ ជាទូទៅការប្រើចំណូលសម្រាប់ម្នាក់ៗមានកម្រិតកាន់តែខ្ពស់នោះ អនុបាតនេះក៏មានកម្រិតកាន់តែខ្ពស់ផងដែរ។ យោងតាមសារពើពន្ធជាក់ស្តែងធៀបនឹងផលិតផលក្នុងស្រុកសរុបមានកម្រិតប្រមាណ ៤០ភាគរយ នៅតាមបណ្តាប្រទេសមានប្រាក់ចំណូលខ្ពស់ ២៥ភាគរយ នៅតាមប្រទេសមានប្រាក់ចំណូលមធ្យម ១៨ភាគរយ នៅតាមបណ្តាប្រទេសមានប្រាក់ចំណូលទាប។

៩. ការចំណាយរបស់រដ្ឋបាលសារពើពន្ធធៀបនឹងចំណូលសារពើពន្ធសរុប(លក្ខខណ្ឌវិនិច្ឆ័យជាអន្តរជាតិបានកំណត់ ១ភាគរយ) គឺជាលក្ខខណ្ឌវិនិច្ឆ័យមួយដើម្បីបង្ហាញថា តើរដ្ឋាភិបាលត្រូវចំណាយខាងផ្នែករដ្ឋបាលក្នុងកម្រិតណា? ចំពោះការកណ្តាប្រមូលចំណូលពន្ធលើប្រជាពលរដ្ឋរបស់ខ្លួន បើទោះបីជាតួលេខមានកម្រិតខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ប៉ុន្តែជាទូទៅប្រទេសមានចំណូលទាប ភាគច្រើនមានបន្ទុកចំណាយនេះខ្ពស់ជាងប្រទេសដែលមានចំណូលខ្ពស់ ដោយសារតែការអភិវឌ្ឍន៍សង្គមមិនដូចគ្នានោះ។ បើតាមការសិក្សារបស់លោក Gallagher ការចំណាយសរុបមានចំណែកចាប់ពី ០.៨ភាគរយ នៅសហរដ្ឋអាមេរិករហូតដល់ ៣.៨៦ភាគរយ នៅនីការ៉ាហ្គានាពាក់កណ្តាលទសត្សវ៍ឆ្នាំ១៩៩០។

១០. អនុបាតនៃភាពអនុលោមតាមបទប្បញ្ញត្តិបង្ហាញអំពីផលធៀបរវាងចំណូលជាក់ស្តែងលើអាករលើតម្លៃបន្ថែម និងចំណូលប៉ាន់ស្មានរបស់អាករលើតម្លៃបន្ថែម។ បើសិន ពុំមានការលើកលែងពន្ធឬការគេចពន្ធទេ អនុបាតនេះនឹងមានកម្រិតខ្ពស់ហើយលក្ខខណ្ឌវិនិច្ឆ័យ បានកំណត់យកលក្ខណៈនេះស្មើនឹង ៦៩ភាគរយ សម្រាប់ប្រទេសជឿនលឿន។

១១.ផលិតភាពនៃអាករលើតម្លៃបន្ថែម (លក្ខខណ្ឌវិនិច្ឆ័យជាអន្តរជាតិកំណត់ ០.៥៨ភាគរយ) គឺជាផលធៀបរវាងអនុបាតចំណូលអាករលើតម្លៃបន្ថែម និងផលិតផលក្នុងស្រុកសរុប ចែកនឹងអត្រាពន្ធអាករលើតម្លៃបន្ថែម។ រវាងអនុបាតនៃការអនុលោមតាមបទប្បញ្ញត្តិ និងផលិតភាពនៃអាករលើតម្លៃបន្ថែម គឺមានទំនាក់ទំនងជាវិជ្ជមានបានបង្ហាញតាមរយៈលទ្ធផលការស្រាវជ្រាវរបស់លោក Gallagher ចំនួនប្រទេស១៣ នៅទ្វីបអាមេរិក ឡាទីន នាពាក់កណ្តាលទសត្សវត្ស៍ឆ្នាំ១៩៩០។

១២.អនុបាតប្រសិទ្ធភាពនៃអាករលើតម្លៃបន្ថែម មានលក្ខណៈស្រដៀងគ្នានឹងអនុបាតនៃការអនុលោមតាមបទប្បញ្ញត្តិ ប៉ុន្តែខុសគ្នាដោយអនុបាតប្រសិទ្ធភាពនៃអាករលើតម្លៃបន្ថែមនៅក្នុងសេដ្ឋកិច្ចទាំងមូល ចំណែកឯអនុបាតនៃការអនុលោមតាមបទប្បញ្ញត្តិវិញ គឺគ្រប់ដណ្តប់តែលើការចំណាយប្រើប្រាស់របស់ផ្នែកឯកជនតែប៉ុណ្ណោះ។

១៣.អនុបាតនៃការគេចវេសអាករលើតម្លៃបន្ថែម (ជាលក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិបានកំណត់១០ភាគរយ) គឺសូចនាករមួយសម្រាប់បង្ហាញអំពីកម្រិតនៃការគេចវេសកាតព្វកិច្ចអាករលើតម្លៃបន្ថែមធៀបទៅនឹងចំណូលប៉ាន់ស្មាននៃអាករលើតម្លៃបន្ថែម។

១៤.ផលិតភាពនៃពន្ធលើប្រាក់ចំណូលសហគ្រាស គឺផលធៀបផលិតផលក្នុងស្រុកសរុបចែកនឹងអត្រាខ្ពស់បំផុតសម្រាប់ពន្ធលើប្រាក់ចំណូលសហគ្រាស។ លក្ខខណ្ឌវិនិច្ឆ័យនេះ អាចផ្តល់លទ្ធភាពឱ្យមានការប្រៀបធៀបជាអន្តរជាតិ បានងាយស្រួលពីកម្រិតនៃផលិតភាពនៃការប្រមូលពន្ធប្រភេទនេះ។ ឧទាហរណ៍ អំពីផលិតភាពនៃពន្ធលើប្រាក់ចំណូលសហគ្រាសនៅតាមបណ្តាប្រទេសមួយចំនួននៅទ្វីបអាមេរិកឡាទីនជាដើម។

១៥.ផលិតភាពនៃពន្ធលើប្រាក់ចំណូលបុគ្គល និងផលិតផលក្នុងស្រុកសរុប ចែកនឹងអត្រាពន្ធម៉ាហ្សីណាល់ខ្ពស់បំផុត គុណនឹងប្រាក់ចំណូលថ្នាក់ខ្ពស់បំផុត គិតជាចំនួនដងនៃផលិតផលក្នុងស្រុកសម្រាប់ម្នាក់ៗ។ កត់សម្គាល់ដែរថាពន្ធលើប្រាក់ចំណូលបុគ្គល គឺជាសមាធាតុមួយនៃសារពើពន្ធ បានឆ្លុះបញ្ចាំងពីលក្ខណៈនៃប្រព័ន្ធសារពើពន្ធតាមបណ្តាប្រទេសនានា។ នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ចំណូលពន្ធប្រភេទនេះមានចំណែកតិចតួចក្នុងចំណូលសារពើពន្ធសរុប ដោយសារហេតុផលមួយចំនួន ដូចជាកម្រិតទាបនៃប្រាក់ចំណូលពន្ធសម្រាប់ម្នាក់ៗ និងការអនុលោមតាមបទប្បញ្ញត្តិនៅអន់ថយមានការលើកលែងពន្ធជាច្រើនករណី ហើយលទ្ធ ភាពនៃប្រមូលចំណូលពន្ធនៅមានកម្រិត ជាពិសេសសម្រាប់វិស័យក្រៅប្រព័ន្ធ រួមទាំងកសិ-ដ្ឋានតូចតាចជាដើម។ ម៉្យាងវិញទៀត គោលនយោបាយក្នុងការប្រមូលចំណូលពន្ធប្រភេទនេះ មានលក្ខណៈខុសគ្នាតាមប្រទេសនីមួយៗ ចំពោះប្រព្រឹត្តិកម្មប្រាក់ចំណេញលើមូលធន ភាគលាភការប្រាក់ និងការកាត់កងប្រាក់ពន្ធជាដើម។

ខ) អង្គការចាត់តាំងគឺជាទិដ្ឋភាពមួយនៃលក្ខខណ្ឌវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធដែលផ្តោតលើមុខងារ និងការរៀបចំរដ្ឋបាលសារពើពន្ធ ក្នុងនោះមានការបញ្ចូលនៅសូចនាករមួយចំនួនដូចតទៅ៖

១. អង្គការចាត់តាំងរដ្ឋបាលសារពើពន្ធទំនើប ច្រើនតែត្រូវបានរៀបចំតាមមុខងារជាជាងការបង្កើតអង្គការចាត់តាំងតាមប្រភេទពន្ធនីមួយៗ។ ដូច្នេះ គឺអាចលើកកម្ពស់សមាហរណកម្មប្រតិបត្តិការដោយពង្រឹងការគ្រប់គ្រងមន្ត្រីពន្ធដារ និងការកែលម្អនូវការអនុលោមតាមបទប្បញ្ញត្តិ និងការជំរុញការអនុវត្តច្បាប់។ ជាទូទៅរដ្ឋបាលសារពើពន្ធ ត្រូវបានរៀបចំទៅតាមផ្នែកអាករលើតម្លៃបន្ថែមផ្នែកពន្ធលើប្រាក់ចំណូល និងផ្នែកអាករពិសេសជាដើម ច្រើនពុំសូវសម្រេចបានប្រសិទ្ធភាពខ្ពស់ដូចជាការរៀបចំតាមមុខងារផ្សេងៗ ផ្នែកសវនកម្ម ផ្នែកសេវាសម្រាប់អ្នកជាប់ពន្ធ និងផ្នែកជំរុញការអនុវត្តច្បាប់។

២. ស្វ័យភាពរដ្ឋបាលសារពើពន្ធនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ត្រូវបានរៀបចំដោយអាជ្ញាធរពាក់កណ្តាលស្វយ័តសម្រាប់ការគ្រប់គ្រងចំណូលសារពើពន្ធ ដែលហៅកាត់ថា (SARAS)អាជ្ញាធរនេះ ត្រូវបានបង្កើតនៅប្រទេសកូឡុំប៊ីក្នុងឆ្នាំ១៩៩១ អាហ្សង់ទីន នៅក្នុងឆ្នាំ១៩៨៨ កេនយ៉ា ក្នុងឆ្នាំ១៩៩៥ ម៉ាឡេស៊ី ក្នុងឆ្នាំ១៩៩៤ សឹង្ហបុរី ក្នុងឆ្នាំ១៩៩២ និងអ៊ូហ្គង់ដា ក្នុងឆ្នាំ១៩៩១។ ជាទូទៅ អាជ្ញាធរនេះមានលទ្ធភាពនូវការលើកទឹកចិត្ត និងប្រាក់បៀវត្សសមស្របដល់មន្ត្រីរបស់ខ្លួនជាមួយនឹងការសម្រេចបានគណនេយ្យភាព និងតម្លាភាពនៃលទ្ធផលការងារ។ អាជ្ញាធរនេះ គឺជាស្ថាប័នដោយឡែកពីស្ថាប័ននានារបស់រដ្ឋាភិបាល និងមានស្វ័យភាពខាងផ្នែកហិរញ្ញវត្ថុទៀតផង។

៣. សមាហរណកម្មរវាងរដ្ឋបាលគយ និងរដ្ឋបាលពន្ធដារ បានប្រព្រឹត្តទៅតាមប្រទេសជាច្រើនក្នុងនោះមានប្រទេសហុងគ្រី ដែលទើបបានធ្វើសមាហរណកម្ម រដ្ឋបាលទាំងពីរឱ្យទៅជារដ្ឋបាលគយ និងពន្ធដារជាតិកាលពីឆ្នាំ២០១១ ហើយប្រទេសហ្វីជី ក៏បានធ្វើសមាហរណកម្មនេះរួចហើយដែរ។ ប៉ុន្តែនៅក្នុងប្រទេសកាណាដាបានរំសាយចោលនូវសមាហរណកម្មរវាងរដ្ឋបាលទាំង២នេះវិញ ដោយបានបង្កើតឱ្យមានរដ្ឋបាលគយ និងរដ្ឋបាលពន្ធដារ ឱ្យដាច់ដោយឡែកពីគ្នា។ ពីព្រោះទីនោះរដ្ឋបាលគយបានដើរតួនាទីជាភ្នាក់ងារត្រួតពិនិត្យសន្តិសុខតាមព្រំដែនច្រើនជាងជាភ្នាក់ងារអ្នកប្រមូលចំណូលសារពើពន្ធ។ ការបង្កើតឱ្យមានរដ្ឋបាលគយ និងរដ្ឋបាលពន្ធដារ ជាអង្គការចាត់តាំងតែមួយ អាចសម្រេចបាននូវឧត្តមភាពជាច្រើន ក្នុងនោះមានធ្វើឱ្យប្រសើរឡើងនូវលំហូរព័ត៌មាន និងភាពងាយស្រួលក្នុងការអនុវត្តសវនកម្ម។ តាមប្រទេសកំពុងអភិវឌ្ឍន៍អាករលើតម្លៃបន្ថែម ត្រូវបានប្រមូលតាមរបបផ្ទៃក្នុងផង និងតាមរបបនាំចូលផង ពោលគឺរដ្ឋបាលពន្ធដារផង និងរដ្ឋបាលពន្ធគយផងដែរ។ ដូច្នេះ ការធ្វើសមាហរ-ណកម្មរវាងរដ្ឋបាលទាំង២នេះ គឺជាកត្តាមួយនៅពេលដែលនាំឱ្យអាករលើតម្លៃបន្ថែមបានរួមចំណែកកាន់តែច្រើនក្នុងចំណូលសារពើពន្ធសរុប។

៤.អង្គភាពប៉ាន់ស្មានសារពើពន្ធ គួរគប្បីបង្កើតឡើងសម្រាប់បំពេញមុខងារស្នូលក្នុងប្រព័ន្ធគ្រប់គ្រងសារពើពន្ធ។ អង្គភាពនេះ មានតួនាទីរៀបចំនិទស្សន៍ពីចំណូល និងការទទួលបានប្រាក់ពន្ធដោយបែងចែកតាមប្រភេទពន្ធស្ថាប័ន និងតំបន់។ ការប៉ាន់ស្មាន អំពីលទ្ធភាពទទួលបានប្រាក់ចំណូលសារពើពន្ធត្រូវធ្វើជាប្រចាំខែ និងត្រីមាស ដើម្បីសម្រេចបានទិសដៅនេះជាផ្នែកមួយដ៏សំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចផងដែរ។

៥. ការបង្កើតឱ្យមានអង្គភាពប្រឆាំងនឹងការកេងបន្លំប្រាក់ពន្ធ ដែលមានដំនាញខាងផ្នែកគតិយុត្តិពាក់ព័ន្ធនឹងការកេងបន្លំប្រាក់ពន្ធមានការយល់ដឹងប្រព័ន្ធយុត្តិធម៌ និងតុលាការ ព្រមទាំងអ្នកឯកទេសខាងដំរុញការអនុវត្តច្បាប់ និងមានសមត្ថភាពធ្វើសហប្រតិបត្តិការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ។

៦. ការបង្កើតឱ្យមានអង្គភាពសម្រាប់អ្នកជាប់ពន្ធធំៗ ដើម្បីផ្តោតការយកចិត្តទុកដាក់ការធ្វើសវនកម្ម និងដំរុញការអនុវត្តច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធសម្រាប់ក្រុមអ្នកជាប់ពន្ធធំៗ។ បទពិសោធន៍បានបង្ហាញថា ប្រទេសដែលបានបង្កើតអង្គភាពជាប់ពន្ធធំៗ បានសម្រេចបង្កើនូវចំណូលសារពើពន្ធ និងការកាត់បន្ថយនូវបាតុភាពមិនប្រកាសពន្ធគួរឱ្យកត់សម្គាល់។

គ) ក្របខណ្ឌគតិយុត្តិ គឺជាលក្ខណៈវិនិច្ឆ័យមួយ សម្រាប់បង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិសារពើពន្ធដែលក្នុងនោះ មានលក្ខខណ្ឌវិនិច្ឆ័យមួយចំនួនដូចខាងក្រោម៖

១. ក្រមរដ្ឋបាលសារពើពន្ធមួយ ត្រូវបានបង្កើតឡើងដើម្បីធ្វើជាផ្នែកមួយដ៏ចាំបាច់នៃនីតិសារពើពន្ធដែលក្នុងនោះមានចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ លក្ខខណ្ឌនានាដែលត្រូវបានអនុវត្តក្នុងសារពើពន្ធព្រមទាំងនីតិវិធីពាក់ព័ន្ធទាំងឡាយដូចជាធ្វើប្រតិវេទន៍ពន្ធការទទួលបានព័ត៌មានការប្រើប្រាស់នៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីរបស់រដ្ឋបាលសារពើពន្ធក្នុងនោះត្រូវមានចែងអំពីករណីប្តឹងទៅតុលាការជាដើម។

២. ការបង្កើតច្បាប់ប្រឆាំងនឹងការកេងបន្លំប្រាក់ពន្ធអាចកើតមានឡើងតាមរយៈការប្រកាសពន្ធមិនត្រឹមត្រូវ និងការក្លែងបន្លំឯកសារជាដើម។ ច្បាប់នេះ មានសារសំខាន់សម្រាប់ធ្វើជាមូលដ្ឋានដល់ការដំរុញការអនុវត្តច្បាប់។

៣. ការអនុវត្តសមត្ថកិច្ចបណ្តឹងព្រហ្មទណ្ឌ ក្នុងករណីកេងបន្លំប្រាក់ពន្ធឱ្យបានម៉ឺងម៉ាត់។

៤. ការផ្តល់ឱកាសឱ្យមានបណ្តឹងឧទ្ធរណ៍ ពីសំណាក់អ្នកជាប់ពន្ធក្នុងករណីមានការជំទាស់ជាមួយនឹងការអនុម័តរបស់រដ្ឋបាលសារពើពន្ធ ដើម្បីគាំពារដល់សិទ្ធិរបស់អ្នកជាប់ពន្ធ។

ឃ) ការដំរុញការអនុវត្តច្បាប់ គឺជាលក្ខខណ្ឌវិនិច្ឆ័យមួយដែលមាននូវសូចនាករផ្សេង ដូចខាងក្រោមនេះ៖

១. ការរៀបចំស្តង់ដារគណនេយ្យសម្រាប់ធ្វើជាឧបករណ៍កត់ត្រា ជាប្រចាំនូវមូលដ្ឋានពន្ធសម្រាប់អ្នកជាប់ពន្ធធ្វើប្រតិវេទន៍ពន្ធតាមរបបស្វ័យប្រកាស។

២. ការជ្រើសរើសតាមប្រព័ន្ធប្រតិបត្តិការសនវកម្មពន្ធ តាមរយៈបច្ចេកវិទ្យាព័ត៌មានចំពោះអ្នកជាប់ពន្ធដែលជាមុខសញ្ញាអាចកេងបន្លំប្រាក់ពន្ធ។ លក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិ បានកំណត់ ៣០ភាគរយ នៃមន្ត្រីដែលបានបំពេញការងារក្នុងរដ្ឋបាលសារពើពន្ធ ត្រូវមានការកិច្ចធ្វើសវនកម្មពន្ធ។

៣. ការប្រើប្រាស់ទិន្នន័យខាងក្រៅ គឺជាសូចនាករមួយសម្រាប់បង្ហាញអំពីលទ្ធភាពទទួលបាននូវព័ត៌មានពាក់ព័ន្ធជាមួយអ្នកជាប់ពន្ធ ដូចជាកម្មសិទ្ធក្នុងក្រុមហ៊ុនផ្សេងៗ ការចុះបញ្ជីយានយន្ត និងការកាន់កាប់នូវដីធ្លី និងអចនទ្រព្យផ្សេងទៀតជាដើម។ ព័ត៌មានប្រភេទទាំងងនេះ គឺជាប្រភពដ៏សំខាន់ក្នុងការវាយតម្លៃករណីដែលមានមន្ទិលថា ការប្រកាសពន្ធមិនមានសង្គតិភាពជាមួយនឹងទ្រព្យសម្បត្តិ។ ច្រកចូលទៅកាន់ព័ត៌មានប្រភេទទាំងនេះ គឺលក្ខខណ្ឌវិនិច្ឆ័យនៃប្រព័ន្ធសារពើពន្ធដែលឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃដំណើរការជំរុញការអនុវត្តច្បាប់។

៤. ភាគរយនៃអ្នកឈប់ធ្វើស្វ័យប្រកាសពន្ធ ធៀបទៅនឹងអ្នកធ្វើស្វ័យប្រកាសពន្ធសរុប គឺជាសូចនាករមួយបង្ហាញអំពីសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធ ក្នុងការគ្រប់គ្រង និងការរំលឹកដល់អ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ច ប្រកាសពន្ធ និងបំពេញកាតព្វកិច្ចឱ្យបានជាប្រចាំ។ ដើម្បីជាការកិច្ចនេះ រដ្ឋបាលសារពើពន្ធ ត្រូវបានបំពាក់ដោយប្រព័ន្ធកត់ត្រាស្វ័យប្រវត្តិ ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ឱ្យបានជាក់លាក់។

៥. ការឆ្លងកាត់ព័ត៌មានរវាងប្រភេទពន្ធផ្សេងៗដែលអ្នកជាប់ពន្ធត្រូវធ្វើស្វ័យប្រកាសនិងជាប់កាតព្វកិច្ចពន្ធ ដូចជាព័ត៌មានរវាងការជាប់អាករលើតម្លៃបន្ថែមតាមរបបផ្ទៃក្នុងនិងរបបនាំចូលរវាងការជាប់កាតព្វកិច្ចពន្ធលើអចលនទ្រព្យ និងពន្ធលើប្រាក់ចំណូលឬរវាងពន្ធគយ និងអាករលើតម្លៃបន្ថែមជាដើម នេះគឺជាសូចនាករមួយបង្ហាញពីកម្រិតនៃសមត្ថភាពគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធ។

៦. ចំនួនមន្ត្រីរដ្ឋបាលសារពើពន្ធម្នាក់ធៀបនឹងចំនួនប្រជាជន ១៣ន់នាក់ គឺជាលក្ខខណ្ឌវិនិច្ឆ័យមួយបង្ហាញពីទំហំនៃរដ្ឋបាលសារពើពន្ធ និងវិសាលភាពការគ្របដណ្តប់របស់រដ្ឋបាលទៅលើប្រជាជន។ បទដ្ឋានអន្តរជាតិ បានកំណត់ចំនួននេះស្មើនឹង១។ នៅកាណាដាអាឡឺម៉ង់ អង់-គ្លេស ប៊ែលហ្សិក និងបារាំង ចំនួននេះស្ថិតក្នុងចន្លោះពី ១.៥ ទៅជាង ២ ហើយនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនចំនួននេះមានកម្រិតប្រមាណ ០.៥ តែប៉ុណ្ណោះ។

៧. ចំនួនមន្ត្រីរដ្ឋបាលសារពើពន្ធ គឺលក្ខខណ្ឌវិនិច្ឆ័យមួយដែលលំបាកនឹងប្រៀបធៀបជាលក្ខណៈអន្តរជាតិដោយសារតែសូចនាកនេះ ចំណុះទៅនឹងកត្តាជាច្រើន ហើយតាមរយៈនេះមាន

កម្រិតខុសគ្នារវាងប្រទេសនីមួយៗ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកជាប់ពន្ធគ្មានប្រភពចំណូលផ្សេងក្រៅពីប្រាក់បៀវត្សរ៍ដែលត្រូវជាប់ពន្ធកាត់ទុក នោះអ្នកជាប់ពន្ធមិនចាំបាច់ធ្វើស្វ័យប្រ-កាសពន្ធទេ តាមរយៈនេះមិនត្រូវបានរាប់បញ្ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីសារពើពន្ធ។ ក្រៅពីនេះ ប្រព័ន្ធសារពើពន្ធចំណុះខ្លាំងទៅនឹងអាករលើតម្លៃបន្ថែម ហើយការចុះបញ្ជីអាករលើតម្លៃ បន្ថែម ត្រូវបានធ្វើឡើងសម្រាប់តែក្រុមហ៊ុនធំៗនោះ ធ្វើឱ្យចំនួនអ្នកជាប់ពន្ធត្រូវចុះបញ្ជីមាន កម្រិតតិចតួចជាងមុនដែរ។ ករណីខ្លះទៀត រដ្ឋបាលសារពើពន្ធបានចុះបញ្ជីពន្ធនូវរាល់បុគ្គល ទាំងឡាយណាដែលមានប្រាក់ចំណូលរាប់ទាំងអ្នកចូលនិវត្តន៍ទៀតផង។ ករណីខ្លះទៀត ពុំបានយកចិត្តទុកដាក់ការចុះបញ្ជីពន្ធចំពោះអ្នកជាប់ពន្ធជាប់កាតព្វកិច្ចបង់ពន្ធឱ្យបានគ្រប់គ្នានោះ។

៨. ប្រព័ន្ធសូចនាករជាលទ្ធផលសម្រាប់សវនកម្ម គឺជាលក្ខខណ្ឌវិនិច្ឆ័យអន្តរជាតិសម្រាប់វាយតម្លៃការងារសវនកម្មរបស់រដ្ឋបាលសារពើពន្ធ តាមរយៈបង្កើតប្រព័ន្ធឃ្លាំមើលលទ្ធផលការងារនៃសវនកម្មសារពើពន្ធដែលអាចមានទម្រង់ និងវិធីសាស្ត្រខុសៗគ្នា ហើយត្រូវពឹងផ្អែកលើមូលដ្ឋានទិន្នន័យ និងការវិភាគស្ថិតិឱ្យបានច្បាស់លាស់។

៩. ការចុះបញ្ជីអ្នកជាប់ពន្ធឱ្យបានច្បាស់លាស់ និងការធ្វើបច្ចុប្បន្នកម្មនៃបញ្ជីអ្នកជាប់ពន្ធទូទាំងប្រទេស បានប្រើកម្មវិធីកុំព្យូទ័រជំនួយដើម្បីសម្រួលដល់ការគ្រប់គ្រង និងការផ្លាស់ប្តូរទិន្នន័យនានាទៅវិញទៅមក រវាងរដ្ឋបាលសារពើពន្ធគ្រប់ជាន់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

១០. ភាគរយនៃអ្នកជាប់ពន្ធ ត្រូវបានធ្វើសវនកម្មជាប្រចាំឆ្នាំ ត្រូវបានកំណត់ដោយលក្ខខណ្ឌវិនិ-ច្ឆ័យសម្រាប់ប្រទេសអភិវឌ្ឍន៍ចំនួន១ភាគរយ។ ការធ្វើសវនកម្មច្រើនពេកអាចស្តែងឡើងនូវបាតុភូតខ្វះប្រសិទ្ធភាព និងការខាន ប៉ុន្តែការធ្វើសវនកម្មតិចពេកក៏ជាសញ្ញាមួយ បង្ហាញអំពីភាពទន់ជ្រាយក្នុងការជំរុញការអនុវត្តច្បាប់របស់រដ្ឋបាលសារពើពន្ធផងដែរ។ ការស្រាវជ្រាវជាច្រើនបានបង្ហាញថា មានទំនាក់ទំនងស្របគ្នារវាងការយល់ឃើញពីលទ្ធភាពដែលត្រូវបានធ្វើសវនកម្ម និងការអនុលោមតាមបទប្បញ្ញត្តិ។

ង) ការទទួល និងការប្រមូលពន្ធ ត្រូវបានកំណត់ដោយលក្ខខណ្ឌវិនិច្ឆ័យមួយចំនួន មានដូចខាងក្រោម៖

១. ការទូទាត់ប្រាក់ពន្ធតាមប្រព័ន្ធ ឬធនាគារការទូទាត់ប្រាក់ពន្ធ ត្រូវតែរៀបចំឱ្យមានលក្ខណៈងាយស្រួល និងការចំណាយតិចតួច ពីព្រោះបើការចំណាយក្នុងការអនុលោមតាមបទប្បញ្ញត្តិ មានកម្រិតទាបនោះ ការលើកទឹកចិត្តឱ្យមានការអនុលោមតាមបទប្បញ្ញត្តិដោយស្ម័គ្រចិត្តបានដែរ។ ដូច្នេះសេវាទូទាត់តាមគណនីរបស់ធនាគារមានប្រសិទ្ធភាព និងតម្លាភាពច្រើនជាងការទូទាត់ប្រាក់ពន្ធជាសាច់ប្រាក់នៅតាមរតនាគារ។

២.ភាគរយនៃអ្នកជាប់ពន្ធធំៗដែលបង់ពន្ធតាមបណ្តាញអ៊ីនធឺណេត គឺសូចនាករមួយបង្ហាញពីកម្រិតនៃទំនើបកម្ម និងស្វ័យប្រវត្តិកម្មរបស់រដ្ឋបាលពន្ធដារ។ ការប្រើប្រាស់បណ្តាញអ៊ីនធឺណេ-តធ្វើឱ្យមានការកែលម្អរដ្ឋបាលពន្ធដារ ជាពិសេសការកាត់បន្ថយអំពើពុករលួយ និងចំណាយអនុលោមតាមបទប្បញ្ញត្តិបានជាច្រើន។ ជាមួយគ្នានេះ បច្ចេកវិទ្យាព័ត៌មានជាក់លាក់សម្រាប់គ្រប់គ្រងការអនុលោមតាមបទប្បញ្ញត្តិសារពើពន្ធរបស់អ្នកជាប់ពន្ធធំៗ ត្រូវបានអភិវឌ្ឍ និងប្រើប្រាស់នៅតាមប្រទេសជឿនលឿនមួយចំនួន។

៣.ភាគរយនិងការមិនទូទាត់បំណុលពន្ធធៀបនឹងចំណូលសារពើពន្ធសរុបបង្ហាញសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធក្នុងការគ្រប់គ្រងការប្រព្រឹត្តបទល្មើសរបស់អ្នកជាប់ពន្ធ។ លក្ខខណ្ឌវិនិច្ឆ័យ ពុំបានកំណត់បទដ្ឋានគិតជាភាគរយឱ្យបានជាក់លាក់ទេ។

ច) ប្រព័ន្ធ និងធនធានរបស់រដ្ឋបាលសារពើពន្ធ មានបញ្ចូលលក្ខខណ្ឌវិនិច្ឆ័យមួយចំនួនដូចខាងក្រោម៖

១. នីតិវិធី និងបទបញ្ជាផ្ទៃក្នុងត្រូវបង្កើតឡើង ដើម្បីពន្យល់អំពីលក្ខខណ្ឌមុខងារ សម្រាប់អនុវត្តនូវដំណើរការទាំងឡាយណារបស់រដ្ឋបាលសារពើពន្ធ។

២.ប្រព័ន្ធផែនការ និងការតាមដាន ត្រូវបានរៀបចំជាផ្នែកមួយនៃរដ្ឋបាលសារពើពន្ធដើម្បីកំណត់គោលដៅផ្សេងៗត្រូវបានកំណត់ និងដើម្បីតាមដាននូវកម្រិតនៃការអនុវត្តតាមគោលដៅទាំងនោះ។

៣.ការសម្របសម្រួលព័ត៌មានជាមួយនឹងក្រសួងស្ថាប័ននានា ដូចជាធនាគារកណ្តាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងអាជ្ញាធរដែនដីជាដើម។ ដើម្បីទទួលបានព័ត៌មានទាក់ទងនឹងចំណូលសារពើពន្ធដោយបែងចែកតាមប្រភេទពន្ធទិន្នន័យម៉ាក្រូសេដ្ឋកិច្ចការវិនិយោគសាធារណៈ និងពាណិជ្ជកម្មអន្តរជាតិលំហូរមូលធនអន្តរជាតិបទល្មើសឬបទឧក្រិដ្ឋផ្សេងៗជាដើម។

៤. ស្វ័យប្រវត្តិកម្មនៃដំណើរការត្រូវបានអនុវត្តជាប្រក្រតីនៅក្នុងរដ្ឋបាលសារពើពន្ធទំនើប សម្រាប់ដាក់ចេញសេចក្តីប្រកាសឬលិខិតបទដ្ឋានផ្សេងៗ និងផ្តល់ព័ត៌មានពាក់ព័ន្ធសេវាទៅឱ្យអ្នកជាប់ពន្ធជាដើម។

៥. ការផ្សារភ្ជាប់ព័ត៌មានទៅវិញទៅមកវាងទីស្នាក់ការកណ្តាល និងសាខាអ្នកជាប់ពន្ធដោយបានប្រើបច្ចេវិទ្យាព័ត៌មានទំនើបសម្រាប់ផ្ទេរនិងផ្លាស់ប្តូរទិន្នន័យទាំងឡាយទាក់ទងនឹងអ្នកជាប់ពន្ធ និងការទូទាត់ប្រាក់ពន្ធ។

៦. ការពង្រឹងប្រព័ន្ធធានាសុវត្ថិភាពនៃទិន្នន័យ និងប្រព័ន្ធកុំព្យូទ័រដែលគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធ។

៧.ភាគរយនៃមន្ត្រីរដ្ឋបាលសារពើពន្ធដែលមានបរិញ្ញាប័ត្រឧត្តមសិក្សា។

៨.ផលធៀបរវាងប្រាប់បៀវត្សរបស់នាយកដ្ឋបាលសារពើពន្ធនិងប្រាក់បៀវត្សរបស់សវនករ ហើយតាមប្រទេសបណ្តាជឿនលឿនផលធៀបនេះ មានកម្រិតស្មើនឹង ២ដង។

៩. ផលធៀបរវាងប្រាប់បៀវត្សមធ្យមរបស់មន្ត្រីរដ្ឋបាលសារពើពន្ធ និងផលិតផលក្នុងស្រុសរុបម្នាក់ៗ។ នៅតាមប្រទេសមួយចំនួនផលធៀបនេះមានចំនួន២ដងឬច្រើនជាងនេះ ដើម្បីអាចទាក់ទាញអ្នកជំនាញសមស្របឱ្យចូលមកធ្វើការនៅក្នុងរដ្ឋបាលសារពើពន្ធ។ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃប្រព័ន្ធសារពើពន្ធ គឺគោលបំណងនៃការអភិវឌ្ឍន៍ប្រព័ន្ធសារពើពន្ធ ឱ្យមានលក្ខណៈទំនើប ដើម្បីឆ្លើយតបនឹងតម្រូវការរបស់វិស័យសាធារណៈនៅក្នុងការកេណ្ឌប្រមូលប្រភពហិរញ្ញប្បទានសម្រាប់បម្រើឱ្យការចំណាយរបស់វិស័យនេះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់និរន្តរភាព និងស្ថិរភាពនៃកំណើនសេដ្ឋកិច្ច។ ការគ្រប់គ្រងចំណូលសារពើពន្ធ គឺផ្នែកមួយនៃការគ្រប់គ្រងចំណូលសាធារណៈនៅតាមប្រទេសជាច្រើន។ ដូច្នេះ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គ្រប់ដណ្តប់ទៅលើកំណែទម្រង់ការគ្រប់គ្រងចំណូលសារពើពន្ធផងដែរ។ តាមលទ្ធផលនៃការស្រាវជ្រាវជាច្រើន បានបង្ហាញឱ្យឃើញថាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានជួបនូវបញ្ហាប្រឈមជាច្រើន ក្នុងការគ្រប់គ្រងចំណូលសារពើពន្ធ ឱ្យបានសមស្របនឹងកំណើនសេដ្ឋកិច្ច។ ប្រព័ន្ធសារពើពន្ធ មានធាតុអនុគ្រោះច្រើន (ការលើកលែងពន្ធ និងការលើទឹកចិត្តសារពើពន្ធតាមរូបភាពផ្សេងៗ មនសិការសារពើពន្ធមានកម្រិតទាប ជាកត្តាមួយធ្វើឱ្យមានការគេចវេសពន្ធច្រើន)។ សកម្មភាពសេដ្ឋកិច្ចគ្រប់ដណ្តប់ដោយវិស័យក្រៅប្រព័ន្ធ និងវិស័យកសិកម្ម(មានអ្នកក្រីក្រភាគច្រើនរស់នៅ និងធ្វើការក្នុងវិស័យនេះ) មានចំណែកធំក្នុងសេដ្ឋកិច្ចដែលធ្វើឱ្យមានការពង្រីកមូលដ្ឋានពន្ធជួបការលំបាក។

ជំពូកទី ៥

គោលនយោបាយសារពើពន្ធ

FISCAL POLICY

៥.១-និយមន័យ(DEFINITION)

ជាទូទៅ គោលនយោបាយសារពើពន្ធ គឺជាគោលនយោបាយដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលសំដៅលើគោលនយោបាយថវិកាជាតិ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការចំណាយរបស់រដ្ឋាភិបាល និងការកម្រិតពន្ធ។ ក្នុងបរិបទវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលអាចប្រើគោលនយោបាយទាំងពីរនេះ ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ចឡើងវិញ។ ទន្ទឹមនឹងនោះ គោលនយោបាយរូបិយវត្ថុ គឺជាគោលនយោបាយដែលបង្កើតឡើងដោយធនាគារកណ្តាលសំដៅលើគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលដែលពាក់ព័ន្ធនឹងការកម្រិតអត្រាការប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុ។ គោលនយោបាយទាំងពីរនេះ មានទំនាក់ទំនងយ៉ាងជិតស្និតនឹងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល និងព្យាយាមកែតម្រូវស្ថានភាពតម្រូវការលើសឬខ្វះខាតថវិកាជាតិ ក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលធ្វើឡើងតាមវិធីផ្សេងៗគ្នា។

ខ្លឹមសារនៃពាក្យថា "គោលនយោបាយសារពើពន្ធ" ត្រូវបានពន្យល់បង្ហាញដោយសេដ្ឋវិទូមួយចំនួន៖

ក) បើតាមទស្សនៈសេដ្ឋវិទូរបស់លោក អាត់សរ ស្មីត(Arthur Smith)ថា៖ គោលនយោបាយសារពើពន្ធ លោកបានកំណត់ថាគឺជាគោលនយោបាយរបស់រដ្ឋាភិបាលទាក់ទងកម្រិតការចំណាយនិងកម្រិតចំណូលពន្ធ ដើម្បីបង្កើនឬបន្តយដល់កម្រិតសកម្មភាពសេដ្ឋកិច្ច។ រាល់ការប្រើគោលនយោបាយរបស់រដ្ឋាភិបាលបានប្រើប្រាស់សម្រាប់កម្មវិធីចំណូល និងចំណាយរបស់ខ្លួនប៉ុណ្ណោះ ក្នុងបំណងដើម្បីបង្កើតសកម្មភាពផលិតកម្មដែលខ្លួនចង់បាន និងចៀសវាងផលប៉ះពាល់ដល់កម្រិតសេដ្ឋកិច្ច សម្រាប់កំណើនផលទុនជាតិសរុប និងនិកម្មភាពពេញលេញ។

ខ) បើតាមទស្សនៈសេដ្ឋវិទូរបស់លោកប៉ូល អេ.សេមុលអែលសុន(Paul A. Semuelson)ថា៖ គោលនយោបាយសារពើពន្ធ មានទំនាក់ទំនងរាល់សកម្មភាពសេដ្ឋកិច្ចទាំងអស់ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាល ដើម្បីកម្មវិធីកៀរគរប្រមូលចំណូលពន្ធ និងការចំណាយរបស់រដ្ឋាភិបាល ដើម្បីធ្វើឱ្យមានស្ថិរភាពសេដ្ឋកិច្ចដែលអាចសម្រេចទៅបានដោយពុំមានអតិផរណា និងបរិត្តផរណា។ គោលនយោបាយសារពើពន្ធមានន័យថាការប្រើប្រាស់ចំណូលពន្ធ និងការចំណាយរបស់រដ្ឋាភិបាលក្នុងគោលបំណងសេដ្ឋកិច្ចដើម្បី "ស្ថិរភាព" និង "ការអភិវឌ្ឍន៍"។

(គ) បើតាមទស្សនៈសេដ្ឋវិទូអង់គ្លេសលោក ចន មេណាដ កេនស៍(John Maynard Key nes) ថា៖ គោលនយោបាយសារពើពន្ធគឺជាមូលដ្ឋានគ្រឹះរបស់រដ្ឋាភិបាល អាចមានឥទ្ធិពលទៅលើការកម្រិតផលិតភាពនៃម៉ាក្រូសេដ្ឋកិច្ចតាមរយៈការបង្កើនឬបន្តយពន្ធ និងការចំណាយរបស់រដ្ឋាភិបាលតាមកម្មវិធីគោលនយោបាយសារពើពន្ធរបស់ខ្លួនចង់បាន ដើម្បីឱ្យសេដ្ឋកិច្ចមានស្ថិរភាពក្នុងរយៈពេលខ្លី។ តាមរយៈទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចនៃទ្រឹស្តីរួមស្តីពី"អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ"។ លោកកេនស៍

បានស-ង្កត់ធ្ងន់លើគោលនយោបាយសារពើពន្ធមានឥទ្ធិពលលើសេដ្ឋកិច្ចរយៈពេលខ្លី ដែលជំរុញតម្រូវការសរុ- បឱ្យកើនឡើង។

៥.២-គោលនយោបាយសារពើពន្ធ (FISCAL POLICY)

មានទស្សនៈជាច្រើន បានពន្យល់បង្ហាញពីខ្លឹមសារ "គោលនយោបាយសារពើពន្ធ"។ គោលនយោបាយសារពើពន្ធ គឺសំដៅលើគោលនយោបាយថវិការបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងលើការចំណាយសាធារណៈ និងការកៀរគរប្រមូលចំណូលពន្ធដែលមានឥទ្ធិពលលើលំនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ តាមរយៈការគ្រប់គ្រងគោលនយោបាយថវិកាជាតិឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច។ គោលនយោបាយសារពើពន្ធជាវិធានការនានាដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាព និងជាពិសេសរៀបចំ កម្រិតចំណូលពន្ធ និងការចំណាយរបស់រដ្ឋាភិបាល។ វិធានការណ៍គោលនយោបាយសារពើពន្ធ ត្រូវបានគេប្រើជាញឹកញាប់ស្របនឹងគោលនយោបាយរូបិយវត្ថុ ដើម្បីសម្រេចបានគោលដៅសេដ្ឋកិច្ចជាក់លាក់មួយ។

៥.២.១-តើអ្វីជាគោលនយោបាយសារពើពន្ធ ? (WHAT'S FISCAL POLICY ?)

រដ្ឋាភិបាលបណ្តាប្រទេសនានាលើពិភពលោក ត្រូវការប្រាក់ចំណូលចាំបាច់ដើម្បីប្រើប្រាស់ក្នុងការដឹកនាំគ្រប់គ្រងអភិវឌ្ឍប្រទេសជាតិឱ្យមានវិបុលភាព និងវឌ្ឍនភាព។ តើអ្វីជាលទ្ធភាពក្នុងការរកចំណូលចូលថវិកាជាតិដែលរដ្ឋាភិបាលអាចប្រតិបត្តិការបាន? តើអ្វីជាប្រសិទ្ធភាពនៃការចំណាយរបស់រដ្ឋាភិបាល? តើត្រូវមានប្រតិបត្តិការចំណូលចំណាយបែបណាដើម្បីធានាឱ្យបានការលូតលាស់របស់ប្រទេសជាតិ? ចម្លើយគឺមានចែងក្នុងគោលនយោបាយសំខាន់ៗមួយចំនួនក្នុងចំណោមគោលនយោ-បាយនានារបស់រដ្ឋាភិបាល។ ក្នុងនោះរួមមាន គោលនយោបាយថវិកា គោលនយោបាយរូបិយវត្ថុ គោលនយោបាយសារពើពន្ធ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយថវិកាជាដើម

ទន្ទឹមនឹងនេះ គោលនយោបាយសារពើពន្ធ គឺសំដៅលើការយកពន្ធ និងវិធីសាស្ត្រកៀរគរចំណូលផ្សេងៗទៀត និងការចំណាយរបស់រដ្ឋាភិបាល ដើម្បីធ្វើការបែងចែកធនធានកម្រសេដ្ឋកិច្ចក្នុងគោលបំណងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ហេតុដូច្នេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយសារពើពន្ធ រដ្ឋាភិបាលត្រូវអនុវត្តសកម្មភាពសំខាន់ៗ មានដូចជា៖

(១)-ប្រសិទ្ធភាពនៃការគ្រប់គ្រង និងកៀរគរចំណូល និង

(២)-ធ្វើវិចារណកម្មលើចំណាយ ដោយបែងចែកចំណាយថវិការវាងការប្រើប្រាស់ និងការវិនិ-យោគសាធារណៈឱ្យបានសមស្រប។

ក្នុងនោះដែរ រដ្ឋាភិបាលបណ្តាប្រទេសនីមួយៗមានគោលដៅជាគោលការណ៍រួមចំនួន៤ ដើម្បីសម្រេចបានគោលបំណងសេដ្ឋកិច្ចគឺ៖

១-ការបែងចែកធនធាន

២-ស្ថិរភាពរូបនីយកម្ម

៣-កំណើន

៤-ការបែងចែកនៃប្រាក់ចំណូលនៃទ្រព្យសម្បត្តិឱ្យស្មើគ្នា។

ដូចនេះ គោលនយោបាយសារពើពន្ធ ក្រៅពីការកម្រិតពន្ធ និងការចំណាយរបស់រដ្ឋាភិបាល។ គោលនយោបាយសារពើពន្ធ ត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបែងចែកកម្រិតធនធានកម្រសេដ្ឋកិច្ច និងជំរុញសង្វាក់ផលិតកម្មមានការកើន ឬថយចុះផងដែរ។ ហេតុនេះ គោលនយោបាយសារពើពន្ធ មានទំនាក់ទំនងទៅនឹងការប្រើប្រាស់របស់គ្រួសារ និងការចំណាយរបស់រដ្ឋាភិបាល ការកម្រិតពន្ធ និងខ្ចីប្រាក់ដែលជាកត្តាជះឥទ្ធិពលលើកម្រិតកំណើនសេដ្ឋកិច្ចនៃតម្រូវការសរុប (AD) នៃកម្រិតផលិតផលជាតិសរុប សមីការ៖ Y=AD=C+I+G+NX និងកម្រិតអនិកម្មភាព ជាពិសេសដំណើរការលូតលាស់ពាណិជ្ជកម្មអន្តរជាតិ។ គោលនយោបាយសារពើពន្ធ ក៏ត្រូវបានគេប្រើដើម្បីធ្វើការផ្លាស់ប្តូរម៉ូដែលនៃការចំណាយរបស់រដ្ឋាភិបាលលើកត្តាផលិតកម្ម។ គោលនយោបាយសារពើពន្ធ មានន័យថាការបែងចែកប្រាក់ចំណូល និងទ្រព្យសម្បត្តិជាតិឡើងវិញរបស់រដ្ឋាភិបាលដែលអាចសម្រេចទៅបានតាមរយៈការផ្លាស់ប្តូរអត្រាពន្ធលើប្រាក់ចំណូល ឬទ្រព្យសម្បត្តិខុសៗគ្នា។ ពោលគឺជាគោលនយោបាយសារពើពន្ធ ក៏ជាយន្តការអន្តរាគមន៍របស់រដ្ឋាភិបាលចំពោះសេដ្ឋកិច្ចខ្នាតតូច (Microeconomic) ដើម្បីកែលម្អការប្រកួតប្រជែងសេដ្ឋកិច្ចទីផ្សារសេរី។ ទន្ទឹមនឹងនេះ ការផ្លាស់ប្តូរគោលនយោបាយសារពើពន្ធ ក៏មានផលប៉ះពាល់ដល់តម្រូវការសរុប និងការផ្តត់ផ្គង់សរុបផងដែរ។

វិទ្យាសាស្ត្រសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ គឺការប្រើប្រាស់ចំណូល និងការចំណាយរបស់រដ្ឋាភិបាល ដើម្បីធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ចទាំងមូល។ គោលនយោបាយសារពើពន្ធ គឺជាផ្នែកមួយនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាតិដែលបានព្យាយាមរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែងតាមរយៈការគ្រប់គ្រងអត្រាការប្រាក់ និងការផ្តត់ផ្គង់រូបិយវត្ថុ។ នៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចជាតិ ដើម្បីរក្សានូវស្ថិរភាពលំនឹងកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ហេតុដូចនេះ រដ្ឋាភិបាលប្រទេសនីមួយៗ តែងតែប្រើនូវគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ។ ករណីសកម្មភាពសេដ្ឋកិច្ចបានធ្លាក់ចុះ ឬរីកចម្រើនតិចតួចនោះ រដ្ឋាភិបាលប្រើគោលនយោបាយសារពើពន្ធ។ ចំពោះសកម្មភាពកំណើនសេដ្ឋកិច្ចខ្លាំងក្លាដែលអាចធ្វើឱ្យមានកម្រិតអតិផរណាតម្រូវការកើនខ្ពស់អាចប្រើគោលនយោបាយរូបិយវត្ថុជំនួសវិញ។

ក្នុងទ្រឹស្តីសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ គឺជាទ្រឹស្តីជំរុញឱ្យមានចរន្តសេដ្ឋកិច្ចខាងផ្នែកតម្រូវការជាជាងខាងផ្នែកផ្តត់ផ្គង់ក្នុងប្រព័ន្ធសេដ្ឋកិច្ច មានពីរផ្នែកសំខាន់គឺ៖ (១)-ផ្នែកតម្រូវការសរុប និង(២)-ផ្នែកការផ្តត់ផ្គង់សរុប។

ពាក្យថាគោលនយោបាយសារពើពន្ធ ពុំមែនគ្រាន់តែជាចលករពន្ធតែមួយផ្នែកប៉ុណ្ណោះទេ ប៉ុន្តែក៏ជាចលករជំរុញកំណើនសេដ្ឋកិច្ចផងដែរ។ រដ្ឋាភិបាល មានគម្រោងបង្កើននូវការចំណាយថវិកាបន្ថែម ដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ពីព្រោះបង្កើនការចំណាយរបស់រដ្ឋាភិបាល (G↑) នឹងជំរុញឱ្យមានការកើនតម្រូវការសរុប (AD↑) តាមរយៈប្រាក់ចំណូលកើនឡើង នាំឱ្យកើនចំណាយលើការប្រើប្រាស់ (C↑) ឬការសន្សំរបស់គ្រួសារ (S↑) ។ ជាពិសេស ការចំណាយលើសេវាសាធារណៈរបស់រដ្ឋាភិបាលជាចលករជំរុញមានតម្រូវការសរុបកើន (AD↑) និងជាកម្លាំងចលករជំរុញឱ្យមានការវិនិយោគឯកជនកើន (I↑) និងការផ្តត់ផ្គង់សរុបកើនឡើង (AS↑) ផងដែរ។

ទន្ទឹមនេះ គោលនយោបាយសារពើពន្ធ មានយន្តការសំខាន់ៗ ដូចជា៖

- ការចំណាយរបស់រដ្ឋាភិបាល (Government Spending) និង
- ការកម្រិតពន្ធ (Taxes)
- ផ្គួបគ្នាបញ្ចូលគ្នាទាំងពីរ

ចំពោះគោលនយោបាយរូបិយវត្ថុវិញ មានយន្តការសំខាន់ៗដូចជា៖

- ការកម្រិតអត្រាការប្រាក់ (Interest rate) និង
- ការផ្តត់ផ្គង់រូបិយវត្ថុ (Money supply)
- ផ្គួបគ្នាបញ្ចូលគ្នាទាំងពីរ

ដូច្នេះ គោលនយោបាយរបស់រដ្ឋាភិបាល គឺជាគោលនយោបាយថវិកាជាតិ ឬហៅថាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ជាតិដើម្បីធ្វើឱ្យមានស្ថិរភាពថ្លៃ អត្រាអនិកម្មភាព និងរក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ដូចនេះ ដើម្បីអនុវត្តនូវគោលនយោបាយខាងលើនេះ ចាំបាច់ត្រូវប្រើម៉ូដែលម៉ាក្រូសេដ្ឋកិច្ច។

តើអ្វីជាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច?


ម៉ាក្រូសេដ្ឋកិច្ចគឺការសិក្សាផ្តោតលើសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូល។ រួមមាន ការសិក្សាអំពីផលទុនជាតិសរុប អត្រានិកម្មភាព ដើម្បីឱ្យយល់ពីសកម្មភាពសេដ្ឋកិច្ចជាតិ។ ដូចនេះ ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចបានបង្កើតម៉ូដែលនេះ ដើម្បីពន្យល់អំពីចលកសេដ្ឋកិច្ច៖

- ចំណូលជាតិ (National income)
- ផលិតផល (Output)
- ការប្រើប្រាស់ (Consumption)
- អត្រាអនិកម្មភាព (Unemployement rate)
- អតិផរណា (Inflation)
- ការសន្សំ (Saving)
- ការវិនិយោគ (Investment)
- ពាណិជ្ជកម្មអន្តរជាតិ (International Trade) និង
- ហិរញ្ញវត្ថុអន្តរជាតិ (International Finance)។

ដូចនេះផលិតផលជាតិសរុប (GDP) គឺចំណូលជាតិសរុបក្នុងសកម្មភាពសេដ្ឋកិច្ច និងបរិមាណចំណាយសរុបលើទំនិញនិងសេវារបស់សេដ្ឋកិច្ច។ មានសមាសធាតុចំណាយចំនួន៤យ៉ាង ដូចជា៖ ចំណាយលើការប្រើប្រាស់របស់គ្រួសារ (C) ចំណាយលើការវិនិយោគ (I) ចំណាយរបស់រដ្ឋាភិបាល (G) និងការនាំចេញសុទ្ធ (NX) អាចតាងសមីការសេដ្ឋកិច្ចគឺ៖ Y=GDP=C+I+G+NX នៅក្នុងបរិបទសេដ្ឋកិច្ចបើកចំហមានទំនាក់ទំនងនឹងពាណិជ្ជកម្មអន្តរជាតិ។ ករណីសេដ្ឋកិច្ចបិទមិនមានទំនាក់ទំនងនឹងពាណិជ្ជកម្មអន្តរជាតិ ឬមិនពាក់ព័ន្ធការខ្ចី និងការផ្តល់កម្ចីជាអន្តរជាតិ សមីការសេដ្ឋកិច្ចគឺ Y=GDP=C+I+G មានន័យថា ការនាំចេញស្មើនឹងសូន្យ។

ជាលទ្ធផល គោលនយោបាយសារពើពន្ធ គឺដើម្បីការគ្រប់គ្រងប្រាក់ចំណូល និងចំណាយរបស់រដ្ឋាភិបាល ជាចាំបាច់ដើម្បីប្រើប្រាស់ក្នុងការដឹកនាំ និងគ្រប់គ្រងអភិវឌ្ឍប្រទេសជាតិឱ្យមានវិបុលភាព និងវឌ្ឍនភាព។ គោលនយោបាយសារពើពន្ធ មានមុខងារបែងចែកថវិកាជាតិ សម្រាប់ផ្តល់ទំនិញនិងសេវាដល់សង្គមជាតិទាំងមូល រួមទាំងការរៀបចំគោលនយោបាយថវិកាដើម្បីធ្វើការបែងចែកធនធានសេដ្ឋកិច្ចប្រកបដោយ "សមភាព"និង"ការកែតម្រូវ" បែងចែកប្រាក់ចំណូលជាតិ និងទ្រព្យសម្បត្តិប្រជាជាតិ។ ម្យ៉ាងវិញទៀត ដើម្បីរក្សានូវស្ថិរភាពនៃគោលនយោបាយថវិកាជាតិនូវនិកម្មភាពពេញលេញ ស្ថិរភាពថ្លៃ និងអត្រាកំណើនសេដ្ឋកិច្ចឱ្យសមស្រប ដោយមិនមានផលប៉ះពាល់ដល់វិស័យពាណិជ្ជកម្ម និងតុល្យ-ភាពជញ្ជីងទូទាត់ ដោយសារគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល។ ការផ្លាស់ប្តូរនូវគោល នយោបាយសារពើពន្ធ និងសមាសភាពផ្សេងៗទៀតនៃចលករសេដ្ឋកិច្ច អាចមានការប្រែប្រួលចំណូលពន្ធ និងការចំណាយសាធារណៈរបស់រដ្ឋាភិបាល។ ហើយគោលនយោបាយសារពើពន្ធបានជះឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ចមានដូចជា៖ ការចំណាយលើការប្រើប្រាស់របស់គ្រួសារ និងការចំណាយរបស់រដ្ឋាភិបាល ការកម្រិតពន្ធ និងការខ្ចីប្រាក់។ ជាពិសេស កម្រិតកំណើនសេដ្ឋកិច្ចពាក់ព័ន្ធនឹងតម្រូវការសរុបនៃកម្រិតផលទុនជាតិសរុប និងនិកម្មភាព និងការវិនិយោគវិស័យឯកជនជាដើម។

គំនូសតាងទី២៖ គោលនយោបាយរបស់រដ្ឋាភិបាល(Government policy)



៥.២.២-ឧបករណ៍នៃគោលនយោបាយសារពើពន្ធ(TOOLS OF FISCAL POLICY)


រដ្ឋាភិបាលបណ្តាប្រទេសនានា តែងតែប្រើគោលនយោបាយសារពើពន្ធដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចជាតិ ត្រូវបានធ្វើការកែទម្រង់លើចំណូលថវិកាជាតិ និងការចំណាយថវិកាជាតិ។ ឧទាហរណ៍ សហរដ្ឋអាមេរិករួមមានទាំងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិបញ្ញត្តិ ត្រូវបានប្រើប្រាស់គោលនយោ-បាយសារពើពន្ធ។ ចំណែកឯការវិនិយោគវិស័យឯកជន ពុំមានឧបករណ៍គោលនយោបាយសារពើពន្ធនោះទេ។ ដូច្នេះ គោលនយោបាយសារពើពន្ធ គឺឧបករណ៍សម្រាប់អនុវត្តនូវគោលនយោបាយរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ ចំពោះការវិនិយោគលើវិស័យឯកជន មិនអាចជាផ្នែកណាមួយនៃសារពើពន្ធនោះទេ ពីព្រោះរដ្ឋាភិបាលគ្មានការគ្រប់គ្រងដោយផ្ទាល់ទៅលើការវិនិយោគឯកជនឡើយ។ ជាឧបករណ៍សម្រាប់ប្រើតែក្នុងគោលនយោបាយសារពើពន្ធ រួមមានការកម្រិតពន្ធ និងចំណាយរបស់រដ្ឋាភិបាល។

បើតាមទស្សនៈទ្រឹស្តីគោលនយោបាយសារពើពន្ធរបស់សេដ្ឋវិទូ ចន មេណាដ កេនស៍ បានពន្យល់ថា"កម្រិតនៃការកើនឡើងចំណូលពន្ធឬការថយចុះចំណូលពន្ធ និងការចំណាយរបស់រដ្ឋាភិបាល មានឥទ្ធិពលលើកម្រិតអត្រាអតិផរណា អត្រានិកម្មភាព និងលំហូរសាច់ប្រាក់ ចេញពីប្រព័ន្ធសេដ្ឋកិច្ច "។

ក្រាហ្វិកទី១ ខាងក្រោមនេះបានបង្ហាញអំពីឧបករណ៍គោលនយោបាយសារពើពន្ធ មានឥទ្ធិពលលើការប្រែប្រួលតម្រូវការសរុប និងការផ្គត់ផ្គង់សរុប ក្នុងបរិបទសេដ្ឋិច្ចរយៈពេលខ្លី និងរយៈពេលវែង។ ចំនុចសមតាក្នុងកម្រិតសេដ្ឋកិច្ចបឋម រវាងខ្សែកោងតម្រូវការសរុប (AD) និងខ្សែកោងការផ្គត់ផ្គង់សរុប (SRAS) នៅក្នុងបរិបទសេដ្ឋកិច្ចរយៈពេលខ្លីដែលជាចំនុចប្រសព្វរវាងកម្រិតថ្លៃ (P_1) និងបរិមាណផលទុនជាតិ (Q_1)។ ចំពោះបរិបទសេដ្ឋកិច្ចរយៈពេលវែងបម្រែបម្រួលនៃតម្រូវការសរុប និងការផ្គត់ផ្គង់សរុបនាំឱ្យរំកិលខ្សែកោងផ្គត់ផ្គង់សរុបទៅខាងស្តាំ អាចជាឥទ្ធិពលរុញចេញនៃគោលនយោបាយសារពើពន្ធពង្រីកដោយសារការប្រែប្រួលកម្រិតថ្លៃ។ ការណ៍នេះជំរុញឱ្យតម្រូវការសរុបកើនឡើង ហើយសកម្មភាពផលិតកម្មកើនផងដែរ។ ជាកត្តាជំរុញឱ្យមានបរិមាណការផ្គត់ផ្គង់សរុបកើនឡើង ហើយបរិមាណផលទុនជាតិសរុបកើនឡើងរំកិលពី (Q_1) ទៅរក (Q_2) គឺកម្រិតគម្លាតសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត បរិមាណការផ្គត់ផ្គង់សរុបមានការកើនឡើង (LRAS↑) ករណីកម្រិតប្រែប្រួលថ្លៃបានកើន (P↑) ជំរុញឱ្យមានសកម្មភាពបង្កើនផលិតកម្មលើការផ្គត់ផ្គង់ទំនិញ និងសេវា ហើយកំណើនសេដ្ឋកិច្ចរយៈពេលវែងនឹងមានឥទ្ធិពលរុញចេញនៃបរិមាណផលទុនជាតិសរុបរំកិលពី (Q_1) ទៅរក (Q_2) និងកម្រិតថ្លៃ។

ដូចនេះ គោលនយោបាយសារពើពន្ធ មានឥទ្ធិពលរុញចេញតម្រូវការសរុបទៅខាងស្តាំ នាំឱ្យមានកំណើនបរិមាណផលទុនជាតិសរុបដែលធ្វើឱ្យរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច។ រដ្ឋាភិបាល អាចនឹងជួបប្រទះកំណើនកម្រិតអតិផរណាតម្រូវការ ដោយសារវិធានការណ៍គោលនយោបាយសារពើពន្ធពង្រីកនេះ។ វិធានការណ៍គោលនយោបាយសារពើពន្ធត្រូវបានគេប្រើជាញឹកញាប់ស្របនឹងគោលនយោបាយរូបិយវត្ថុ ដើម្បីសម្រេចបានគោលដៅជាក់លាក់។

ក្រាហ្វិកទី១៖ ឧបករណ៍គោលនយោបាយសារពើពន្ធ



៥.២.៣-ប្រភេទនៃគោលនយោបាយសារពើពន្ធ (TYPES OF FISCAL POLICY)

ផ្អែកលើបទពិសោធន៍ ក្នុងការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលល្អប្រសើរ និងមានប្រសិទ្ធភាព។ បណ្តារដ្ឋាភិបាលប្រទេសនានា ត្រូវបានផ្តោតលើគោលនយោបាយសារពើពន្ធ ដើម្បីធ្វើឱ្យបានសមស្របតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។ សេដ្ឋកិច្ចសម័យទំនើបភាគច្រើន អនុវត្តកំណែទម្រង់មួយចំនួនលើមុខងារហិរញ្ញវត្ថុសាធារណៈ ជាពិសេសការសម្រេចចិត្តលើគោលនយោបាយសារពើពន្ធរបស់ពួកគេ។ បណ្តាប្រទេសអភិវឌ្ឍន៍ភាគច្រើន គោលបំណងចម្បងនៃគោលនយោបាយសារពើពន្ធ គឺដើម្បីទប់ទល់ទៅនឹងផលប៉ះពាល់ដែលបង្កឡើងដោយការប្រែប្រួលសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះដែរ គោលនយោបាយសារពើពន្ធ គឺត្រូវបានប្រើជាយន្តការដើម្បីប្រមូលចំណូលពន្ធ និងការចំណាយសាធារណៈរបស់រដ្ឋាភិបាលដែលមានឥទ្ធិពលលើលំនឹងស្ថិរភាពសេដ្ឋកិច្ចជាតិរយៈពេលវែង។ ករណី សកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ ឬរីកចម្រើនតិចតួច ហើយរដ្ឋាភិបាលប្រើនូវគោលនយោបាយសារពើពន្ធ។

ដូចនេះ គោលនយោបាយសារពើពន្ធមានពីរប្រភេទសំខាន់ រួមមាន៖

១.គោលនយោបាយសារពើពន្ធពង្រីក(Exapansionary Fiscal Policy) គឺគោលនយោបាយសារពើពន្ធដែលរដ្ឋាភិបាលបង្កើនការចំណាយ និងការកាត់បន្ថយពន្ធ ឬរួមបញ្ចូលគ្នាលក្ខខណ្ឌទាំងពីរសម្រាប់ការបញ្ចុះកម្រិតពន្ធ គឺមានឥទ្ធិពលលើប្រាក់ចំណូលជាតិសរុប និងចំណាយលើការប្រើប្រាស់របស់គ្រួសារ ពីព្រោះរដ្ឋាភិបាលបានបង្កើនការចំណាយសាធារណៈរបស់ខ្លួន ដើម្បីដំរុញកំណើនតម្រូវការសរុប។ ម្យ៉ាងវិញទៀត ដោយសារតែមេគុណនៃពន្ធ (Tax multiplier) គឺតូចជាងមេគុណនៃការចំណាយ (Spending multiplier) ។

២.គោលនយោបាយសារពើពន្ធបង្រួម (Contractionary Fiscal Policy) គឺគោលនយោបាយសារពើពន្ធដែលរដ្ឋាភិបាលកាត់បន្ថយការចំណាយ ឬដំឡើងពន្ធ ឬរួមបញ្ចូលគ្នានៃលក្ខខណ្ឌទាំងពីរ។ ចំពោះគោលនយោបាយសារពើពន្ធបង្រួម គឺផ្ទុយពីគោលនយោបាយសារពើពន្ធពង្រីក ដោយសារតែគោលនយោបាយនេះ បានធ្វើឱ្យថយចុះនូវតម្រូវការសរុបដែលនាំឱ្យថយចុះការចំណាយលើការប្រើប្រាស់របស់គ្រួសាររួមទាំងកាត់បន្ថយការវិនិយោគឯកជន ករណីការកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាល។ ម្យ៉ាងវិញទៀត គឺមេគុណនៃពន្ធ (Tax multiplier) គឺធំជាងមេគុណនៃការចំណាយ (Spending multiplier)។ ហេតុដូច្នេះ គោលដៅក្នុងការអនុវត្តនូវគោលនយោបាយសារពើពន្ធទាំងពីរ មានទិសដៅបញ្ច្រាស់គ្នា។

គំនូសតាងខាងក្រោមនេះ បង្ហាញអំពីប្រភេទនៃគោលនយោបាយទាំងពីរ គឺជាគោលនយោបាយសារពើពន្ធពង្រីក និងគោលនយោបាយសារពើពន្ធបង្រួម ត្រូវបានផ្លាស់ប្តូរទៅតាមតម្រូវការជាក់លាក់ណាមួយរបស់រដ្ឋាភិបាលស្តីពីយុទ្ធសាស្ត្រគ្រប់គ្រងគោលនយោបាយថវិកាជាតិ និងផ្តោតលើការកៀរគរចំណូល និងការចំណាយរបស់រដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពដល់សកម្មភាពសេដ្ឋកិច្ច។

គំនូសតាងទី៣៖ ប្រភេទនៃគោលនយោបាយសារពើពន្ធ

ប្រភេទនៃគោលនយោបាយសារពើពន្ធ	ការផ្លាស់ប្តូរចំណាយរដ្ឋាភិបាល		ការផ្លាស់ប្តូរកម្រិតពន្ធ
ពង្រីក	↑	និង/ឬ	↓
បង្រួម	↓	និង/ឬ	↑

៥.២.៤-គោលបំណងនៃគោលនយោបាយសារពើពន្ធ (OBJECTIVE: FISCAL POLICY)

តើគោលនយោបាយសារពើពន្ធ មានគោលបំណងអ្វីខ្លះ?

គោលបំណងនៃគោលនយោបាយសារពើពន្ធ គឺដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច រក្សាស្ថិរភាពថ្លៃ យុត្តិ ធម៌សង្គម និងរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចជាដើម។ គោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល អាចសម្រេចទៅបានលុះត្រាតែយន្តការនៃគោលនយោបាយសារពើពន្ធ ដូចជាការចំណាយសាធារណៈ ការកម្រិតពន្ធ ការខ្ចីប្រាក់ ការផ្តល់នូវហិរញ្ញប្បទានឥនភាព ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងគោលបំណងសេដ្ឋកិច្ច។

ភាពជោគជ័យនៃគោលនយោបាយសារពើពន្ធ អាស្រ័យលើការចាត់វិធានការគោលនយោបាយសារពើពន្ធ ទាន់ពេលវេលា និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការអនុវត្តគោលនយោបាយនេះ។

ដូច្នេះ គោលបំណងគោលនយោបាយសារពើពន្ធមាន៖

១- ប្រសិទ្ធភាពសេដ្ឋកិច្ច (Economics efficiency)៖ ដើម្បីធានាឱ្យបាននូវការប្រើប្រាស់និងការបែងចែកធនធានខ្សត់កម្ររបស់សេដ្ឋកិច្ចឱ្យបានសមស្រប។ ក្នុងគោលបំណងសេដ្ឋកិច្ចនេះ អាចសម្រេចទៅបាននៅពេលដែលធនធានទាំងនេះ ត្រូវបានធ្វើផលិតកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុតដោយមិនខ្ជះខ្ជាយធនធានខ្សត់កម្ររបស់សេដ្ឋកិច្ច។

២- សមតាសេដ្ឋកិច្ច(Economic equity)៖ សេដ្ឋកិច្ចនេះ មានការទាក់ទងនឹងការបែងចែកប្រាក់ចំណូល និងទ្រព្យសម្បត្តិជាតិក្នុងសង្គមជាតិមួយប្រកបដោយស្មើភាព ឬសមធម៌។ ការបែងចែកប្រាក់ចំណូលសមរម្យ មានន័យថាគម្លាតរវាងអ្នកមាន និងអ្នកក្រ គឺឱ្យភាពយឺតរួញមកតូច។

៣- កំណើនសេដ្ឋកិច្ច(Economic growth)៖ គោលបំណងនៃកំណើនសេដ្ឋកិច្ច គឺជាសមត្ថ-ភាពសេដ្ឋកិច្ចក្នុងការផលិតទំនិញនិងសេវាកម្ម ក្នុងរយៈពេលជាក់លាក់មួយ។ ផលិតផលក្នុងស្រុកសរុបបានវាស់វែងសមត្ថភាពផលិតភាពរបស់សេដ្ឋកិច្ចជាតិ ដែលគិតគូរពីលទ្ធផលពិតប្រាកដនៃសេដ្ឋកិច្ចទាំងមូល។

៤- សេរីភាពសេដ្ឋកិច្ច(Economic freedom)៖ សេរីភាពសេដ្ឋកិច្ច ត្រូវបានសម្រេចខណៈពេលដែលសមាជិកនៃសង្គមនីមួយៗ អាចធ្វើការជ្រើសរើស ឬធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។ ប្រជាជនមានសេរីភាពក្នុងការទិញទំនិញ និងសេវាកម្ម និងការកាន់កាប់ទ្រព្យសម្បត្តិ ភាពមានការងារធ្វើ ឬការបង្កើតអាជីវកម្មក្នុងសេដ្ឋកិច្ច មិនមានឧបសគ្គពីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃ។

៥- សន្តិសុខសេដ្ឋកិច្ច(Economic security)៖ ការណ៍នេះ ពាក់ព័ន្ធនឹងការការពារប្រឆាំងនឹងហានិភ័យសេដ្ឋកិច្ចដែលប្រជាជនក្នុងសង្គមសេដ្ឋកិច្ច មានសមត្ថភាពរកប្រាក់ចំណូល និងមានស្ថិរភាពសម្រាប់ការរស់នៅសមរម្យ។

៦- និកម្មភាពពេញលេញ(Full employment)៖ នេះកើតមានឡើងនៅពេលដែលធនធានដែលមានទាំងអស់ត្រូវបានប្រើប្រាស់ ដើម្បីជាសមត្ថភាពក្នុងការផលិតទំនិញនិងសេវាកម្ម។ នេះត្រូវបានបង្ហាញពីភាពមានការងារធ្វើនៃកម្លាំងពលកម្មដែលត្រូវបានវាស់វែងដោយអត្រានិកម្មភាព ឬអត្រាអនិកម្មភាព។

៧- ស្ថិរភាពសេដ្ឋកិច្ច(Economic stabitity)៖ អាចជួយឱ្យកម្រិតសេដ្ឋកិច្ច កាត់បន្ថយការប្រែប្រួលខ្លាំងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជាតិ។ មិនមានអតិផរណា ក៏ដូចជាបរិត្តផរ-ណា។ អាចនិយាយបានថា សេដ្ឋកិច្ចមានស្ថិរភាពថ្លៃនៃទំនិញនិងសេវាកម្ម។

៨- តុល្យភាពពាណិជ្ជកម្មសមហេតុផល(Reason balance of trade)៖ គោលដៅនេះ គឺត្រូវតែសម្រេចឱ្យបាននៅពេលបរិមាណនាំចេញរបស់ប្រទេសមួយកាន់តែច្រើន ដែលច្រើនជាងបរិមាណនាំចូលរបស់ខ្លួន។

៥.៣-ទិដ្ឋភាពទ្រឹស្តីគោលនយោបាយសារពើពន្ធ (THEORY OF FISCAL POLICY)

រដ្ឋាភិបាលជាអ្នកបង្កើតនយោបាយសារពើពន្ធ និងអនុវត្តនយោបាយសារពើពន្ធក្នុងគោលបំណងសំខាន់ពីរយ៉ាងគឺ៖

១)-ដើម្បីជួយបង្កើនល្បឿនកំណើនសេដ្ឋកិច្ច៖ ក្នុងករណីសកម្មភាពសេដ្ឋកិច្ច មានផលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច ឬកំណើនសេដ្ឋកិច្ចតិចតួច រដ្ឋាភិបាលបានប្រើគោលនយោបាយសារពើពន្ធពង្រីក ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច ឬបិទបញ្ចប់គម្លាតវិបត្តិសេដ្ឋកិច្ច។

២)-ដើម្បីជួយបន្ថយល្បឿនកំណើនសេដ្ឋកិច្ច៖ ករណីសេដ្ឋកិច្ចមានផលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចខ្លាំក្លាពេក អាចបណ្តាលឱ្យមានអតិផរណាតម្រូវការ ហើយពេលនោះរដ្ឋាភិបាលអាចប្តូរមកប្រើនូវគោលនយោបាយសារពើពន្ធបង្រួមដើម្បីបន្ថយកល្បឿនសេដ្ឋកិច្ចវិញ។

៥.៣.១-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធអំឡុងវិបត្តិសេដ្ឋកិច្ច (EFFECT OF FISCAL POLICY: RECESSIONARY GAP)

ប្រសិនបើ សេដ្ឋកិច្ចបានជួបប្រទះការធ្លាក់ចុះនៃតម្រូវការសរុប ហេតុការណ៍នេះអាចជាស្ថានភាពការធ្លាក់ចុះនៃកង្វះខាតនៃតម្រូវការសរុប មានន័យថាមានគម្លាតនៃវិបត្តិសេដ្ឋកិច្ច(Recessionary gap)។ ដូចនេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងសកម្មភាពធ្លាក់ចុះនៃវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលប្រទេសនានា អាចនឹងប្រើគោលនយោបាយសារពើពន្ធពង្រីក មានន័យថាបង្កើនចំណាយសាធារណៈរបស់រដ្ឋាភិបាល និងបន្ថយកម្រិតពន្ធដើម្បីជួយជំរុញតម្រូវការសរុបរំកិលទៅផ្នែកខាងស្តាំ។

សេដ្ឋកិច្ចកំពុងមានគម្លាតវិបត្តិសេដ្ឋកិច្ចមានន័យថាការចំណាយលើវិស័យឯកជនក្នុងសកម្មភាពសេដ្ឋកិច្ចបានធ្លាក់ចុះ ដូចជាការធ្លាក់ចុះចំណាយលើការប្រើប្រាស់របស់គ្រួសារ ការធ្លាក់ចុះការវិនិយោគរបស់វិនិយោគិន និងការធ្លាក់ចុះការនាំចេញសុទ្ធជាដើម ជាកត្តាបណ្តាលឱ្យថយចុះតម្រូវការសរុប។ ដូចនេះ ដើម្បីដោះស្រាយគម្លាតនៃវិបត្តិសេដ្ឋកិច្ចនេះ រដ្ឋាភិបាលអាចនឹងព្យាយាមប្រើនូវគោលនយោបាយសារពើពន្ធពង្រីក។ មានន័យថាអនុវត្តនូវគោលនយោបាយសារពើពន្ធពង្រីក ដោយប្រើយន្តការរួមមាន៖

១)-ការកាត់បន្ថយពន្ធ(Reduction taxes) និង/ឬ

២)-ការបង្កើនចំណាយរបស់រដ្ឋាភិបាល(Increasing government spending)

ទន្ទឹមនឹងនេះ ការកាត់បន្ថយកម្រិតពន្ធ ឬបង្កើនចំណាយរបស់រដ្ឋាភិបាលត្រូវបានប្រើអាស្រ័យលើសកម្មភាពសេដ្ឋកិច្ចមានកត្តាពីរគឺ៖


- ទំហំនៃគម្លាតវិបត្តិសេដ្ឋកិច្ច(Size of recessionary gap)
- ទំហំនៃមេគុណចំណាយ(Size of spending multiplier)

សរុបជារួម ទស្សន:សេដ្ឋវិទូលោកកេនស៍បានណែនាំថា បង្កើនការចំណាយរបស់រដ្ឋាភិបាល និងតំហយពន្ធ គឺវិធីសាស្ត្រល្អបំផុតសម្រាប់ជំរុញឱ្យមានតម្រូវការសរុបកើនឡើង។ លោកកេ-នស៍ បានពន្យល់បន្ថែមថា គោលនយោបាយសារពើពន្ធ មានឥទ្ធិពលលើសេដ្ឋកិច្ចរយៈពេលខ្លី ដើម្បីបង្កើនតម្រូវការសរុប និងជំរុញការវិនិយោគលើវិស័យឯកជន។

ដូចនេះ ការអនុវត្តគោលនយោបាយសារពើពន្ធនេះ អាស្រ័យទៅលើទំហំនៃគម្លាតវិបត្តិសេដ្ឋកិច្ច និងទំហំនៃមេគុណចំណាយរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយគម្លាតនៃវិបត្តិសេដ្ឋកិច្ច។ បរិបទសេដ្ឋកិច្ចរយៈពេលវែងមានកម្រិតអតិរណាតម្រូវការបានកើនឡើងខ្ពស់ ហេតុការណ៍នេះ រដ្ឋាភិបាលអាចធ្វើការផ្លាស់ប្តូរមកប្រើគោលនយោបាយសារពើពន្ធបង្រួមវិញ ដើម្បីរាំងខ្ទប់កម្រិតកំណើនអតិផរណាតម្រូវការ។

ក្រាហ្វិកទី២ខាងក្រោម បង្ហាញអំពីឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីក កំឡុងពេលគម្លាតវិបត្តិសេដ្ឋកិច្ចបានធ្លាក់ចុះ ត្រង់ចំនុចប្រសព្វរវាងការប្រែប្រួលថ្លៃ (P) និងផលិតផលជាតិសរុប (Y) គឺជាចំនុចសមតារវាងខ្សែកោងតម្រូវការសរុប (AD) និងខ្សែកោងការផ្គត់ផ្គង់សរុប (SRAS) ដែលគម្លាតវិបត្តិសេដ្ឋកិច្ចបានធ្លាក់ចុះ។ ករណីគម្លាតនៃវិបត្តិសេដ្ឋកិច្ចឬកែចម្រើនតិចតួច មានឥទ្ធិពលលើខ្សែកោងតម្រូវការសរុបរំកិលទៅខាងឆ្វេង រដ្ឋាភិបាលបានប្រើគោលនយោបាយសារពើពន្ធពង្រីក តាមរយៈបង្កើនការចំណាយរបស់រដ្ឋាភិបាល និងបន្ថយកម្រិតពន្ធ ដើម្បីទប់ស្កាត់គម្លាតនៃវិបត្តិសេដ្ឋកិច្ច និងបានជំរុញខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំ នៅចំនុចប្រសព្វរវាងការប្រែប្រួលថ្លៃពី (P) ទៅរក (P_{fg}) និងប្រែប្រួលនៃផលិតផលជាតិសរុបរំកិលពី (Y) ទៅរក (Y_{fg}) គឺជាចំនុចសមតាថ្មីរវាងខ្សែកោងតម្រូវការសរុប (AD_1) និងខ្សែកោងផ្គត់ផ្គង់សរុប (LRAS) ដែលជាគម្លាតកំណើនសេដ្ឋកិច្ច(រុញចេញ)។ សម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែង (LRAS) ការប្រែប្រួលនៃផលិតផលជាតិសរុប (Y_{fg}) ដែលការផ្លាស់ប្តូរកម្រិតផលិតផលជាតិសរុបនេះ រត់ស្របនឹងអ័ក្សរបញ្ឈរត្រង់កម្រិតប្រែប្រួលនៃថ្លៃគឺ (P_{fg})។ ផលទុនជាតិសរុប (Y_{fg}) និងកម្រិតប្រែប្រួលថ្លៃ (P_{fg}) គឺចំនុចសមតារវាងខ្សែកោងតម្រូវការសរុប (AD_1) និងខ្សែកោងផ្គត់ផ្គង់សរុប (LRAS)។ ប៉ុន្តែសកម្មភាពសេដ្ឋកិច្ចរយៈពេលវែង កម្រិតថ្លៃមានការប្រែប្រួលធ្វើឱ្យមានការកើនការវិនិយោគ ដោយសារតែកម្រិតថ្លៃកាន់តែខ្ពស់។

ក្រាហ្វិកទី២៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធកំឡុងវិបត្តិសេដ្ឋកិច្ច




៥.៣.២-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើចំនុចសមតា

(EFFECTS OF FISCAL POLICY ON AD-AS EQUILIBRIUM)

ទិដ្ឋភាពទ្រឹស្តី បានបង្ហាញលើក្រាហ្វិកទី៣ខាងក្រោម ស្តីពីឥទ្ធិពលគោលនយោបាយសារពើពន្ធ នៅពេលសកម្មភាពសេដ្ឋកិច្ចបានធ្លាក់ចុះ និងអត្រាអនិកម្មភាពកើនខ្ពស់។ ទំនាក់ទំនងរវាងកម្រិតថ្លៃ (P_0) និងកម្រិតផលទុនជាតិសរុប (Y_0) គឺជាចំនុចសមតាកម្រិតសេដ្ឋកិច្ចបឋម (E_0) ដែលជាចំនុចប្រសព្វរវាងខ្សែកោងតម្រូវការសរុប (AD_0) និង ខ្សែកោងការផ្គត់ផ្គង់សរុប(AS_0) នៅក្នុងបរិបទសកម្មភាពសេដ្ឋកិច្ចរយៈពេលខ្លី។ អំឡុងពេលរដ្ឋាភិបាល អនុវត្តគោលនយោបាយសារពើពន្ធពង្រីក ដោយបង្កើនការចំណាយរបស់រដ្ឋាភិបាល ($G\uparrow$) និងបន្ថយកម្រិតពន្ធ ($T\downarrow$) នាំឱ្យខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំ។ ដូចនេះ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធ បានរុញច្រានទៅខាងស្តាំកម្រិតសមតាសេដ្ឋកិច្ចថ្មីរំកិលពី (E_0) ទៅរក (E_1) ការកើនតម្រូវការសរុបតាមរយៈបង្កើនការចំណាយសាធារណៈ និងបន្ថយកម្រិតពន្ធនាំឱ្យរំកិលខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំពី (AD_0) ទៅរក (AD_1)។ ការណ៍នេះ នាំឱ្យកម្រិតនៃផលទុនជាតិសរុបបានកើន ($Y_{GTP}\uparrow$) ។ ដូច្នេះ កម្រិតគម្លាតនៃវិបត្តិសេដ្ឋកិច្ច និងកម្រិតកំណើនសេដ្ឋកិច្ចកម្រិតផលទុនជាតិសរុបបានរំកិលពី(Y_0) ទៅរក (Y_{GTP}) ជាកត្តារុញច្រានបិទបញ្ចប់វិបត្តិសេដ្ឋកិច្ចរយៈពេលខ្លី។ ជាលទ្ធផល ទិដ្ឋភាពទ្រឹស្តីនៃគោលនយោបាយសារពើពន្ធត្រង់ចំណុចសមតារវាងខ្សែកោងតម្រូវការសរុប និងខ្សែកោងការផ្គត់ផ្គង់សរុប មានឥទ្ធិពលលើកម្រិតនៃគម្លាតវិបត្តិសេដ្ឋកិច្ច និងត្រូវបានបិទបញ្ចប់វិបត្តិសេដ្ឋកិច្ច។

ដូចនេះ គោលនយោបាយសារពើពន្ធពង្រីក តាមរយៈបង្កើនការចំណាយសៀវាសាធារណៈ និងកាត់បន្ថយកម្រិតពន្ធ ដើម្បីជំរុញកំណើនតម្រូវការសរុប បានធ្វើឱ្យមានកំណើនវិនិយោគលើវិស័យឯកជនតាមរយៈការឱ្យខ្ចីប្រាក់ដែលផ្តល់កម្រិតអត្រាការប្រាក់ទាប បង្កើនសកម្មភាពផលិតកម្ម។

ក្រាហ្វិកទី៣៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធត្រង់ចំនុចសមតា



៥.៣.៣-ឥទ្ធិពលនៃគោលនយោបាយពង្រីកលើការផ្គត់ផ្គង់សរុប (EFFECT OF FISCAL POLICY: SUPPLY-SIDE)

តើការធ្លាក់ចុះនៃប្រាក់ចំណូលពន្ធ មានឥទ្ធិពលទៅលើការផ្គត់ផ្គង់សរុបយ៉ាងដូចម្តេច? រដ្ឋាភិបាលតែងតែពឹងផ្អែកលើការកៀរគរប្រមូលចំណូលពន្ធ ដើម្បីគ្រប់គ្រងចំណាយសាធារណៈ និងរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ករណីចំណូលពន្ធធ្លាក់ចុះក៏នាំឱ្យបរិមាណចំណូលជាតិសរុបធ្លាក់ចុះផងដែរ។ ពេលកម្រិតពន្ធលើអាជីវកម្មមានកម្រិតនៅទាប បានជួយលើកទឹកចិត្តដល់សកម្មភាពវិនិយោគថ្មីថ្មោងៗដើម្បីចំណាយលើមូលធនដើមទុនវិនិយោគបានកើនឡើង តាមរយៈភាគហ៊ុនដើមទុនកើនកាន់តែច្រើន ជំរុញបង្កើនសមត្ថភាពផលិតកម្មនាំឱ្យខ្សែកោងការផ្គត់ផ្គង់សរុបកើនឡើង អាចនឹងផ្លាស់ប្តូរទៅខាងស្តាំ ដូចបង្ហាញក្នុងក្រាហ្វិកទី៤ខាងក្រោម។

តើការកើនឡើងការចំណាយរបស់រដ្ឋាភិបាល នឹងជះឥទ្ធិពលទៅលើផ្នែកការផ្គត់ផ្គង់សរុបយ៉ាងដូចម្តេច?


ឥទ្ធិពលលើផ្នែកការផ្គត់ផ្គង់សរុបមានពីរលក្ខខណ្ឌ៖

(១)-ប្រសិនបើរដ្ឋាភិបាលបង្កើនការចំណាយរបស់ខ្លួនលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុ-ខាភិបាល និងគម្រោងដទៃទៀតដែលបង្កើនផលិតភាពនៃធនធានសេដ្ឋកិច្ចជាតិនាំឱ្យខ្សែកោងផ្គត់ផ្គង់សរុបកើនឡើងរុញចេញទៅខាងស្តាំ។

(២)-ប្រសិនបើរដ្ឋាភិបាលបង្កើនការចំណាយរបស់ខ្លួន ធ្វើឱ្យអត្រាការប្រាក់កើនឡើង នាំឱ្យខ្សែកោងការផ្គត់ផ្គង់សរុបថយចុះ អាចនឹងផ្លាស់ប្តូរទៅផ្នែកខាងឆ្វេង និងការវិនិយោគឯកជនក្នុងមូលធនថយចុះ និងបន្តយទំហំភាគហ៊ុនដើមទុននឹងនាំឱ្យខ្សែកោងផ្គត់ផ្គង់សរុបថយចុះ រុញច្រានទៅខាងឆ្វេង។

សរុបជារួម បង្កើនការចំណាយលើវិស័យវិនិយោគរបស់រដ្ឋាភិបាលដែលនាំឱ្យការផ្គត់ផ្គង់សរុបកើនឡើង អាចនឹងផ្លាស់ប្តូររុញចេញទៅខាងស្តាំ។ ការបង្កើនចំណាយរបស់រដ្ឋាភិបាល បានជះឥទ្ធិពលរុញចេញលើតម្រូវការសរុប និងជំរុញបង្កើនផលិតផលជាតិសរុប តាមរយៈគម្រោងវិនិយោគធំៗរបស់រដ្ឋាភិបាលដែលនាំឱ្យមានការកើនឡើងការចំណាយរបស់គ្រួសារ ដោយសារតែមានប្រាក់ចំណូលពីថ្លៃឈ្នួលពលកម្ម។

ក្រាហ្វិកទី៤៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីកលើការផ្គត់ផ្គង់សរុប



៥.៣.៤-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ


(DISCREPTIONARY: CLOSE RECESSIONARY GAP)

ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ ក្នុងករណីបិទគម្លាតវិបត្តិសេដ្ឋកិច្ចខ្សែកោងតម្រូវការសរុប (AD*) និងខ្សែកោងការផ្គត់ផ្គង់សរុប ($SRAS_{e^*}$) ក្នុងបរិបទសេដ្ឋកិច្ចរយៈពេលខ្លី គឺ

ជាចំនុចប្រសព្វសមតាថ្មី (e*)។ កម្រិតចំណូលជាតិសរុបបានធ្លាក់ចុះពី (Ye*) មកកម្រិត (Ye˝) បានទទួលរងឥទ្ធិពលរុញចូលដោយរុញច្រាននូវតម្រូវការសរុបឱ្យថយចុះ ជាកម្រិតគម្លាតនៃវិបត្តិសេដ្ឋកិច្ច រយៈពេលខ្លី។

ជាលទ្ធផល កម្រិតគម្លាតនៃវិបត្តិសេដ្ឋកិច្ចធ្លាក់ចុះពី (Ye˝) និង (Ye*) ត្រូវបានបិទបញ្ចប់នូវគម្លាតនៃវិបត្តិសេដ្ឋកិច្ច ករណីរដ្ឋាភិបាលអនុវត្តគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិជាកត្តាចាំបាច់ត្រូវបានបង្កើនបរិមាណតម្រូវការសរុបឱ្យបានត្រឹមត្រូវ។ បង្កើនការទិញទំនិញរបស់រដ្ឋាភិបាល និងការធ្លាក់ចុះចំណូលពន្ធសុទ្ធ ឬរួមបញ្ចូលគ្នានាំឱ្យផ្លាស់ទីខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំពី (AD) ទៅរក (AD*) ។ ឥទ្ធិពលរុញច្រានចេញ បានរំកិលទៅរកកម្រិតផលទុនជាតិសរុប (AD_e^f) ជំរុញឱ្យមានកំណើនសក្តានុពលសេដ្ឋកិច្ចថ្មីត្រង់ចំនុច (e*) ។

ក្រាហ្វិកទី៥៖ ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ



៥.៤-គោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ (DISCRETIONARY OF FISCAL POLICY)

តើអ្វីជាភាពសមហេតុផលនៃវិធានការរបស់គោលនយោបាយសារពើពន្ធ? តើរដ្ឋាភិបាល ត្រូវតែដំឡើងពន្ធ ឬបញ្ចុះពន្ធ បង្កើនការចំណាយ ឬបន្ថយការចំណាយរបស់រដ្ឋាភិបាលនៅពេលណា? តើក្នុងស្ថានភាពបែបនេះ រដ្ឋាភិបាលមានចេតនាបង្កើតឱ្យមានឱនភាពថវិកា ឬអតិរេកថវិកា?

ដូចនេះ គោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ គឺជាគោលនយោបាយដែលចាត់ចែងដោយចេតនាលើកម្រិតពន្ធ និងការចំណាយរបស់រដ្ឋាភិបាលដែលត្រូវបានអនុម័តដោយរដ្ឋសភា ដើម្បីបង្កើនល្បឿន ឬបន្ថយល្បឿនសេដ្ឋកិច្ចជាតិដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច។

ការប្រើពាក្យសព្ទ "ឆន្ទានុសិទ្ធិ" មានន័យថាការកម្រិតពន្ធ និងការចំណាយរបស់រដ្ឋាភិបាល ត្រូវបានផ្លាស់ប្តូរទៅតាមសេចក្តីសម្រេចរបស់រដ្ឋាភិបាល និងបានអនុម័តដោយសភា។ ការផ្លាស់ប្តូរនេះមិនមែនកើតឡើងដោយស្វ័យប្រវត្តិនោះទេ ពោលគឺទាល់តែមានការយល់ព្រមពីរដ្ឋសភាផងដែរ។

គំនូសតាងទី៤៖ គោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិ



គោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិនេះ មានយន្តការពីរសំខាន់គឺ៖

១) គោលនយោបាយសារពើពន្ធពង្រីក (Expansionary fiscal policy) គឺជាគោលនយោបាយសារពើពន្ធដែលជួយបង្កើនល្បឿនកំណើនសេដ្ឋកិច្ច។

២) គោលនយោបាយសារពើពន្ធបង្រួម (Contractionary fiscal policy) គឺជាគោលនយោបាយសារពើពន្ធ ដែលជួយបន្ថយល្បឿនកំណើនសេដ្ឋកិច្ច។

សរុបជារួម រដ្ឋាភិបាលប្រទេសនានាតែងតែប្រើគោលនយោបាយសារពើពន្ធពង្រីក ដើម្បីជួយបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងបិទបញ្ចប់គម្លាតវិបត្តិសេដ្ឋកិច្ច និងគោលនយោបាយសារពើពន្ធបង្រួម ដើម្បីជួយកាត់បន្ថយល្បឿនកំណើនសេដ្ឋកិច្ច និងរាំងខ្ទប់កម្រិតអតិផរណាតម្រូវការកើន (Infl a-tion pull demand)។


៥.៤.១-គោលនយោបាយសារពើពន្ធពង្រីក (EXPANSIONARY OF FISCAL POLICY)

តាមទស្សនៈសេដ្ឋវិទូអង់គ្លេសលោក ចន មេណាដ កេនស៍ បានណែនាំថា ការបង្កើន "តម្រូវការ"របស់រដ្ឋាភិបាល ត្រូវប្រើប្រាស់នូវគោលនយោបាយសារពើពន្ធពង្រីក ដោយបង្កើនការចំណាយរបស់ រដ្ឋាភិបាល (G↑) និងការកាត់បន្ថយកម្រិតពន្ធ (T↓) ។ បង្កើនការចំណាយសាធារណៈ (G↑) អាចប្រព្រឹត្តិទៅបានតាមរយៈការបង្កើនចំណាយសេវាសាធារណៈ ឬបំពេញសេចក្តីត្រូវការរបស់ប្រជាពល- រដ្ឋ ដោយផ្តល់ឱ្យថវិកាសម្រាប់សោធនិវត្តន៍ មនុស្សចាស់ជរា និងការផ្តល់អាហារូបករណ៍ជាដើម។ ដូចនេះ តាមរយៈយន្តការរបស់រដ្ឋាភិបាលទាំងនេះ នាំឱ្យកើនឡើង "កម្លាំងទិញ" និងកើនឡើង "តម្រូវការ"នៅក្នុងសេដ្ឋកិច្ច។ ពេលដែល"តម្រូវការ"កើនឡើង នាំឱ្យកើនឡើងនូវកត្តាផលិតកម្ម នៅទីបំផុតគឺកំណើនតម្រូវការនៃកម្លាំងពលកម្ម។ កំណើនខាងតម្រូវការកម្លាំងពលកម្ម មានន័យថាមនុស្សមានការ ងារធ្វើពេញលេញ ហើយមានប្រាក់បៀវត្ស ទស្សនៈរបស់លោកកេនស៍ យល់ថានឹងធ្វើឱ្យកើនឡើងនូវ"កម្លាំងទិញ"ថែមទៀត។ ការណ៍នេះ ជាកត្តានាំឱ្យមានការវិនិយោគបន្ថែមទៅលើផលិតកម្មទំនិញនិងសេវា ព្រមទាំងបង្កើតឱ្យមានការងារធ្វើពេញលេញប្រាក់បៀវត្ស និងកំណើនសេដ្ឋកិច្ចជាតិទាំងមូល។

ទស្សនៈជាច្រើនយល់ថា វិធានការសារពើពន្ធរបស់រដ្ឋាភិបាលប្រើប្រាស់ ដើម្បីជួយធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាពបានក្លាយជាយន្តការសំខាន់ នាសម័យមហាវិបត្តិសេដ្ឋកិច្ចសកលនាឆ្នាំ១៩៣០។ តាមរយៈទស្សនៈទ្រឹស្តីរួមរបស់លោក ចន មេណាដ កេនស៍ ស្តីពី"*អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ*" បានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៣៦ បានដើរតួនាទីជាគន្លឹះបញ្ជាក់អំពីវិធានការសារពើពន្ធដ៏មានសារសំខាន់ និងផ្តល់នូវភាពចាំបាច់។ ចាប់តាំងពីពេលនោះមក មុខវិជ្ជាម៉ាក្រូសេដ្ឋកិច្ច បានចូលរួមក្នុងការរៀបចំនូវវិធានការសារពើពន្ធ និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាតិ។ ក្នុងនោះដែរ លោក ចន មេណាដ កេនស៍ បានលើកយកទ្រឹស្តីជារួមថា ការកើនឡើងនូវទម្រង់នៃការចំណាយរបស់រដ្ឋាភិបាល គឺដើម្បីប្រយុទ្ធប្រឆាំងទៅនឹងកម្លាំងធ្លាក់ចុះសេដ្ឋកិច្ច(Recession force)។ អំឡុងពេលវិបត្តិសេដ្ឋកិច្ចសកលលោក កេនស៍ បានគូសបញ្ជាក់ថា រដ្ឋាភិបាលអាចប្រើប្រាស់នូវអំណាចរបស់ខ្លួន ដើម្បីជំរុញការចំណាយរបស់រដ្ឋាភិបាល និងកម្រិតពន្ធដែលមានឥទ្ធិពលរុញចេញតម្រូវការសរុបឱ្យកើនឡើងរំកិលទៅរកខាងស្តាំបាន។

ចំពោះបរិបទសេដ្ឋកិច្ចរយៈពេលវែង កំណើនកម្រិតអតិផរណាតម្រូវការ បានកើនឡើងភាពចាំបាច់របស់រដ្ឋាភិបាល ត្រូវតែផ្លាស់ប្តូរមកប្រើគោលនយោបាយសារពើពន្ធបង្រួមវិញ ដើម្បីរាំងខ្ទប់កម្រិតអតិផរណាតម្រូវការនេះ។

គំនូសតាងទី៥៖ ការអនុវត្តគោលនយោបាយសារពើពន្ធ



ដូចនេះ គោលនយោបាយសារពើពន្ធពង្រីក (Expansionary of Fiscal Policy) គឺជាច្បាប់នៃការកាត់បន្ថយអត្រាអនិកម្មភាព និងបង្កើនផលិតផលក្នុងស្រុកសរុបពិត ដើម្បីបិទបញ្ចប់គម្លាតនៃវិបត្តិសេដ្ឋកិច្ចធ្លាក់ចុះ។ ការធ្លាក់ចុះការចំណាយលើវិស័យវិនិយោគឯកជន បណ្តាលមកពីការធ្លាក់ចុះនៃតម្រូវការសរុប និងផលិតផលក្នុងស្រុកសរុបពិតត្រូវបានធ្លាក់ចុះផងដែរ។ ទន្ទឹមនឹងនេះ ទីផ្សារការងារពលកម្មក៏បានធ្លាក់ចុះព្រមគ្នា ជាហេតុបង្កឱ្យមានអត្រាអនិកម្មភាពកើនឡើង។ ជាលទ្ធផល ការប្រើវគោលនយោបាយសារពើពន្ធពង្រីក អាចជួយបង្កើននូវផលិតផលក្នុងស្រុកសរុប និងបង្កើតការងារពលកម្មកើនឡើងវិញបាន។

ក្នុងទិដ្ឋភាពទ្រឹស្តីនៃការអនុវត្តគោលនយោបាយសារពើពន្ធពង្រីករួមមាន៖

- ការបង្កើនចំណាយរបស់រដ្ឋាភិបាល បានជំរុញឱ្យផ្លាស់ប្តូរទីនៃខ្សែតម្រូវការសរុបរំកិលទៅខាងស្តាំច្រើនជាងការផ្លាស់ប្តូរចំណាយរបស់រដ្ឋាភិបាល ដោយសារចំនួនមេគុណ(multiplier)។
- ការធ្លាក់ចុះនៃកម្រិតពន្ធ(បង្កើនប្រាក់ចំណូល និងបង្កើនចំណាយលើការប្រើប្រាស់ដោយពេលវេលានៃការផ្លាស់ប្តូរប្រាក់ចំណូលឧបនិស្ស័យលើចំណាយម៉ាជីន (MPC) តម្រូវការសរុបដែលបានផ្លាស់ប្តូរទីទៅខាងស្តាំ ដោយសារការផ្លាស់ប្តូរច្រើនដងនៃការចំណាយលើការប្រើ ប្រាស់។
- ការរួមបញ្ចូលគ្នាការកើនឡើងនៃការចំណាយរបស់រដ្ឋាភិបាល និងការកាត់បន្ថយកម្រិតពន្ធ។
- ករណីបើថវិកាមានតុល្យភាពពីដំបូង គោលនយោបាយសារពើពន្ធពង្រីកបង្កើតឱ្យមានឱនភាពថវិកា។

អំឡុងពេលដំណើរសេដ្ឋកិច្ចមិនចម្រើនទៅមុខ គឺកើតឡើងភាពចាំបាច់គោលនយោបាយសារពើពន្ធពង្រីក ពោលគឺគោលនយោបាយនេះសំដៅឱ្យមានកំណើនសេដ្ឋកិច្ច។ យើងបានអង្កេតឃើញថា

ការធ្លាក់ចុះនៃការចំណាយលើវិស័យវិនិយោគ វាបណ្តាលឱ្យខ្សែកោងតម្រូវការសរុបនៅក្នុងសេដ្ឋកិច្ច មានការធ្លាក់ចុះ។ ជាលទ្ធផលរំពឹងទុកទទួលបានប្រាក់ចំណេញពីគម្រោងវិនិយោគ គឺមានភាពស្រពេចស្រ-ពិល។ ដូច្នេះការចំណាយលើការវិនិយោគ និងបរិមាណតម្រូវការសរុប ត្រូវបានកាត់បន្ថយជាច្រើន។

ឧបមាថា រដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិក បរិមាណផលិតផលក្នុងស្រុកសរុបពិត ត្រូវបានកាត់បន្ថយទឹកប្រាក់ចំនួន៥០៥ប៊ីលានដុល្លារ ដែលជាទំហំទឹកប្រាក់ប្រហាក់ប្រហែលទៅនឹងកម្រិតផលិតកម្ម ក្នុងករណីភាពមាននិកម្មភាពពេញលេញមានត្រឹមតែទឹកប្រាក់ចំនួន ៤៨៥ប៊ីលានដុល្លារ តែប៉ុណ្ណោះ ។ ដូច្នេះ ការធ្លាក់ចុះបរិមាណផលិតផលក្នុងស្រុសរុបប្រមាណទឹកប្រាក់ចំនួន ២០ប៊ីលានដុល្លារ បណ្តាលឱ្យរួមដំណើរជាមួយនឹងកំណើនភាពគ្មានការងារធ្វើកើនឡើងផងដែរ។ ដោយហេតុថា កត្តា ផលិតកម្មមួយចំនួនត្រូវបានកាត់បន្ថយកាន់តែតិចទៅៗ គឺថាតម្រូវការកម្លាំងពលកម្មក៏កាន់តែតិចៗទៅ ។ ដូច្នេះដំណើរកំណើនសេដ្ឋកិច្ច គឺស្ថិតក្នុងដំណាក់កាលធ្លាក់ចុះជារួមជាមួយអនិកម្មភាពជាវដ្ត។ ស្ថិតក្នុងស្ថានភាពបែបនេះ តើរដ្ឋាភិបាលសហព័ន្ធសហរដ្ឋអាមេរិក ត្រូវមានវិធានការបែបណាខ្លះលើបញ្ហានេះ?

រដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិក មានលទ្ធភាពសំខាន់៣យ៉ាង សម្រាប់អនុវត្តគោលនយោ-បាយសារពើពន្ធពង្រីក៖

១-បង្កើនការចំណាយរបស់រដ្ឋាភិបាល

២-កាត់បន្ថយពន្ធ

៣-ផ្គួបគ្នាបញ្ចូលគ្នាទាំងពីរ។

ប្រសិនបើថវិការដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិក មានតុល្យភាពនោះ គោលនយោបាយសារពើពន្ធពង្រីក អំឡុងពេលគម្លាតវិបត្តិសេដ្ឋកិច្ចធ្លាក់ចុះ គឺត្រូវសំដៅលើការបង្កើតឱនភាពថវិកាជាតិពោល គឺជាបង្កើនការចំណាយរបស់រដ្ឋាភិបាលឱ្យខ្ពស់ជាងប្រាក់ចំណូលពន្ធ ដើម្បីជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើនតម្រូវការសរុប(ឥទ្ធិពលរុញចេញ)។

ប្រសិនបើ ថវិការដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិក មានអតុល្យភាពនោះគោលនយោបាយសារពើពន្ធបង្រួម អំឡុងពេលអតិផរណាតម្រូវការ គឺត្រូវសំដៅទៅលើការបន្ថយឱនភាពថវិកា ពោលគឺបង្កើនប្រាក់ចំណូលពន្ធខ្ពស់ជាងការចំណាយរបស់រដ្ឋាភិបាល ដើម្បីជួយរាំងខ្ទប់កម្រិតអតិផរណាតម្រូវការតាមរយៈកាត់បន្ថយតម្រូវការសរុប(ឥទ្ធិពលរុញចូល)។

គោលនយោបាយសារពើពន្ធ ជាជម្រើសរបស់រដ្ឋាភិបាលចំពោះវដ្តសេដ្ឋកិច្ចទាំងមូលនៃការទិញឬការកម្រិតពន្ធរបស់រដ្ឋាភិបាល។ ពោលគឺគោលនយោបាយសារពើពន្ធដែលមានឥទ្ធិពលលើការសន្សំ ការវិនិយោគ និងដំណើរកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ដំណើរការសេដ្ឋកិច្ចរយៈពេលខ្លីឥទ្ធិពលគោ-លនយោបាយសារពើពន្ធ គឺមានលើតម្រូវការសរុបសម្រាប់ទំនិញនិងសេវាកម្មជាក់លាក់។

៥.៤.២-ការបង្កើនចំណាយរបស់រដ្ឋាភិបាល(INCREASING GOVERNMENT SPENDING)

បទពិសោធន៍របស់រដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៦២ រដ្ឋបាលប្រធានាធិប-តេយ្យ John F. Kennedy ជាប្រធានាធិបតេយ្យទី៣៥របស់សហរដ្ឋអាមេរិក។ លោក Kennedy បានស្នើសុំសេចក្តីព្រាងច្បាប់ស្តីពីការបញ្ចុះពន្ធដោយគ្មានការកាត់បន្ថយចំណាយរដ្ឋាភិបាល។ នៅក្នុងរដ្ឋបាលប្រធានាធិបតី Lyndon B. Johnson ជាប្រធានាធិបតេយ្យទី៣៦របស់សហរដ្ឋអាមេរិក ក៏បានអនុវត្តសេចក្តីព្រាងច្បាប់ស្តីពីការបញ្ចុះពន្ធ និងមិនបានកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាលដែរ។ រហូតមកដល់ឆ្នាំ១៩៩០ រដ្ឋបាលរបស់ប្រធានាធិបតេយ្យ Gorge W. Bush ជាប្រធានាធិបតេយ្យទី ៣៧ ក៏បានអនុម័តនូវកញ្ចប់ថវិកាច្បាប់ស្តីពីការកម្រិតពន្ធ និងការចំណាយរបស់រដ្ឋាភិបាលសំដៅទៅលើកាត់បន្ថយឱនភាពថវិការបស់រដ្ឋសហព័ន្ធទឹកប្រាក់ចំនួន ៥០០ប៊ីលានដុល្លារ ក្នុងរយៈពេល៥ឆ្នាំ។ ក្នុងរយៈពេល៣ឆ្នាំបន្ទាប់មកនៅក្នុងរដ្ឋបាលប្រធានាធិបតេយ្យ William Jefferson Clinton ជាប្រធានាធិប- តេយ្យទី៤២ របស់សហរដ្ឋអាមេរិក បានដំឡើងអត្រាពន្ធលើប្រាក់ចំណូលបុគ្គល និងការកាត់បន្ថយការចំ-ណាយរបស់រដ្ឋាភិបាល សំដៅកាត់បន្ថយឱនភាពថវិការដ្ឋសហព័ន្ធ។

បទពិសោធន៍នៃវិបត្តិសេដ្ឋកិច្ច នាទសវត្សរ៍១៩៣០ និងទសវត្សរ៍១៩៦០។ រដ្ឋបាលប្រធានាធិប-តេយ្យសហរដ្ឋអាមេរិក បានប្រើគោលនយោបាយសារពើពន្ធឱ្យដើរតួនាទីយ៉ាងសំខាន់ ដើម្បីអន្តរាគមន៍វិបត្តិសេដ្ឋកិច្ចដោយធ្វើឱ្យមានការផ្លាស់ប្តូរខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំ (រុញចេញ) ដូចបានបង្ហាញលើក្រាហ្វិកទី៦ខ្សែកោងតម្រូវការសរុប (AD_1) រំកិលទៅខាងស្តាំខ្សែកោងតម្រូវការសរុប (AD_2)។

រដ្ឋាភិបាលសហព័ន្ធសហរដ្ឋអាមេរិក បានបន្ធូរបន្ថយការចំណាយឱ្យធ្លាក់ចុះដោយរដ្ឋាភិបាលត្រូវបានបែងចែកថវិកាចំនួន៥ប៊ីលានដុល្លារ បន្ថែមលើការសាងសង់ផ្លូវ ប្រព័ន្ធផ្គាយណប និងពន្ធនាគារ សហព័ន្ធជាដើម។ ការចំណាយបន្ថែមនេះ លើអង្គត់អ័ក្សដេកចន្លោះរវាងខ្សែកោងតម្រូវការសរុប (AD_1)។ នៅក្នុងកម្រិតនៃថ្លៃទូទៅ បរិមាណផលិតផលជាតិសរុបពិត (realGDP) ដែលបរិមាណតម្រូវការសរុប(ទំហំតម្រូវការសរុប) គឺមានទំហំទឹកប្រាក់ចំនួន៥ប៊ីលានដុល្លារ បានកើនច្រើនជាងមុននៅពេលរដ្ឋាភិ-បាលសហរដ្ឋបានបង្កើនការចំណាយសាធារណៈរបស់ខ្លួន។ ប៉ុន្តែខ្សែកោងតម្រូវការសរុបត្រូវបានផ្លាស់ទីរំកិលទៅខាងស្តាំរុញចេញ ពោលគឺជាបរិមាណតម្រូវការសរុបត្រូវបានកើនឡើង ច្រើនជាងទឹកប្រាក់ ៥ប៊ីលានដុល្លារ ពីលើការចំណាយរបស់រដ្ឋាភិបាលទឹកប្រាក់ចំនួន ២០ប៊ីលានដុល្លារបន្ថែមទៀត។ ការណ៍នេះ បានកើតមានឡើងដោយសារតែឥទ្ធិពលមេគុណ (Multiplier) បន្ថែមលើការប្រែប្រួលតម្រូវការសរុបដំបូងជាមួយរៀងរាល់វដ្តនៃចំណាយលើការប្រើប្រាស់ថ្មីនីមួយៗជាបន្តបន្ទាប់។

៥.៤.៣-ការបន្ថយពន្ធ (REDUCTION TAX)

ជម្រើសមួយទៀតដើម្បីឱ្យខ្សែកោងតម្រូវការសរុបធ្វើការផ្លាស់ប្តូរទីទៅខាងស្តាំបាននោះ លុះត្រាតែរដ្ឋាភិបាលកាត់បន្ថយកម្រិតពន្ធ (Redue tax)។

ឧបមាថា រដ្ឋាភិបាលបានកាត់បន្ថយពន្ធលើប្រាក់ចំណូលបុគ្គល ជាលទ្ធផលបានធ្វើឱ្យប្រាក់ចំ-ណូលបុគ្គលក្រោមការចាត់ចែងរបស់អ្នកជាប់ពន្ធ គឺត្រូវបានកើន។

អាចកត់សម្គាល់ឃើញថា ការផ្លាស់ទីតែមួយដូចគ្នានៃខ្សែកោងតម្រូវការសរុបទៅខាងស្តាំ គេត្រូវតែកាត់បន្ថយកម្រិតពន្ធចំនួនច្រើន ជាជាងបង្កើនការចំណាយរបស់រដ្ឋាភិបាល។ កត្តានេះ ត្រូវបានបកស្រាយថាជាចំណែកណាមួយនៃការកាត់បន្ថយពន្ធ គឺវាធ្វើឱ្យមានការបង្កើនការសន្សំ មិនមែនបង្កើនការចំណាយនោះទេ។ ដើម្បីបង្កើនបរិមាណការប្រើប្រាស់ចំនួនណាមួយ រដ្ឋាភិបាលត្រូវតែបន្ថយពន្ធលើសចំនួនដែលត្រូវប្រើប្រាស់។

ក្នុងឧបនិស្ស័យចំណាយម៉ាជីន (MPC) ដើម្បីបង្កើនការចំណាយលើការប្រើប្រាស់នាពេលខាងមុខនោះ ត្រូវតែកាត់បន្ថយកម្រិតពន្ធ។ បើសិនឧបនិស្ស័យចំណាយម៉ាជីន (MPC) ត្រូវបានបង្កើនការចំណាយលើការប្រើប្រាស់នោះ គេត្រូវការបន្ថយកម្រិតពន្ធ ហើយឧបនិស្ស័យចំណាយម៉ាជីន (MPC) ឱ្យកាន់តែតិចនោះ ការបន្ថយពន្ធទាមទារឱ្យកាន់តែច្រើន ដើម្បីសម្រេចបានការបង្កើនចំនួនជាក់លាក់ការចំណាយលើការប្រើប្រាស់ និងការរំកិលជាក់លាក់នៃខ្សែកោងតម្រូវការសរុប។

នៅពេលកំណើនការទិញរបស់រដ្ឋាភិបាល នឹងបង្កើនចំណាយរបស់អ្នកប្រើប្រាស់។ រូបមន្តនេះគឺជាឧបនិស្ស័យចំណាយម៉ាជីន (MPC) ដែលជាចំណែកនៃចំណូលបន្ថែមដែលក្រុមគ្រួសារអាចប្រើប្រាស់ក្រៅពីការសន្សំ។

ឧបមាថា ប្រសិនបើឧបនិស្ស័យចំណាយម៉ាជីនរបស់គ្រួសារស្មើនឹង $\frac{3}{4}$។ មានន័យថា បើសិនពួកគេរកប្រាក់ចំណូលបានមួយដុល្លារ, ពួកគេនឹងចំណាយ ០.៧៥ដុល្លារ ស្មើនឹង ($\frac{3}{4}$ នៃចំនួនមួយដុល្លារ) ហើយពួកគេ បានសន្សំស្មើនឹង ០.២៥ដុល្លារ។ ឧបនិស្ស័យចំណាយម៉ាជីនរបស់គ្រួសារស្មើនឹងនៃ $\frac{3}{4}$ របស់កម្មករ និងម្ចាស់សហគ្រាស TOYOTA រកចំណូលបាន ៥០ពាន់លានដុល្លារ, ពួកគេបង្កើនការចំណាយលើការប្រើប្រាស់របស់ខ្លួន ៥០ពាន់លានដុល្លារ x $\frac{3}{4}$។

រូបមន្តតួគុណចំណាយ $Multiplier\ Effect = \frac{1}{(1-MPC)}$

ករណី $MPC = \frac{3}{4}$


នាំឱ្យតួគុណនៃចំណាយ $= \frac{1}{(1-\frac{3}{4})}$

៥.៤.៤-ការផ្គួបផ្គងនៃការបង្កើនចំណាយរដ្ឋាភិបាល និងបន្ថយពន្ធ (COMBINATION BETWEEN RAISE GOV'T SPENDING AND REDUE TAX)

រដ្ឋាភិបាល អាចអនុវត្តឧបករណ៍ទាំងពីរនៅក្នុងពេលតែមួយ ដើម្បីបង្កើនការចំណាយរបស់រដ្ឋាភិបាល និង/ឬកាត់បន្ថយពន្ធ ដើម្បីបង្កើនការចំណាយដំបូងរបស់រដ្ឋាភិបាលចង់បាន ជាលទ្ធផលចុងក្រោយនឹងបង្កើនតម្រូវការសរុប និងផលិតផលជាតិសរុបពិត (realGDP) ហើយរដ្ឋាភិបាលអាចបង្កើនការចំណាយរបស់ខ្លួនព្រមពេលជាមួយគ្នាការបន្ថយពន្ធ។ ហេតុការណ៍ ផ្គួបផ្សំគ្នានេះធ្វើឱ្យមានការកើនឡើងដំបូងនៃការចំណាយថ្មីកើតឡើង។ ជាលទ្ធផល វិភាគអថេរប្រែប្រួលចំនួនបីនៃគោលនយោបាយសារពើពន្ធនៅក្នុងការវិភាគគម្លាតវិបត្តិសេដ្ឋកិច្ចទាក់ទងជាមួយនឹងម៉ូដែលនៃការរំកិលខ្សែកោងតម្រូវការ

សរុបទៅខាងស្តាំ គឺទាក់ទងដោយផ្ទាល់ទៅនឹងការផ្លាស់ទីខ្សែកោងតម្រូវការសរុបកើន ដោយសារតែការចំណាយរបស់រដ្ឋាភិបាលបានកើនឡើង។

ក្រាហ្វិកទី៦៖ ការអនុវត្តគោលនយោបាយសារពើពន្ធពង្រីក



៥.៤.៥-គោលនយោបាយសារពើពន្ធបង្ហួម (CONTRACTIONARY OF FISCAL POLICY)

គោលនយោបាយសារពើពន្ធបង្ហួម គឺត្រូវបានប្រើដើម្បីកាត់បន្ថយល្បឿនកំណើនសេដ្ឋកិច្ច។ គោលនយោបាយនេះ គឺជាពេលវេលាដែលរដ្ឋាភិបាលត្រូវតែបង្កើនពន្ធ ឬបន្ថយការចំណាយ។ គោលនយោបាយសារពើពន្ធបង្ហួម(ហ្វាំង) គឺជាច្បាប់នៃការកាត់បន្ថយកម្រិតអតិផរណា និងការកាត់បន្ថយកម្រិតកំណើនផលិតផលជាតិសរុប(ដើម្បីបិទគម្លាតអតិផរណាតម្រូវការ)។ ជាពិសេស គឺថារដ្ឋាភិបា-លប្រើគោលនយោបាយសារពើពន្ធបង្ហួមពេលកើតមានការកើនអតិផរណាតម្រូវការតែប៉ុណ្ណោះ។ ថាតើឧបករណ៍នៃគោលនយោបាយសារពើពន្ធបង្ហួមមានអ្វីខ្លះ?

ដូចនេះ ឧបករណ៍នៃគោលនយោបាយសារពើពន្ធបង្ហួម រួមមាន៖

១-បន្ថយចំណាយរបស់រដ្ឋាភិបាល (Decreasing government spending) ឬ

២-ដំឡើងពន្ធ (Increasing taxes) ឬ

៣-រួមបញ្ចូលគ្នាលក្ខខណ្ឌទាំងពីរ។

ក្នុងករណី ការកើតមានឡើងកម្រិតនៃអតិផរណាតម្រូវការ (Demand pull inflation) ដើម្បីគ្រប់គ្រងអតិផរណាតម្រូវការនេះ។

តើរដ្ឋាភិបាលប្រទេសនីមួយៗ ត្រូវការគ្រប់គ្រងអតិផរណាតម្រូវការដោយប្រើគោលនយោបាយសារពើពន្ធអ្វី? តើគោលនយោបាយសារពើពន្ធបង្ហួម គឺជាអ្វី?

គោលនយោបាយសារពើពន្ធបង្រួម គឺសំដៅលើការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល ដូចជាចំណាយដែលធ្វើឱ្យមានឱនភាពថវិកាជាតិ (Budget deficit) ឬការកាត់បន្ថយចំនួនប្រាក់ធ្វើចរាចរណ៍ដោយធនាគារកណ្តាលជាដើម។ យន្តការទាំងនេះ ជាប្រភេទនៃគោលនយោបាយឬជាឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច ត្រូវបានបង្កើតឡើង តាមរយៈការធ្វើអន្តរាគមន៍របស់ធនាគារកណ្តាលឬរដ្ឋាភិបាល ដើម្បីទប់ស្កាត់ទៅលើអតិផរណាតម្រូវការដែលកំពុងកើនឡើង ឬកម្រិតបម្រែបម្រួលសេដ្ឋកិច្ចដទៃទៀត។ ការណ៍នេះ គោលនយោបាយសារពើពន្ធបង្រួម ត្រូវប្រើផ្ទុយពីគោលនយោបាយសារពើពន្ធពង្រីក ឬគោលន-យោយបាយសារពើពន្ធវិត្ថារកម្ម។

ករណីសេដ្ឋកិច្ចជួបបញ្ហាអតិផរណាតម្រូវការ គោលនយោបាយសារពើពន្ធបង្រួម បានផ្តោតលើថវិកាអតិរេក (Budget surplus) ដែលចំណូលពន្ធប្រមូលបានលើសការចំណាយរបស់រដ្ឋាភិបាល។

ការអនុវត្តនូវគោលនយោបាយសារពើពន្ធបង្រួម ដូចបង្ហាញក្រាហ្វិកទី៧ ខាងក្រោមនេះ ពន្យល់ពីអង្កត់ឈរពណ៌(ក្រហម)ជាខ្សែកោងការផ្គត់ផ្គង់សរុបនៃបរិបទសេដ្ឋកិច្ចរយៈពេលវែង (LRAS) មានការប្រែប្រួលការផ្គត់ផ្គង់សរុប។ ឧបមាថាការរំកិលខ្សែកោងតម្រូវការសរុបពី (AD_4) ទៅរក (AD_3) លើអង្កត់ឈរនៃខ្សែកោងការតម្រូវការសរុប (AD) នៃបរិបទសេដ្ឋកិច្ចរយៈពេលវែង (SRAS)។ វាបានធ្វើឱ្យកម្រិតថ្លៃឡើងរំកិលពី (P_3) ទៅរក (P_4) ខណៈពេលដែលយើងមិនចាប់អារម្មណ៍លើសញ្ញាព្រួញនៅផ្នែកខាងស្តាំ និងបន្ទាត់គំនូសនោះ។ ការកើនឡើងនៃតម្រូវការសរុប (AD↑) អាចនឹងកើតមានឡើងដោយសារតែកំណើនខ្លាំងនៃការចំណាយវិនិយោគ ឬនាំចេញសុទ្ធ។ ប្រសិនបើ រដ្ឋាភិបាលត្រៀមត្រួតត្រាអតិផរណានោះ វិធានការសារពើពន្ធរបស់ខ្លួនត្រូវតែមានចរិតលក្ខណៈខុសអំពីវិធានការដែលបានប្រើប្រាស់សម្រាប់ទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ច។

ដូចនេះ ពេលដែលសេដ្ឋកិច្ចជួបប្រទះនូវអតិផរណាតម្រូវការ គោលនយោបាយសារពើពន្ធបង្រួម សំដៅលើការបង្កើតអតិរេកថវិកាពោលគឺដំឡើងចំណូលពន្ធឱ្យខ្ពស់ជាងការចំណាយរបស់រដ្ឋាភិបាល។ ជាពិសេសការអនុវត្តនូវគោលនយោបាយសារពើពន្ធបង្រួម សំដៅលើការទប់ទល់កម្រិតអតិផរណា។ គោលនយោបាយសារពើពន្ធ គឺដើម្បីកាត់បន្ថយតម្រូវការសរុបតាមរយៈការកាត់បន្ថយចំណាយរបស់ រដ្ឋាភិបាល និងការដំឡើងពន្ធ ឬផ្គូបគ្នានូវសមាសធាតុនៃវិធានការទាំងពីរបញ្ចូលគ្នា។

ឧបមាថា៖ រដ្ឋាភិបាលបានកាត់បន្ថយការចំណាយរបស់ខ្លួនមានទឹកប្រាក់ចំនួន ៥ប៊ីលានដុល្លារ ឬដំឡើងពន្ធមានទឹកប្រាក់ចំនួន ៦.៦ប៊ីលានដុល្លារ មានន័យថាស្មើនឹងកាត់បន្ថយការប្រើប្រាស់មានទឹកប្រាក់ចំនួន ៥ប៊ីលានដុល្លារ ដើម្បីរាំងខ្ទប់កម្រិតអតិផរណាតម្រូវការ ដូចបានបង្ហាញលើក្រាហ្វិកទី៦ខាងលើ។

៥.៤.៦-ការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល (DECREASING GOVERNMENT SPENDING)

រដ្ឋាភិបាល អាចកាត់បន្ថយការទិញរបស់ខ្លួន ដើម្បីពន្យឺតអត្រាអតិផរណា ឬ ក៏លុបបំបាត់ទាំងស្រុងកម្រិតអតិផរណា។ ការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលធ្វើឱ្យខ្សែកោងតម្រូវការសរុបផ្លាស់ទីទៅខាងឆ្វេង មានន័យថាការថយចុះតម្រូវការសរុប។ ប្រសិនបើ ដំណើរការឥទ្ធិពលនៃមេគុណ (Multiplier) ត្រូវបានសម្រេច។ ក្នុងលក្ខខណ្ឌកម្រិតថ្លៃមានភាពទន់ភ្លន់ធ្លោះទៅរកការធ្លាក់ចុះកម្រិតអតិផរណាបានចាប់ផ្តើម។ បរិមាណផលិតផលជាតិសរុបពិត ស្ថិតនៅត្រង់កម្រិតនៃលទ្ធភាពផលិតកម្មអតិផរណា។

ក្នុងសេដ្ឋកិច្ចជាក់ស្តែងកម្រិតថ្លៃគឺមិនងាយធ្លាក់ចុះនោះទេ ដូច្នេះដើម្បីទប់ស្កាត់អតិផរណា គេត្រូវទប់ស្កាត់ការកើនកម្រិតថ្លៃនេះ គឺមិនមែនព្យាយាមទម្លាក់ថ្លៃដល់កម្រិតដើមនោះទេ។ ជាទូទៅ អតិ-ផរណាតម្រូវការ វារំកិលរកខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំជាប្រចាំ។ ហេតុនេះ គោលបំណងនៃគោលនយោបាយសារពើពន្ធបង្រួម គឺបញ្ឈប់ការរំកិលអតិផរណាតម្រូវការទាំងនោះ ពោលគឺមិនធ្វើឱ្យកម្រិតថ្លៃកាន់តែទាបដូចដើមវិញនោះទេ។ គោលនយោបាយសារពើពន្ធបង្រួម គឺជាគោលការណ៍កាត់បន្ថយចំណាយរបស់រដ្ឋាភិបាល ដើម្បីទប់ស្កាត់អតិផរណាតម្រូវការ។

៥.៤.៧-ការដំឡើងពន្ធ (INCREASING TAXES)


រដ្ឋាភិបាល អាចបញ្ចុះកម្រិតពន្ធដើម្បីបង្កើនការចំណាយទៅលើការប្រើប្រាស់។ ដូចគ្នានេះដែរ រដ្ឋាភិបាលអាចចាត់វិធានការដំឡើងកម្រិតពន្ធដើម្បីកាត់បន្ថយការចំណាយលើការប្រើប្រាស់វិញម្តង។ ប្រសិនបើកម្រិតនៃឧបនិស្ស័យចំណាយម៉ាជីន (MPC) ក្នុងសេដ្ឋកិច្ច និងរដ្ឋាភិបាលត្រូវបានដំឡើងកម្រិតពន្ធដើម្បីកាត់បន្ថយបរិមាណលើការប្រើប្រាស់មួយចំនួននោះ ឬការដំឡើងពន្ធ ដើម្បីកាត់បន្ថយបរិមាណលើការសន្សំមួយចំនួននោះ ហើយកម្រិតឧបនិស្ស័យលើការសន្សំ (MPS) តាមនិយមន័យនេះ គឺមិនមែនជាការកាត់បន្ថយការចំណាយនោះទេ។ ប៉ុន្តែការដំឡើងពន្ធ ធ្វើឱ្យកាត់បន្ថយចំណាយលើការប្រើប្រាស់បរិមាណមួយចំនួន ដែលជាក់ស្តែងបានបង្ហាញឱ្យឃើញតាមរយៈអង្គត់ខ្សែកោងតម្រូវការ (AD_4) និងបន្ទាត់គំនូសរំកិលពីខាងស្តាំទៅខាងឆ្វេងវិញ។ ការណ៍នេះ ដោយសារឥទ្ធិពលមេគុណ (Multiplier)នោះ ខ្សែងកោងតម្រូវការសរុប(AD) ត្រូវបានផ្លាស់ប្តូរទីទៅខាងឆ្វេងក្នុងកម្រិតថ្លៃទាំងឡាយ។ ចំណែកកម្រិតថ្លៃ គឺធ្លាក់ចុះពី (P_4) ទៅរក (P_3) ក្នុងលក្ខណៈនេះ អាចត្រួតត្រាទៅលើកម្រិតអតិផរណាតម្រូវការ។

៥.៤.៨-ការផ្គូបផ្គងការបន្ថយចំណាយរដ្ឋាភិបាល និងការដំឡើងពន្ធ (COMBINATED BETWEEN REDUCE GOVERNMENT SPENDING AND RAISING TAXES)

ដើម្បីកាត់បន្ថយតម្រូវការសរុប និងការត្រួតត្រាកម្រិតអតិផរណារដ្ឋាភិបាលអាចចាត់វិធានការដោយផ្គូបផ្គង គឺកាត់បន្ថយការចំណាយរបស់រដ្ឋាភិបាល និងដំឡើងពន្ធវិញម្តង។ អំណះអំណាងនេះ កំណត់ពីមូលហេតុកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលបរិមាណណាមួយ ដោយផ្គូបផ្គងជាមួយការដំឡើង

ពន្ធនូវបរិមាណណាមួយជាក់លាក់។ ចំពោះខ្សែកោងតម្រូវការសរុប នឹងបន្លាស់ទីពីស្តាំទៅឆ្វេង (AD_4) ទៅរក (AD_3)។ ក្រៅពីនេះ អាចបកស្រាយអថេរប្រែប្រួលមួយចំនួននៃគោលនយោបាយសារពើពន្ធ ស្តីពីទស្សនាទានគម្លាតនៃអតិផរណា (Inflationary gap concept) ដែលបានធ្វើឡើងក្នុងម៉ូដែលការចំណាយសរុប។ ការរំកិលខ្សែកោងតម្រូវការសរុបទៅឆ្វេងនេះ គឺត្រូវបន្លាស់ទីនៃខ្សែកោងការចំណាយសរុបចុះក្រោម។

ក្រាហ្វិកទី៧៖ ការអនុវត្តគោលនយោបាយសារពើពន្ធបង្រួម



៥.៥- គោលនយោបាយសារពើពន្ធអនន្ទានុសិទ្ធិ (NON-DISCRETIONARY OF FISCAL POLICY)

ទិដ្ឋភាពទ្រឹស្តីស្តីពីគោលនយោបាយឆន្ទានុសិទ្ធិ រួមមានគោលនយោបាយសារពើពន្ធពង្រីក និងគោលនយោបាយសារពើពន្ធបង្រួម គឺគោលនយោបាយសារពើពន្ធបានបង្កើតឡើងដោយរដ្ឋាភិបាលដើម្បីបង្កើន ឬបន្ថយកម្រិតសេដ្ឋកិច្ច។ ចំពោះគោលនយោបាយសារពើពន្ធអនន្ទានុសិទ្ធិវិញ ក្នុងករណីមានប្រែប្រួលនៃការចំណាយរបស់រដ្ឋាភិបាល និងកម្រិតពន្ធ ដែលកើតឡើងជាស្វ័យប្រវត្តិក្នុងកម្រិតជាក់លាក់ណាមួយ។ នេះជាកត្តាធ្វើឱ្យមានស្ថិរភាពជាស្វ័យប្រវត្តិ (Automatic stability)។ ដូច្នេះ រដ្ឋាភិបាលមិនត្រូវបានគិតគូរអនុវត្តគោលនយោបាយសារពើពន្ធឆន្ទានុសិទ្ធិនោះទេ។

ប្រសិនបើ រដ្ឋាភិបាលប្រមូលពន្ធដុល(ពន្ធសរុបរួម) ដែលធ្វើឱ្យប្រាក់ចំណូលពន្ធមានបរិមាណថេរ នៅគ្រប់កម្រិតផលិតផលក្នុងស្រុកសរុបទាំងអស់។ ការណ៍នេះ ធ្វើឱ្យមានស្ថិរភាពជាស្វ័យប្រវត្តិត្រូវបានបកស្រាយថានៅក្នុងស្ថានភាពប្រព័ន្ធពន្ធជាក់ស្តែង គឺការផ្តត់ផ្តង់សរុបដកចេញប្រភេទពន្ធ

សុទ្ធមានន័យថា(ពន្ធសុទ្ធ=ចំណូលពន្ធសរុប-ចំនួនប្រាក់ផ្ទេរ និងការឧបត្ថម្ភធន) ត្រូវបានប្រែប្រួលសមា មាត្រនឹងទំហំនៃផលិតផលក្នុងស្រុកសរុប។ ជាក់ស្តែងនៅគ្រប់ប្រភេទពន្ធទាំងអស់ បានផ្តល់ចំណូលពន្ធកាន់តែច្រើនទៅតាមកំណើនផលិតផលក្នុងស្រុកសរុបដែរ។ ដូចជាប្រភេទពន្ធលើចំណូលបុគ្គល បានកំណត់អត្រាពន្ធកំណើនតាមថ្នាក់ ទៅតាមកម្រិតកំណើនផលិតផលក្នុងស្រុកសរុប គឺវាផ្តល់កំ-ណើនចំណូលពន្ធច្រើនជាងចំណូលពន្ធតាមអត្រាសមាមាត្រ។ ក្រៅពីនេះ កំណើននៃផលិតផលក្នុងស្រុកសរុប និងការបង្កើនទំហំនៃការទិញទំនិញនិងសេវា ពេលនោះវាកើនឡើងកាន់តែច្រើនឡើងនូវប្រាក់ចំណូលពន្ធដែលប្រមូលបានពីពន្ធលើប្រាក់ចំណូលសាជីវកម្ម (Corporate income tax) កម្រិតពន្ធពីការលក់ (Sales tax) និងពន្ធអាករ (Excise tax) ។ ដូចនេះ ពន្ធលើប្រាក់បៀវត្សក៏ត្រូវបានកើនឡើងនៅពេលមានកំណើនសេដ្ឋកិច្ចដោយបានបង្កើតកន្លែងការងារថ្មី។ ផ្ទុយទៅវិញ ការធ្លាក់ចុះផលិតផលក្នុងស្រុកសរុបនោះ ចំណូលពន្ធពីគ្រប់ប្រភពទាំងអស់ក៏នឹងធ្លាក់ចុះដែរ។


ចំពោះ "ប្រាក់ផ្ទេរ" ឬ "ពន្ធអវិជ្ជមាន"(Transfer payment or negative taxes) គឺមានលក្ខណៈផ្ទុយគ្នាស្រឡះ។ សម្រាប់ការចំណាយឧបត្ថម្ភធន អត្រានិកម្មភាព ជានាវ៉ាប់រងសង្គមកិច្ចឧបត្ថម្ភដល់កសិករ ចំណាយទាំងអស់នេះ គឺត្រូវបានកាត់បន្ថយ ក្នុងអំឡុងពេលកំណើនសេដ្ឋកិច្ចជាស្វ័យប្រវត្តិ។ ក៏ប៉ុន្តែ វានឹងកើនឡើងក្នុងអំឡុងពេលផលិតកម្មធ្លាក់ចុះ មានន័យថាការធ្លាក់ចុះនូវសេដ្ឋកិច្ចជាបន្ទុករបស់រដ្ឋាភិបាលត្រូវបញ្ចេញ"ប្រាក់ផ្ទេរ"(Transfer payment)កាន់តែច្រើន។

៥.៥.១-ស្ថិរភាពជាស្វ័យប្រវត្តិ (AUTOMATIC STABILIZERS)

ប្រព័ន្ធនៃសារពើពន្ធ អាចជួយជំរុញឱ្យសម្រេចបាននូវស្ថិរភាពជាស្វ័យប្រវត្តិបាន (Automatic Stabilizers)។ ការចំណាយរបស់រដ្ឋាភិបាល បង្ហាញលើក្រាហ្វិកទី៨ កំណត់ពីបន្ទាត់អ័ក្សរផ្តេច(*ពណ៌ក្រហម*) ត្រូវបានចាត់ទុកជាការចំណាយរដ្ឋាភិបាលមានបរិមាណថេរដោយមិនអាស្រ័យទៅលើទំហំនៃផលផលិតក្នុងស្រុកសរុប ក្នុងកម្រិតជាក់លាក់មួយនោះទេ។ បរិមាណការចំណាយត្រូវបានសម្រេចដោយរដ្ឋសភាអនុម័ត។ ប៉ុន្តែរដ្ឋសភា មិនបានកំណត់ចំនួននៃប្រាក់ចំណូលពន្ធនោះទេ គឺបានត្រឹមតែកំណត់កម្រិតអត្រាពន្ធតែប៉ុណ្ណោះ។ ទំហំនៃចំណូលពន្ធនេះទៀតសោធ ត្រូវបានវាស់វែងតាមទិសដៅដូចគ្នាទៅនឹងកម្រិតផលិតផលសរុបក្នុងស្រុកសរុប ដែលសេដ្ឋកិច្ចសម្រេចបានជាក់ស្តែង។ ចំពោះខ្សែបន្ទាត់កម្រិតចំណូលពន្ធ បានបង្ហាញអំពីទំនាក់ទំនងដោយត្រង់នៃចំណូលពន្ធ និងកម្រិតផលិតផលសរុបក្នុងស្រុកសរុប គឺត្រូវបានឆ្លុះបង្ហាញដោយខ្សែបន្ទាត់(ពណ៌ខៀវ)រត់ត្រង់លើ។ ក្រាហ្វិកទី៨ ខាងក្រោមបង្ហាញពីកត្តាធ្វើឱ្យមានស្ថិរភាពជាស្វ័យប្រវត្តិ (Automatic stabilizers) ។

ប្រសិនបើ ចំណូលពន្ធ ត្រូវបានប្រែប្រួលសមាមាត្រជាមួយនឹងផលិតផលក្នុងស្រុកសរុប និងឱនភាពថវិកាជាតិ (Budget Deficit)។ ជាទូទៅ វាកើតមានឡើងជាស្វ័យប្រវត្តិក្នុងពេលសេដ្ឋកិច្ចធ្លាក់ចុះវាជួយសង្គ្រោះការធ្លាក់ចុះនោះ។ ផ្ទុយទៅវិញ ករណីអតិរេកថវិកា (Budget surplus) គឺកើតមានឡើងជាស្វ័យប្រវត្តិនៅក្នុងពេលសេដ្ឋកិច្ចមានកំណើន និងជួយអន្តរាគមន៍សង្គ្រោះអតិផរណាដែលអាចមាន។

ក្រាហ្វិកទី៨៖ ស្ថិរភាពស្វ័យប្រវត្តិ



៥.៥.២-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើសេដ្ឋកិច្ច (EFFECT OF ECONOMICS GROWTH)

គោលនយោបាយសារពើពន្ធ មានឥទ្ធិពលមកលើសេដ្ឋកិច្ច មានទំនាក់ទំនងដោយផ្ទាល់រវាងចំណូលពន្ធ និងផលិតផលក្នុងស្រុកសរុប គឺមានលក្ខណៈពិសេសប្រព័ន្ធនៃសារពើពន្ធ ពេលដែលយើងរំលឹកពីស្ថានភាពពីរយ៉ាងសំខាន់ៗ

១)-ពន្ធគឺជាកត្តាកាត់បន្ថយការចំណាយ និងតម្រូវការសរុប, និង

២)-តាមទស្សនៈស្ថិរភាពសេដ្ឋកិច្ច ការកាត់បន្ថយចំណាយ គឺជាវិធីដែលចង់បាននៅពេលសេដ្ឋកិច្ចឈានដល់កម្រិតអតិផរណាតម្រូវការ។ ផ្ទុយមកវិញ ត្រូវបង្កើនការចំណាយនៅក្នុងអំឡុងពេលការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ច ឬសេដ្ឋកិច្ចមានកំណើនតិចតួច។ ម្យ៉ាងវិញទៀត អាចនិយាយបានថាប្រព័ន្ធនៃសារពើពន្ធបង្ហាញពីការផ្តត់ផ្តង់ស្ថិរភាពមួយចំនួនក្នុងសេដ្ឋកិច្ច ដែលបានធ្វើឱ្យមានប្រែប្រួលចំណូលពន្ធជាស្វ័យប្រវត្តិ។ ដូចនេះ ចំណូលពន្ធត្រូវបានសមាមាត្រជាមួយនឹងផលិតផលក្នុងស្រុកសរុប ហើយការប្រែប្រួលកម្រិតថវិកា ដែលអាចទប់ទល់ទាំងអតិផរណាតម្រូវការ និងកម្រិតអត្រាអនិកម្មភាព។ កត្តានេះ ធ្វើឱ្យមានស្ថិរភាពជាស្វ័យប្រវត្តិ គឺជាវិធានការទាំងឡាយ ដែលបង្កើនឱនភាពថវិការដ្ឋ(ឬកាត់បន្ថយអតិរេកថវិកា) ក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ និងបង្កើនអតិរេកថវិកា(ឬកាត់បន្ថយឱនភាពថវិកា) ក្នុងអំឡុងពេលអតិផរណា ដោយគ្មានភាពចាំបាច់នូវវិធានការណាមួយពីអ្នករៀបចំនូវគោលន-យោបាយ។ ជាមួយគ្នានេះដែរ កំណើនផលិតផលក្នុងស្រុកសរុប ក្នុងអំឡុងពេលមានវិបុលភាពសេដ្ឋកិច្ច ចំណូលពន្ធត្រូវបានកើនឡើងជាស្វ័យប្រវត្តិ ដោយហេតុថាចំណូលពន្ធទាំងនោះ វាកាត់បន្ថយចំណាយ គឺទប់ស្កាត់ការកើនឡើងសេដ្ឋកិច្ច។ គេអាចនិយាយថា តាមចរន្តសេដ្ឋកិច្ចឆ្ពោះទៅរកការកើន

ឡើងផលិតផលក្នុងស្រុកសរុបកាន់តែខ្ពស់ ចំណូលពន្ធនឹងត្រូវកើនឡើងជាស្វ័យប្រវត្តិ និងជួយលុបបំបាត់ឱនភាពថវិកា ហើយបង្កើតទៅជាអតិរេក (surplus) ។

ផ្ទុយទៅវិញ នៅពេលផលិតផលក្នុងស្រុកសរុប (GDP) ត្រូវបានធ្លាក់ចុះក្នុងអំឡុងពេលវិបត្តិសេដ្ឋកិច្ចនាំឱ្យចំណូលពន្ធត្រូវបានកាត់បន្ថយជាស្វ័យប្រវត្តិធ្វើឱ្យមានកំណើនការចំណាយ ដើម្បីទប់ស្កាត់ការធ្លាក់ចុះសេដ្ឋកិច្ច។ ពោល គឺជាមួយនឹងការធ្លាក់ចុះកម្រិតផលិតផលក្នុងស្រុកសរុប (GDP) នាំឱ្យចំណូលពន្ធក៏ត្រូវបានធ្លាក់ចុះដូចគ្នានេះដែរ។ រុញចេញថវិកាជាតិពីអតិរេកឆ្ពោះទៅរកឱនភាពថវិ-កា។ នៅលើក្រាហ្វិកទី៨ខាងលើ បានបង្ហាញយើងថាកម្រិតទាបនៃប្រាក់ចំណូលជាតិសរុប (GDP_1) មានឱនភាពថវិកាជាស្វ័យប្រវត្តិ ត្រូវបានកើតឡើងសម្រាប់កំណើនសេដ្ឋកិច្ច។ ចំណែកឯកម្រិតខ្ពស់នៃចំណូលជាតិ និងអាចកម្រិតអតិផរណាផលិតផលក្នុងស្រុកសរុប (GDP_3) ថវិកាអតិរេកទប់ស្កាត់អតិផរណាតម្រូវការត្រូវបានបង្កើតឡើងជាស្វ័យប្រវត្តិ។

៥.៦-ឥទ្ធិពលរុញច្រានចេញ (CROWDING-OUT EFFECT)


ខ្លឹមសារនៃឥទ្ធិពលរុញចេញ គឺជាគោលនយោបាយសារពើពន្ធពង្រីក (ឬហៅថាគោលនយោបា-យឱនភាពថវិកា) ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ដោយប្រើឧបករណ៍គោលនយោបាយសារពើពន្ធតាមរយៈបង្កើនចំណាយរបស់រដ្ឋាភិបាល និងការកាត់បន្ថយកម្រិតពន្ធ ដើម្បីជំរុញខ្សែកោងតម្រូវការសរុបឱ្យរំកិលទៅខាងស្តាំ(ឥទ្ធិពលរុញចេញ)។ ខណៈពេល បង្កើនការចំណាយរបស់រដ្ឋាភិបាល ជំរុញឱ្យមានកំណើនតម្រូវការសរុបទៅលើទំនិញនិងសេវា ពេលនោះវានឹងបណ្តាលឱ្យអត្រាការប្រាក់កើនឡើងផងដែរ ហើយអត្រាការប្រាក់កើនឡើង បានជះឥទ្ធិពលលើការចំណាយវិនិយោគ និងសម្ភាធសម្រាប់តម្រូវការសរុបផងដែរ ។ ថាតើឥទ្ធិពលរុញចេញនឹងកើតឡើងពិតប្រាកដអាស្រ័យលើគម្លាតរបិត្តិសេដ្ឋកិច្ច នៅពេលរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយសារពើពន្ធពង្រីករបស់ខ្លួនឬ? ទោះបីជាយ៉ាងនេះក្តី ក៏នៅមានឥទ្ធិ-ពលនៃគោលនយោបាយផ្សេងទៀត កំពុងដំណើរការក្នុងទិសដៅបញ្ច្រាស់គ្នាផងដែរ។ ការថយចុះតម្រូវការសរុបកើតឡើង នៅពេលគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលត្រូវបានបង្កើនអត្រាការប្រាក់ និងកាត់បន្ថយការវិនិយោគ ត្រូវបានគេហៅថា"ឥទ្ធិពលរុញចេញ"។ ឧទាហរណ៍ប្រសិនបើរដ្ឋាភិបាល បង្កើនកាចំណាយចំនួនទឹកប្រាក់ $500Million សម្រាប់ការទិញលើទំនិញនិងសេវា តាមរយៈការចំណាយរបស់រដ្ឋាភិបាលទាំងនេះ បានជំរុញកំណើនតម្រូវការសរុប ដូចជាចំណូលពីប្រាក់បៀវត្សរបស់កម្មករ និងចំណូលក្រុមហ៊ុនអាជីវកម្ម(ឥទ្ធិពលតួគុណ) សម្រាប់ក្រុមហ៊ុនផ្សេងទៀតក៏នឹងទទួលបានផលចំណេញ។ ពេលចំណូលកើនឡើង ភ្នាក់ងារគ្រួសារមានគម្រោងចំណាយកាន់តែច្រើនឡើងលើទំនិញនិងសេវា ជាលទ្ធផលភ្នាក់ងារគ្រួសារមានជម្រើសបន្ថែមទៀតនៅក្នុងទម្រង់សន្ទនីយ។ ពោលគឺ ចំណូលកើនឡើងដោយសារគោលនយោបាយសារពើពន្ធពង្រីក តាមរយៈការបង្កើនតម្រូវការរូបិយវត្ថុដូចមានបង្ហាញលើក្រាហ្វិកទី៩ខាងក្រោម។

ទិដ្ឋភាពទ្រឹស្តីឥទ្ធិពលរុញចេញ៖

នៅកំឡុងពេលមានវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ (During deep recessionary)៖ ឥទ្ធិពលរុញចេញ (Crowding-out effect) ហាក់បីដូចជាមិនងាយនឹងកើតមានឡើងនោះឡើយ។ នៅក្នុងន័យការវិនិយោគក្នុងវិស័យឯកជន មានការធ្លាក់ចុះយ៉ាងខ្លាំងក្លារួចជាស្រេចទៅហើយ នៅពេលមានគម្លាតវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរបែបនោះ។ ករណីការចំណាយដ៏តិចតួចនោះ ឥទ្ធិពលរុញចេញដែលអាចកើតទៅបានលុះត្រាតែរដ្ឋាភិបាលគួរតែផ្តល់នូវការខ្ចីប្រាក់ ក្នុងកម្រិតមួយដែលមានកម្រិតអត្រាការប្រាក់ទាប។

កំឡុងពេលមានវិបត្តិនៃសេដ្ឋកិច្ចមិនធ្ងន់ធ្ងរ (During mild recessions)៖ ឥទ្ធិពលរុញចេញ គឺទំនងជាអាចកើតមានឡើង។ ដោយសារតែការប្រើប្រាស់ធនធានសេដ្ឋកិច្ច ត្រូវបានបិទបញ្ចប់វិបត្តិសេដ្ឋកិច្ច ដោយធ្វើឱ្យមានការងារពេញលេញ ជំរុញការចំណាយវិស័យវិនិយោគឯកជនកាន់តែខ្ពស់។ ក្នុងករណីនេះ រដ្ឋាភិបាលអាចផ្តល់នូវកម្រិតអត្រាការប្រាក់ឱ្យបានខ្ពស់ជាងមុន ដើម្បីទាក់ទាញឱ្យអ្នកផ្តល់នូវប្រាក់កម្ចីឱ្យកាន់តែច្រើនឡើង។

ក្រាហ្វិកទី៩៖ ឥទ្ធិពលរុញចេញ (Crowding-out effect)




៥.៦.១-តើអ្វីជាឥទ្ធិពលរុញចេញ? (WHAT IS CROWDING OUT?)

ឥទ្ធិពលរុញចេញ (Crowding-out effect) គឺថារុញចេញកំណើនសេដ្ឋកិច្ចឱ្យធាប់រហ័សតាមរយៈការចំណាយ ឬការឱ្យខ្ចីប្រាក់របស់រដ្ឋាភិបាល ដើម្បីផ្លាស់ប្តូរនូវធនធានសេដ្ឋកិច្ចខ្សត់កម្រក្នុងវិស័យឯកជនទៅកាន់វិស័យសាធារណៈ ដែលមានកម្រិតផលិតភាពអាចនៅមានកម្រិតទាបជាង។ រាល់ការចំណាយរបស់រដ្ឋាភិបាល គឺការចំណាយសាធារណៈលើទំនិញនិងសេវាកម្មរបស់សង្គមជាតិ ដូចជាការចំណាយលើវិស័យអប់រំ ការចំណាយលើការថែទាំសុខភាព និង ការចំណាយលើការការពារជាតិជាដើម។ រាល់ការចំណាយទាំងនេះ គឺជាឥទ្ធិពលរុញចេញរបស់គោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល តាមរយៈការចំណាយផ្ទេរ(Transfer payments)របស់រដ្ឋាភិបាល សម្រាប់ការចំណាយសាធារណៈលើសុខមាលភាពសង្គមចំពោះបុគ្គលចាស់ជរា អនិកម្មភាព សោធននិវត្តិន៍ជាដើម។ ការចំណាយឡើងវិញលើសេវាសាធារណៈទាំងនេះ មានឥទ្ធិពលរុញចេញជាស្វ័យប្រវត្តិ ដែលជំរុញកំណើនសេដ្ឋកិច្ចមានស្ថិរភាពរយៈពេលវែង។ ជាពិសេស ការរុញចេញកំណើនវិនិយោគរបស់រដ្ឋាភិបាលលើគម្រោង

ធំៗ ដែលមានដូចជា ហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ផ្លូវថ្នល់ ជាដើម។ ជាលទ្ធផល ឥទ្ធិពលនៃរុញចេញ មានដំណើរការលើការចំណាយរបស់រដ្ឋាភិបាលលើសុខភាពសង្គមជាតិ ដែលជាកត្តាជំរុញឱ្យមានការចំណាយសេវាសាធារណៈកើនឡើង តាមរយៈការបង្កើនគម្រោងវិនិយោគធំៗរបស់រដ្ឋ ដើម្បីបង្កើនកំណើនសេដ្ឋកិច្ច ខ្សែកោងតម្រូវការសរុបរំកិលទៅផ្នែកខាងស្តាំ។

គំនូសតាងទី៦៖ ឥទ្ធិពលរុញចេញ(Crowding-out effect)




ឧទាហរណ៍៖

ការវិភាគលើទ្រឹស្តីនៃឥទ្ធិពលរុញចេញ៖

គំនូសតាងទី៧ខាងក្រោមនេះ បង្ហាញពីដំណើរការប្រព្រឹត្តិទៅនៃឥទ្ធិពលរុញចេញរបស់រដ្ឋាភិបាល ដែលបានបង្កើនការចំណាយសាធារណៈលើការទិញទំនិញនិងសេវារបស់រដ្ឋាភិបាល។ ខណៈពេលរដ្ឋាភិបាល បានបង្កើនការចំណាយលើការទិញទំនិញនិងសេវា ដើម្បីជំរុញកំណើនតម្រូវការសរុបកើនឡើង។ ប្រសិនបើករណីរដ្ឋាភិបាលបានបង្កើនចំណាយរបស់ខ្លួននាំឱ្យមានកម្រិតឯនភាពថវិកាជាតិនៅពេលនោះតម្រូវឱ្យរដ្ឋាភិបាលលក់ប័ណ្ណបំណុលត្រូវបានកើតឡើង។ បណ្តាលឱ្យការខ្ចីប្រាក់កើនហើយអត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ផងដែរ នាំឱ្យកាត់បន្ថយការវិនិយោគវិស័យឯកជន និងការប្រើប្រាស់របស់គ្រួសារបានជះឥទ្ធិពលលើតម្រូវការសរុប។ ករណីរដ្ឋាភិបាលចង់បង្កើនការចំណាយសេវាសាធារណៈ ចាំបាច់ត្រូវតែបង្កើនការប្រមូលចំណូលពន្ធឱ្យបានច្រើនជាងការចំណាយរបស់ខ្លួន ។ ករណីការបង្កើនចំណូលពន្ធរបស់រដ្ឋាភិបាល នឹងជះឥទ្ធិពលទៅលើការប្រើប្រាស់របស់គ្រួសារ ដូចជាផលប៉ះពាល់ដល់ការវិនិយោគវិស័យឯកជនផងដែរ។ ចំពោះការបង្កើនអត្រាការប្រាក់នាំឱ្យកាត់បន្ថយការវិនិយោគឯកជននេះ ដោយសាររដ្ឋាភិបាលបានអនុវត្តគោលនយោបាយសារពើពន្ធពង្រីកមានឥទ្ធិពលតិចតួចលើវិនិយោគឯកជន និងការប្រើប្រាស់របស់គ្រួសារ ត្រូវបានគេហៅថា *"ឥទ្ធិពលរុញចេញ"* ។

គំនូសតាងទី៧៖ គំនូសបំព្រួញឥទ្ធិពលរុញច្រាន



ដូច្នេះ កំណើននៃអត្រាការប្រាក់ នាំឱ្យកាត់បន្ថយការបរិមាណតម្រូវការលើការទិញទំនិញ និងសេវា ដោយសារតែថ្លៃដើមលើទំនិញនិងសេវាកើនឡើង រួមបញ្ចូលអត្រាការប្រាក់កម្ចីមានកម្រិតខ្ពស់ជាកត្តានាំឱ្យធ្លាក់ចុះតម្រូវការចំណាយលើការប្រើប្រាស់ និងកាត់បន្ថយការវិនិយោគ។

ជាឧទាហរណ៍ ការចំណាយសេវាសាធារណៈរបស់រដ្ឋាភិបាលអង់គ្លេស ដែលសរុបមានប្រមាណ ៧៤៥ពាន់លានផោន ក្នុងឆ្នាំ២០០៥។ នេះគឺស្មើនឹង ៤៣% នៃផលិតផលក្នុងស្រុកសរុប។ ក្នុងនោះដែរ ទឹកប្រាក់ចំនួន ៥០ ពាន់លានផោន ទៅលើចំណាយមូលធន(Capital expenditure)។ ហើយ

ការចំណាយលើសេវាសាធារណៈ ដូចជាការអប់រំ និងសុខភាព ស្មើនឹង ៤៣% នៃផលិតផលក្នុងស្រុកសរុប។


សរុបជារួម ទិដ្ឋភាពទ្រឹស្តីនៃឥទ្ធិពលរុញចេញតាមរយៈគំនូសតាងខាងលើ មានខ្លឹមសារថា ប្រសិនបើ រដ្ឋាភិបាលបង្កើនការចំណាយលើការទិញទំនិញ និងសេវារបស់ខ្លួន តម្រូវការសរុបសម្រាប់ទំនិញនិងសេវា អាចកើតឡើងដោយតែចំនួនច្រើនជាង ឬតិចជាងនេះ អាស្រ័យលើឥទ្ធិពលគុណ ឬ ឥទ្ធិពលរុញចេញធំជាង។


៥.៦.២-ការវិភាគឥទ្ធិពលរុញចេញ (ANALYSIS CROWDING OUT)

វិភាគឥទ្ធិពលរុញចេញ គឺជាគោលនយោបាយសារពើពន្ធពង្រីក (គោលនយោបាយឱនភាពថវិកា)គឺជួយឱ្យមានកំណើនអត្រាការប្រាក់ និងកាត់បន្ថយការចំណាយវិនិយោគ មាននយថាការថយចុះវិស័យវិនិយោគឯកជន។ ហេតុនេះ វាបានធ្វើឱ្យថយចុះ ឬផ្តាច់ទាំងស្រុងឥទ្ធិពលនៃគោលនយោបាយពង្រីក ។ ថាតើឥទ្ធិពលរុញចេញវានឹងកើតឡើងពិតប្រាកដ អាស្រ័យលើដម្រៅរបិត្តិនៃសេដ្ឋកិច្ច នៅពេលដែលរដ្ឋាភិបាល អនុវត្តនូវគោលនយោបាយសារពើពន្ធពង្រីករបស់ខ្លួន។ ក្នុងករណី រដ្ឋាភិបាលបង្កើនប្រាក់កម្ចីនាំឱ្យមានតម្រូវការកើនខ្ពស់ សម្រាប់មូលនិធិដែលអាចខ្ចីបាន និងការកើនឡើងអត្រាការប្រាក់។ ឧទាហរណ៍ មូលបត្របំណុល។ នេះអាចបង្កើនការខ្ចីប្រាក់សម្រាប់អាជីវកម្មក្នុងវិស័យឯកជន។

ឧបមាថា សេដ្ឋកិច្ចស្ថិតក្នុងស្ថានភាពធ្លាក់ចុះ រដ្ឋាភិបាលចាត់វិធានការគោលនយោបាយពង្រីកដោយបង្កើនចំណាយរដ្ឋាភិបាល។ ដោះស្រាយបញ្ហារដ្ឋាភិបាល ត្រូវចេញមុខនៅលើទីផ្សាររូបិយវត្ថុក្នុងគោលបំណងផ្តល់ហិរញ្ញប្បទានឱនភាពថវិកា។ បន្ទាប់ពីនេះ ការកើនឡើងតម្រូវការរូបិយវត្ថុ គឺបានធ្វើឱ្យអត្រាការប្រាក់ឡើងខ្ពស់។ ពោល គឺបរិមាណនៃប្រាក់កម្ចីកើនឡើងខ្ពស់។ ដោយសារតែការចំណាយបានប្រែប្រួលបញ្ច្រាសសមាមាត្រទៅនឹងអត្រាការប្រាក់ ដែលជាកត្តានាំឱ្យការវិនិយោគមួយចំនួនត្រូវបង្អាក់ ឬរុញចេញ។ បង្ហាញលើក្រាហ្វិកទី១០ខាងក្រោមនេះ។

ក្រាហ្វិកទី១០៖ វិភាគឥទ្ធិពលរុញចេញ





៥.៦.៣-ការវាយតម្លៃទ្រឹស្តីរុញចេញ(EVALUATING OF CROWDING OUT THEORY)

- ប្រូបាប៊ីលីតេនៃឥទ្ធិពលរុញចេញកំណត់ជា១០០% គឺជាឧបករណ៍បញ្ហារពីចម្ងាយ ប្រសិនបើសកម្មភាពសេដ្ឋកិច្ចកំពុងដំណើរការកម្រិតទាបជាងសមត្ថភាពរបស់ខ្លួននោះ ហើយការផ្គត់ផ្គង់មានការសន្សំចំនួនដ៏ច្រើនដើម្បីទិញប័ណ្ណបំណុលរបស់រដ្ឋទើបចេញថ្មី(មូលប័ត្ររដ្ឋ)
- សេដ្ឋវិទូលោកកេនស៍ បានអះអាងថាឥនភាពសារពើពន្ធមានឥទ្ធិពលរុញចូល ដែលធ្វើឱ្យមានកង្វះខាតការវិនិយោគវិស័យឯកជន។
- ការអនុវត្តគោលនយោបាយឱ្យចំគោលដៅបានល្អ ទាន់ពេលវេលា និងស្ថានភាពបណ្តោះអាសន្នការចំណាយរបស់រដ្ឋាភិបាលអាចស្រូបទាញយកសមត្ថភាពការប្រើប្រាស់ ដែលមិនសូវបានល្អ ដើម្បីផ្តល់នូវឥទ្ធិពលមេគុណខ្លាំងក្លា ដែលបង្កើតចំណូលពន្ធបន្ថែម។
- ការរិះគន់លើទ្រឹស្តីជាមូលដ្ឋាន គឺថាការផ្គត់ផ្គង់មូលនិធិដែលអាចរកខ្ចីបាន មិនត្រូវបានកំណត់តែប្រភពក្នុងស្រុកទេ ក៏ប៉ុន្តែហិរញ្ញវត្ថុខាងក្រៅស្រុកក៏អាចរកខ្ចីបានដែរ។

ដូចនេះ បង្វែរការចាប់អារម្មណ៍បញ្ហានៃការអនុវត្តគោលនយោបាយសារពើពន្ធទៅជាគុណវិបត្តិសំខាន់ៗនៃគោលនយោបាយសារពើពន្ធ។ ជាទ្រឹស្តីឥទ្ធិពលរុញច្រានចេញ គឺជាគោលនយោបាយសារពើពន្ធពង្រីកដែលជួយជំរុញឱ្យមានកំណើនអត្រាការប្រាក់ និងបន្ថយចំណាយវិនិយោគឯកជន។ ហេតុនេះ វាធ្វើឱ្យថយចុះឬកាត់ផ្តាច់នូវឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីកទាំងស្រុង។

ករណីសេដ្ឋកិច្ចស្ថិតនៅក្នុងស្ថានភាពធ្លាក់ចុះ រដ្ឋាភិបាលចាត់វិធានការគោលនយោបាយឆន្ទានុសិទ្ធិដោយបង្កើនការចំណាយរបស់រដ្ឋាភិបាល។ ដើម្បីបំពេញតម្រូវការការងារនោះរដ្ឋាភិបាលនឹងចេញមុខលើទីផ្សាររូបិយវត្ថុ ក្នុងគោលបំណងដើម្បីផ្តល់ហិរញ្ញប្បទានឥនភាព។ បន្ទាប់ពីនោះ ការកើនឡើងតម្រូវការលុយ គឺវាធ្វើឱ្យអត្រាការប្រាក់ឡើងខ្ពស់ ពេលគឺថ្លៃនៃប្រាក់កម្ចីកើនខ្ពស់។ ដោយហេតុថាការចំណាយត្រូវបានប្រែប្រួលបញ្ច្រាសសមាមាត្រនឹងអត្រាការប្រាក់ ការវិនិយោគឯកជនមួយចំនួននឹងត្រូវបង្អាក់ ឬរុញចេញ(Choked-off ឬCrowded-out)។

ឥទ្ធិពលតួគុណបញ្ជាក់ថា ពេលរដ្ឋាភិបាលទិញទំនិញនិងសេវាមានទឹកប្រាក់ចំនួន៥០ពាន់លានដុល្លារពីក្រុមហ៊ុន។ បានបង្ហាញឱ្យឃើញថា លទ្ធផលកំណើនតម្រូវការសរុប ជាធម្មតាមានទំហំធំជាង ៥០ពាន់លានដុល្លារ។ ខណៈពេលកំណើនការទិញរបស់រដ្ឋាភិបាលជំរុញឱ្យមានកំណើនតម្រូវការសរុបសម្រាប់ទំនិញនិងសេវាកម្ម បណ្តាលឱ្យអត្រាការប្រាក់កើនឡើង ហើយអត្រាការប្រាក់ដ៏ខ្ពស់នោះក៏នឹងកាត់បន្ថយដល់ការវិនិយោគផងដែរ និងជាសម្ពាធសម្រាប់តម្រូវការសរុប។ តំហាយតម្រូវការសរុបដែលកើតឡើង ពេលការពង្រីកគោលនយោបាយសារពើពន្ធ បង្កើនអត្រាការប្រាក់ត្រូវបានហៅថា ឥទ្ធិពលនៃការរុញចេញ (Crowding-out effect) ។

ឥទ្ធិពលនៃការរុញចេញកើតឡើងនៅក្នុងទីផ្សាររូបិយវត្ថុ។ នៅពេលរដ្ឋាភិបាលទិញទំនិញពីក្រុមហ៊ុន។ កំណើនក្នុងតម្រូវការនឹងបង្កើនប្រាក់ចំណូលកម្មករ និងម្ចាស់ក្រុមហ៊ុន(ឥទ្ធិពលគុណ)។ ការកើនឡើងចំណូលរបស់ក្រុមគ្រួសារ មានផែនលើការចំណាយលើទំនិញនិងសេវាកម្មកាន់តែច្រើនថែមទៀត។ ជាលទ្ធផល ពួកគេក៏ជ្រើសរើសកាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួនគេបន្ថែម ក្នុងទម្រង់សន្ទនីយ-ភាព ។ ពោលគឺជាកំណើនចំណូលដែលបណ្តាលមកពីការពង្រីកគោលនយោបាយសារពើពន្ធ និងបង្កើនតម្រូវការរូបិយវត្ថុ។

ឥទ្ធិពលនៃកំណើនតម្រូវការរូបិយវត្ថុ ត្រូវបានបង្ហាញនៅក្នុងក្រាហ្វិកទី១០ខាងលើ។ ការប្រែប្រួលដល់ការផ្គត់ផ្គង់រូបិយវត្ថុ ខ្សែកោងការផ្គត់ផ្គង់ដែលជាបន្ទាត់ឈរត្រង់ គឺស្ថិតនៅដដែល។ នៅពេលកម្រិតចំណូលកាន់តែខ្ពស់ ខ្សែកោងតម្រូវការរូបិយវត្ថុរំកិលទៅខាងស្តាំពី (MD_1) ទៅរក (MD_2) ហើយ អត្រាការប្រាក់បានកើនឡើងពី (r_1) ទៅរក (r_2) ដើម្បីរក្សាការផ្គត់ផ្គង់ និងតម្រូវការឱ្យមានតុល្យភាព។

បញ្ច្រាស់មកវិញ កំណើននៃអត្រាការប្រាក់ បានកាត់បន្ថយបរិមាណតម្រូវការលើទំនិញ និងសេវាកម្ម។ ជាពិសេស ថ្លៃដើមនៃប្រាក់កម្ចី មានកម្រិតខ្ពស់ពីតម្រូវការសម្រាប់ការវិនិយោគ និងអាជីវ-កម្មបានធ្លាក់ចុះ។ ពោលគឺនៅពេលកំណើនក្នុងការទិញរបស់រដ្ឋាភិបាល បង្កើនតម្រូវការសម្រាប់ទំនិញ និងសេវា ហើយវាក៏អាចរុញច្រានការវិនិយោគផងដែរ។ ឥទ្ធិពលនៃការរុញចេញនេះ មួយផ្នែកនឹងប៉ះប៉ូវដល់ការទិញរបស់រដ្ឋាភិបាល ដែលមានលើតម្រូវការសរុប។

៥.៧-ឥទ្ធិពលគោលនយោបាយសារពើពន្ធមកលើសេដ្ឋកិច្ច (EFFECT OF FISCAL POLICY ON ECONOMICS)

តើគោលនយោបាយសារពើពន្ធ អាចប្រើដើម្បីជំរុញកំណើនសេដ្ឋកិច្ចយូរអង្វែងបានដែរឬទេ ?

គោលនយោបាយសារពើពន្ធត្រូវបានប្រើប្រាស់ ដើម្បីសម្រេចគោលដៅសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ជាពិសេសសម្រាប់រក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ជារួម កត្តាសំខាន់នៃគោលនយោបាយសារពើពន្ធ ដើម្បីរក្សាកម្រិតនិកម្មភាព និងរាំងខ្ទប់កម្រិតអតិផរណាតម្រូវការ ជាពិសេសរក្សាការពារមិនឱ្យមានកម្លាំងចលករនៅក្នុងសេដ្ឋកិច្ចរយៈពេលវែង។

៥.៧.១-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើសេដ្ឋកិច្ចរយៈពេលវែង (IMPACT OF FISCAL POLICY ON LONG-TERM ECONOMY)

ការវិភាគទ្រឹស្តីការដំឡើងពន្ធ ឬបន្ថយពន្ធ៖


ករណីដំឡើងពន្ធ (T↑) របស់រដ្ឋាភិបាល៖ យន្តការដំឡើងពន្ធរបស់រដ្ឋាភិបាល ដើម្បីគោលដៅកាត់បន្ថយឱនភាពថវិកាជាតិ និងរាំងខ្ទប់កម្រិតអតិផរណាតម្រូវការរបស់សេដ្ឋកិច្ច។ ប៉ុន្តែយន្តការនេះបានជះឥទ្ធិពលលើការប្រើប្រាស់របស់គ្រួសារលើការទិញទំនិញនិងសេវា និងកាត់បន្ថយការវិនិយោគ ដែលជាកត្តានាំឱ្យការថយចុះបរិមាណតម្រូវការសរុប និងការថយចុះទំហំផលិតផលជាតិសរុបរបស់


សេដ្ឋកិច្ចផងដែរ។ ទំហំសេដ្ឋកិច្ចត្រង់ចំនុចប្រសព្វរវាង (P_{fc}) និង (Y_{fc}) គឺជាកម្រិតសមតាបរិបទសេដ្ឋកិច្ចចំនុចប្រសព្វខ្សែកោងតម្រូវការសរុប(AD) និងខ្សែកោងការផ្គត់ផ្គង់សរុប(SRAS) គឺជាចំនុចសមតាសេដ្ឋកិច្ចដែលជាយន្តការដំឡើងពន្ធត្រង់ចំនុច (E_{fc}) ។

ករណីបន្ថយពន្ធ(T↓)របស់រដ្ឋាភិបាល៖ យន្តការបន្ថយពន្ធរបស់រដ្ឋាភិបាល ដើម្បីគោលដៅជំរុញកំណើនតម្រូវការសរុប ជាកត្តាជំរុញឱ្យការចំណាយលើការប្រើប្រាស់របស់គ្រួសារ និងជំរុញការវិនិ-យោគវិស័យឯកជនបានកើនឡើង។ ក្នុងបរិបទសេដ្ឋកិច្ចរយៈពេលវែងត្រង់ចំនុចសមតាថ្មី (P_0) និង(Y_{fc}) គឺជាកម្រិតចំនុចសមតាថ្មីក្នុងបរិបទសេដ្ឋកិច្ចមានកំណើន ដែលជាចំនុចប្រសព្វរវាងខ្សែកោងតម្រូវការសរុប (AD_1) និងខ្សែកោងការផ្គត់ផ្គង់ ($SRAS_1$) ។ ដោយសារតែរដ្ឋាភិបាលជំរុញកំណើនសេដ្ឋ-កិច្ចបង្កើនការផ្គត់ផ្គង់តាមរយៈការវិនិយោគកើនឡើង ករណីបន្ថយអត្រាការប្រាក់ធ្វើឱ្យទីផ្សារភាគហ៊ុន (Capital stock) កើនឡើង។

ករណីបង្កើនការចំណាយ (G↑) របស់រដ្ឋាភិបាល៖ យន្តការបង្កើនការចំណាយ សេវាសាធារណៈរបស់រដ្ឋាភិបាល ដូចជាចំណាយការការពារជាតិ ចំណាយលើការអប់រំ និងការចំណាយលើហេដ្ឋារចនាសម្ព័ន្ធដែលចំណាយទាំងនេះ ដើម្បីជំរុញកំណើនតម្រូវការសរុបតាមរយៈការផ្តល់នូវការងារពេលកម្មដល់ភ្នាក់ងារគ្រួសារពេញលេញ ក្នុងគោលបំណងកាត់បន្ថយអត្រានិកម្មភាពក្នុងបរិបទវិបត្តិសេដ្ឋកិច្ច។ ការបង្កើតចំណូលរបស់គ្រួសារ នាំឱ្យមានការចំណាយលើការទិញទំនិញនិងសេវា និងក្រុមហ៊ុនអាជីវ-កម្មជំរុញបង្កើនការវិនិយោគ។ ពេលចំណូលកើនឡើង ភ្នាក់ងារគ្រួសារមានគម្រោងចំណាយកាន់តែច្រើនឡើងលើទំនិញនិងសេវា ជាលទ្ធផលភ្នាក់ងារគ្រួសារមានជម្រើសបន្ថែមទៀត នៅក្នុងទម្រង់សន្ន-និយ។ ពោលគឺចំណូលកើនឡើង ដោយសារតែគោលនយោបាយសារពើពន្ធតាមរយៈការបង្កើនតម្រូវការរូបិយវត្ថុរបស់រដ្ឋាភិបាល។

ក្រាហ្វិកទី១១៖ ឥទ្ធិពលគោលនយោបាយសារពើពន្ធលើសេដ្ឋកិច្ចរយៈពេលវែង






៥.៧.២-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើការផ្គត់ផ្គង់សរុប
(SUP-PLY-SIDE: EFFECTS OF FISCAL POLICY)

ជាទូទៅ ការបង្កើនការចំណាយរបស់រដ្ឋាភិបាល និងបញ្ចុះកម្រតិពន្ធ ដើម្បីជួយជំរុញកំណើនផលិតផលក្នុងស្រុកសរុប (Y_1) ក្នុងបរិបទសកម្មភាពសេដ្ឋកិច្ចរីកចម្រើនតិចតួច ដើម្បីជំរុញកំណើនតម្រូវការសរុបនាំឱ្យខ្សែកោងតម្រូវការសរុបរំកិលពី (AD_1) ទៅរក (AD_2) នៅក្នុងពេលតែមួយ។ រដ្ឋាភិ-បាល បានបង្កើនចំណាយសេវាសាធារណៈ ជាហេតុនាំឱ្យមានការកើនតម្រូវការសរុបរំកិលទៅខាងស្តាំ ដោយបង្កើនកម្រិតកំណើននូវផលិតផលជាតិសរុបរំកិលពី (Y_1) ទៅរក (Y_2) និងបន្តយកម្រិតពន្ធ រុញច្រានទីផ្សារពលកម្មពេញលេញ ធ្វើឱ្យមានប្រាក់ចំណូលបុគ្គលកើន នាំឱ្យតម្រូវការប្រើប្រាស់របស់គ្រួ-សារកើន ជាកត្តាជំរុញឱ្យល្បឿនសកម្មភាពផលិតកម្ម ដោយសារកម្រិតបម្រែបម្រួលនៃថ្លៃរំកិលពី (P_1)ទៅរក (P_2) របស់សេដ្ឋកិច្ច នាំឱ្យកើនឡើងការវិនិយោគវិស័យឯកជន។ ករណីរដ្ឋាភិបាលបញ្ចុះកម្រិតពន្ធ ជះឥទ្ធិពលល្អទៅលើការផ្គត់ផ្គង់សរុបនាំឱ្យកើនវិស័យវិនិយោគឯកជន ជាកត្តានាំឱ្យជះឥទ្ធិពលលើការផ្គត់ផ្គង់សរុប ត្រូវបានផ្លាស់ទីទៅខាងស្តាំរំកិលពី (AS_1) ទៅរក (AS_2) ។ ការណ៍នេះ ជំរុញឱ្យកម្រិតផលិតកម្មកាន់តែខ្ពស់ ដែលបានកើនឡើងផលិតផលជាតិសរុប (Y_3) ធៀបនឹងផលិតផលជាតិសរុប (Y_2) និងកម្រិតថ្លៃកាន់តែធ្លាក់ទាបពី (P_3) រំកិលទៅ (P_2) ។ បើតាមរយៈមធ្យោបាយទាំងនេះ គោលនយោបាយសារពើពន្ធពង្រីក ក្នុងន័យថាការបញ្ចុះពន្ធ (Redue Tax) នាំឱ្យផ្លាស់ទីខ្សែកោងតម្រូវការសរុបរំកិលទៅខាងស្តាំពី (AS_1) ទៅ (AS_2) ។

តាមទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក ពួកគេបានទទួលស្គាល់ថាការចញ្ចុះកម្រិតអត្រាពន្ធ មិនចាំបាច់ត្រូវធ្វើឱ្យមានការកាត់បន្តយប្រាក់ចំណូលពន្ធនោះទេ។ ពួកគេបានយល់ថាការបញ្ចុះកម្រិតអត្រាពន្ធ គឺជួយឱ្យកើនឡើងបរិមាណផលិតផលលើទំនិញនិងសេវា និងប្រាក់ចំណូលពន្ធ ព្រមទាំងអាចទាក់ទាញកំណើនចំណូលពន្ធបានច្រើនទៀតផង។ ដូចនេះ គោលនយោបាយសារពើពន្ធពង្រីកអាចនាំឱ្យមានកំណើនប្រាក់ចំណូលពន្ធ ក្នុងករណីអត្រាពន្ធកាន់តែទាបនោះ។ សេចក្តីសន្និដ្ឋានរបស់សេដ្ឋវិទូក្លាស៊ីក មានន័យថាការបញ្ចុះអត្រាពន្ធអាចត្រូវធ្វើឡើង ដើម្បីផ្គត់ផ្គង់កំណើនប្រាក់ចំណូលពន្ធ និងការកាត់បន្តយឱនភាពថវិកា។ ប៉ុន្តែចំពោះទស្សនៈ ទូទៅបានយល់ឃើញថាការបញ្ចុះកម្រិតអត្រាពន្ធ គឺធ្វើឱ្យកាត់បន្តយប្រាក់ចំណូលពន្ធ និងកំណើនឱនភាពថវិកាជាតិ។

ក្រាហ្វិកទី១២៖ ឥទ្ធិពលគោលនយោបាយសារពើពន្ធលើខ្សែកោងផ្គត់ផ្គង់សរុប



៥.៧.៣-ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើការនាំចេញសុទ្ធ

(NET EXPORT: EFFECTS OF FISCAL POLICY)

ឥទ្ធិពលនៃការនាំចេញសុទ្ធ តាមរយៈពាណិជ្ជកម្មអន្តរជាតិ អាចនឹងធ្វើឱ្យចុះខ្សោយប្រសិទ្ធភាពនៃគោលនយោបាយសារពើពន្ធផងដែរ។ ការវិភាគឥទ្ធិពលរុញចេញ បានបញ្ជាក់អំពីលទ្ធភាពនៃការឡើងអត្រាការប្រាក់ស្ថិតក្រោមឥទ្ធិពលគោលនយោបាយសារពើពន្ធពង្រីក ដែលនាំឱ្យការកាត់បន្ថយការវិនិយោគឯកជន។ ដូចនេះ គោលនយោបាយសារពើពន្ធពង្រីក មានឥទ្ធិពលលើការនាំចេញសុទ្ធផងដែរ។

ការអនុវត្តនូវគោលនយោបាយសារពើពន្ធពង្រីក អាចធ្វើឱ្យអត្រាការប្រាក់ឡើងកាន់តែខ្ពស់ ដែលអាចជះឥទ្ធិពលដល់ការវិនិយោគឯកជន និងការផ្គត់ផ្គង់ត្រូវបានកាត់បន្ថយ។ ក៏ប៉ុន្តែ អត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ គឺអាចទាក់ទាញមូលធនហិរញ្ញវត្ថុពីក្រៅប្រទេស ដោយសារកម្រិតអត្រាការប្រាក់មានការប្រែប្រួល។ ដូចនេះតើការកើនឡើងថ្លៃប្រាក់ដុល្លារអាមេរិក មានឥទ្ធិពលបែបណាទៅដល់ការនាំចេញសុទ្ធរបស់សហរដ្ឋអាមេរិក?

ហេតុផលនៃការឡើងថ្លៃប្រាក់ដុល្លារនេះ សម្រាប់ការទិញទំនិញរបស់អាមេរិក គឺត្រូវការចំនួនឯកសាររូបិយវត្ថុបរទេសកាន់តែច្រើនជាងមុន។ ដូច្នេះទំនិញនាំចេញរបស់អាមេរិក គឺថ្លៃកាន់តែខ្ពស់ជាងថ្លៃ

ទំនិញទិញពីបរទេស។ បញ្ហានេះ ធ្វើឱ្យការនាំចេញរបស់អាមេរិកត្រូវបានកាត់បន្ថយ។ តែផ្ទុយមកវិញ ប្រជាពលរដ្ឋអាមេរិកអាចសម្រេចចិត្តប្តូររូបិយវត្ថុរបស់ខ្លួនជាមួយនឹងរូបិយប័ណ្ណបរទេស(Currency) ដោយទទួលបានចំនួនកាន់តែច្រើន ពោល គឺពួកគេនឹងទិញទំនិញនាំចូលកាន់តែច្រើន។ នេះជាហេតុផល ធ្វើឱ្យមានការកាត់បន្ថយការនាំចេញរបស់អាមេរិក បែរជាបង្កើនការនាំចូលទំនិញពីបរទេសវិញ។ ហេតុការណ៍នេះ នាំឱ្យការចំណាយនាំចេញសុទ្ធរបស់សហរដ្ឋអាមេរិកត្រូវបានកាត់បន្ថយ។ ការ ណ៍នេះ បានធ្វើឱ្យគោលនយោបាយសារពើពន្ធពង្រីក ត្រូវបានជាប់គាំង។ ដូចនេះ គោលនយោបាយសារពើពន្ធពង្រីក អាចនឹងចុះខ្សោយនូវប្រសិទ្ធភាពរបស់ខ្លួន ដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច។

វិភាគទិដ្ឋភាពទ្រឹស្តី៖


គោលនយោបាយសារពើពន្ធពង្រីក សំដៅទៅលើការបង្កើនតម្រូវការសរុប នាំឱ្យខ្សែកោងតម្រូវការសរុបរំកិលពី(AD_1)ទៅរក(AD_2) គឺអាចដំឡើងអត្រាការប្រាក់ក្នុងស្រុក ជាលទ្ធផលចុងក្រោយនាំឱ្យកាត់បន្ថយការនាំចេញសុទ្ធ ដោយសារតែឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីក មានឥទ្ធិពលលើការនាំចេញសុទ្ធ។ ការកាត់បន្ថយនាំចេញសុទ្ធ គឺជាសមាសធាតុនៃតម្រូវការសរុបមួយផ្នែក ត្រូវបានទូទាត់ដោយឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីក។ ឥទ្ធិពលនាំចេញសុទ្ធ កើតឡើងដោយសារគោលនយោបាយសារពើពន្ធ ត្រូវបានផ្សារភ្ជាប់ជាមួយបញ្ហាពេលវេលា (Time) បញ្ហានយោបាយ(Political) ឥទ្ធិពលរុញចេញ និងអតិផរណា(Inflation) ដែលជាបុព្វហេតុធ្វើឱ្យមានភាពស្មុគស្មាញដល់ការគ្រប់គ្រងតម្រូវការសរុបផងដែរ។ យើងដឹងថា ឥទ្ធិពលនាំចេញសុទ្ធ (Net export effect) នឹងកើតឡើងដោយសារតែគោលនយោបាយសារពើពន្ធ គឺមានទិសដៅបញ្ចុះអត្រាការប្រាក់ក្នុងស្រុក ដោយប្រើនូវគោលនយោបាយសារពើពន្ធបង្រួម គឺដើម្បីបង្កើនការនាំចេញសុទ្ធវិញម្តង។ ដូចនេះ ឥទ្ធិពលរុញចេញបានបង្ហាញថា គោលនយោបាយសារពើពន្ធពង្រីក អាចដំឡើងអត្រាការប្រាក់ និងកាត់បន្ថយការចំណាយវិនិយោគ។ ទន្ទឹមនឹងនោះ គោលនយោបាយសារពើពន្ធ អាចត្រូវបានចុះខ្សោយដោយសារតែឥទ្ធិពលនាំចេញសុទ្ធកើតឡើងតាមរយៈ៖

១)-អត្រាការប្រាក់,

២)-តម្លៃប្រាក់ដុល្លារនៅលើទីផ្សារពិភពលោក និង

៣)-ទំហំការនាំចេញនិងការនាំចូល។

ក្រាហ្វិកទី១៣៖ ឥទ្ធិពលគោលនយោបាយសារពើពន្ធលើការនាំចេញសុទ្ធ





(ក)-គោលនយោបាយសារពើពន្ធសុទ្ធ និងសាមញ្ញ (ខ)-គោលនយោបាយសារពើពន្ធ និងឥទ្ធិពលរុញច្រាន (គ)-គោលនយោបាយសារពើពន្ធ និងអតិផរណា (ឃ)-គោលនយោបាយសារពើពន្ធ និងការនាំចេញសុទ្ធ

សរុបជារួម គោលនយោបាយសារពើពន្ធ អាចត្រូវបានចុះខ្សោយ ដោយសារតែឥទ្ធិពលនាំចេញសុទ្ធដូចបានពន្យល់ខាងលើនេះស្រាប់។ ទន្ទឹមនឹងនេះដែរ មានគោលនយោបាយពាណិជ្ជកម្មអន្តរជាតិមួយទៀត គឺជាគោលនយោបាយដែលមានទិសដៅធ្វើឲ្យមានឥទ្ធិពលដោយផ្ទាល់លើបរិមាណផលិតផលទំនិញនិងសេវា ដែលត្រូវនាំចេញ និងនាំចូល។ គោលនយោបាយពាណិជ្ជកម្ម គឺមានទិសដៅបង្កើនការនាំចេញ ឬការពារឧស្សាហកម្មនៅក្នុងស្រុកពីការប្រណាំងប្រជែងពីបរទេស ដោយយោងទៅលើការនាំចូលឬកំណត់បរិមាណទំនិញឬសេវា ដែលត្រូវនាំចូលដោយប្រើប្រាស់នូវប្រព័ន្ធ កូតា។ គោលនយោបាយនេះ ការពារឧស្សាហកម្មក្នុងស្រុក ហៅថាគោលនយោបាយគាំពារនិយម។

ជំពូកទី ៦

គោលនយោបាយរូបិយវត្ថុ

MONETARY POLICY

៦.១-ប្រវត្តិសង្ខេបនៃរូបិយវត្ថុ (HISTORY OF THE DEfiNITION OF MONEY)

៦.១.១-សេចក្តីផ្តើម (INTRODUCTION)

រូបិយវត្ថុ គឺជាមានមុខងារជាច្រើនដោយពុំអាចកំណត់អត្តសញ្ញាណទ្រព្យសកម្មឱ្យបានជាក់លាក់នោះទេ ហើយច្រើនតែបង្កបញ្ហាធ្ងន់ធ្ងរដល់ការកំណត់អត្តសញ្ញាណរបស់វាថែមទៀត។ ពីព្រោះថាទ្រព្យសកម្មដែលមានភាពខុសៗគ្នា និងមានមុខងារខុសៗគ្នាជាច្រើន។ល។ បញ្ហានឹងវិធានជាក់ស្តែងរបស់រូបិយវត្ថុ គឺមិនមែនជារឿងថ្មីទេ ហើយរូបិយវត្ថុក៏មិនចាំបាច់ប្រើទម្រង់ឱ្យស្រួចស្រាវខ្លាំងពេកនោះទេ នាពេលបច្ចុប្បន្ននេះ។

ការវិវត្តដំបូងនៃសេដ្ឋកិច្ចមិនចាយលុយ (barter economy) បានផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចរូបិយវត្ថុ (monetary economy) ដែលមានទម្រង់ទូទាត់ចំនួនមួយ ឬច្រើនជាងមួយ។ ហើយមានទម្រង់មួយនៃរូបិយប័ណ្ណទាំងនេះ គឺរូបិយប័ណ្ណដែលមានទម្រង់ជាប្រាក់កាសពីលោហៈដ៏មានតម្លៃជាមួយនឹងតម្លៃប្តូរជារូបិយវត្ថុ ដែលវាយ៉ាងហោចណាស់ស្មើនឹងតម្លៃនៃលោហៈក្នុងប្រាក់កាសនោះដែរ។

ជាទូទៅ ប្រាក់កាសទាំងនេះត្រូវបានបញ្ចូលនូវអំណាចអាជ្ញាធរព្រះមហាក្សត្រ ហើយត្រូវបានគេហៅថា "legal tender" ដែលតម្រូវឱ្យអ្នកលក់ ឬម្ចាស់បំណុលទទួលយកប្រាក់កាសទាំងនេះ ធ្វើជាមធ្យោបាយទូទាត់។ ការដេញថ្លៃស្របច្បាប់ស្ថិតក្រោមកាលៈទេសៈដ៏ជាក់លាក់មួយ ត្រូវបានបន្ថែមមុខងារជាមធ្យោបាយទូទាត់ដោយប័ណ្ណបំណុលរបស់រូបវន្តបុគ្គល ឬស្ថាប័នហិរញ្ញវត្ថុ ដែលគេបានយកចិត្តទុកដាក់នាសតវត្សរ៍ទី ១៨ និង ១៩ ដោយបានចេញប័ណ្ណប្តូរប្រាក់នៅក្នុងចក្រភពអង់គ្លេសដំបូងគេបង្អស់ ។ ទោះយ៉ាងណា ប្រាក់កាសទាំងនេះមិនត្រូវបានក្លាយជាមធ្យោបាយទូទាត់ដែលអាចទទួលយកជាទូទៅនោះទេ។

ការលេចចេញនូវមុខងាររបស់ធនាគារពាណិជ្ជកម្ម(ឯកជន)[៧៧] នាសតវត្សរ៍ទី១៨ នៅចក្រភពអង់គ្លេស បាននាំឱ្យមានការបោះផ្សាយក្រដាសប្រាក់ជាឯកជនដោយធនាគាររបស់ពួកគេ ហើយក៏មានការបញ្ជាដកក្រដាសប្រាក់ដែរ។ ភាពទាក់ទាញពីធនាគារទាំងនេះ ចំពោះអ្នកដែលមានប្រាក់តម្កល់ជាមួយនឹងធនាគាររបស់ពួកគេ។ ទោះបីយ៉ាងណា ការរក្សាប្រាក់បញ្ញើតាមតម្រូវការរបស់ធនាគារទាំង

[៧៧] Many of the bankers were originally goldsmiths who maintained safety vaults and whose customers would deposit gold coins with them for security reasons. When a depositor needed to make a payment to someone, he could write a note/letter authorizing the recipient to withdraw a certain amount from the deposits of the payer with the goldsmith.

នេះ បានក្លាយជារឿងធម្មតាក្នុងចំណោមបណ្តាសហគ្រាស និងអ្នកដែលមានលុយច្រើន នាដើមសតវត្សរ៍ទី ២០។ ប្រជាប្រិយភាពនៃប្រាក់បញ្ញើទាំងនេះ បានចាប់ផ្តើមមានប្រជាប្រិយភាពក្នុងចំណោមមនុស្សម្នាសាមញ្ញ បានកើតឡើងនៅក្នុងសតវត្សរ៍ទី ២០ ជាមួយនឹងប្រជាប្រិយភាពនេះ ប្រាក់បញ្ញើតាមតម្រូវការ បានក្លាយជាធាតុផ្សំនៃមធ្យោបាយទូទាត់នៅក្នុងសេដ្ឋកិច្ចជាមួយនឹងបរិមាណប្រាក់បញ្ញើតាមតម្រូវការដែលកាន់តែធំជាងបរិមាណរូបិយប័ណ្ណ។

នៅក្នុងចក្រភពអង់គ្លេសនាពាក់កណ្តាលសតវត្សរ៍ទី ១៩ មានក្រុមសេដ្ឋវិទូ និងធនាគារិក បានប្រឈមនឹងបញ្ហាតស៊ូមតិ នៅចំពោះមុខថាតើត្រូវដោះស្រាយបំណុលដែលមានតម្រូវការរបស់ធនាគារពាណិជ្ជកម្មលើរូបិយប័ណ្ណ ដូចជារូបិយវត្ថុ ឬ អត់? ដោយសារធនាគារពាណិជ្ជកម្ម ស្ថិតក្នុងភាពក្មេងខ្ចីនៅឡើយ ហើយត្រូវបានគេយកចិត្តទុកដាក់ចំពោះតែបុគ្គលដែលមានទ្រព្យសម្បត្តិ និងសហគ្រាសធំៗតែប៉ុណ្ណោះ ។

ខណៈពេលដែលបានដំណើរការជាមធ្យោបាយទូទាត់ក្នុងចំណោមរូបិយវត្ថុទាំងនេះ ដែលប្រជាជនភាគច្រើនមិនបានប្រើប្រាស់វានោះទេ។ នៅក្នុងបរិបទបែបនេះ មានការជជែកវែកញែកគួរឱ្យកត់សម្គាល់លើមុខងាររបស់រូបិយវត្ថុ (ក្រដាសប្រាក់និងកាស) គោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិរូបិយវត្ថុដែលសមស្របនាពាក់កណ្តាលសតវត្សរ៍ទី ១៩ មាននៅប្រទេសអង់គ្លេស។

បញ្ហាទំនាស់ទាំងនេះ បានកើតឡើងជុំវិញការលេចចេញប្រាក់បញ្ញើតាមតម្រូវការរបស់ធនាគារដែលអាចដំនួសឱ្យគ្នាបាន។ ទោះបីជារូបិយប័ណ្ណមិនល្អឥតខ្ចោះក៏ដោយ ដែលពីមុនជាផ្នែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុឬ? ការវិវត្តបន្ថែមទៀតប្រាក់បញ្ញើតាមតម្រូវការ និងធនាគារ នាចុងសតវត្សរ៍ទី ១៩ និងពាក់កណ្តាលសវតវត្សរ៍ទី ២០ មាននៅចក្រភពអង់គ្លេស កាណាដា និងសហរដ្ឋអាមេរិក បាននាំឱ្យមានសុវត្ថិភាពទាក់ទងនឹងការប្រើប្រាស់ប្រាក់បញ្ញើតាមតម្រូវការ និងបង្កើតឱ្យអាចដំនួសឱ្យគ្នាបានយ៉ាងជិតស្និទ្ធជាមួយនឹងរូបិយប័ណ្ណ។

ដូច្នេះ ការទទួលស្គាល់និយមន័យរបស់រូបិយវត្ថុនៅអំឡុងសតវត្សរ៍ទី ២០ បានឱ្យក្លាយជារូបិយប័ណ្ណដែលស្ថិតក្នុងដៃរបស់សាធារណជន និងប្រាក់បញ្ញើនៅក្នុងធនាគារពាណិជ្ជកម្ម។ ក្នុងអំឡុងពេលនោះ ប្រាក់បញ្ញើសន្សំមិនអាចត្រូវបានពិនិត្យបាននោះទេ ហើយធនាគារដែលកាន់កាប់ប្រាក់បញ្ញើសន្សំទាំងនេះ បានទទួចឱ្យមានការជូនដំណឹងជាមុនសិននៅពេលដកប្រាក់ដោយផ្ទាល់របស់អ្នកដាក់ប្រាក់បញ្ញើរបស់ពួកគេ។ បើមិនដូច្នេះ ពួកគេមិនអាចដកតម្កល់ប្រាក់បញ្ញើបានទេ និងមិនអាចដកប្រាក់បានជាសាច់ប្រាក់ដែលជាមធ្យោបាយទូទាត់បានទៀតផង។ ហេតុផលនេះ ទើបមកដល់ពាក់កណ្តាលសត-វត្សរ៍ទី២០ ការកំណត់និយមន័យរូបិយវត្ថុមានលក្ខណៈតូចចង្អៀត ត្រូវបានកំណត់ដោយនិមិត្តសញ្ញារូបិយវត្ថុ M1 ។

រហូតមកដល់ពាក់កណ្តាលសតវត្សរ៍ទី ២០ ការតម្កល់ប្រាក់បញ្ញើតាមតម្រូវការនៅតាមបណ្តាប្រទេសភាគច្រើនមិនមានបង់ការប្រាក់នោះទេ ហើយប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្មត្រូវបានអនុវត្ត។ ទោះបីជាត្រូវមានពិដាន(Ceiling)ច្បាប់រារាំងទៅលើការកំណត់អត្រាការប្រាក់ក៏ដោយ។ នៅក្នុងអំឡុងទសវត្សរ៍ ១៩៥០ ការផ្លាស់ប្តូរនូវការអនុវត្តរបស់ធនាគារលើប្រាក់បញ្ញើសន្សំទាំងនេះកាន់តែ

មានលក្ខណៈកាន់តែជិតគ្នា និងជំនួសឱ្យគម្លាប់ប្រាក់បញ្ញើតាមតម្រូវការ ដូច្នេះទំនាស់ដ៏ធំនៅទសវត្សរ៍ឆ្នាំ ១៩៥០ ទាក់ទងនឹងប្រាក់សន្សំនេះ *ថាតើប្រាក់បញ្ញើសន្សំគួរមាន ឬមិនគួរមានត្រូវបានរាប់បញ្ចូលជានិយមន័យរូបិយវត្ថុមានលក្ខណៈតូចចង្អៀតដែរឬទេ?*

ទោះយ៉ាងណា នាដើមទសវត្សឆ្នាំ១៩៦០ មានសេដ្ឋវិទូភាគច្រើន បានវាស់វែងការផ្គត់ផ្គង់រូបិយវត្ថុប្រភេទ M2 ពោលគឺជាប្រភេទរូបិយវត្ថុ M1 បូកនឹងប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្ម ដោយមិនរាប់បញ្ចូលប្រភេទប្រាក់បញ្ញើណាមួយនៅក្នុងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតទេ។ ទម្រង់នៃការផ្លាស់ប្តូរប្រភេទរូបិយវត្ថុ M2 ដែលត្រូវបានគេស្គាល់ថាគឺជាទ្រឹស្តីរបស់លោក Milton Friedman (វិធាននៃការវាស់វែងរូបិយវត្ថុ) បានចាប់ផ្តើមតាំងពីសម័យលោក Milton Friedman មកម្ល៉េះ ដែលលោកជាអ្នករូបិយវត្ថុនិយមបានគាំទ្រដ៏សំខាន់ម្នាក់នៅអំឡុងទសវត្សរ៍ ១៩៥០ និង ១៩៦០ ។

នៅក្នុងសហរដ្ឋអាមេរិកនាអំឡុងទសវត្សរ៍ ១៩៦០ អត្រាការប្រាក់ទីផ្សារលើមូលបត្របំណុល (bond) និងប័ណ្ណបំណុល (Treasury bill) បានកើនឡើងគួរឱ្យកត់សម្គាល់ដោយមានកម្រិតខ្ពស់លើសពិដាន (Ceiling) ដែលច្បាប់បានកំណត់ដោយអាជ្ញាធរលើអត្រាការប្រាក់ដែលត្រូវបង់លើប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្ម។ ការប្រកួតប្រជែងនៅក្នុងវិស័យនេះ មិនមានការគ្រប់គ្រងបានល្អដែលនាំឱ្យមានការផ្លាស់ប្តូរលក្ខណៈរូបិយវត្ថុប្រហាក់ប្រហែល (near-monies) ដែលមានស្រាប់ក្នុងអន្តរការីដែលមិនមែនហិរញ្ញវត្ថុ និងធ្វើឱ្យកាន់តែខិតជិតប្រាក់បញ្ញើតាមតម្រូវការ ហើយក៏ឈានទៅរកការបង្កើតទ្រព្យសម្បត្តិផ្សេងទៀត នៅក្នុងវិស័យដែលមិនមានការគ្រប់គ្រងច្បាស់លាស់។

ដូច្នេះ ទ្រព្យបំណុលមិនមែនជាអន្តរការីហិរញ្ញវត្ថុ មិនអាចជំនួសឱ្យគ្នាបានទេ។ ទ្រព្យបំណុលខ្លះភាគច្រើនមានភាពមិនល្អឥតខ្ចោះ ចំពោះរូបិយប័ណ្ណ និងប្រាក់បញ្ញើ។ ចំពោះភាពចម្រូងចម្រាស នេះបានកើតឡើងនក្នុងសតវត្សទី ១៩ ពីតួនាទីនៃប្រាក់បញ្ញើតាមតម្រូវការនៅក្នុងទសវត្សឆ្នាំ ១៩៥០ បានកើតឡើងប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្ម។ ការវិវត្តស្រដៀងគ្នានេះ បានជជែកវែកញែកគ្នាកើតឡើងមាននៅប្រទេសកាណាដា និងចក្រភពអង់គ្លេស។ សំណួរដ៏សំខាន់ក្នុងភាពចម្រូងចម្រាសទាំងនេះ *ថាតើត្រូវមានទ្រព្យបំណុលយ៉ាងដូចម្តេច? ប្រភេទរូបិយវត្ថុ M1 គឺជាមធ្យោបាយទូទាត់ចម្បងដែលត្រូវដាក់បញ្ចូលនៅក្នុងវង្វាស់នៃរូបិយវត្ថុយ៉ាងដូចម្តេច?*

៦.១.២-ការបង្កើតរូបិយវត្ថុគឺជាអ្វី? (WHAT IS MONEY CREATION?)

ការបង្កើតរូបិយវត្ថុ គឺជាដំណើរការដែលនាំឱ្យមានការកើនឡើងការផ្គត់ផ្គង់រូបិយវត្ថុ។ ការផ្គត់ផ្គង់រូបិយវត្ថុនេះ អាចត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺ:

- រូបិយប័ណ្ណ (Currency)៖ នេះគឺក្រដាសប្រាក់និងកាសដែលកំពុងចរាចរនៅក្នុងប្រទេស។ វាតំណាងឱ្យប្រហែល ៥% នៃការផ្គត់ផ្គង់រូបិយវត្ថុរបស់ពិភពលោក។
- សៀវភៅគណនី (Book money)៖ នេះគឺជារូបិយវត្ថុដែលមានទម្រង់ជាគណនេយ្យ។ វាតំណាងឱ្យ ៩៥% នៃការផ្គត់ផ្គង់រូបិយវត្ថុរបស់ពិភពលោក។ រូបិយវត្ថុនេះ មិនមានជារូបរាងទេវាគ្រាន់តែជាបន្ទាត់ដែលរំលេចឡើងនៅលើឥណពន្ធ ឬលើផ្នែកឥណទាននៃគណនីធ

នាគារ។ នោះ ជាមូលហេតុដែលធនាគារភ័យខ្លាចរឿងមួយក្នុងកំឡុងពេលមានវិបត្តិរូបវន្ត បុគ្គលម្នាក់ៗ នឹងសម្រេចចិត្តលុបចោលគណនីរបស់ពួកគេដោយខ្លាចការដួលរលំធនាគារ។ ចលនាភ័យស្លន់ស្លោ បាននាំឱ្យមានការបិទធនាគារ ដែលអសមត្ថភាពក្នុងការចេញផ្សាយក្រដាសប្រាក់និងកាស។ ប្រសិទ្ធភាពរូបិយវត្ថុនេះ ពិតជាមិនមានទេ វាគឺជាការចុះបញ្ជូលគណនេយ្យសាមញ្ញមួយ។ ការបង្កើតរូបិយវត្ថុ គឺមានជាអចិន្ត្រៃយ៍ ហើយត្រូវបានគ្រប់គ្រងតាមទ្រឹស្តីធនាគារ កណ្តាល។ ពួកគេគឺជាអ្នកសម្រេចចិត្តលើកម្រិតនៃការបង្កើតរូបិយវត្ថុដែលពួកគេចង់បាន។

ជាទូទៅ មានរូបភាពមិនត្រឹមត្រូវនៃការបង្កើតរូបិយវត្ថុជាច្រើន ជាប់ពាក់ព័ន្ធនឹងពាក្យថា "printing press"។ សម្រាប់មនុស្សសាមញ្ញតែងតែយល់ខុសពីការបង្កើតរូបិយវត្ថុដែលពួកគេភ្ជាប់នឹងពាក្យនេះ។ មានអ្នកក្លែងបន្លំដំណើរការម៉ាស៊ីនបោះពុម្ពផ្សាយក្រដាសប្រាក់ ប៉ុន្តែទោះបីជាមានលក្ខណៈខ្លះដូចគ្នានឹងធនាគារកណ្តាលក៏ដោយ ក៏អ្នកក្លែងបន្លំក្រដាសប្រាក់ទាំងនេះមិនមានអ្វីមួយដូចគ្នានោះទេ។ រវាងអ្នកក្លែងបន្លំ និង ធនាគារកណ្តាល មិនមានអ្វីដូចគ្នាទាំងស្រុងឡើយ។ អ្នកឈ្នះរង្វាន់ណូបែលផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចលោក Maurice Allais ក៏ជឿជាក់ផងដែរថា មិនមានភាពខុសគ្នារវាងរូបិយវត្ថុបង្កើតដោយធនាគារកណ្តាល និងដោយអ្នកក្លែងបន្លំបង្កើតក្រដាសប្រាក់ទេ។ វាត្រូវបានបង្កើតឡើងដោយនាំទៅរកលទ្ធផលដូចគ្នា។ អ្វីដែលជាភាពខុសគ្នាតែមួយគត់ គឺថាអ្នកទទួលបានអត្ថប្រយោជន៍ពីវាខុសគ្នា។ តើអ្វីដែលត្រូវពិចារណា?

៦.១.៣-យន្តការដែលនាំឱ្យមានការបង្កើតប្រាក់ (MECHANISMS LEADING TO MONEY CREATION)

ប្រសិនបើ ជាក់ពាក្យស្នើសុំប្រាក់កម្ចីត្រូវបានទទួលយកដោយធនាគារ វានឹងបញ្ចូលក្នុងគណនីរបស់អ្នកជាក់ពាក្យស្នើសុំជាមួយនឹងចំនួនប្រាក់កម្ចី។ ឧទាហរណ៍ អ្នកត្រូវការប្រាក់ចំនួន ២០០,០០០ ដោន ដើម្បីទិញគេហដ្ឋានរបស់អ្នក ធនាគារនឹងបញ្ចូលគណនីរបស់អ្នកជាមួយនឹងចំនួនទឹកប្រាក់នេះ ហើយចំនួននេះបង្ហាញគណនីឥណពន្ធលើគណនីធនាគារ។ វាផ្តល់បុរេប្រទានឱ្យអ្នកនូវចំនួនទឹកប្រាក់ ២០០,០០០ដោន។ ដើម្បីផ្តល់នូវប្រាក់កម្ចីនេះ ធនាគារអាចប្រើប្រាក់បញ្ញើដែលប្រមូលបានទាំងអស់ (ប្រាក់សន្សំរយៈពេលខ្លី និងរយៈពេលវែងរបស់អតិថិជនរបស់ខ្លួន)។ ដូច្នេះធនាគារ ប្រើប្រាក់សន្សំអតិថិជនដើម្បីរកប្រាក់ចំណេញ។ ប្រសិទ្ធិភាពរបស់ធនាគារ គឺផ្តល់ប្រាក់កម្ចីដល់អតិថិជន ហើយអតិថិជនត្រូវបង់អត្រាការប្រាក់(នេះជារឿងធម្មតា)។ ជាការពិតធនាគារ ផ្តល់ខ្ចីប្រាក់ដែលមិនមែនជាប្រាក់របស់ធនាគារ (ជាលុយរបស់អតិថិជន)។ នេះគ្រាន់តែ ធនាគារមានសិទ្ធិដែលផ្តល់ដោយធនាគារកណ្តាល។ តាមរយៈការកត់ត្រាបញ្ចូលគណនេយ្យសាមញ្ញ (ភ្ជាប់ទៅនឹងការបង្កើតប្រាក់កម្ចីថ្មី) ដូច្នេះមានការបង្កើតរូបិយវត្ថុពីប្រាក់បញ្ញើរបស់ធនាគារ។ ធនាគារ បម្លែងប្រាក់សន្សំអតិថិជនទៅជាប្រាក់កម្ចីថ្មី។ ប៉ុន្តែការបង្កើតរូបិយវត្ថុ មិនបានបញ្ចប់នៅត្រឹមនេះទេ។ ដូចនេះ ប្រសិទ្ធភាពនៃបរិមាណប្រាក់កម្ចី

ក៏នឹងបង្កើតប្រាក់កម្ចីថ្មីៗបានផងដែរ នេះត្រូវបានគេហៅថាប្រាក់បញ្ញើ ឬមេគុណឥណទាន (credit multiplier) ។

ឧទាហរណ៍៖ អ្នកនឹងទទួលបាន ២០០,០០០ដោនពីធនាគាររបស់អ្នក ដើម្បីទិញផ្ទះរបស់អ្នក។ អ្នកបានទូទាត់ថ្លៃចំណាយឱ្យទៅម្ចាស់ផ្ទះចាស់ ឬអ្នកសាងសង់ផ្ទះលក់នោះទាំងអស់។ ពួកគេដាក់ប្រាក់ចំនួន ២០០,០០០ដោន អ្នកបានឱ្យពួកគេចូលទៅក្នុងគណនីធនាគារនៅឯធនាគាររបស់ពួកគេ។ បន្ទាប់មក ធនាគារនោះបានទទួលប្រាក់សន្សំដែលខ្លួនអាចខ្ចីជាថ្នូរនឹងការផ្តល់ប្រាក់កម្ចីថ្មីៗ។ វាគឺជាបង្វិលជុំគ្មានទីបញ្ចប់នៃការបង្កើតរូបិយវត្ថុ។ ទោះយ៉ាងណាក៏ដោយ ក៏មានដែនកំណត់ចំពោះការប-ង្កើតរូបិយវត្ថុប្រភេទនេះដែរ ដោយសារតែច្បាប់ Basell III (Basell III rules) ។ បទបញ្ញត្តិទាំងនេះស្តីពីការធ្វើសោធនភាពធនាគាដែលកំណត់ដោយអាជ្ញាធរ។ វិធានទាំងនេះបានចែងថា ធនាគារត្រូវតែមានសមាមាត្រសោធនភាព ៨% (អត្រាទុនបម្រុងកាតព្វកិច្ច) បូកនឹងប័ណ្ណបំណុល (securi ty) ២,៥% ពោលគឺ១០.៥%។ សមាមាត្រនេះហើយ រារាំងដល់ធនាគារពីការផ្តល់ប្រាក់កម្ចីសន្សំទាំងអស់ដែលអាចរកបានពីអតិថិជនរបស់ខ្លួន។ ឧទាហរណ៍ នៅពេលធនាគារទទួលបានប្រាក់សន្សំ € ១,០០០ ពីអតិថិជនតរបស់ធនាគារ ត្រូវតែរក្សាទុកប្រាក់បម្រុង €១០៥(១,០០០*១០.៥/១០០)។ ដូច្នេះ ធនាគារអាចផ្តល់នូវប្រាក់កម្ចីត្រឹមតែ €៨៩៥ តែប៉ុណ្ណោះ។ សម្រាប់ធនាគារបន្ទាប់ អាចទទួលបានឥណទានដែលអាចខ្ចីបានត្រឹមតែ €៨០១ តែប៉ុណ្ណោះ។ នេះជាដែនកំណត់មេគុណឥណទាន (credit multiplier) ដើម្បីបង្កើតរូបិយវត្ថុ។ ជាមួយនឹងការដាក់ប្រាក់បញ្ញើដំបូងចំនួន €១,០០០ ក្នុងការហាមឃាត់ការបង្កើតរូបិយវត្ថុតាមទ្រឹស្តី គឺប្រហែល €៤,៥០០(៨៩៥+៨០១។ល។) ឬជាគុណឥណទាន ៤.៥(៤,៥០០/១,០០០)។ ការកំណត់ផ្សេងទៀតនៃការបង្កើតរូបិយវត្ថុដោយមេគុណឥណទាន គឺជាតម្រូវការរូបិយវត្ថុ។ ដើម្បីផ្តល់ប្រាក់កម្ចីថ្មីៗដ៏ចាំបាច់ ត្រូវតែមានថវិកាពីតួអង្គសេដ្ឋកិច្ចផ្សេងៗទៀត។ ខណៈពេលមានវិបត្តិសេដ្ឋកិច្ច តម្រូវការទាំងនេះត្រូវបានកាត់បន្ថយដោយសារទំនុកចិត្តរបស់វិនិយោ-គិនមានកម្រិតទាបនាពេលអនាគត។ ធនាគារ ត្រូវតែរកអតិថិជនដែលខ្លួនចាត់ទុកថាជាធាតុដែលនាំឱ្យបាត់បង់។ មេគុណនៃឥណទាន មិនត្រូវបានប្រើក្នុងកម្រិតទ្រឹស្តីអតិបរមានោះទេ។

៦.១.៤-ការបង្កើតរូបិយវត្ថុតាមរយៈបំណុល (THE CREATING MONEY THROUGH DEBT)

ដើម្បីផ្តល់នូវឥណទានថ្មី ការបង្កើតរូបិយវត្ថុរបស់ធនាគារ ត្រូវតែមានធនធាន។ ប្រសិនបើ ប្រាក់បញ្ញើរបស់អតិថិជន មិនអនុញ្ញាតិឱ្យធនាគារផ្តល់ប្រាក់កម្ចីជាថ្មីទេ ធនាគារអាចងាកទៅរកធនាគារកណ្តាល ដើម្បីស្នើសុំខ្ចីប្រាក់ពីធនាគារកណ្តាលបាន។ ធនាគារបានផ្តល់គណនីដល់អតិថិជនរបស់ខ្លួនជាមួយនឹងចំនួនប្រាក់កម្ចី ហើយចំនួនទឹកប្រាក់កម្ចីដូចគ្នាត្រូវបានបញ្ចូលទៅក្នុងគណនីធនាគារពា-ណិជ្ជកម្ម ស្របពេលជាមួយគ្នានេះធនាគារត្រូវបញ្ចូលចំនួនប្រាក់កម្ចីពីធនាគារកណ្តាលទៅក្នុងគណនីរបស់ខ្លួន។

ប៉ុន្តែ តើអ្នកណាផ្តល់ហិរញ្ញប្បទានឱ្យដល់ធនាគារកណ្តាល? គ្មានទេ!! ធនាគារកណ្តាលអាចបង្កើតរូបិយវត្ថុបានច្រើនតាមដែលខ្លួនចង់បានដោយបញ្ចូលទៅក្នុងគណនេយ្យសាមញ្ញ ហើយវាគ្មានជំពាក់បំណុលអ្នកណាម្នាក់ឡើយ។ នេះគឺជាឥទ្ធិពលនៃប្រព័ន្ធរូបិយវត្ថុ។ នេះគឺជាប្រភពដើមនៃការបង្កើតរូបិយវត្ថុ។ ក្រោយមកទៀតវាអាចផ្តល់ប្រាក់កម្ចីនេះដល់ធនាគារពាណិជ្ជកម្ម ឬទិញវិក្កយបត្រតេ-នាគារ (treasury bills) ។ គោលបំណងរបស់វា គឺបញ្ចូលរូបិយវត្ថុទៅក្នុងសេដ្ឋកិច្ចពិត ដើម្បីផ្តល់នូវហិរញ្ញប្បទានដល់ការអភិវឌ្ឍន៍។ បញ្ហានេះ គឺថាធនាគារពាណិជ្ជមិនចាំបាច់បញ្ចូលប្រាក់នេះទៅក្នុងសេដ្ឋកិច្ចពិតទេ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយយើងថា ការតបន្តឹងច្បាប់ធនាគារដើម្បីទទួលបានឥណទាន ប៉ុន្តែពួកគេមានសាច់ប្រាក់ងាយស្រួលលើស (excess liquidity) ពីធនាគារកណ្តាល។

នេះគឺជាភាពចម្លែកនៃប្រព័ន្ធរូបិយវត្ថុ។ ធនាគារកណ្តាលផ្តល់ប្រាក់កម្ចីដល់ធនាគារពាណិជ្ជកម្មដោយមិនដឹងថាពួកគេនឹងធ្វើអ្វីជាមួយរូបិយវត្ថុ។ ជាលទ្ធផល រូបិយវត្ថុនេះបញ្ចប់លើទីផ្សារហិរញ្ញវត្ថុ។ ហើយមិនមែននៅក្នុងសេដ្ឋកិច្ចពិតទេ!

ទោះយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ដែលបានផ្តល់ឱ្យធនាគារមិនមានកំណត់ទេ។ ជារៀងរាល់សប្តាហ៍ធនាគារកណ្តាល កំណត់ចំនួនទឹកប្រាក់ដែលខ្លួនបានត្រៀមផ្តល់ជូនធនាគាររក្សាការគ្រប់គ្រងទ្រឹស្តីលើការបង្កើតរូបិយវត្ថុ។ ចំនួននេះប្រែប្រួលទៅតាមគោលបំណងរបស់ធនាគារកណ្តាល ដើម្បីប្រយុទ្ធប្រឆាំងបរិត្តផរណាជំរុញកំណើន។ល។ (ធនាគារផ្តល់អត្រាការប្រាក់ខ្ពស់ដល់ធនាគារកណ្តាលត្រូវបានគេវិភាជរូបិយវត្ថុជាមួយនឹងអត្រាទាប នាពេលបច្ចុប្បន្នរូបិយវត្ថុនេះត្រូវបានផ្តល់ឱ្យធនាគារស្ទើរតែមិនគិតថ្លៃសេវា។

ជាមួយនឹងប្រាក់ឥតគិតថ្លៃនេះ ធនាគារទាំងនេះ (ឬក្នុងតម្លៃទាបបំផុត) ធនាគារទាំងនេះ អាចផ្តល់ប្រាក់កម្ចីប្រសិនបើពួកគេចង់បាន។ ប្រសិនបើប្រាក់កម្ចីថ្មី ត្រូវបានផ្តល់ប្រាក់ដែលបានបង្កើតកើនឡើងទ្វេដង។ ការបង្កើតរូបិយវត្ថុដោយធនាគារកណ្តាល និងបង្កើតរូបិយវត្ថុដោយធនាគារពាណិជ្ជកម្មជាមួយនឹងផលប៉ះពាល់នៃមេគុណឥណទាន។ សម្រាប់ធនាគារទាំងនេះ គឺមានវាសនាល្អសម្រាប់ប្រាក់កម្ចីដែលបានមកពីអតិថិជនរបស់ខ្លួន ឬពីធនាគារកណ្តាល។ ប្រាក់នេះមិនមែនជារបស់ពួកគេទេ ប៉ុន្តែធនាគារអាចទទួលបានប្រាក់ចំណេញយ៉ាងសំខាន់ពីវា ។ អត្រាការប្រាក់លើប្រាក់កម្ចី មានហានិភ័យតែមួយគត់ គឺប្រាក់កម្ចីនឹងមិនត្រូវបានសងវិញ។ ប៉ុន្តែប្រសិនបើនេះជាករណីធនាគារ អាចរឹបអូសទ្រព្យ សម្បត្តិដែលទាក់ទងនឹងប្រាក់កម្ចីធនាគារ។ ជាឧទាហរណ៍ ប្រសិនបើអ្នកមិនអាចសងបំណុលលើបំណុលទិញផ្ទះរបស់អ្នកទេ ធនាគារនឹងរឹបអូសផ្ទះរបស់អ្នក ហើយលក់វាដើម្បីសងប្រាក់កម្ចីធនាគារ។ វាជាការងារដ៏អស្ចារ្យមួយក្នុងនាមជាធនាគារិក។ នោះពួកគេឈ្នះគ្រប់ពេល។

៦.១.៥-គុណប្រាក់បញ្ញើធនាគារ (DEPOSIT MULTIPLIER)

យើងបានឃើញថា ធនាគារមានលក្ខណៈពិសេសពីរ គឺទិដ្ឋភាពដើមទុនដំបូងរបស់ធនាគារមានកម្រិតទាប និងធនាគារអាចបង្វិលបំណុលរបស់ខ្លួនបានឆាប់រហ័សទៅតាមតម្រូវការរបស់អតិថិជន។

លក្ខណៈពិសេសទាំងពីរនេះ បានជំរុញឱ្យធនាគារមានលទ្ធភាពគ្រប់គ្រងលើសាធនភាព សន្ទនីយភាព និងប្រាក់ចំណេញ។ ដើម្បីទប់ស្កាត់មិនឱ្យក្សីយធនធនាគារ និងមិនធ្វើឱ្យទ្រព្យសកម្មថយចុះនោះទេ ដែលគេហៅថា "សាធនភាព"។ ចំណែកឯទ្រព្យសកម្ម គឺលទ្ធភាពដែលធនាគារពាណិជ្ជសម្រាប់ទូទាត់សងទៅឱ្អកដាក់ប្រាក់បញ្ញើតែប៉ុណ្ណោះ។ *តើធនាគារបង្កើតរូបិយវត្ថុដូចម្តេច?*

ធនាគារមានសិទ្ធិបង្កើតរូបិយវត្ថុ ឬទ្រព្យសន្ទនីយភាព និងទុនបម្រុងសម្រាប់ជាមធ្យោបាយក្នុងការចំណាយរបស់ខ្លួនដោយសារលទ្ធភាពនេះ ធនាគារមានតួនាទីតែមួយគត់ខាងផ្នែកហិរញ្ញវត្ថុសម្រាប់សេដ្ឋកិច្ច និងរាប់បញ្ចូលជាស្ថាប័នដែលមានឥទ្ធិពលបំផុតលើវត្តមានបរិមាណរូបិយវត្ថុ។ ធនាគារអាចមានលទ្ធភាពបង្កើតបាន គឺប្រាក់បញ្ញើ និងផ្តល់ប្រាក់កម្ចី ប៉ុន្តែអ្វីៗទាំងអស់នេះត្រូវបានកំណត់ដោយបរិមាណប្រាក់តម្កល់រក្សាទុក។ អត្រាសាច់ប្រាក់តម្រូវឱ្យតម្កល់រក្សាទុក គឺអត្រាតម្កល់រក្សាទុកជាសាច់ប្រាក់បញ្ញើដែលត្រូវបញ្ចូលក្នុងធនាគារ និងការកាន់កាប់បរិមាណរូបិយវត្ថុ។

យើងអាចរកឃើញសាច់ប្រាក់ប៉ុន្មានត្រូវបានតម្កល់រក្សាទុក គឺអាស្រ័យលើតួគុណប្រាក់បញ្ញើ។ អត្រាតម្រូវការប្រាក់តម្កល់រក្សាទុក ចែកចេញជាពីរប្រភេទ៖

ក- លក្ខន្តិក:តម្រូវការសាច់ប្រាក់បញ្ញើ គឺជាតម្រូវការប្រាក់តម្កល់ចាំបាច់ក្នុងធនាគារពីទុនដើមអប្បបរមា។

ខ- តម្រូវការតម្កល់ប្រាក់ផ្តាច់ (Non–Calable Deposit) គឺជាតម្រូវការសាច់ប្រាក់សម្រាប់បម្រុងទុកនៅធនាគារកណ្តាល ដោយមិនមានសិទ្ធិដកមកវិញទេ ទោះបីជាធនាគារដើម ប្រកាសរំលាយស្ថាប័នរបស់ខ្លួនក៏ដោយ។ ជាទូទៅ វាមានកម្រិត ១ភាគរយ តែប៉ុណ្ណោះ ហើយគេប្រើមូលនិធិទាំងនេះសម្រាប់ទូទាត់ហានីភ័យ និងជំនួយសប្បុរសធម៌ពីធនាគារ។

តួគុណបញ្ញើ (Deposit Multiplier) គឺជាផលគុណដែលបានបង្កើតរូបិយវត្ថុតម្កល់រក្សាទុកក្នុងធនាគារកណ្តាល ដើម្បីគណនាកំណើនប្រាក់បញ្ញើនៅក្នុងធនាគារ។

រូបមន្តរបស់វាគឺ៖

តួគុណប្រាក់បញ្ញើ (Deposit multiplier) = 1/(1-L)

ឧទាហរណ៍៖ អត្រាតម្រូវឱ្យតម្កល់រូបិយវត្ថុគឺ ២៥ភាគរយ ហេតុនេះតួគុណបញ្ញើស្មើនឹង ៤។ វាមានន័យថា ប្រសិនបើកំណើន ១លានដុល្លារ តម្កល់រក្សាទុកក្នុងធនាគារបានបង្កើតឱ្យមានកំណើនបញ្ញើ ៤លាន។ ដូចនេះ ធនាគារមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ទទួលប្រាក់បញ្ញើដោយលៃរក្សាទុក ២៥ភាគរយ សម្រាប់តម្កល់រក្សាទុក ៧៥ភាគរយ សម្រាប់ផ្តល់កម្ចី។

បរិមាណកម្ចីបានបង្កើតបញ្ញើថ្មីសម្រាប់ធនាគារដទៃដែលទទួលបានប្រាក់កម្ចី និងចាប់ផ្តើមកំណត់ប្រាក់តំកល់ និងផ្តល់កម្ចីបន្តទៀតតាមរយៈការកំណត់តួគុណបញ្ញើរបស់គេ។

ការបង្កើតសាច់ប្រាក់តាមរយៈកម្ចីជាមួយនឹងធនាគារជាច្រើន បានបង្ហាញដំណើរការមួយដែលពហុធនាគារ ឬធនាគារចម្រុះបង្កើតបរិមាណរូបិយវត្ថុរបស់ខ្លួនតាមរយៈសាច់ប្រាក់កម្ចី និងតម្កល់ទុក។ ដើម្បីបង្ហាញឱ្យឃើញច្បាស់នៅក្នុងដំណើរការរួម យើងសូមពិនិត្យដោយប្រុងប្រយ័ត្នទៅលើដំណើរការផ្តល់កម្ចី។ នៅក្នុងមួយដំណាក់កាលកម្ចី គឺមាន៧៥ភាគរយ ពីបំណុលរបស់ធនាគារ និងបញ្ញើចំនួន ៧៥ ភាគរយពីបញ្ញើមុន។

ការបង្កើតសាច់ប្រាក់តាមរយៈកម្ចីជាមួយនឹងធនាគារជាច្រើន បានបង្ហាញដំណើរការមួយដែលពហុធនាគារ ឬធនាគារចម្រុះ បង្កើតបរិមាណរូបិយវត្ថុរបស់ខ្លួន តាមរយៈសាច់ប្រាក់កម្ចី និងតម្កល់ទុក។ ដើម្បីបង្ហាញឲ្យឃើញកាន់តែច្បាស់ ក្នុងដំណើរការរួមយើងសូមពិនិត្យដោយប្រុងប្រយ័ត្នលើដំណើរការផ្តល់កម្ចី។ នៅក្នុងមួយដំណាក់កាលកំចី គឺមាន៧៥ភាគរយ ពីបំណុលរបស់ធនាគារ និងបញ្ញើចំនួន ៧៥ភាគរយពីបញ្ញើមុន។ យើងហៅសមាមាត្រនេះថា L និងលទ្ធផលពេញលេញរបស់វាគឺ ៖

$S = 1 + L^2 + L^3 + \ldots.. L^n$

គុណនឹង

L៖ $LS = L + L^2 + L^3 + \ldots.. L^{n+1}$

ដកសមីការទាំង២ចេញ, យើងនឹងទទួលបាន៖

$S (1 - L) = 1$

$S = 1 / 1 - L$

តួគុណបញ្ញើអាចខុសពីការគណនា របស់យើងខាងលើដោយមូលហេតុ បីយ៉ាង ៖

- អត្រាតម្រូវការប្រាក់តំកល់កាន់តែតូច កាលណារដ្ឋាភិបាលត្រូវការលុយសម្រាប់ចរាចរណ៍។
- វាមិនពិតប្រាកដទេថារាល់កម្ចីដែលធនាគារផ្តល់នឹងចូលមកក្នុងតម្កល់វិញនៅពេលសងរួច។

ដូនកាលធនាគារសម្រេចចិត្តជ្រើសរើសមិនឲ្យចេញប្រាក់តម្កល់តេនាគារ និងធនាគារកណ្តាល។

មុនពេលបន្តសិក្សាឲ្យបានលំអិតថែមទៀត អំពីថាតើធនាគារអាចគ្រប់គ្រងទ្រព្យ និងបំណុលរបស់ខ្លួនយ៉ាងដូចម្តេច ដើម្បីធ្វើឲ្យទទួលបានប្រាក់ចំណេញខ្ពស់បំផុត អ្នកគួរតែយល់អំពីប្រតិបត្តិការជាមូលដ្ឋានរបស់ធនាគារ។ នៅក្នុងលក្ខខណ្ឌទូទៅធនាគារបង្កើតប្រាក់ចំណេញ តាមរយៈការលក់នូវបំណុលដែលមានលក្ខណៈពិសេសមួយស៊េរី (ជាពិសេស គឺការបន្សំចូលគ្នានៃសន្ទនីយភាព ហានីភ័យ និងចំណូលការប្រាក់) និងប្រើប្រាស់វាដើម្បីទិញទ្រព្យបន្តដែលមានលក្ខណៈពិសេសមួយស៊េរី។ ដើម្បីធ្វើការវិភាគលើប្រតិបត្តិការរបស់ធនាគារដែលអាចំកំបាំងថែមទៀតយើងប្រើឧបករណ៍ដែលត្រូវគេហៅឈ្មោះថាធីអាខោន (T-Account)។

៦.២-ការផ្គត់ផ្គង់រូបិយវត្ថុ(MONEY SUPPLY)[៧៨]

[៧៨] Anna J. Schwartz is an economist at the National Bureau of Economic Research in New York. She is a distinguished fellow of the American Economic Association.

៦.២.១-ការផ្គត់ផ្គង់រូបិយវត្ថុ និងស្តុករូបិយវត្ថុ(MONEY SUPPLY & MONEY STOCK)

រូបិយវត្ថុ គឺជាទំនិញដែលដូចគ្នានឹងទំនិញផ្សេងទៀតដែរដែលមានតម្រូវការ និងការផ្គត់ផ្គង់ដោយភ្នាក់ងារសេដ្ឋកិច្ច។ កត្តាកំណត់ខ្លះទៀត គឺតម្រូវការរូបិយវត្ថុ (money demand) និងការផ្គត់ផ្គង់រូបិយវត្ថុ (money supply) ដែលជាកត្តាកំណត់សំខាន់បំផុតនៃតម្រូវការរូបិយវត្ថុ គឺជាប្រាក់ចំណូ-លជាតិ កម្រិតថ្លៃ និងអត្រាការប្រាក់ ខណៈពេលដែលការផ្គត់ផ្គង់រូបិយវត្ថុ គឺជាតំរិយាបទរបស់ធនាគារកណ្តាលនៃប្រទេសនីមួយៗ ដែលត្រូវបានផ្តល់អំណាចឱ្យគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ និងដឹកនាំការផ្លាស់ប្តូរវា។ បរិមាណរូបិយវត្ថុត្រង់ចំនុចលំនឹងសមតាសម្រាប់ទីផ្សាររូបិយវត្ថុ គឺជាទីផ្សារស្តុករូបិយវត្ថុ (money stock) ហើយផ្ទុយមកវិញការផ្គត់ផ្គង់រូបិយវត្ថុដែលមានមុខងាររូបិយវត្ថុបញ្ជាក់អំពីបរិមាណការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតអត្រាការប្រាក់ និងប្រាក់ចំណូលផ្សេងៗទៀត។ លំនឹងសមតារូបិយវត្ថុ គឺជាបរិមាណរូបិយវត្ថុដែលបរិមាណតម្រូវការរូបិយវត្ថុ និងបរិមាណការផ្គត់ផ្គង់រូបិយវត្ថុស្មើគ្នា។ សម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ និងស្តុករូបិយវត្ថុ គឺមានភាពដូចគ្នាបេះបិទក្នុងករណីដែលការផ្គត់ផ្គង់រូបិយវត្ថុ ត្រូវបានរឹតបន្តឹងយ៉ាងខ្លាំងតាមរយៈគោលការណ៍របស់ធនាគារកណ្តាល។ ករណីបែបនេះ វាគឺឯករាជ្យលើអត្រាការប្រាក់ និងអថេរសេដ្ឋកិច្ចផ្សេងទៀត ទោះបីជាវាអាចមានឥទ្ធិពលរបស់វាក៏ដោយ។ មានហេតុផលជាច្រើនលើទ្រឹស្តីរបស់រូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ដែលបានបង្កើតពាក្យថា "ស្តុករូបិយវត្ថុ" និង "ការផ្គត់ផ្គង់រូបិយវត្ថុ" ត្រូវបានគេប្រើជាសទិសន័យទាំង២នេះ។ ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ស្ថិតក្រោមអាជ្ញាធររូបិយវត្ថុ ឬធនាគារកណ្តាល។ គោលនយោបាយរបស់ធនាគារកណ្តាល មានទាក់ទងនឹងការផ្លាស់ប្តូរការផ្គត់ផ្គង់រូបិយវត្ថុដែលត្រូវបានគេស្គាល់ថាជា "គោលនយោបាយរូបិយវត្ថុ"។

៦.២.២-តើអ្វីជាការផ្គត់ផ្គង់រូបិយវត្ថុ(WHAT IS THE MONEY SUPPLY)?

សហរដ្ឋអាមេរិកចំពោះពាក្យថាការផ្គត់ផ្គង់រូបិយវត្ថុ រួមមានរូបិយប័ណ្ណ (currency) ដែលមានជាក្រដាសប្រាក់និងកាស (N&C) បានចេញផ្សាយដោយធនាគារកណ្តាល និងរតនាគារអាម៉េរិក និងមានប្រាក់បញ្ញើច្រើនប្រភេទទៀតដែលកាន់កាប់ដោយសាធារណជននៅធនាគារពាណិជ្ជកម្ម និងស្ថាប័នតម្កល់ប្រាក់ដទៃផ្សេងៗទៀត ដូចជាគ្រឹះស្ថានទទួលប្រាក់បញ្ញើ និងសហគមឥណទានជាដើម ។

ឧទាហរណ៍៖ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ការផ្គត់ផ្គង់រូបិយវត្ថុរបស់ FED ត្រូវបានវាស់វែងដោយផលបូករូបិយប័ណ្ណ និងគណនីប្រាក់បញ្ញើមានចំនួន ១,៣៣៣ពាន់លានដុល្លារអាម៉េរិក។ រួមមានទាំងប្រភេទប្រាក់បញ្ញើសន្សំមួយចំនួនក្នុងការផ្គត់ផ្គង់រូបិយវត្ថុចំនួន ៦,២៧៥ពាន់លានដុល្លារអាម៉េរិក។ វិធានការវាស់វែងកាន់តែធំទូលំទូលាយលើការផ្គត់ផ្គង់រូបិយវត្ថុចំនួន ៩,២៧៥ពាន់លានដុល្លារអាម៉េរិក។ វិធានការទាំងនេះ ត្រូវគ្នានឹងនិយមន័យទាំងបីយ៉ាងនៃរូបិយវត្ថុដែលធនាគារកណ្តាលបានកំណត់ប្រើ មានដូចជា៖

- M1 ជាវិធានតូចចង្អៀតនៃមុខងាររូបិយវត្ថុជាមធ្យោបាយដោះដូរ។
- M2 ជាវិធានទូលំទូលាយដែលឆ្លុះបញ្ចាំងពីមុខងាររូបិយវត្ថុជាឃ្លាំងនៃតម្លៃ។

- M3 នៅតែជាវិធានទូលំទូលាយដែលគ្របដណ្តប់លើប្រភេទដែលចាត់ទុកជាការជំនួសរូបិយ-វត្ថុយ៉ាងជិតស្និទ្ធ។ និយមន័យនៃរូបិយវត្ថុ គឺមានភាពខុសៗគ្នា។

អស់រយៈកាលជាច្រើនសតវត្សរ៍មកហើយ សម្រាប់រូបវន្តជាទំនិញដែលភាគច្រើនជាកាសប្រាក់ ឬកាសមាស ត្រូវបានប្រើជារូបិយវត្ថុ។ ក្រោយមកទៀត រូបិយវត្ថុដែលជាក្រដាសនិងកាស (N&C) ជាប្រាក់បញ្ញើត្រូវបានគេណែនាំឱ្យប្តូរវិញ។ ការបោះបង់ចោលរូបិយវត្ថុទៅជារូបិយវត្ថុទំនិញ បានចាប់ផ្តើមពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧១ នៅពេលដែលប្រធានាធិបតី Richard M. Nixon ឈប់បន្តប្តូរក្រដាសប្រាក់ដុល្លារជានឹងមាស ៣៥ ដុល្លារក្នុងមួយអោន។ រូបិយវត្ថុ គឺជាក្រដាសប្រាក់ជាតិនៃអាជ្ញាធររូបិយវត្ថុឬធនាគារកណ្តាល មានអំណាចក្នុងការបោះផ្សាយដោយគ្មានឧបសគ្គផ្នែកផ្លូវច្បាប់ឡើយ ។

៦.២.៣-ហេតុអ្វីការផ្គត់ផ្គង់ប្រាក់មានសារៈសំខាន់ (WHY IS THE MONEY SUPPLY IMPORTANT)?

ដោយសាររូបិយវត្ថុ ត្រូវបានប្រើក្នុងប្រតិបត្តិការសេដ្ឋកិច្ចស្ទើរតែទាំងស្រុង វាមានឥទ្ធិពលខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ច។ ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ ធ្វើឱ្យបញ្ចុះអត្រាការប្រាក់ដែលជួយជំរុញការធ្វើវិនិយោគទុន និងតាមរយៈដាក់ប្រាក់បញ្ញើកាន់តែច្រើនដែលមានក្នុងដៃរបស់អ្នកប្រើប្រាស់ធ្វើឱ្យពួកគេមានអារម្មណ៍ថាពួកគេមានទ្រព្យសម្បត្តិ ដូច្នេះបានជំរុញឱ្យការចំណាយកើនឡើង។ ក្រុមហ៊ុនអាជីវកម្ម ឆ្លើយតបនឹងការកើនឡើងនៃការលក់ដោយការបញ្ជាទិញវត្ថុធាតុដើមកាន់តែច្រើន និងបង្កើនផលិតកម្ម។ ការរីករាលដាលនៃសកម្មភាពអាជីវកម្ម បង្កើនតម្រូវការកម្លាំងពលកម្ម (ទីផ្សារពលកម្ម) និងបង្កើនតម្រូវការទំនិញមូលធន។ នៅក្នុងសេដ្ឋកិច្ចមានការរីកចម្រើនតម្លៃភាគហ៊ុនរបស់ទីផ្សារភាគហ៊ុន (stock market) ហើយក្រុមហ៊ុននានាបានចេញផ្សាយភាគហ៊ុន និងប័ណ្ណបំណុល។ ប្រសិនបើការផ្គត់ផ្គង់ប្រាក់នៅតែបន្តពង្រីកតម្លៃ ការចាប់ផ្តើមកើនឡើងជាពិសេស ប្រសិនបើកំណើនទិន្នផលសរុបឈានដល់កម្រិតសមត្ថភាព។ ខណៈពេលដែលសាធារណជនចាប់ផ្តើមរំពឹងថានឹងទទួលបានប្រាក់កម្ចីពីអ្នកផ្តល់ប្រាក់កម្ចីទទួចឱ្យមានអត្រាការប្រាក់ទាប ដើម្បីទូទាត់ការធ្លាក់ចុះនៃអំណាចទិញដែលរំពឹងទុកក្នុងរយៈពេលនៃប្រាក់កម្ចីរបស់ពួកគេ។ ផលប៉ះពាល់ផ្ទុយគ្នាកើតឡើងនៅពេលដែលការផ្គត់ផ្គង់ប្រាក់ធ្លាក់ចុះ ឬនៅពេលដែលអត្រាកំណើនរបស់វាធ្លាក់ចុះ។ សកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ ព្រមទាំងការចុះខ្សោយអតិផរណា (បន្ថយអតិផរណា) ឬបរិត្តផរណា (ថ្លៃធ្លាក់ចុះ)។

៦.២.៤-តើអ្វីកំណត់ការផ្គត់ផ្គង់រូបិយវត្ថុ? (WHAT DETERMINES THE MONEY SUPPLY)?

គោលនយោបាយរបស់ FED គឺជាកត្តាសំខាន់ៗសម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ។ ធនាគារកណ្តាលអាម៉េរិក មានឥទ្ធិពលដល់ការផ្គត់ផ្គង់រូបិយវត្ថុភាគច្រើន គឺពាក់ព័ន្ធនឹងប្រាក់បញ្ញើធនាគារ។ នេះដារបៀបដែលវាដំណើរការគោលនយោបាយរបស់វា។ FED តម្រូវឱ្យស្ថាប័នតម្កល់ប្រាក់ (មានធនាគារពាណិជ្ជកម្ម និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត) ត្រូវរក្សាទុកទុនបម្រុងនៃបំណុលប្រាក់បញ្ញើដែលបាន

កំណត់។ ស្ថាប័នប្រាក់បញ្ញើ ត្រូវតែកាន់កាប់ប្រាក់បម្រុងទាំងនេះជាសាច់ប្រាក់ក្នុងគណនី ឬម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) និងប្រាក់បញ្ញើរបស់ FED។ ក្នុងការត្រួតពិនិត្យរបស់ FED ផ្តល់ប្រាក់កម្ចីដល់ស្ថាប័នតម្កល់ប្រាក់ និងផ្លាស់ប្តូរអត្រាបញ្ចុះតម្លៃប្រាក់បម្រុងទុករបស់ធនាគារសហព័ន្ធលើប្រាក់កម្ចីទាំងនោះ និងប្រតិបត្តិការទីផ្សារបើកចំហ (OMO)។ FED បានប្រើប្រាស់ប្រតិបត្តិការទីផ្សារបើកចំហ (OMO) ដើម្បីបង្កើនទុនបម្រុង ឬបន្ថយទុនបម្រុង។ ការបង្កើនទុនបម្រុងរបស់ FED ដោយការទិញមូលប័ត្រតេនាគារអាមេរិក (U.S. Treasury Securities) ដែលចាត់ជាមូលប្បទានប័ត្រដែលកំណត់ដោយខ្លួនឯង។ អ្នកលក់មូលបត្របំណុល បានដាក់ប្រាក់ជាមូលប្បទានប័ត្រទៅក្នុងធនាគារដែលបង្កើនប្រាក់បញ្ញើរបស់អ្នកលក់។ ជាលទ្ធផល ធនាគារដាក់ប្រាក់បញ្ញើជាមូលប្បទានប័ត្រនៅ FED របស់ខ្លួន ដូច្នេះបង្កើនបានទុនបម្រុងរបស់ខ្លួន។ ផ្ទុយគ្នាមកវិញ ការកើតឡើងជាបន្តបន្ទាប់នៅពេលដែល FED លក់ចេញមូលប័ត្រតេនាគារ៖ ប្រាក់បញ្ញើរបស់អ្នកទិញបានធ្លាក់ចុះ ហើយលទ្ធផលប្រាក់បម្រុងរបស់ធនាគារក៏ធ្លាក់ចុះ។ ប្រសិនបើ FED បង្កើនប្រាក់បម្រុងរបស់ធនាគារតែមួយ អាចធ្វើឱ្យប្រាក់កម្ចីដែលជាប្រាក់បម្រុងលើសកំណត់បង្កើតបរិមាណប្រាក់បញ្ញើស្មើគ្នា។ ទោះយ៉ាងណា ប្រព័ន្ធធនាគារអាចបង្កើនការពង្រីកប្រាក់បញ្ញើបានច្រើន។ ដោយសារតែធនាគារនីមួយៗផ្តល់ប្រាក់កម្ចី និងបង្កើតប្រាក់បញ្ញើធនាគារ ហើយវាបាត់បង់ប្រាក់បម្រុងនៅធនាគារផ្សេងទៀត ដែលប្រើវាដើម្បីបង្កើនប្រាក់កម្ចី ហើយបង្កើតប្រាក់បញ្ញើថ្មីរហូតដល់ប្រាក់បម្រុងលើសត្រូវបានប្រើ។

នៅក្នុងឆ្នាំ ២០០៤ ធនាគារដែលមានទឹកប្រាក់បញ្ញើសរុប ៧លានដុល្លារ ត្រូវបានរួចផុតពីតម្រូវការប្រាក់បម្រុងកាតព្វកិច្ច។ អ្នកដែលមានទឹកប្រាក់លើសពី ៧លានដុល្លារ ប៉ុន្តែតិចជាង ៤៧,៦ លានដុល្លារ ជាប្រាក់បញ្ញើមូលប្បទានដែលតម្រូវឱ្យរក្សាទុនបម្រុង ៣ភាគរយ ក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច។ រីឯអ្នកដែលមានគណនីមូលប្បទានបត្រដែលមានចំនួន ៤៧,៦លានដុល្លារ ឬច្រើនជាងនេះ គឺតម្រូវឱ្យរក្សាបម្រុង ១០ភាគរយ មិនតម្រូវឱ្យមានការបម្រុងទុកកាតព្វកិច្ច ផ្ទុយនឹងប្រាក់បញ្ញើមានកាលកំណត់នោះទេ។ ទោះបីជាមិនមានប្រាក់បម្រុងកាតព្វកិច្ចស្របច្បាប់សម្រាប់ធនាគារក៏ដោយ ក៏ពួកគេនៅតែបន្តរក្សាសមតុល្យទូទាត់ដែលត្រូវការទុនបម្រុងជាមួយនឹងធនាគារសហព័ន្ធ ដែលមានសមត្ថភាពក្នុងការគ្រប់គ្រងបរិមាណប្រាក់បញ្ញើ មិនត្រូវបានចុះខ្សោយឡើយ។ ធនាគារបន្តរក្សាប្រាក់បម្រុងដើម្បីឱ្យពួកគេអាចទូទាត់បំណុលដែលកើតឡើងពីប្រតិបត្តិការជាមួយធនាគារផ្សេងទៀត ដើម្បីទទួលបានរូបិយប័ណ្ណ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកដាក់ប្រាក់បញ្ញើ និងចៀសវាងឱនភាពដែលជាលទ្ធផលអតុល្យភាពក្នុងការទូទាត់។ សមាសធាតុរូបិយប័ណ្ណនៃការផ្គត់ផ្គង់រូបិយវត្ថុដោយប្រើនិយមន័យប្រភេទរូបិយវត្ថុ M2 គឺតូចជាងសមាសធាតុប្រាក់បញ្ញើ។ រូបិយប័ណ្ណរួមបញ្ចូលទាំងក្រដាសប្រាក់និងកាសរបស់ធនាគារសហព័ន្ធផងដែរ។ ក្រុមប្រឹក្សាភិបាល FED បានដាក់ចេញបទបញ្ជាជាមួយនឹងការិយាល័យចារកម្ម និងគ្រឹះស្ថានបោះពុម្ពផ្សាយក្រដាសប្រាក់និងកាសរបស់ FED ទាំងអស់។ ហើយបន្ទាប់មក ការបែងចែកក្រដាសប្រាក់ទៅឱ្យធនាគារបម្រុងនីមួយៗទាំងនោះ។ បច្ចុប្បន្ននេះ ក្រដាសប្រាក់និងកាស មិនត្រូវបានសម្គាល់ដោយសារគ្រារបស់តំបន់នីមួយៗទៀតទេ។ ជាទូទៅ FED បានកាប់កាប់ក្រដាសប្រាក់និងកាស នៅក្នុងគណនីរបស់ពួកគេរហូតដល់មានការលក់ទៅឱ្យធនាគារ

ពាណិជ្ជកម្មដែលបង់ថ្លៃដោយក្រុមហ៊ុនដឹកជញ្ជូនឯកជន ដើម្បីយកសាច់ប្រាក់ពីធនាគារបម្រុងក្នុងតំបន់របស់ពួកគេ។ ធនាគារដកប្រាក់ពីគណនីបម្រុងរបស់ធនាគារពាណិជ្ជជាការទូទាត់ សម្រាប់តម្រូវការក្រដាសប្រាក់ និងកាសរបស់អតិថិជន។ នៅពេលដែលតម្រូវការសម្រាប់ក្រដាសប្រាក់ធ្លាក់ចុះ ធនាគារបម្រុងទទួលយកលំហូរត្រឡប់មកវិញក្រដាសប្រាក់ពីធនាគារពាណិជ្ជកម្ម និងផ្តល់ប្រាក់កម្ចីបម្រុងរបស់ពួកគេ។

ក្រុមហ៊ុនផលិតក្រដាសប្រាក់ និងកាសរបស់សហរដ្ឋអាម៉េរិក សម្រាប់ការចែកចាយដោយ FED ។ ក្រុមប្រឹក្សាភិបាលជាក់បញ្ជាទិញវត្ថុធាតុដើមរ៉ែឱ្យបានសមរម្យ។ FRS រក្សាទុកកាសរបស់ខ្លួនដែលផ្តល់សិទ្ធិដល់ក្រុមហ៊ុនដឹកជញ្ជូន និងប្រតិបត្តិការ។ ធនាគារពាណិជ្ជកម្ម ទិញកាសតាមតម្លៃពីធនាគារបម្រុ-ងដែលទទួលការទូទាត់ដោយការដកប្រាក់គណនីបម្រុងរបស់ធនាគារពាណិជ្ជកម្ម។ ធនាគារពាណិជ្ជបង់ថ្លៃចំណាយទាំងស្រុងក្នុងការដឹកជញ្ជូនក្រដាសប្រាក់ និងកាស។ FRS មានចំណែកលំហូររូបិយប័-ណ្ណពីធនាគារ បានកាត់បន្ថយប្រាក់បម្រុងរបស់ខ្លួន ហើយលុះត្រាធនាគារសហព័ន្ធផ្តល់នូវបរិមាណទឹកប្រាក់បន្ថែមនៃរូបិយប័ណ្ណបម្រុងគ្រប់គ្រាន់ និងប្រាក់បម្រុងទុក សម្រាប់ការដាក់ប្រាក់បញ្ញើច្រើនធ្វើឱ្យបរិមាណប្រាក់មានការថយចុះ។ រូបិយប័ណ្ណ និងប្រាក់បម្រុងធនាគារ បានបូកបញ្ចូលគ្នាស្មើគ្នានឹងមូលដ្ឋានរូបិយវត្ថុដែលពេលខ្លះត្រូវបានគេស្គាល់ថាជាប្រាក់ដែលមានថាមពលខ្ពស់។ FED មានអំណាចគ្រប់ គ្រងបញ្ហានៃសមាសធាតុទាំងពីរ តាមរយៈការកែសម្រួលសមតុល្យប្រាក់បម្រុងរបស់ធនាគារក្នុងរយៈពេលជាច្រើនត្រីមាស វាអាចសម្រេចបានអត្រាកំណើនប្រាក់បញ្ញើ និងការផ្គត់ផ្គង់រូបិយវត្ថុដែលចង់ បាន។ នៅពេលដែលសាធារណៈ និងធនាគារផ្លាស់ប្តូរសមាមាត្ររូបិយប័ណ្ណ និងប្រាក់បម្រុងរបស់ខ្លួនទៅនឹងប្រាក់បញ្ញើធនាគារ។ FED អាចទូទាត់ផលប៉ះពាល់លើការផ្គត់ផ្គង់រូបិយវត្ថុដោយការផ្លាស់ប្តូរប្រាក់បម្រុង និង/ឬរូបិយប័ណ្ណ។ ប្រសិនបើ ធនាគារសហព័ន្ធកំណត់ទំហំនៃការផ្គត់ផ្គង់រូបិយវត្ថុ *ថាតើអ្វីដែលធ្វើឱ្យតម្លៃនាមករណ៍ដែលមានស្រាប់ស្មើនឹងចំនួនទឹកប្រាក់ដែលប្រជាជនចង់កាន់កាប់?* ការផ្លាស់ប្តូរអត្រាការប្រាក់ គឺមធ្យោបាយមួយដើម្បីធ្វើឱ្យមានការឆ្លើយឆ្លងកើតឡើង។ ការធ្លាក់ចុះអត្រាការប្រាក់បង្កើននូវបរិមាណរូបិយវត្ថុដែលមនុស្សចង់កាន់កាប់ ខណៈពេលដែលការកើនឡើងអត្រាការប្រាក់ថយចុះបរិមាណរូបិយវត្ថុ។ ការផ្លាស់ប្តូរថ្លៃ គឺជាវិធីមួយផ្សេងទៀតដើម្បីធ្វើឱ្យការផ្គត់ផ្គង់រូបិយវត្ថុស្មើនឹងបរិ-មាណទឹកប្រាក់ដែលមានតម្រូវការ។ នៅពេលមនុស្សកាន់ដុល្លារនាមករណ៍កាន់តែច្រើនជាងអ្វីដែលពួកគេចង់បាន ពួកគេចំណាយវាលឿនជាងមុនដែលជាហេតុបណ្តាលឱ្យថ្លៃរបស់វាកើនឡើង។ ការកើនឡើងថ្លៃទាំងនេះ កាត់បន្ថយអំណាចទិញរបស់រូបិយវត្ថុរហូតដល់បរិមាណដែលមនុស្សចង់បានស្មើនឹងបរិមាណដែលមាន។ ផ្ទុយទៅវិញ នៅពេលមនុស្សកាន់រូបិយវត្ថុតិចជាងអ្វីដែលពួកគេចង់បាន ពួកគេចំណាយយឺតៗបណ្តាលឱ្យថ្លៃធ្លាក់ចុះ។ ជាលទ្ធផល តម្លៃបច្ចុប្បន្ននៃរូបិយវត្ថុ ដែលមានស្រាប់ស្មើនឹងបរិមាណទឹកប្រាក់ដែលមនុស្សមានបំណងកាន់កាប់ប៉ុណ្ណោះ។

៦.៣-ការវាស់អតិផរណា (MEASUREMENT INFLATION)

៦.៣.១-អ្វីទៅជាអតិផរណា? (WHAT IS INFLATION?)

មិនមែនសុទ្ធតែកម្រិតថ្លៃកើតឡើង បង្កើតជាអតិផរណានោះទេ។ កម្រិតថ្លៃនៃទំនិញ និងសេវាណានោះ ត្រូវបានកំណត់ដោយវិធីផ្សេងៗ។ ក្នុងទីផ្សារប្រកួតប្រជែងការដេះដូរទិញទៅវិញទៅមកនៃអ្នកទិញ និងអ្នកលក់ជាច្រើន ដែលកំណត់បានកម្រិតថ្លៃ។ ក្នុងទីផ្សារប្រកួតប្រជែងមិនពេញលេញថ្លៃត្រូវបានកំណត់ដោយការសម្រេចចិត្តរបស់ផលិតករ។ ចំណែកឯក្នុងម៉ាក្រូសេដ្ឋកិច្ចថ្លៃផ្លាស់ប្តូរជាបន្តបន្ទាប់ ក្នុងខណៈពេលដែលទីផ្សារកែតម្រូវចំពោះការផ្លាស់ប្តូរលក្ខខណ្ឌទាំងឡាយ។ ជាការពិតណាស់ មិនមែនការកើនឡើងនៃថ្លៃបូកបញ្ចូលគ្នាជាអតិផរណាទេ ពីព្រោះការកើនកម្រិតថ្លៃនៃទំនិញណាមួយនោះវាអាច ឬមិនអាចជាចំណែកនៃអតិផរណា។ ដូច្នេះ *អតិផរណាជាអ្វី?*

អតិផរណា (inflation) គឺជាការកើននៃកម្រិតថ្លៃរួម (Overall price level) នៅអំឡុងពេលណាមួយ។ វាកើតឡើងពេលដែលថ្លៃជាច្រើនកើនព្រមគ្នា។ បរិត្តផរណា (deflation) គឺជាការធ្លាក់ចុះនៃកម្រិតថ្លៃរួម។ វាកើតឡើងពេលថ្លៃជាច្រើនធ្លាក់ចុះរួមគ្នា ឬព្រមគ្នា។ វិធីមួយដើម្បីវាស់ការប្រែប្រួលនៃកម្រិតថ្លៃរួម គឺគណនាសន្ទស្សន៍ថ្លៃ (Price Index)។

៦.៣.២-សន្ទស្សន៍ថ្លៃ(PRICE INDEX)

សន្ទស្សន៍ថ្លៃ គឺជាផលធៀបរវាងថ្លៃនៃសំណុំទំនិញមួយក្នុងដំណាក់កាលណាមួយនោះជាមួយថ្លៃនៃសំណុំទំនិញនោះ នៅដំណាក់កាលគោល (Basic period) គុណនឹង ១០០។ សន្ទស្សន៍បង្ហាញឱ្យយើងឃើញថា តើថ្លៃមធ្យមនៃសំណុំទំនិញផ្លាស់ប្តូរយ៉ាងណាខ្លះពីពេលមួយ? មានសន្ទស្សន៍ថ្លៃបីប្រភេទ ៖

- ផលិតផលក្នុងស្រុកសរុបបរិត្តផរណា (GDP Deflator)៖ ផលិតផលក្នុងស្រុកសរុបបរិ-ត្តផរណា គឺជាផលធៀបនៃផលិតផលសរុបក្នុងស្រុកមានតែនាម និងផលិតផលសរុបក្នុងស្រុកពិតនៅឆ្នាំណាមួយនោះ។
- សន្ទស្សន៍ថ្លៃប្រើប្រាស់ (Consumer price:CPI)៖ សន្ទស្សន៍ថ្លៃប្រើប្រាស់វាស់តម្លៃនៃការទិញទំនិញ និងសេវាក្នុងទីផ្សារមួយ។
- សន្ទស្សន៍ថ្លៃផលិតករ (Producer Price Index:PPI)
  សន្ទស្សន៍ថ្លៃផលិតករ គឺជាសន្ទស្សន៍ថ្លៃទីបី ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ក៏ដូចជា សន្ទស្សន៍ថ្លៃ (CPI) ដែរ។ សន្ទស្សន៍ថ្លៃផលិតករ (PPI) គឺជាខ្នាត់វាស់តម្លៃទំនិញ និងសេវាក្នុងទីផ្សារណាមួយ។ វាវាស់ថ្លៃដែលផលិតករទទួលបាន ចំពោះផលិតផលនៅគ្រប់ដំណាក់កាលក្នុងអភិក្រមផលិតកម្មមិនមែនត្រឹមតែទំនិញ និងសេវាចុងក្រោយទេ។

៤. បច្ច័យនៃអតិផរណា (Effects of Inflation)

៤ក. អតិផរណាផ្លាស់ប្តូរបែងចែកចំណូល (Inflation change distribute of income)

សំណួរសួរថាតើយើងទទួលបានចំណេញ ឬខាតក្នុងពេលមានអតិផរណា? តើចំណូលរបស់យើងកើនលឿនជាង ឬក៏យឺតជាងថ្លៃនៃទំនិញដែលយើងទិញ? ជាការពិតណាស់ ប្រសិនបើចំណូលរបស់យើងថេរហើយ ថ្លៃវាកើនឡើងនោះ លទ្ធភាពទិញទំនិញ និងសេវាកម្មរបស់យើង

មានការធ្លាក់ចុះ។ តើអ្នកណាជាអ្នកមានចំណូលថេរ? ជាទូទៅ អ្នកចូលនិវត្តន៍ជាច្រើនរស់នៅដោយសារតែប្រាក់ចូលនិវត្តន៍ប្រចាំខែថេរ។ ប៉ុន្តែមានប្រទេសខ្លះ ក៏បានគិតអតិផរណាចូលទៅក្នុងប្រាក់និវត្តន៍នេះដែរ។ នេះជាប្រាក់ឧបត្ថម្ភដែលត្រូវបានគិតបញ្ចូលជាស្វ័យប្រវត្តិ ពេលដែលកម្រិតថ្លៃទូទៅកើនឡើង។ ជាឧទាហរណ៍៖ ប្រសិនបើថ្លៃនៃទំនិញកើនឡើង ១០ភាគរយ ប្រាក់ឧបត្ថម្ភក៏កើនឡើង ១០ភាគរយដែរ។

៤ខ. ម្ចាស់បំណុល និងកូនបំណុល (Creditor and Dector)

អ្នកដឹងថា៖ កូនបំណុលទទួលផលប្រយោជន៍ពីការខ្ចីប្រាក់នៅពេលមានអតិផរណា។ ជាការពិត ប្រសិនបើខ្ញុំឱ្យអ្នកខ្ចី ១០០រៀល ដោយសងវិញក្នុងរយៈពេល១ឆ្នាំ ហើយថ្លៃកើនឡើង ១០%ក្នុងចន្លោះពេលនោះប្រាក់ដែលខ្ញុំឱ្យអ្នកខ្ចីពេលទទួលបានតិចជាង១០០រៀល ដូច្នេះ៖

Real interest rate = Nominal interest rate -inflation

ប្រសិនបើយើងប្រមើលមើលឃើញថា ថ្លៃកើនឡើង ១០% ការពិតណាស់ ខ្ញុំដាក់បញ្ហានេះទៅក្នុងការពិនិត្យមើលទំនាក់ទំនងដែលខ្ញុំធ្វើឱ្យអ្នកពេលនោះ ខ្ញុំនឹងគិតឱ្យអ្នកអត្រាការប្រាក់ណាមួយដែលអាចទប់ទល់នឹងការធ្លាក់ចុះថ្លៃ ដោយយោងទៅលើការប្រមើលមើលអតិផរណា។

ឧទាហរណ៍៖ ប្រសិនបើយើងឯកភាពលើអត្រាការប្រាក់ ១៥% ដូច្នេះនៅចុងឆ្នាំអ្នកសងវិញ ១១៥។ ភាពខុសគ្នារវាងអត្រាការប្រាក់ដែលបានខ្ចី និងអតិផរណា គឺអត្រាការប្រាក់ពិត (real interest rate)។ តាមការទំនាក់ទំនងរបស់យើងខ្ញុំនឹងទទួលបាននូវអត្រាការប្រាក់ពិត ៥% ដោយគិតពីអ្នកអត្រា ១៥% ខ្ញុំគ្មានបាត់បង់អ្វីដោយ សារតែអតិផរណាទេ។ ចំពោះ អតិផរ-ណាដែលខ្ពស់ជាងការប្រាក់ដែលបានគិតអ្នកទទួលផលចំណេញ គឺកូនបំណុលចំណែកអតិផរ-ណាទាបជាងការប្រាក់ដែលបានគិតអ្នកទទួលផលចំណេញ គឺម្ចាស់បំណុល។

៤គ. ភាពគ្មានប្រសិទ្ធភាព (Inefficiencies)

វានឹងមានការបាត់បង់ ទោះបីយើងបានប្រមើលមើលអតិផរណាក៏ដោយ បញ្ហាជាក់ស្តែងគឺជាការគិតគូរដែលត្រូវធ្វើឱ្យទាន់ពេល។ ក្នុងអំឡុងពេលដែលអតិផរណាកើនឡើងយ៉ាងឆាប់រហ័សនៅប្រទេសអូស្ត្រាលីនាទស្សវត្សរ៍ឆ្នាំ ១៩៨០ ហើយម្ចាស់ហាងត្រូវតែគិតតម្លៃឡើងវិញយ៉ាងញឹកញាប់ ហើយបញ្ហានេះទាមទារពេលវេលាដើម្បីធ្វើឱ្យមានប្រសិទ្ធភាព។ បន្ថែមលើនេះទៀត បើសិនប្រជាជនគ្មានពត៌មានគ្រប់គ្រាន់ទេ ឬប្រសិនបើគេមិនយល់នូវអ្វីដែលកើតឡើងចំពោះថ្លៃទេនោះ គេនឹងជួបបញ្ហាក្នុងមុខរបរជំនួញរបស់ពួកគេ។

៤ឃ. ការប្រថុយប្រថានកើនឡើង និងកំណើនសេដ្ឋកិច្ចធ្លាក់ចុះ (Increase risk and slower economic growth)

ពេលដែលមិនបានប្រមើលមើលអតិផរណា នោះវានឹងមានការប្រថុយប្រថានៃការធ្វើវិនិ-យោគក្នុងសេដ្ឋកិច្ច។ ដោយសារតែ មានភាពមិនច្បាស់លាស់នេះហើយ ដែលវិនិយោគស្ទាក់ស្ទើរក្នុងការដាក់ទុនវិនិយោគ និងការសន្សាធ្វើអ្វីមួយក្នុងរយៈពេលវែង។ ការិនិយោគធ្លាក់ចុះ ហេតុនេះវាអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចរយៈពេលវែងធ្លាក់ចុះផងដែរ។

៥. មូលហេតុទាំងឡាយនៃអតិផរណា៖ (Basic causes of Inflation)

៥ក. អតិផរណាដោយសារថ្លៃ (Inflation by price)

ការកើនឡើងជាបន្តបន្ទាប់នៃថ្លៃទំនិញមិនឈប់ឈរជាបាតុភូតអតិផរណា។ ជាទូទៅវាជាបាតុភូតបន្តគ្នារវាងការកើនឡើងនូវថ្លៃរបស់កត្តាផលិតកម្មនានា។ ការកើនឡើងប្រាក់ ខែរបស់បុគ្គលិក បានបង្កើតតម្រូវការថ្មីដែលជំរុញឱ្យមានការកើនឡើង តែការកើនឡើងប្រាក់ខែនេះ មិនមានការកើនឡើងប្រាក់ខែពិតនោះទេ បើកាលណាមានការកើនឡើងថ្លៃតាមទិសដៅសមាមាត្រគ្នានោះ។ បាតុភូតនេះ តម្រូវឱ្យកម្មករត្រូវទាមទារឱ្យមានការកើនឡើងជាបន្តទៀតនូវប្រាក់ខែទៀត។ ចំពោះកត្តាផលិតកម្មផ្សេងៗទៀត ដូចជាវត្ថុធាតុដើម និងអត្រាការប្រាក់កើនឡើងដូចគ្នានោះដែរ។ សោហ៊ុយហិរញ្ញវត្ថុជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់សហគ្រាសក្នុងការធ្វើវិនិយោគទាំងនេះ ហើយផលិតផលមានការកើនឡើងជាលំដាប់ក្នុងអំឡុងពេលមួយនោះ។

៥ខ. អតិផរណាបណ្តាលមកពីតម្រូវការ (Inflation by demand)

ការកើនឡើងនូវប្រាក់បៀវត្ស បានបង្កើតនូវតម្រូវការថ្មីលើទីផ្សារ។ ហើយវាបាននាំឱ្យមាននូវថ្លៃរបស់ទំនិញ និងជំរុញឱ្យមានការទាមទារឱ្យមានការគិតឡើងនូវប្រាក់ខែ ដើម្បីទូទាត់ឱ្យបានដូចពីមុន។

កំណើតតម្រូវការ ⟶ ការឡើងថ្លៃ ⟶ កំណើតផលទុន ⟶ កំណើនតម្រូវការ

៥គ. អតិផរណារូបិយវត្ថុ (Monetary Inflation)

ហេតុការណ៍នេះ បានក្លាយជាច្បាប់ទៅហើយ បើកាលណាមានការកើនឡើងនូវថ្លៃ ខណៈពេលដែលបរិមាណតម្រូវការនៅដដែលនោះ បរិមាណតម្រូវការទៅសមាសភាពនឹងរូបិយវត្ថុ ស-ម្រាប់ចរាចរណ៍កើតមានជាមិនខាន។ បើកាលណាការកើនឡើងបរិមាណរូបិយវត្ថុក្នុងចរាចរណ៍ ពេលនោះថ្លៃរបស់រូបិយវត្ថុមានការធ្លាក់ចុះ ដោយសារការផ្គត់ផ្គង់ធំជាងតម្រូវការដែលធ្វើឱ្យមានការបាត់បង់អំណាចទិញរបស់វាចំពោះទំនិញជាទូទៅ។

ហេតុនេះ ត្រូវបានគេហៅថា *អតិផរណារូបិយវត្ថុ*។ តាមច្បាប់បរិមាណរូបិយវត្ថុ MV = P.Q, ដែល Q ទំហំនៃការលក់៖

P ថ្លៃទំនិញ ឬក៏កម្រិតថ្លៃទូទៅលើទីផ្សារ

M បរិមាណរូបិយវត្ថុក្នុងសារាចរណ៍

V ល្បឿនចរាចរណ៍

ដោយនៅក្នុងទ្រឹស្តីនេះ មានការលំបាកមួយចំនួនដូចជា តើយើងអាចវាស់ល្បឿនចរាចរបានយ៉ាងណា? ការវាស់វែងកម្រិតថ្លៃរួមរបស់ទំនិញយ៉ាងណានោះនៅក្នុងការអនុវត្តនេះ សូម្បីក្នុងទ្រឹស្តីក៏ជាការលំបាកដែរដែលត្រូវយកសន្ទស្សន៍ថ្លៃណានោះ។ ទ្រឹស្តីនេះក៏បានបង្កើតឡើងនូវសម្មតិកម្ម២ទៀត គឺល្បឿនរបស់រូបិយវត្ថុនៅថេរក្នុងរយៈពេលខ្លី និងចំនួនការលក់ដូរមិនមានការប្រែប្រួលទៅតាមថ្លៃនោះទេ។

ដូច្នេះ $\Delta P = (V.Q).\Delta M$

៦. ផលវិបាកនៃអតិផរណា (Impact on Inflation)

៦ក. ផលវិបាកនៃរូបិយវត្ថុ (Impact on Monetary)

ជាបឋមតួនាទីសំខាន់របស់ រូបិយវត្ថុមានបីគឺ៖

- ឧបករណ៍សម្រួលដល់ការដោះដូរ
- ឧបករណ៍ខ្នាត់រង្វាស់តម្លៃ
- ឧបករណ៍រក្សាតម្លៃ

កាលណាមានអតិផរណា បានធ្វើឱ្យវាមានការខូចខាតដល់តួនាទីទាំងបីនេះ ការបាត់បង់អំណាចទិញនៃរូបិយវត្ថុ ភ្នាក់ងារសេដ្ឋកិច្ច បានប្តូរវាឱ្យទៅជាទ្រព្យពិតនៅក្នុងដៃវិញដែលជាមូលហេតុនាំឱ្យរូបិយវត្ថុកាន់តែបាត់បង់នូវអំណាចទិញជាបន្តបន្ទាប់ទៅទៀត។

៦ខ. ផលវិបាកលើសកម្មភាពសេដ្ឋកិច្ច (Impact on Activity Economy)

វាជាផលល្អនិងអាចជាផលអាក្រក់ សម្រាប់សហគ្រាសក្នុងការបណ្តាក់ទុនរកស៊ី ដោយហេតុថាកាលណាមានអតិផរណានោះ សហគ្រាសប្រាកដជាមានភាពមិនច្បាស់លាស់ចំពោះការនាំចេញនិងនាំចូល។ អតិផរណា អាចមានផលប្រយោជន៍ចំពោះអ្នកនាំចេញសម្រាប់រយៈពេលខ្លី នេះក៏ដោយយើងមានប្រៀបខាងអត្រាប្តូរប្រាក់។ ចំពោះការនាំចូល អាចមានការរាំងស្ទះវិញដោយការនាំចូលពុំមានលទ្ធភាពគ្រប់គ្រាន់ សម្រាប់ការប្រកួតប្រជែងនោះទេ។

៦គ. ផលវិបាកនៃការបែងចែកទុន (Impact on distribution capital)

ចំពោះសហគ្រាសដែលជំពាក់បំណុលគេអតិផរណាក៏ឱ្យអត្ថប្រយោជន៍ដែរ ដោយតម្លៃរូបិយវត្ថុធ្លាក់ចុះថ្លៃ ដែលជាមូលហេតុនាំឱ្យយើងឃើញថា ការទូទាត់សងនៅពេលនេះមានតម្លៃតិចជាងមានអតិផរណា តែចំពោះអ្នកមានបំណុលវិញប្រឹត្តិការណ៍វាជាដំណើរការអាក្រក់ទៅវិញ។

៧. គោលនយោបាយប្រឆាំង និងអតិផរណា (Political protection inflation)

ដោយយើងសង្កេតទៅលើមូលហេតុនានានៃអតិផរណាពេលនោះ យើងអាចលើកឡើងនូវនយោបាយនានាដែលប្រឆាំង និងអតិផរណា ដូចជានយោបាយរូបិយវត្ថុ វាគឺជាឧបករណ៍គោលនយោបាយរបស់អជ្ញាធររូបិយវត្ថុ ឬធនាគារកណ្តាល ដែលមានតួនាទីជាអ្នកអនុវត្តន៍ និងការគ្រប់គ្រងបរិមាណសាច់ប្រាក់ក្នុងចរាចរនៅលើទីផ្សារ។ បើកាលណាមានចរាចរសាច់ប្រាក់ច្រើនពេកនោះ បានធ្វើឱ្យរូបិយវត្ថុត្រូវបាត់បង់នូវតម្លៃរបស់វា។

៦.៤-គោលនយោបាយរូបិយវត្ថុ (MONETARY POLICY)

៦.៤.១-សេចក្តីផ្តើម (INTRODUCTION)

ការកំណត់បទដ្ឋានវិភាគលើរូបិយវត្ថុ គឺថាធនាគារកណ្តាលអនុវត្តការគ្រប់គ្រងសេដ្ឋកិច្ច ដោយពិនិត្យលើការផ្គត់ផ្គង់រូបិយវត្ថុសរុប (aggregate supply)។ ក្នុងករណីនេះ ការវិភាគលើតម្រូវការរូបិយវត្ថុសរុប(aggregate demand) ត្រូវបានគេហៅថាខ្សែកោង៖ IS–LM ។ ការវិភាគលើទីផ្សាររូបិយវត្ថុ បង្កើតបានសមីការខ្សែកោង IS ។ ទោះយ៉ាងណាក៏ដោយ ប្រភេទនៃសេដ្ឋកិច្ចខ្លះ ការគ្រប់គ្រងអត្រាការប្រាក់ អាចជាមធ្យោបាយមួយក្នុងការគ្រប់គ្រងតម្រូវការរូបិយវត្ថុសរុបច្រើនជាងការផ្គត់ផ្គង់រូបិយវត្ថុសរុប។ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍មួយចំនួនរួមទាំងសហរដ្ឋអាមេរិក កាណាដា និងអង់គ្លេស បច្ចុប្បន្ននេះ ហាក់ដូចជាពឹងផ្អែកកាន់តែខ្លាំងលើអត្រាការប្រាក់ជាជាងការផ្គត់ផ្គង់លុយសរុប ដែលជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុជាចម្បង។[៧៩]

សម្រាប់សេដ្ឋកិច្ចប្រទេសរបស់ពួកគេ ការវិភាគលើខ្សែកោង LM ពុំសូវសមស្របនោះទេ។ ផ្ទុយទៅវិញ ការវិភាគលើខ្សែកោង IRT(interest rate target) ដែលបន្ថែមលើខ្សែកោង IS កំណត់តម្រូវការលុយសរុបនៅក្នុងគំរូវិភាគ។ ការវិភាគលើខ្សែកោង IS–LM និង IS–IRT ត្រូវបានបង្ហាញលម្អិតក្នុងជំពូកទី ១៣ នៃសៀវភៅចំណងជើង "សេដ្ឋកិច្ចរូបិយវត្ថុ" ។ ប្រសិនបើធនាគារកណ្តាលកំណត់អត្រាការប្រាក់ជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុហួសហេតុពេក ដែលមានគោលបំណងផ្គត់ផ្គង់បរិមាណរូបិយវត្ថុសរុប ទៅតាមអត្រាការប្រាក់នោះដែរ។ ធនាគារកណ្តាល អាចធ្វើឱ្យមានការផ្លាស់ប្តូរសមស្របទៅតាមមូលដ្ឋាននៃរូបិយវត្ថុ ដោយការស្ម័គ្រចិត្តឬអនុញ្ញាតិឱ្យធនាគារពាណិជ្ជកម្ម អាចខ្ចីលុយពីធនាគារកណ្តាលបាន។ ក្នុងករណីនេះ ការផ្គត់ផ្គង់រូបិយវត្ថុបានក្លាយទៅជារឿងមិនល្អសម្រាប់សេដ្ឋកិច្ច។

៦.៤.២-និយមន័យគោលនយោបាយរូបិយវត្ថុ និង គោលនយោបាយសារពើពន្ធ (DEFINITIONS OF MONETARY AND FISCAL POLICIES)

សារៈសំខាន់នៃគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចរូបិយវត្ថុ ដោយសារតែផលប៉ះពាល់នៃគោលនយោបាយរូបិយវត្ថុមកលើសេដ្ឋកិច្ច។ គោលនយោបាយរូបិយវត្ថុ ត្រូវបានគេចាត់ទុកថា ជាការផ្លាស់ប្តូរគោលនយោបាយនៃការផ្គត់ផ្គង់រូបិយវត្ថុ ឬ/និងអត្រាការប្រាក់។ ការគ្រប់គ្រងគោលនយោបាយរូបិ-យវត្ថុ ត្រូវធ្វើឡើងដោយធនាគារកណ្តាលឬអាជ្ញាធររូបិយវត្ថុ ដែលពាក្យទាំង២នេះមាននិយមន័យខ្លឹមសារដូចគ្នា។

តាមគំរូម៉ូដែលរបស់លោក Walrasian និងគំរូម៉ូដែលក្លាស៊ីកបែបទំនើប បានគូសបញ្ជាក់ថាលំនឹងសមតាសេដ្ឋកិច្ចរូបិយវត្ថុ ទោះបីក្នុងរយៈពេលខ្លីក៏ដោយ ក៏មិនមានផលវិជ្ជមានអ្វីទាក់ទងនឹងលទ្ធផលខ្ពស់ ឬទាបនៃភាពអត់ការងារធ្វើ ដោយប្រតិបត្តិការជាប្រព័ន្ធ ឬការរំពឹងទុករបស់ពួកគេ។ តាមលោក (Friedman, ១៩៧៧; Lucas, ១៩៩៦)បានគូសបញ្ជាក់ថាបើទោះបីជាមានផលប៉ះ

[៧៩] This is also so for the European Central Bank, which claims to treat the interest rate as its primary monetary policy instrument but also monitors monetary aggregates.

ពាល់ បណ្តោះអាសន្នក្នុងរយៈពេលខ្លីនៃគោលការណ៍ចៃដន្យក៏ដោយ។ ចំពោះគំរូម៉ូដែលរបស់លោកកេនស៍បានគូសបង្ហាញថា មានអត្ថប្រយោជន៍បែបនេះ សម្រាប់សេដ្ឋកិច្ចរយៈពេលខ្លី។ គោលនយោបាយសារពើពន្ធ គឺជាការចំណាយ និងការកម្រិតពន្ធរបស់រដ្ឋាភិបាល នៅពេលមានវិន-ភាពថវិកា ឬអតិរេកថវិកា។ ការអនុវត្តគោលនយោបាយនេះ គឺដើម្បីផ្លាស់ប្តូរកម្រិតសេដ្ឋកិច្ច។ ខណៈពេលដែលវិនភាពថវិការបស់រដ្ឋាភិបាល អាចត្រូវបានផ្គត់ផ្គង់តាមរយៈការកើនឡើងនៃការផ្គត់ផ្គង់លុយ (បន្ទុកត្រូវបានអមដោយការថយចុះនៅក្នុងនោះដែរ) មុខងារម៉ាក្រូសេដ្ឋកិច្ច គឺជាគោលនយោបាយសារពើពន្ធមួយ ដែលការផ្គត់ផ្គង់លុយត្រូវតែរក្សាឱ្យមានស្ថិរភាពជាប្រចាំ។ ដូច្នេះការផ្តល់ប្រាក់កម្ចី ត្រូវតែផ្តល់ដោយហិរញ្ញប្បទានរបស់រដ្ឋាភិបាលតាមរយៈការកើនឡើង នៅក្នុងមូលបត្របំណុលរបស់ខ្លួនបានជាក់លក់ជាសាធារណៈ។

ដូចគ្នានេះដែរ អតិរេកសារពើពន្ធ ត្រូវបានវាស់វែងដោយបានសន្មត់ថា តម្រូវឱ្យទិញសញ្ញាប័ណ្ណ(មូលបត្របំណុល)ពីធនាគារកណ្តាល និងប្រាក់សោធននិវត្តរបស់ពួកគេ ដោយមិនផ្លាស់ប្តូរការផ្គត់ផ្គង់លុយនៅក្នុងចរន្តសេដ្ឋកិច្ច។ ហេតុផលនេះ សម្រាប់គោលនយោបាយសារពើពន្ធ គឺដើម្បីបែងចែកផលប៉ះពាល់នៃការផ្លាស់ប្តូរអថេរសារពើពន្ធពីការផ្គត់ផ្គង់លុយរបស់ពួកគេ។ ដូចនេះ គោលនយោបាយសារពើពន្ធ គឺជាការអនុវត្តន៍នូវគោលនយោបាយថវិកា។

ធាតុពិតនៃគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ដូច្នេះ មានប្រទេសខ្លះ និយមប្រើនូវគោលនយោបាយទាំងនេះផ្សេងៗគ្នា។ ទោះយ៉ាងណាក៏ដោយ គោលបំណងនៃគោលនយោបាយរបស់ពួកគេ ត្រូវបានចាត់ទុកថា ជាគំនិតឯករាជ្យ។ ដូច្នេះ គោលនយោបាយសារពើពន្ធពង្រីក ត្រូវបានផ្តល់ដោយការបង្កើនការផ្គត់ផ្គង់លុយ ត្រូវបានចាត់ទុកជាសមាសធាតុពីរយ៉ាង គឺគោលនយោបាយសារពើពន្ធពង្រីក និងគោលនយោបាយរូបិយវត្ថុពង្រីក។

គោលនយោបាយសារពើពន្ធគឺជាការប្រើប្រាស់ចំណាយ និងការយកពន្ធរបស់រដ្ឋាភិបាលដែលជះឥទ្ធិពលមកលើសេដ្ឋកិច្ច។ នៅពេលរដ្ឋាភិបាលធ្វើការសម្រេចលើការទិញទំនិញ និងសេវារបស់ខ្លួន ការបង្វែរការទូទាត់ដែលរដ្ឋបែងចែក ឬពន្ធដែលរដ្ឋត្រូវប្រមូលគឺជាប់ពាក់ព័ន្ធនឹងគោលនយោបាយសារពើពន្ធ។ ផលប៉ះពាល់បឋមផ្នែកសេដ្ឋកិច្ចពីបម្រែបម្រួលថវិការបស់រដ្ឋាភិបាលដែលមានមកលើក្រុម ជាក់លាក់មួយចំនួន ពោលគឺការកាត់បន្ថយពន្ធសម្រាប់គ្រួសារដែលមានកូន ឧ. បង្កើនប្រាក់ចំណូលជាក់ស្តែងរបស់ពួកគេ។ ទោះបីយ៉ាងណា ការពិភាក្សាអំពីគោលនយោបាយសារពើពន្ធ ជាទូទៅផ្តោតលើផលប៉ះពាល់នៃបម្រែបម្រួលថវិការបស់រដ្ឋាភិបាលមកលើសេដ្ឋកិច្ចទាំងមូល។ ទោះបីជាបម្រែ បម្រួលខាងពន្ធដារ ឬការចំណាយដែល "រក្សានៅកម្រិតប្រាក់ចំណូលអព្យាក្រឹត្យ" អាចត្រូវបានបកស្រាយថាជាគោលនយោបាយសារពើពន្ធ ហើយអាចប៉ះពាល់ដល់កម្រិតទិន្នផលសរុបដោយការកែសម្រួលការលើកទឹកចិត្តដែលប្រឈមដោយក្រុមហ៊ុនសហគ្រាស ឬរួបរួតបុគ្គលក៏ដោយ ប៉ុន្តែពាក្យថា "គោលនយោបាយសារពើពន្ធ" ជាធម្មតាត្រូវបានប្រើដើម្បីពិពណ៌នាអំពីឥទ្ធិពលមកលើកម្រិតទូទៅនៃការចំណាយ និងពន្ធដាររបស់សេដ្ឋកិច្ចទាំងមូល និងជាពិសេសគម្លាតរវាងការចំណាយ និងពន្ធដារ។

៦.៤.៣-កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ (OBJECTIVE OF MONETARY POLICY)

កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ គឺរក្សាស្ថិរភាពថ្លៃ (stable price) ដើម្បីចៀសវាងការអូសបន្លាយនៃអតិផរណា ឬបរិត្តផរណា។ ស្ថិរភាពថ្លៃ គឺរួមចំណែកដល់ការសម្រេចបាននូវកំណើនសកម្មភាពសេដ្ឋកិច្ច និងការងារពេញលេញតាមរយៈការកែលម្អតម្លាភាពនៃយន្តការថ្លៃ។ ស្ថិរភាពកម្រិតថ្លៃអាចធ្វើឱ្យអ្នកចូលរួមក្នុងទីផ្សារឆាប់សម្គាល់បានអំពីការប្រែប្រួលថ្លៃទំនិញ និងសេវាកម្មផ្សេងៗ និងងាយស្រួលក្នុងការអនុម័តចំពោះការចំណាយប្រើប្រាស់ និងការវិនិយោគ។ ឈរលើមូលដ្ឋានស្ថិរភាពថ្លៃធនាគារ អាចត្រូវបានវិភាជន៍សេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ការកាត់បន្ថយនូវបុព្វលាភនៃហានិភ័យអតិផរណា (inflation risk) សម្រាប់អត្រាការប្រាក់មានតែនាម ដែលធ្វើឱ្យអត្រាការប្រាក់ពិតថយចុះ និងអាចបង្កើតការលើកទឹកចិត្តដល់ការវិនិយោគ។ ម្យ៉ាងវិញទៀត ដើម្បីចៀសវាងសកម្មភាពដែលមិនគាំទ្រផលិតភាព ក្នុងការគាំពារចំពោះឥទ្ធិពលអវិជ្ជមាននៃអតិផរណា និងបរិត្តផរ-ណា។ មួយវិញទៀត កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុជួយបង្កាផលប៉ះពាល់ដល់ការបែងចែកចំណូល និងទ្រព្យសម្បត្តិដែលបណ្តាលមកពីអតិផរណា ឬបរិត្តផរណាមិនរំពឹងទុក។

ដូច្នេះ កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុរួមបញ្ចូលទាំងការរៀបចំ និងការអនុវត្តនូវគោលនយោបាយរូបិយវត្ថុ ដោយធនាគារកណ្តាលក្នុងទម្រង់ប្រតិបត្តិការទីផ្សារបើកចំហរ ដើម្បីបង្ហាញពីសារសំខាន់នៃអត្រាការប្រាក់ ដែលមានប្រសិទ្ធិភាពជំរុញក្នុងគោលដៅណែនាំដល់គ្រឹះស្ថានផ្តល់នូវប្រាក់កម្ចីទៅនឹងភាពបត់បែនក្នុងការទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ដែលមានភាពយឺតទាំងនេះត្រូវតែមានរៀបចំទុកជា មុន។ ការសម្រេចបានកម្រិតអតិផរណាទាប និងកម្រិតទិន្នផលសរុបសេដ្ឋកិច្ចខ្ពស់ និងមាននិរន្តរ ភាព។ ក្រុមប្រឹក្សាភិបាលនៃធនាគារសហព័ន្ធបានកំណត់គោលនយោបាយរូបិយវត្ថុដូចខាងក្រោម៖[៨០] *ពាក្យថា "គោលនយោបាយរូបិយវត្ថុ" សំដៅទៅលើសកម្មភាពដែលធ្វើឡើងដោយធនាគារសហព័ន្ធ ដូចជាធនាគារកណ្តាលដើម្បីដុះឥទ្ធិពលដល់លទ្ធភាព និងថ្លៃដើមនៃរូបិយវត្ថុ និងឥណទាន ដើម្បីជួយលើកកម្ពស់គោលដៅសេដ្ឋកិច្ចជាតិ"។*

ធនាគារកណ្តាលនៅតាមបណ្តាប្រទេសភាគច្រើន បានកំណត់នូវគោលនយោបាយរូបិយវត្ថុទាក់ទងនឹងគោលបំណងសេដ្ឋកិច្ចរបស់ខ្លួន។

ធនាគារកណ្តាលនៃប្រទេសអង់គ្លេស៖[៨១]

"គោលបំណងគោលនយោបាយរូបិយវត្ថុ គឺស្ថិរភាពថ្លៃ ដើម្បីរក្សាតម្លៃរូបិយវត្ថុ ឬជាក់មធ្យោបាយផ្សេងទៀតដើម្បីទប់ស្កាត់អតិផរណា ឬការកើនឡើងជាទូទៅនៃតម្លៃទំនិញ និងសេវាកម្ម។ ភាពមិនប្រាកដប្រជាអំពីអតិផរណា ដូច្នេះអំពីកម្រិតថ្លៃនាពេលអនាគតកំពុងធ្វើឱ្យខូចខាតដល់ដំណើរការត្រឹមត្រូវនៃសេដ្ឋកិច្ច។ ជាមួយនឹងកម្រិតថ្លៃទូទៅ ដែលមានសញ្ញាស្ថិរភាពថ្លៃនីមួយៗអាចត្រូវបានសិក្សាឱ្យកាន់តែច្បាស់ និងការសម្រេចចិត្តសមហេតុផលថាតើត្រូវសន្សំ ឬខ្ចីប្រាក់ តើត្រូវវិនិយោគប៉ុន្មាន និងប្រើប្រាស់

[៨០] Bank of Canada

[៨១] This section benefitted from www.reservebank.co.za

ហើយត្រូវផលិតអ្វីនឹងពេលណា? តាមវិធីនេះស្ថិរភាពថ្លៃ អាចជួយជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយចីរភាព។

ធនាគារកណ្តាលកាណាដា៖[៨២]

"គោលដៅគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលកាណាដា គឺចូលរួមចំណែកក្នុងការកើនឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជនកាណាដាទាំងអស់ តាមរយៈអតិផរណាទាប និងមានស្ថិរភាពល្អ។ ជាពិសេស ធនាគារកណ្តាលមានគោលបំណងរក្សាអត្រាអតិផរណា...នៅក្នុងគោលដៅដែលបានបង្កើតរួមគ្នាជាមួយរដ្ឋាភិបាល។ ចាប់តាំងពីឆ្នាំ ១៩៩៥ មក គោលដៅមានកម្រិតអតិផរណាពី ១ ទៅ ៣ ភាគរយ"។ ទស្សនៈទាំងនេះ អាចត្រូវបានសំយោគដូចខាងក្រោម៖

- ធនាគារកណ្តាលមានគោលបំណងពីរ៖ គោលបំណងមួយដែលអាចត្រូវបានគេហៅថាគោលបំណងចម្បង (ត្រូវបានគេកំណត់ថាអតិផរណាទាប និងមានស្ថិរភាព) និងគោលបំណងមួយទៀត ដែលអាចត្រូវបានគេហៅថាគោលបំណងចុងក្រោយ (ត្រូវបានកំ-ណត់ថាជាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយនិរន្តរភាព)។
- គោលបំណងចុងក្រោយ គឺអថេរឯករាជ្យ (dependent variable)។ ទោះជាយ៉ាងណាក៏ដោយអតិផរណាទាប និងស្ថិរភាពមិនមែនជាលក្ខខណ្ឌគ្រប់គ្រាន់ សម្រាប់ការសម្រេចបានប្រសិទ្ធភាពខ្ពស់នេះទេ។ វាគឺផ្នែកមួយនៃកត្តាជាច្រើន ប៉ុន្តែវាគឺជាផ្នែកមួយដ៏សំខាន់បំផុត។
- ភាពមិនប្រាកដប្រជាពីអតិផរណា គឺមានគ្រោះថ្នាក់ដល់ដំណើរការត្រឹមត្រូវសេដ្ឋកិច្ច។ អតិផរណាខ្ពស់ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្រាការប្រាក់ពិតទាប និងអត្រាការប្រាក់មានតែនាមខ្ពស់ដែលនឹងបង្កជាហានិភ័យ។ ភាពប្រែប្រួលខ្ពស់មានន័យថា ហានិភ័យហើយអាជីវកម្មមិនពេញចិត្តនឹងហានិភ័យនេះទេ។ អាជីវកម្ម មិនធ្វើបានល្អក្នុងបរិ-ស្ថានសេដ្ឋកិច្ច ដែលមានហានិភ័យខ្ពស់នោះទេ ពីព្រោះកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេត្រូវបានបញ្ជូនទៅរកហានិភ័យ។
- កម្រិតថ្លៃរួមដែលមានស្ថិរភាព និងអត្រាការប្រាក់ មានស្ថិរភាពមានន័យថាសញ្ញាសេដ្ឋកិច្ចសំខាន់ៗមានតម្លាភាពដែលនាំឱ្យមានហានិភ័យទាប និងមានភាពងាយស្រួលក្នុងការសម្រេចចិត្តវិនិយោគ។ តាមរបៀបនេះ ស្ថិរភាពថ្លៃរួមចំណែកដល់កំណើនសេដ្ឋកិច្ចរយៈពេលវែងខ្ពស់ និងមានចីរភាព។

ដើម្បីសម្រេចបាននូវគោលបំណងចម្បង និងចុងក្រោយ ធនាគារកណ្តាលមានគោលបំណងគោលនយោបាយរូបិយវត្ថុសម្រាប់រយៈពេលមធ្យម ហើយគោលបំណងគោលនយោបាយទាំងនេះរួមមានធ្វើឱ្យមានកំណើនប្រាក់កម្ចី ប្រាក់បញ្ញើធនាគារ និងស្ថិរភាពលើសូចនាករផ្សេងទៀត ដូចជាអត្រាប្តូរប្រាក់ និងតម្លៃទ្រព្យសកម្ម។ ការសិក្សាពិភាក្សាលើគោលនយោបាយរូបិយវត្ថុ អាចត្រូវបានសង្ខេប

[៨២] www.reservebank.co.za


ដូចក្នុងរូបភាពទី៣។ គម្លាតដ៏ធំគួរឱ្យកត់សម្គាល់ វាត្រូវបានបំពេញដោយផ្នែកប្រតិបត្តិការនៃគោលនយោបាយរូបិយវត្ថុ ដែលត្រូវបានរៀបរាប់លម្អិតនៅពេលក្រោយទៀត។

ធនាគារកណ្តាល អាចមានឥទ្ធិពលដល់ការប្រែប្រួលរូបិយវត្ថុមូលដ្ឋាន អញ្ញត្តិរូបិយវត្ថុ លំហូរឥណទាន និងតាមរយៈគោលនយោបាយនេះ បានធ្វើឱ្យមានការប្រែប្រួលអថេរម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមួយចំនួនដូចជា៖

- អត្រាការប្រាក់
- ចំណូលជាតិសរុប, និង
- អត្រាអតិផរណា

ដោយប្រើប្រាស់នូវឧបករណ៍នយោបាយរូបិយវត្ថុដែលមាន។

គំនូសតាងទី៨ បង្ហាញពីៈ កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ (Object of monetary policy)



៦.៤.៤-គោលនយោបាយរូបិយវត្ថុ (MONETARY POLICY)

ធនាគារកណ្តាល គឺជាអ្នកបោះផ្សាយផ្តាច់មុខនូវក្រដាសប្រាក់ និងកាស (N&C) និងទុនបម្រុងធនាគារ ពោលគឺអ្នកផ្តត់ផ្គង់ផ្តាច់មុខនូវរូបិយវត្ថុមូលដ្ឋាន។ ធនាគារកណ្តាល អាចកំណត់លក្ខខណ្ឌមួយចំនួនដែលមានឥទ្ធិពលដល់ការឱ្យខ្ចីដល់ធនាគារ និងប្រាក់កម្ចីលើទីផ្សារអន្តរ ធនាគារផ្សេងៗ សម្រាប់រយៈពេលខ្លីការប្រែប្រួលអត្រាការប្រាក់លើទីផ្សាររូបិយវត្ថុ ជាពិសេសទីផ្សារអន្តរធនាគារ ជាលទ្ធផលនៃការអនុវត្តគោលនយោបាយអត្រាការប្រាក់របស់ធនាគារកណ្តាល អាចមានការប្រែប្រួលសកម្មភាពភ្នាក់ងារសេដ្ឋកិច្ច និងអថេរម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមួយចំនួនដូចជាកម្រិតទិន្នផលសរុប កម្រិតថ្លៃ និងជញ្ជីងទូទាត់ជាដើម ដំណើការនេះគេហៅថា *"យន្តការបញ្ជូននៃគោលនយោបាយរូបិយវត្ថុ"*។ ឥទ្ធិពលនៃយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុរួមមានដូចខាងក្រោម៖

- ជះឥទ្ធិពលដល់បម្រែបម្រួលអត្រាការប្រាក់ផ្សារការ៖ សំដៅដល់ធនាគារកណ្តាល ជាអ្នកផ្តល់មូលនិធិកម្ចីមានការប្រាក់ទៅឱ្យប្រព័ន្ធធនាគារ និងមានសិទ្ធិផ្តាច់មុខក្នុងការផ្សាយ

ចេញរូបិយវត្ថុ។ ដូចនេះធនាគារកណ្តាល មានលទ្ធភាពគ្រប់គ្រាន់សម្រាប់កំណត់អត្រាការប្រាក់ផ្លូវការ។

- ជះឥទ្ធិពលដល់អត្រាការប្រាក់ធនាគារ និងអត្រាការប្រាក់ទីផ្សារអន្តរធនាគារ៖ សំដៅដល់បម្រែបម្រួលអត្រាការប្រាក់ផ្លូវការ ដែលមានឥទ្ធិពលដោយផ្ទាល់លើអត្រាការប្រាក់លើទីផ្សាររូបិយវត្ថុ និងដោយប្រយោលដល់អត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើធនាគារកំណត់សម្រាប់អតិថិជនរបស់ខ្លួន។
- ជះឥទ្ធិពលដល់ការរំពឹងទុក៖ សំដៅដល់ការរំពឹងទុក ចំពោះការប្រែប្រួលនៃអត្រាការប្រាក់ផ្លូវការសម្រាប់គ្រាខាងមុខអាចមានឥទ្ធិពលដល់អត្រាការប្រាក់សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង។ ជាពិសេសអត្រាការប្រាក់រយៈពេលវែង ដែលអត្រាការប្រាក់គឺចំណុះទៅនឹងការរំពឹងទុករបស់ទីផ្សារ ចំពោះការវិវត្តន៍នៃអត្រាការប្រាក់សម្រាប់រយៈពេលខ្លី។ គោលនយោបាយរូបិយវត្ថុ ត្រូវបានបង្ហាញពីភាពប្រាកដប្រជាដើម្បីទាក់ទាញជំនឿទុកចិត្តពីភ្នាក់ងារសេដ្ឋកិច្ចចំពោះស្ថានភាពថ្លៃ និងអត្រាការប្រាក់។
- ជះឥទ្ធិពលដល់ការសន្សំ និងការវិនិយោគ៖ សំដៅដល់ការប្រែប្រួលអត្រាការប្រាក់ធ្វើឱ្យប៉ះពាល់ដល់ការសន្សំ និងការវិនិយោគផ្នែកឯកជន។ ឧទាហរណ៍ បើសិនអត្រាការប្រាក់មានកម្រិតខ្ពស់ នោះបណ្តាលឱ្យមានការថយចុះនូវតម្រូវការប្រាក់កម្ចីសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគ និងការចំណាយលើការប្រើប្រាស់។
- ជះឥទ្ធិពលដល់តម្លៃទ្រព្យសម្បត្តិ៖ សំដៅដល់គោលនយោបាយរូបិយវត្ថុអាចកែប្រែលក្ខ-ខណ្ឌហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច និងការរំពឹងទុករបស់ទីផ្សារ ហើយធ្វើឱ្យប៉ះពាល់ដល់តម្លៃទ្រព្យសកម្ម (ដូចជាថ្លៃភាគហ៊ុន និងមូលបត្របំណុល) ព្រមទាំងអត្រាការប្រាក់។
- ជះឥទ្ធិពលដល់ការផ្តត់ផ្តង់ឥណទាន៖ សំដៅដល់អត្រាការប្រាក់មានកម្រិតខ្ពស់ ដែលអាចបង្កើននូវហានិភ័យ ចំពោះអ្នកខ្ចីប្រាក់ក្នុងការប្រឈមមុខទល់នឹងការគ្មានលទ្ធភាពសងបំណុល។ ហេតុនេះ ធនាគារអាចនឹងកាត់បន្ថយមូលនិធិកម្ចីទៅឱ្យក្រុមហ៊ុន និងអ្នកប្រើប្រាស់ដែលជាហេតុធ្វើឱ្យការវិនិយោគ និងការចំណាយលើប្រើប្រាស់ថយចុះ។
- ជះឥទ្ធិពលលើបម្រែបម្រួលដល់តម្រូវការសរុប និងកម្រិតថ្លៃ៖ សំដៅដល់ការប្រែប្រួលនូវការវិនិយោគ និងការចំណាយលើការប្រើប្រាស់ ដោយបណ្តាលឱ្យប្រែប្រួលដល់តម្រូវការក្នុងស្រុក។ ប្រសិនបើ តម្រូវការសរុបមានកម្រិតខ្ពស់ជាងការផ្តត់ផ្តង់សរុបនោះ គឺកម្រិតថ្លៃនឹងកើនឡើង។ ដូច្នេះការប្រែប្រួលតម្រូវការសរុប អាចធ្វើឱ្យប៉ះពាល់ដល់កម្រិតថ្លៃលើទីផ្សារពលកម្ម និងទីផ្សារទំនិញអន្តរការី។ សម្រាប់រយៈពេលវែង ការប្រែប្រួលបរិ-មាណផ្តត់ផ្តង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ច និងឆ្លុះបញ្ចាំងតាមរយៈការប្រែប្រួលកម្រិតថ្លៃ ប៉ុន្តែពុំអាចមានឥទ្ធិពលជាអចិន្ត្រៃយ៍ដល់សកម្មភាពផលិតកម្មនោះទេ។ គោលការណ៍នេះគេហៅថាអព្យាក្រឹត្យភាពនៃរូបិយវត្ថុក្នុងរយៈពេលវែង ពីព្រោះ


កំណើនផលិតកម្ម គឺអាស្រ័យលើកត្តាផ្សេងៗទៀត ដូចជាបច្ចេកវិទ្យាផលិតភាពនៃការប្រើប្រាស់នូវធនធានកំណើនប្រាក់ចំណូល និងការពេញនិយមរបស់អ្នកចូលរួមទៅក្នុងទីផ្សារ។

សម្រាប់ការបង្ហាញឧបករណ៍សំខាន់នៃគោលនយោបាយរូបិយវត្ថុ៖

- បង្កើតសមីការ LS ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់ KIR
- ប្រែប្រួលឱ្យបានសមស្រប KIR
- អនុវត្ត OMO តាមទម្រង់ផ្សេងៗគ្នា ដើម្បីធានាឱ្យបាននូវស្ថានភាព LS

ការសិក្សាមេរៀននេះ បានបង្ហាញក្នុងរូបភាពទី១ ស្តីពីឧបករណ៍ចម្បងក្នុងបរិបទនៃគោលបំណងគោលនយោបាយរូបិយវត្ថុ។ ផ្នែកនេះ ក៏បានបង្ហាញពីការអនុវត្តនូវឧបករណ៍គោលនយោបាយរូបិយវត្ថុទាំងនេះឱ្យមានប្រសិទ្ធភាព ដោយពឹងផ្អែកលើការវិវត្តប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលមានប្រសិទ្ធភាព។

គំនូសតាងទី៩ បង្ហាញពី៖ គោលនយោបាយរូបិយវត្ថុ (Monetary policy)



គំរូគោលនយោបាយរូបិយវត្ថុ សិក្សាវិគាគលើបញ្ហាពាក់ព័ន្ធលើផ្នែកទាំងនេះ មានដូចជា៖

- គំរូតម្រូវការទុនបម្រុងកាតព្វកិច្ច (Required reserves model)
- គំរូការប្រាក់អន្តរធនាគារ (Interbank rate model)
- សសរស្តម្ភគោលនយោបាយរូបិយវត្ថុ (Quoins of monetary policy)

លោក Paul Volcker ខណៈដែលធ្វើជាប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធបម្រុងសហព័ន្ធ (ឆ្នាំ ១៩៧៩-១៩៨៧) ដែលជារឿយៗត្រូវបានហៅថាជាបុគ្គលដែលមានឥទ្ធិពលបំផុតទី២ នៅសហរដ្ឋ-អាមេរិក។ លោក Volcker និងក្រុមហ៊ុនបានឆ្លើយតបយ៉ាងរហ័សចំពោះវិបត្តិសេដ្ឋកិច្ច "ដែលកើតឡើងដូនគ្នា" ក្នុងអំឡុងឆ្នាំ ១៩៨០ និងអំឡុងឆ្នាំ ១៩៨១-១៩៨២ ដោយសម្រេចបានអតិផរណាពីរខ្ទង់ក្នុងអំឡុងឆ្នាំ ១៩៧៩-១៩៨០ និងធ្វើឱ្យអត្រានៃភាពអត់ការងារធ្វើធ្លាក់មកនៅពីរខ្ទង់ជាលើក

ដំបូងចាប់តាំងពីឆ្នាំ ១៩៤០។ បន្ទាប់មក លោក Volcker បានប្រកាសពីជ័យជំនះលើការគ្រប់គ្រងអតិផ-រណា និងបានដឹកនាំសេដ្ឋកិច្ចឱ្យឆ្លងកាត់ការស្ទុះងើបឡើងវិញក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដែលធ្វើឱ្យ អត្រានៃភាពអត់ការងារធ្វើស្ថិតក្រោម ៥.៥ ភាគរយទាបជាងកាលពីអំឡុងឆ្នាំ ១៩៧៨-១៩៧៩។ លោក Volcker មានឥទ្ធិពលខ្លាំងណាស់ព្រោះគាត់គឺជាអ្នកបង្កើតគោលនយោបាយរូបិយវត្ថុ។ អ្នកកាន់តំណែងមុនគាត់ក៏មានឥទ្ធិពលដែរ។ យ៉ាងហោចណាស់វិបត្តិសេដ្ឋកិច្ចក្រោយសង្គ្រាមចំនួនប្រាំក្នុងចំណោមវិបត្តិទាំងប្រាំបី គឺបណ្តាលមកពីគោលនយោបាយប្រឆាំងនឹងអតិផរណា។ ដូចគ្នាដែរ ប្រព័ន្ធបម្រុងសហព័ន្ធរបស់លោក Alan Greenspan មានទំនួលខុសត្រូវដ៏ធំចំពោះវិបត្តិសេដ្ឋកិច្ចក្នុងអំឡុងឆ្នាំ ១៩៩០-១៩៩១ និង ២០០១ ។

ធនាគារកណ្តាល មានឥទ្ធិពលនៅគ្រប់ទិសទី ទោះបីជាមានមួយចំនួនតូចដំណើរការដោយឯករាជ្យពីរដ្ឋាភិបាលរបស់ខ្លួនដូចជាសហព័ន្ធមានឯករាជ្យពីសភា និងសេតវិមានក៏ដោយ។ សកម្មភាពរបស់ធនាគារកណ្តាល គឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់រដ្ឋាភិបាល ដែលដៈឥទ្ធិពលដល់សកម្មភាពសេដ្ឋកិច្ចពីមួយត្រីមាសទៅមួយត្រីមាស ឬពីមួយឆ្នាំទៅមួយឆ្នាំ។

គោលនយោបាយរូបិយវត្ថុ គឺជាប្រធានបទដ៏ចម្រូងចម្រាសយ៉ាងរស់រវើករវាងពីអ្នកជំនាញផ្នែកសេដ្ឋកិច្ចចំនួនពីរក្រុម គឺក្រុមរូបិយវត្ថុនិយម និងក្រុមគាំទ្រទ្រឹស្តីកេនស៊ាន (KEYNESIAN) ។ ទោះបីជាពួកគេយល់ស្របលើគោលដៅរួមក៏ដោយ ក៏ពួកគេមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំងទៅលើ ***អាទិភាព យុទ្ធសាស្ត្រ គោលដៅ និងយុទ្ធវិធី*** ។ នៅពេលខ្ញុំពន្យល់ពីរបៀបដែលគោលនយោបាយរូបិយវត្ថុដំណើរការ នោះខ្ញុំនឹងពិភាក្សាអំពីការខ្វែងគំនិតគ្នាទាំងនេះ។ ជាដំបូងខ្ញុំសូមបង្ហាញថាខ្ញុំជាសេដ្ឋវិទូបែបកេនស៊ាននិយម ។

<u>គោលដៅរួម៖</u>

មានក្រុមរូបិយវត្ថុនិយម ឬបែបកេនស៊ាននិយមតិចតួចដែលមិនយល់ស្របនឹងការស្រមៃតាមសេណារីយ៉ូនេះ៖

- ទីមួយ មិនមានវដ្តអាជីវកម្ម។ ផ្ទុយទៅវិញ ផលិតកម្មផ្អែកតាមការវាស់វែងផលិតផលជាតិសរុបពិត (ដែល កែតម្រូវតាមអតិផរណា) នឹងកើនឡើងជាលំដាប់ជាមួយនឹងសមត្ថភាពសេដ្ឋកិច្ច និងកម្លាំងពលកម្ម។
- ទីពីរ វាជាការល្អណាស់ដែលអតិផរណាតម្លៃក្នុងអត្រាទាបថេរស្មើនឹងសូន្យ។
- ទីបី អត្រាខ្ពស់បំផុតនៃការប្រើប្រាស់សមត្ថភាព និងកម្លាំងពលកម្មស្របទៅតាមនិន្នាការតម្លៃថេរ។
- ទីបួន និន្នាការកើនឡើងខ្ពស់នៃផលិតភាព និងផលិតផលក្នុងស្រុកសរុបពិតសម្រាប់អ្នកធ្វើការម្នាក់។

គោលនយោបាយរូបិយវត្ថុគឺជាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលគាំទ្រតម្រូវការ។ គោលនយោបាយដំណើរការជំរុញ ឬលើកទឹកចិត្តដល់ការចំណាយលើទំនិញ និងសេវា។ វិបត្តិសេដ្ឋកិច្ច និងវិបុលភាពទូទាំងសេដ្ឋកិច្ចឆ្លុះបញ្ចាំងពីការប្រែប្រួលនៃតម្រូវការសរុបជាជាងលើសមត្ថភាពផលិតភាព

របស់សេដ្ឋកិច្ច។ គោលនយោបាយរូបិយវត្ថុព្យាយាមបញ្ជ្រាបបន្តិចម្តងៗរហូតឈានដល់ការលុបបំបាត់ចោលនូវអតិផរណាទាំងនោះ។ វាមិនមែនជាឧបករណ៍ទ្រទ្រង់ការផ្តត់ផ្តង់ទេ (សូមមើលសេដ្ឋកិច្ចគាំទ្រការផ្តត់ផ្តង់) ។ ធនាគារកណ្តាលមិនមានឥទ្ធិពលលើផលិតភាព និងកំណើនសេដ្ឋកិច្ចពិតប្រាកដទេ។

<u>អាទិភាពៈ</u>

គោលដៅទី ២ និងទី ៣ តែងមានភាពចម្រូងចម្រាស។ តើអ្នកធ្វើគោលនយោបាយគួរផ្តល់អាទិភាពដល់ការរក្សាស្ថេរភាពតម្លៃ ឬកម្លាំងពលកម្មពេញលេញ? គោលនយោបាយរូបិយវត្ថុអាមេរិក និងអ៊ឺរ៉ុបមានភាពខុសគ្នាយ៉ាងខ្លាំងបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចដ៏ជ្រៅក្នុងអំឡុងឆ្នាំ ១៩៨១-១៩៨២ ។ សហព័ន្ធបាន "ធ្វើការកែសម្រួល" ដើម្បីស្រោចស្រង់សេដ្ឋកិច្ចឡើងវិញរយៈពេល ៦ ឆ្នាំ និងបានស្តារកម្លាំងពលកម្ម និងផលិតកម្មដែលបាត់បង់នៅក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចចន្លោះឆ្នាំ ១៩៨០ និង ១៩៨១-១៩៨២ ។ សហព័ន្ធ បានយកចិត្តទុកដាក់លើកម្លាំងពលកម្ម និងទិន្នផល ហើយលើប្រាក់ឈ្នួល និងតម្លៃ ដោយបន្តប្រើហ្គាស នៅពេល ដែលក្បាលម៉ាស៊ីនសេដ្ឋកិច្ចធ្លាក់ចុះ និងឈប់ដំណើរការ ខណៈដែលមានការ គំរាមកំហែង ឡើងកម្តៅខ្លាំង។ ក្នុងអំឡុងពេលស្តារឡើងវិញ សេដ្ឋកិច្ចមានការកើនឡើងយ៉ាងលឿនខ្លាំងពេលដែល ពុំអាចទ្រទ្រង់បាននៅពេលក្រោយ។ សហព័ន្ធបានព្យាយាមបន្តយសន្ទុះកំណើនរបស់ខ្លួនមកនៅកម្រិតមួយ ដែលមានចីរភាពនៅពេលដែលកម្លាំងពលកម្មត្រូវបានស្តារឡើងវិញទាំងស្រុង។

ធនាគារកណ្តាលអ៊ឺរ៉ុបដែលដឹកនាំដោយធនាគារអាល្លឺម៉ង់ឈ្មោះ Bundesbank មានចរិតអភិរក្សខ្លាំង។ ពួកគេមិនបានជួយអ្វីច្រើនដល់សេដ្ឋកិច្ចរបស់ពួកគេ។ ពួកគេបានចាត់ទុកសន្ទុះរូបិយវត្ថុសកម្មថាជាអតិផរណាប្រកបដោយគ្រោះថ្នាក់ បើទោះបីជាសេដ្ឋកិច្ចរបស់ពួកគេកម្រលេចចេញនូវវិបត្តិសេដ្ឋកិច្ចក៏ដោយ។ ពួកគេប្តេជ្ញាថានឹងមិនផ្តល់ហិរញ្ញប្បទានឱ្យហួសពីកំណើនដែលមានចីរភាពដោយគ្មានអតិផរណាឡើយ ទោះបីជាបណ្តោះអាសន្នក៏ដោយ។ អ៊ឺរ៉ុបបានស្ទុះងើបឡើងវិញយឺតជាងអាមេរិក ហើយអត្រាគ្មានការងារធ្វើរបស់ប្រទេសនេះបានកើនឡើងរហូតចាប់ពីទសវត្សរ៍ឆ្នាំ ១៩៧០។

អាទិភាពឆ្លុះបញ្ចាំងពីក្តីសុបិន្ត និងសុបិន្តអាក្រក់របស់ប្រទេសជាតិ។ ឧទាហរណ៍ ប្រទេស អាឡឺម៉ង់ បានជួបប្រទះនូវមហាវិបត្តិអតិផរណាដ៏គួរឱ្យរន្ធត់ចាប់តាំងពីឆ្នាំ ១៩២៣ និងរលកទីពីរនៃអតិផរណាបន្ទាប់ ពីសង្គ្រាមលោកលើកទី២។ អាទិភាពក៏ឆ្លុះបញ្ចាំងពីទស្សនៈខុសៗគ្នាពីដំណើរការសេដ្ឋកិច្ច។ អាជ្ញាធររូបិយវត្ថុអ៊ឺរ៉ុបបានធ្វើសកម្មភាពដូចក្រុមសេដ្ឋវិទូខាងរូបិយវត្ថុនិយម ខណៈដែលជនជាតិអាម៉េរិកធ្វើតាមក្រុម កេនស៊ាន ទោះបីជាទាំងសងខាងមិនគាំទ្រចំពោះការដាក់ឈ្មោះក៏ដោយ។

នេះគឺជាបញ្ហាសំខាន់ ពោលគឺគោលនយោបាយពង្រីករូបិយវត្ថុបង្កើននូវការចំណាយសរុបលើទំនិញ និងសេវារបស់អ្នកប្រើប្រាស់ សហគ្រាសអាជីវកម្ម រដ្ឋាភិបាល និងជនបរទេស។ តើតម្រូវការថ្មីទាំងនេះនឹងបង្កើនលទ្ធផល និងកម្លាំងពលកម្មដែរឬទេ? ឬតើពួកគេគ្រាន់តែជំរុញឡើងថ្លៃ និងបង្កើនសន្ទុះអតិផរណាកាន់តែខ្លាំងឡើង? ក្រុមសេដ្ឋវិទូកេនស៊ានអះអាងថាចម្លើយ គឺអាស្រ័យទៅលើកាលៈទេសៈជាក់ស្តែង។ កម្លាំងពលកម្មពេញលេញមានន័យថាមនុស្សគ្រប់រូប (ការផ្តល់លទ្ធភាពដល់អ្នកដែលកំពុងស្វែងរកការងារ) ដែលមានផលិតភាពគ្រប់គ្រាន់នឹងទទួលបានប្រាក់ឈ្នួលដែលមានពិត

ប្រាកដ ហើយចង់បានការងារនៅកម្រិតប្រាក់ឈ្នួលនោះ នឹងត្រូវបានទទួលឱ្យធ្វើការ។ ក្នុងកាល:-ទេស:ទាំងនេះ ការចំណាយកាន់តែច្រើននឹងនាំមកនូវអតិផរណា។ ទោះយ៉ាងណា ជារឿយៗអ្នកដែលមានទាំងសមត្ថភាពនិងឆន្ទ:ធ្វើការនឹងត្រូវបង្ខំឱ្យគ្មានការងារធ្វើ។ មិនមានតម្រូវការចំពោះផលិតផលដែលពួកគេនឹងផលិតនោះទេ។ ដោយការចំណាយកាន់តែច្រើន នឹងជំរុញឱ្យពួកគេធ្វើការ។ ការប្រកួតប្រជែងពីសំណាក់ក្រុមហ៊ុនសហគ្រាសដែលមានសមត្ថភាពលើសលុប និងពីអ្នកធ្វើការដែលនៅទំនេរនឹងក្សាការចំណាយបន្ថែមឱ្យរួចផុតពីអតិផរណាដែលកំពុងចេញផ្កាភ្លើង។

ក្រុមសេដ្ឋវិទូខាងរូបិយវត្ថុនិយមឆ្លើយថាជាធម្មតា ដំណោះស្រាយចំពោះការផ្តត់ផ្តង់លើសនៅលើទីផ្សារគឺការកាត់បន្ថយតម្លៃ។ ប្រសិនបើប្រាក់ឈ្នួលមិនត្រូវបានកែសម្រួលស្របទៅនឹងភាពអត់ការងារធ្វើនោះទាំងបទប្បញ្ញត្តិរបស់រដ្ឋាភិបាល និងខាងសហជីព នឹងធ្វើឱ្យប្រាក់ឈ្នួលឡើងកាន់ខ្ពស់តែសំបកក្រៅ ឬអ្នកដែលគ្មានការងារងាកទៅរកការកម្សាន្ត និង/ឬសំណងសម្រាប់ភាពអត់ការងារធ្វើនៅកម្រិតប្រាក់ឈ្នួលធម្មតា។ ទោះបីជាតាមវិធីណាក៏ដោយ ក៏បញ្ហាមិនអាចដោះស្រាយបានតាមគោលនយោបាយរូបិយវត្ថុដែរ។ ការបង្កើនការចំណាយថ្មីបន្ថែមនឹងគ្មានប្រយោជន៍ទេ និងនាំឱ្យមានអតិផរណា។

ផ្អែកតាមបទពិសោធន៍ជាក់ស្តែងនៅពេលមានមហាវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ និងនៅពេលមានវិបត្តិសេដ្ឋកិច្ចជាបន្តបន្ទាប់ បានបង្ហាញថាការកែសម្រួលប្រាក់ឈ្នួល និងការបន្ថយតម្លៃមិនអាចបញ្ចៀសនូវការខូចខាតចំពោះទិន្នផល និងកម្លាំងពលកម្មបានទេ។ [កំណត់សម្គាល់និពន្ធនាយក៖ សម្រាប់ ទស្សន:មួយទៀត សូមមើលផ្នែកមហាវិបត្តិសេដ្ឋកិច្ច]។

យោងតាមខ្សែកោងដ៏ល្បីរបស់ A. W. Phillips (សូមមើលខ្សែកោង PHILLIPS) បានបង្ហាញថា ប្រាក់ឈ្នួលអំឡុងពេលអតិផរណាមានភាពខុសគ្នាផ្ទុយស្រឡះនឹងភាពអត់ការងារធ្វើ។ ក្រុមសេដ្ឋវិទូបែប កេនស៊ាន មានការប៉ុនប៉ងបកស្រាយថា វាជាគោលនយោបាយដោះដូរ៖ កាត់បន្ថយភាពអត់ការងារ ជំរុញឱ្យកើតមានអតិផរណាយ៉ាងជាក់ច្បាស់។ MILTON FRIEDMAN បានបញ្ចុះបញ្ចូលអ្នកមានជំនាញផ្នែកសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៦៨ ដោយលើកឡើងថា ប្រសិនបើគោលនយោបាយរូបិយវត្ថុព្យាយាមកាត់បន្ថយអត្រាគ្មានការងារធ្វើឱ្យធ្លាក់ចុះក្រោម "អត្រាគ្មានការងារធ្វើទូទៅ" (អត្រាដែលឆ្លើយតបនឹង "កម្លាំងពលកម្មពេញលេញ" របស់ Keynes) នោះវានឹងជួយជំរុញអត្រាអតិផរណាឱ្យផ្ទុះឡើង។ លោក Friedman បានការសន្និដ្ឋានបន្ថែមទៀត ថាគោលនយោបាយរូបិយវត្ថុមិនគួរយកចិត្តទុកដាក់លើភាពគ្មានការងារធ្វើតែមួយនោះទេ ពុំដូច្នោះទេផលិតកម្ម ឬកត្តាអថេរពិតផ្សេងទៀតនឹងមានឥទ្ធិពលខ្លាំង។ ប៉ុន្តែនៅក្នុងស្ថានភាពនៃការធ្លាក់ចុះសេដ្ឋកិច្ចចំពោះក្រុមកេនស៊ាន ផ្អែកតាមបទពិសោធរបស់ អាមេរិកថ្មីៗនេះបានបញ្ជាក់បន្ថែមថា ការពង្រីកតម្រូវការបន្ថែមអាចធ្វើឱ្យប្រសើរឡើងនូវលទ្ធផលម៉ាក្រូសេដ្ឋកិច្ចពិតដោយមិនបង្កើនតម្លៃ។

យុទ្ធសាស្ត្រ៖

នៅចំណុចនេះដែរ ភាពចម្រូងចម្រាសរវាងក្រុមផ្នែករូបិយវត្ថុនិយម និងក្រុមកេនស៊ានត្រូវបានបង្ហាញ នៅក្នុងគោលនយោបាយបម្រុងសហព័ន្ធ និងរបស់ធនាគារ Bundesbank ក្នុងអំឡុងទសវត្សរ៍

ឆ្នាំ១៩៨០។ បញ្ហាគឺថា តើអ្នកធ្វើគោលនយោបាយគួរឆ្លើយតបយ៉ាងដូចម្តេចចំពោះការងាកចេញពីគោលជៅដែលពួកគេបានសង្កេត និងរំពឹងទុក? Friedman ចង់ឱ្យពួកគេធ្វើតាមទម្លាប់ដដែលដោយមិនគិតពីបរិយាកាសសេដ្ឋកិច្ច ដោយបង្កើនការផ្គង់ផ្គត់រូបិយវត្ថុក្នុងអត្រាថេរ។ តាមទស្សនៈរបស់គាត់យល់ឃើញថាការព្យាយាមទស្សន៍ទាយសេដ្ឋកិច្ចជ្រុលខ្លាំងពេលជាធម្មតាធ្វើឱ្យមានការប្រែប្រួលកាន់តែអាក្រក់ឡើង។

ទោះបីជាមិនមានក្រុមរូបិយវត្ថុនិយមទាំងអស់គាំទ្រច្បាប់របស់លោក Friedman យ៉ាងណាក៏ដោយ ក៏ពួកគេសង្កត់ធ្ងន់លើសារសំខាន់នៃច្បាប់ផ្សព្វផ្សាយនេះដែលអនុញ្ញាតឱ្យសាធារណជនអាចព្យាករណ៍ពីឥរិយាបថរបស់ធនាគារកណ្តាល។ ជាគោលការណ៍ ច្បាប់ផ្សព្វផ្សាយនេះមិនគួរជាឧបសគ្គរារាំងអ្នកធ្វើគោលនយោបាយមិនឱ្យមើលឃើញពីកាលៈទេសៈប្រែប្រួលនោះទេ។ ពួកគេអាចបញ្ជាក់ជាមុននូវការឆ្លើយតបរបស់ពួកគេចំពោះព័ត៌មានត្រឡប់។ ប៉ុន្តែវាមិនអាចទៅរួចទេក្នុងការព្យាករណ៍ដឹងជាមុនគ្រប់ហេតុការណ៍ទាំងអស់។ គ្មានធនាគារកណ្តាលណាអាចព្យាករណ៍ដឹងជាមុនអំពីវិបត្តិសេដ្ឋកិច្ចរបស់អង្គការ OPEC ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ នោះទេ ហើយក៏បានសម្រេចឆ្លើយតបជាមុនដែរ។ ច្បាប់អនុវត្តចាំបាច់ត្រូវមានលក្ខណៈសាមញ្ញ។ ប្រតិកម្មគោលនយោបាយណាមួយ ដូចជាការកែតម្រូវរបស់សហព័ន្ធ បន្ទាប់ពីឆ្នាំ ១៩៨២ ត្រូវអនុញ្ញាតឱ្យឆន្ទានុសិទ្ធិ។

ទំនាក់ទំនងជាមួយគោលនយោបាយសារពើពន្ធ

តាមទស្សនៈរបស់ក្រុមរូបិយវត្ថុនិយម បានបង្ហាញថា ថវិការបស់រដ្ឋាភិបាលមានផលប៉ះពាល់ដ៏សំខាន់ក្នុងការគាំទ្រការផ្គត់ផ្គង់ទាំងល្អ និងអាក្រក់ ប៉ុន្តែមិនមានតួនាទីទ្រទ្រង់តម្រូវការទេ ដរាបណាវាជំរុញឱ្យមានការកែប្រែគោលនយោបាយរូបិយវត្ថុ។ ផ្អែកតាមទ្រឹស្តីរបស់កេនស៊ាន បានលើកឡើងថាគោលនយោបាយហិរញ្ញវត្ថុគឺជាឧបករណ៍ពិសេសមួយដែលទ្រទ្រង់នូវតម្រូវការ។ រដ្ឋាភិបាលមានឥទ្ធិពលមកលើតម្រូវការសរុបដោយផ្ទាល់តាមរយៈការចំណាយផ្ទាល់ខ្លួន និងដោយប្រយោលតាមរយៈពន្ធរបស់ខ្លួន។ មុនឆ្នាំ ១៩៨១ បណ្តាប្រធានាធិបតី និងសភាបានពិចារណាអំពីផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួនក្នុងការធ្វើផែនការថវិកាប្រចាំឆ្នាំ។ ក្នុងឆ្នាំ ១៩៨០ ការធ្វើផែនការថវិកាមានការយឺតយ៉ាវ និងពិបាក ហើយដោយការផ្ទុះឡើងនូវឱនភាព និងបំណុលបានធ្វើឱ្យគោលនយោបាយសារពើពន្ធប្រឆាំងនឹងវដ្តសេដ្ឋកិច្ចជួបនូវបញ្ហាកាន់តែពិបាកខ្លាំងឡើង។ ចាប់តាំងពីពេលនោះមក បន្ទុកគោលនយោបាយរក្សាស្ថេរភាពបានធ្លាក់ចុះ ស្ទើរតែទាំងស្រុងមកលើគោលនយោបាយរូបិយវត្ថុ។ មានករណីលើកលែងដ៏សំខាន់មួយ មិនថាដោយចេតនា ឬអត់ គឺការកំណត់ពេលវេលាក្នុងការកាត់បន្ថយពន្ធរបស់លោកប្រធានាធិបតី George W. Bush ដែលជាធាតុដ៏សំខាន់មួយនៃគោលនយោបាយសារពើពន្ធរបស់សកម្មជនបន្ទាប់ពីឆ្នាំ ២០០១។

គោលនយោបាយរូបិយវត្ថុ និងសារពើពន្ធមានភាពខុសគ្នាតែនៅក្នុងប្រទេសដែលមានការអភិវឌ្ឍផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះដែលរដ្ឋាភិបាលមិនចាំបាច់ស្តារឱនភាពថវិកាដោយការបោះពុម្ពក្រដាសប្រាក់នោះទេ ប៉ុន្តែអាចលក់កាតព្វកិច្ចទូទាត់នាពេលអនាគត ដូចជាបណ្ណរតនាគារ ក្រដាសប្រាក់ និងសញ្ញាបណ្ណ។ នៅសហរដ្ឋអាមេរិក សភា និងប្រធានាធិបតីជាអ្នកសម្រេចលើកម្មវិធីចំណាយ និងក្រមសារពើ

ពន្ធ ហើយអាស្រ័យលើស្ថានភាពសេដ្ឋកិច្ច ឬលើឱនភាព (ឬអតិរេកថវិកា) ។ ឱនភាព (ឬអតិរេក) នេះ បូកបន្ថែម (ឬដកចេញ) បំណុលសហព័ន្ធបង្គរដែលបានពីថវិកាកន្លងមក។ ប្រព័ន្ធបម្រុងសហព័ន្ធសម្រេចថាតើបំណុល "ជាប្រាក់" មានប៉ុន្មានក្នុងទម្រង់ជារូបិយបណ្ណ ឬតម្លៃសមមូល។ អ្វីផ្សេងទៀតរួមមានមូលបត្ររតនាគារ ដែលគិតការប្រាក់។ ការសម្រេចរបស់ធនាគារកណ្តាលទាំងនោះគឺជាធាតុដ៏សំខាន់នៃគោលនយោបាយរូបិយវត្ថុ។

យន្តការនៃគោលនយោបាយរូបិយវត្ថុ

ធនាគារកណ្តាលគឺជា "បណ្តុំធនាគារ" ។ អតិថិជនរបស់ធនាគារបម្រុងសហព័ន្ធទាំង ១២ មិនមែនជាពលរដ្ឋសាមញ្ញទេ ប៉ុន្តែជា "បណ្តុំធនាគារ" ដែលរួមបញ្ចូលគ្នាបង្កើតបានជាស្ថាប័នទទួលប្រាក់បញ្ញើ - ធនាគារពាណិជ្ជ ធនាគារសន្សំ សមាគមសន្សំ និងឥណទាន និងសហជីពឥណទាន។ ពួកគេមានសិទ្ធិ កាន់កាប់ប្រាក់បញ្ញើ និងខ្ចីប្រាក់ពីធនាគារបម្រុងសហព័ន្ធ ហើយត្រូវគោរពតាមលក្ខខណ្ឌ ធនបម្រុងរបស់សហព័ន្ធ និងបទប្បញ្ញត្តិផ្សេងទៀត។

នៅដំណាច់ឆ្នាំ ២០០៣ បំណុលរដ្ឋសហព័ន្ធមានចំនួន ៧.០០១ ប៊ីលានដុល្លារដែលក្នុងនោះមានតែ ១១ ភាគរយ ឬ ៧៥៣ ប៊ីលានដុល្លារប៉ុណ្ណោះដែលមានតម្លៃជាប្រាក់។ ពោលគឺធនាគារបម្រុងសហព័ន្ធជាម្ចាស់បណ្តឹងទាមទារប្រាក់ចំនួន ៧៥៣ ប៊ីលានដុល្លារអាមេរិកចំពោះបំណុលដែលពួកគេមានជារូបិយបណ្ណ (ក្រដាសប្រាក់របស់ធនាគារបម្រុងសហព័ន្ធ) ឬប្រាក់បញ្ញើដែលអាចប្តូរទៅជារូបិយប័ណ្ណបានតាមការទាមទារ។ រូបិយបណ្ណសរុបដែលកំពុងធ្វើចរាចរណ៍សាធារណៈនៅខាងក្រៅធនាគារមានចំនួន ៦៦៤ ប៊ីលាន ដុល្លារនៅដំណាច់ឆ្នាំ ២០០៣។ ប្រាក់បម្រុងរបស់ធនាគារ ពោលគឺរូបិយបណ្ណជាប្រាក់របស់ពួកគេបូកនឹង ប្រាក់បញ្ញើរបស់ពួកគេនៅសហព័ន្ធមានចំនួន ៨៩ ប៊ីលានដុល្លារ។ ទាំងពីររួមគ្នាបង្កើតបានមូលដ្ឋានរូបិយវត្ថុ (M0ឬMB) ស្មើនឹង ៧៥៣ ប៊ីលានដុល្លារនៅដំណាច់ឆ្នាំឆ្នាំ ២០០៣។

ធនាគារតម្រូវឱ្យកាន់កាប់ធនបម្រុង យ៉ាងហោចណាស់ស្មើនឹងចំនួនភាគរយដែលបានកំណត់លើប្រាក់បញ្ញើដកជា មូលប្បទានបត្របាន។ ការអនុលោមតាមលក្ខណ្ឌត្រូវបានធ្វើតេស្តត្រួតពិនិត្យជាទៀងទាត់ រៀងរាល់ពីរសប្តាហ៍ម្តងសម្រាប់ធនាគារ ដែលមានចំនួនប្រាក់បញ្ញើច្រើន។ ការធ្វើតេស្តត្រួតពិនិត្យធនបម្រុង គឺជាផ្នែកមួយនៃគោលនយោបាយរូបិយវត្ថុ។ ធនាគារត្រូវការ "មូលនិធិសហព័ន្ធ" (រូបិយបណ្ណ ឬប្រាក់បញ្ញើនៅធនាគារបម្រុងសហព័ន្ធ) ដើម្បីជាប់តេស្តត្រួតពិនិត្យធនបម្រុង ហើយសហព័ន្ធគ្រប់គ្រងលើការផ្គត់ផ្គង់។ នៅពេលដែលសហព័ន្ធទិញមូលបត្រពីធនាគារ ឬអ្នកជាក់ប្រាក់បញ្ញើនៅសហព័ន្ធដោយប្រើមូលដ្ឋានរូបិយវត្ថុ នោះធនាគារទទួលបានសមតុល្យបម្រុង។ ដូចគ្នាដែរ សហព័ន្ធបំបាត់តុល្យភាពបម្រុងដោយការលក់មូលបត្ររតនាគារ។ ទាំងនេះ គឺជាប្រតិបត្តិការទីផ្សារបើកចំហដែលជាមុខងារចម្បងនៃប្រតិបត្តិការគោលនយោបាយរូបិយវត្ថុ។ ប្រតិបត្តិការទាំងនេះត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការទីផ្សារបើកចំហសហព័ន្ធ (FOMC) ដែលជាស្ថាប័នមេរៀបចំគោល នយោបាយរបស់សហព័ន្ធ។

ធនាគារដែលមានតម្រូវការទុនបម្រុងអាចខ្ចីសមតុល្យបម្រុងលើប្រាក់បញ្ញើនៅសហព័ន្ធពីធនាគារផ្សេងទៀតបាន។ ប្រាក់កម្ចីធ្វើឡើងមួយថ្ងៃម្តងនៅក្នុងទីផ្សារ "មូលនិធិសហព័ន្ធ" ។ អត្រាការប្រាក់លើប្រាក់កម្ចី ទាំងនេះត្រូវបានស្រង់ជាបន្តបន្ទាប់។ ប្រតិបត្តិការទីផ្សារបើកចំហរបស់ធនាគារកណ្តាលគឺជាការអន្តរាគមន៍នៅក្នុងទីផ្សារនេះ។ នៅពេលដែលធនាគារបម្រុងសហព័ន្ធ (ឬធនាគារកណ្តាលផ្សេងទៀត) ធ្វើប្រតិបត្តិការទីផ្សារបើកចំហជាធម្មតា ធនាគារទិញបណ្ណរតនាគារដោយទូទាត់ជាមួយប្រាក់បម្រុង ឬលក់ចេញវិញដោយយកប្រាក់បម្រុងមកទូទាត់។ ដូច្នេះ ប្រតិបត្តិការទីផ្សារបើកចំហគឺជាអន្តរា-គមន៍មួយនៅក្នុងទីផ្សារមូលនិធិសហព័ន្ធ។ ធនាគារក៏អាចខ្ចីប្រាក់ពីធនាគារបម្រុងសហព័ន្ធក្នុងអត្រាអប្បហារដែលបានប្រកាសដោយធនាគារបម្រុង ដែលជាក់ស្តែងត្រូវបានអនុវត្តនៅទូទាំងធនាគារទាំង ១២ ។ ការកំណត់អត្រាអប្បហារនេះគឺជាឧបករណ៍មួយផ្សេងទៀតនៃគោលនយោបាយរបស់ធនាគារកណ្តាល។ សព្វថ្ងៃ វាចំណុះឱ្យប្រតិបត្តិការទីផ្សារបើកចំហ ហើយជាទូទៅធនាគារកណ្តាលរក្សាអត្រាអប្បហារឱ្យនៅត្រឹមជិតអត្រាទីផ្សារមូលនិធិសហព័ន្ធ។ ទោះយ៉ាងណា ការប្រកាសអត្រាអប្បហារថ្មីជារឿយៗគឺជាមធ្យោបាយងាយស្រួលក្នុង ការបញ្ជូនសារទៅទីផ្សាររូបិយវត្ថុ។ ក្រៅពីទំនួលខុសត្រូវរបស់ខ្លួនក្នុងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារកណ្តាលមានតួនាទីជាបណ្តាញសុវត្ថិភាពបែបប្រពៃណីក្នុងការផ្តល់ជំនួយបណ្តោះអាសន្នដល់ធនាគារនីមួយៗ និងក្នុងការការពារ ឬទប់ស្កាត់ភាពមិនប្រក្រតីនៃប្រព័ន្ធដែលជាអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ។

យុទ្ធវិធី៖ នីតិវិធីប្រតិបត្តិការ

តាមរយៈប្រតិបត្តិការទីផ្សារបើកចំហ FOMC អាចកំណត់អត្រាគោលដៅនៃមូលនិធិសហព័ន្ធ និងណែនាំផ្នែកពាណិជ្ជកម្មរបស់ខ្លួននៅធនាគារបម្រុងសហព័ន្ធញ៉ាំញីឱ្យឈានចូលទីផ្សារតាមភាពចាំបាច់ ដើម្បីរក្សាអត្រាមូលនិធិតាមគោលដៅ។ គោលដៅផ្ទាល់គឺមានលក្ខណៈបណ្តោះអាសន្ន។ FOMC ធ្វើការពិនិត្យពិចារណាឡើងវិញរៀងរាល់ប្រាំមួយសប្តាហ៍ម្តង ឬក្នុងពេលប្រជុំជាទៀងទាត់ ឬឆាប់ជាងនេះ ប្រសិនបើមានបញ្ហាផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកើតឡើងគួរឱ្យកត់សម្គាល់។

នីតិវិធីប្រតិបត្តិការមានជម្រើសកំណត់ពីបរិមាណមូលនិធិដែលអនុញ្ញាតឱ្យទីផ្សារដំណើរការរក្សាអត្រាការប្រាក់មូលនិធិនៅកម្រិតណាមួយដែលតម្រូវការរបស់ធនាគារស្មើនឹងបរិមាណនោះ។ ជាក់ស្តែង ក្នុងអំឡុងឆ្នាំ ១៩៧៩-១៩៨២ ធនាគារកណ្តាលបានប្រកាន់ការអនុវត្តបែបនេះដើម្បីឆ្លើយតបទៅនឹងការអះអាងរបស់ក្រុមរូបិយវត្ថុនិយមដែលលើកឡើងថាធនាគារកណ្តាលមានភាពយឺតយ៉ាវក្នុងការដំឡើងអត្រាការប្រាក់ដែលកំពុងតែមានការកើនឡើងក្នុងការត្រួតពិនិត្យកំណើនរូបិយវត្ថុ និងអតិផ-រណា។ នៅក្នុងរបបនេះ អត្រាការប្រាក់មានការប្រែប្រួលយ៉ាងខ្លាំងជាងរបបកំណត់អត្រាការប្រាក់គោលដៅ។

តើការគ្រប់គ្រងលើទីផ្សាររូបិយវត្ថុរបស់សហព័ន្ធបានបញ្ជូនសារទៅកាន់ទីផ្សារហិរញ្ញវត្ថុផ្សេងទៀត និងសេដ្ឋកិច្ចយ៉ាងដូចម្តេច? តើវាជះឥទ្ធិពលយ៉ាងណាមកលើការចំណាយលើទំនិញ និងសេវា? ចំពោះធនាគារ អត្រាទីផ្សាររូបិយវត្ថុ គឺជាបន្ទុកមូលនិធិដែលពួកគេអាចផ្តល់ប្រាក់កម្ចីដល់អតិថិជនរបស់ខ្លួន ឬវិនិយោគលើមូលបត្រ។ នៅពេលដែលការចំណាយទាំងនេះកើនឡើងធនាគារនឹង

បង្កើន អត្រាការប្រាក់កម្ចីរបស់ខ្លួន ហើយមានជម្រើសកាន់តែច្រើនក្នុងការជំរុញឥណទាន។ អតិថិជនរបស់ពួកគេខ្វីប្រាក់ និងចំណាយតិច។ ផលប៉ះពាល់មានការីកភាលដាលដែលប៉ះពាល់ដល់អាជីវកម្មដែលពឹងផ្អែកលើប្រាក់កម្ចីពាណិជ្ជកម្មដើម្បី ផ្តល់ហិរញ្ញប្បទានសន្និធិ ក៏ដូចជាអ្នកអភិវឌ្ឍន៍ដែលកំពុងស្វែងរកឥណទានសម្រាប់មជ្ឈមណ្ឌលផ្សារទំនើប អគារការិយាល័យ និងអគារលំនៅឋាន អ្នកទិញផ្ទះដែលត្រូវការប្រាក់កម្ចីទិញផ្ទះ អតិថិជនទិញរថយន្ត និងគ្រឿងសម្ភារៈប្រើប្រាស់ ម្ចាស់បណ្ណឥណទាន និងសាលាក្រុងដែលកំពុងសាងសង់សាលារៀន និងបណ្តាញលូបង្ហូរ។

ធនាគារប្រកួតប្រជែងដណ្តើមគ្នាទាំងលើប្រាក់កម្ចី និងប្រាក់បញ្ញើ។ មុនឆ្នាំ ១៩៨០ កម្រិតអតិ-បរមាស្របច្បាប់នៃការប្រាក់លើប្រាក់បញ្ញើ បានដាក់កំហិតលើការប្រកួតប្រជែងដណ្តើមប្រាក់បញ្ញើ ប៉ុន្តែឥឡូវនេះ អត្រាការប្រាក់លើវិញ្ញាបនបត្រប្រាក់បញ្ញើ គណនីសញ្ចុយ ក៏ដូចជាលើប្រាក់បញ្ញើដែលអាចដកជាមូលប្បទានបត្របានមិនត្រូវបានកំណត់ទេ។ ដោយសារតែលម្អៀង ប្រាក់ចំណេញរបស់ធនាគារពឹងផ្អែកលើលម្អៀង ការប្រាក់ដែលពួកគេរកបានពីប្រាក់កម្ចី និងទ្រព្យសម្បត្តិផ្សេងទៀត និងអ្វីដែលពួកគេទូទាត់លើប្រាក់បញ្ញើ ធាតុទាំងពីរនេះត្រូវដើរទន្ទឹមគ្នា។

ធនាគារប្រកួតប្រជែងជាមួយស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត និងជាមួយទីផ្សារហិរញ្ញវត្ថុបើកចំហរ។ ក្រុមហ៊ុនសាជីវកម្មមិនត្រឹមតែខ្វីប្រាក់ពីធនាគារប៉ុណ្ណោះទេ ប៉ុន្តែក៏ខ្វីពីអន្តរការីហិរញ្ញវត្ថុផ្សេងទៀតផងដែរ ដូចជា ក្រុមហ៊ុនធានារ៉ាប់រង មូលនិធិសោធន និងក្រុមហ៊ុនវិនិយោគ។ ពួកគេលក់សញ្ញាបណ្ណហ៊ុន និងក្រដាសអាចដួញដូរបាននៅលើទីផ្សារបើកចំហដែលអ្នកទិញរួមមានរូបវន្តបុគ្គល ស្ថាប័នមិនស្វែងរកប្រាក់ចំណេញ និងមូលនិធិសង្គហៈ ក៏ដូចជាធនាគារ។ គ្រួសារ និងសហគ្រាសអាជីវកម្មធ្វើការប្រៀបធៀបរវាងផលចំណេញ និងគុណប្រយោជន៍នៃប្រាក់បញ្ញើនៅធនាគារជាមួយនឹងមូលនិធិទីផ្សាររូបិយវត្ថុ មូលនិធិសង្គហៈផ្សេងទៀត មូលបត្រទីផ្សារបើកចំហ និងទ្រព្យសម្បត្តិផ្សេងទៀត។

ដោយសហព័ន្ធគ្រប់គ្រងលើទីផ្សាររូបិយវត្ថុ និងធនាគារ វាមានឥទ្ធិពលលើអត្រាការប្រាក់ តម្លៃទ្រព្យសម្បត្តិ និងលំហូរឥណទាននៅទូទាំងប្រព័ន្ធហិរញ្ញវត្ថុ។ ការដណ្តើម និងការប្រកួតប្រជែងគ្នាធ្វើឱ្យមានការកើនឡើង ឬថយចុះនូវអត្រាការប្រាក់ក្រោមការគ្រប់គ្រងផ្ទាល់របស់សហព័ន្ធ រីករាលដាលទៅដល់ទីផ្សារផ្សេងទៀត។ សូម្បីតែតម្លៃហ៊ុនក៏ងាយនឹងប្រែប្រួលដែរ គឺធ្លាក់ចុះនៅពេលបរិមាណសញ្ញាបណ្ណកើនឡើង និងកើនឡើងនៅពេលបរិមាណធ្លាក់ចុះ។

សហព័ន្ធមិនសូវតឹងតែងក្នុងការគ្រប់គ្រងលើបរិមាណសញ្ញាបណ្ណ និងអត្រាការប្រាក់រយៈពេលវែងផ្សេងទៀតដូចលើទីផ្សាររូបិយវត្ថុ និងអត្រាការប្រាក់រយៈពេលខ្លីទេ។ អត្រាការប្រាក់រយៈពេលវែង ពឹងផ្អែកយ៉ាងខ្លាំងទៅលើការរំពឹងទុកនៃអត្រារយៈពេលខ្លីនាពេលអនាគត និងផ្អែកលើការរំពឹងទុកនៃគោលនយោបាយរបស់សហព័ន្ធនាពេលអនាគត។ ឧទាហរណ៍ ការរំពឹងខ្ពស់នៃអតិផរណានាពេលអនាគត ឬឱនភាពថវិកាសហព័ន្ធខ្ពស់នឹងនាំឱ្យអត្រារយៈពេលវែងកើនឡើងបើធៀបនឹងអត្រារយៈពេលខ្លី ព្រោះសហព័ន្ធបានរំពឹងទុកថាខ្លួននឹងតឹងតែងគោលនយោបាយរូបិយវត្ថុក្នុងកាលៈទេសៈទាំងនោះ។ យន្តការមួយទៀត ការបញ្ជូនសារគោលនយោបាយរូបិយវត្ថុជុំវិញតម្រូវការទំនិញ និងសេវា គឺកាន់តែមានសារសំខាន់ឡើងបន្ទាប់ពីឆ្នាំ១៩៧៣។ ចាប់តាំងពីឆ្នាំ ១៩៧៣ ត្រូវបានអនុញ្ញាតឱ្យមាន

អត្រាប្តូររូបិយបណ្ណអណ្តែត ហើយឧបសគ្គចំពោះចលនាមូលនិធិជាអន្តរជាតិបានបាត់បង់ជាបណ្តើរៗ ។ ការកើនឡើងនូវអត្រាការប្រាក់របស់អាមេរិកធៀបនឹងអត្រាការប្រាក់នៅទីក្រុងតូក្យូទីក្រុងឡុងដ៍ និងហ្វ្រែងហ្វើតបានទាក់ទាញមូលនិធិដោយបង្វែរទៅជាទ្រព្យសកម្មប្រាក់ដុល្លារ និងបង្កើនតម្លៃប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េន ផោន ស្វ៊ែរលីង និងប្រាក់ម៉ាក។ ទំនិញអាមេរិកមានតម្លៃកាន់តែថ្លៃជាងទំនិញបរទេសចំពោះអ្នកទិញទាំងក្នុង និងក្រៅប្រទេស។ ការធ្លាក់ចុះនូវការនាំចេញ និងការកើនឡើងនូវការនាំចូលធ្វើឱ្យតម្រូវ ការសរុប ចំពោះផលិតកម្មក្នុងស្រុកមានការធ្លាក់ចុះ។ អត្រាការប្រាក់ខ្ពស់ និងហាងឆេងប្តូរប្រាក់បានបង្កើតឱ្យមានឱនភាពពាណិជ្ជកម្មសហរដ្ឋអាមេរិកជាលក្ខណៈទ្រង់ទ្រាយធំ ដោយឥតងាករេក្នុងអំឡុងឆ្នាំ ១៩៨១-១៩៨៥ ។ ចាប់តាំងពីឆ្នាំ ១៩៨៥ ដោយសារអត្ថប្រយោជន៍ពីការប្រាក់នៃទ្រព្យសម្បត្តិជាប្រាក់ដុល្លារបានធ្លាក់ចុះ ឬមានដំណើរថយក្រោយ រូបិយបណ្ណដុល្លារក៏បានធ្លាក់ចុះ ហើយឱនភាពពាណិជ្ជកម្មសហរដ្ឋអាមេរិក បានធ្លាក់ចុះបន្តិចម្តងៗ។ លំនាំស្រដៀងគ្នានេះបានកើតឡើងក្នុងចន្លោះឆ្នាំ ១៩៩៥ និង ២០០២ ដោយសារមានការប្រែប្រួល ឡើងចុះនៃអត្រាប្តូរប្រាក់ ហើយឱនភាពពាណិជ្ជកម្មកាន់តែរីកធំឡើងៗនូវសមាមាត្រនៃផលិតផលសរុបក្នុងស្រុករហូតលើសពី ៥០ ភាគរយបើប្រៀបធៀបនឹងអំឡុងឆ្នាំ ១៩៨០។ គិតរហូតត្រឹមដំណាច់ឆ្នាំ ២០០៤ ការលែស់រូបិយបណ្ណដុល្លារយៈពេល ២ឆ្នាំ មិនទាន់បានកាត់បន្ថយឱនភាពពាណិជ្ជកម្មនៅឡើយទេ។

<u>គោលដៅ៖ លទ្ធផលរូបិយវត្ថុសរុប ឬលទ្ធផលម៉ាក្រូសេដ្ឋកិច្ច ?</u>

មនុស្សរក្សាទុករូបិយបណ្ណដុល្លារ ព្រោះវាជាមធ្យោបាយទូទាត់ក្នុងប្រតិបត្តិការជាច្រើន។ ប៉ុន្តែប្រាក់បញ្ញើ ដែលអាចដកជាមូលប្បទានបត្របានជាធម្មតាមានភាពងាយស្រួលជាង។ វាមិនកំណត់ចំពោះប្រភេទរូបិយបណ្ណជាក់លាក់ណាមួយទេ មិនបាត់បង់ ឬមិនមានចោរលួច ទទួលបានការទូទាត់ការប្រាក់ និងបង្កើតកំណត់ត្រាផ្សេងទៀតដែលយើងភាគច្រើនយល់ថាមានប្រយោជន៍។

ការប្រើប្រាស់ប្រាក់បញ្ញើ ជារូបិយវត្ថុមានឥទ្ធិពលយ៉ាងខ្លាំងទៅលើមូលដ្ឋានរូបិយវត្ថុ។ ប្រាក់បម្រុងធនាគារចំនួន ៨៩ ប៊ីលានដុល្លារនៅដំណាច់ឆ្នាំ ២០០៣ បានរួមចំណែកប្រហែល ៦២៩ ប៊ីលានដុល្លារជាប្រាក់បញ្ញើដែលអាចដកជាមូលប្បទានបត្របាន។ (ទ្រព្យសកម្មចំនួន ៥៧២ ប៊ីលានដុល្លារ ផ្សេងទៀត ដែលបានពីប្រាក់បញ្ញើទាំងនោះគឺជាប្រាក់កម្ចី និងការវិនិយោគរបស់ធនាគារ។ ក្នុងន័យនេះ ធនាគារមានបំណុល "ជាប្រាក់" គ្រប់ប្រភេទ)។ ប្រាក់បញ្ញើទាំងនេះបូកនឹងប្រាក់ចំនួន ៦៦៤ ប៊ីលានដុ ល្លារជារូបិយ បណ្ណកំពុងចរាចរណ៍ផ្តល់នូវស្តុករូបិយវត្ថុប្រតិបត្តិការ (M1) ចំនួន ១.១៩៣ ប៊ីលានដុល្លារ។ ប៉ុន្តែប្រាក់ បញ្ញើមានកាលកំណត់ និងវិញ្ញាបនបត្រប្រាក់បញ្ញើទោះបីជាមិនអាចដកជាមូលប្បទានបានក៏ដោយ គឺជាមធ្យោបាយដ៏ងួសឱ្យប្រាក់បញ្ញើប្រតិបត្តិការជាច្រើន។ ចំណែកមូលនិធិ ទីផ្សាររូបិយវត្ថុ និងទ្រព្យសកម្ម ផ្សេងទៀតដែលនៅក្រៅរង្វង់ធនាគារទាំងអស់ក៏ដូចគ្នាដែរ។ ដូច្នេះ សហព័ន្ធរក្សាដានទម្រង់ផ្សេងៗនៃរូបិយវត្ថុសរុបនីមួយៗ ដូចជា M1, M2, M3 ដែលមានលក្ខណៈរួមចម្រុះកាន់តែខ្លាំងឡើង។

ប្រតិបត្តិការទីផ្សាររបើកចំហដែលនាំឱ្យមូលដ្ឋានរូបិយវត្ថុ និងអត្រាការប្រាក់មានការប្រែប្រួលចុះឡើង ក៏ធ្វើឱ្យបរិមាណរូបិយវត្ថុ M1 និងរូបិយវត្ថុសរុបផ្សេងទៀតមានការប្រែប្រួលផងដែរ។ ប្រតិបត្តិ

ការដែលកាត់បន្ថយអត្រាមូលនិធិសហព័ន្ធ និងអត្រាការប្រាក់ដែលទាក់ទងក្នុងរយៈពេលខ្លីបំពេញបន្ថែមនូវប្រាក់បម្រុងរបស់ធនាគារក៏ដូចជាប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារផងដែរ។ នៅឆ្នាំ ២០០៣ តម្រូវការធនបម្រុងមានជាមធ្យមស្មើនឹង ១០ភាគរយនៃប្រាក់បញ្ញើដែលអាចដកជាមូលប្បទានបត្រ បាន។ ដូច្នេះ ការកើនឡើងប្រាក់មួយដុល្លារលើសមាសធាតុធនបម្រុងរបស់ធនាគារមានន័យថាមាន ការកើនឡើងប្រាក់ចំនួនដុល្លារ ១០ ដុល្លារលើសមាសធាតុប្រាក់បញ្ញើ M1 ។ ផ្ទុយទៅវិញ ការកើនឡើង ប្រាក់មួយ ដុល្លារនៅក្នុងសមាសធាតុរូបិយបណ្ណនៃមូលដ្ឋានរូបិយវត្ថុជានិច្ចកាលគឺគ្រាន់តែជាការកើនឡើងប្រាក់មួយដុល្លារអាមេរិកនៅក្នុង M1 តែប៉ុណ្ណោះ។

ប្រសិនបើមិនមានការផ្លាស់ប្តូរសមាមាត្រប្រាក់បញ្ញើធៀបនឹងរូបិយបណ្ណដែលសាធារណៈចង់បានក្នុងឆ្នាំ ២០០៣ នោះការកើនឡើងប្រាក់មួយដុល្លារលើមូលដ្ឋានរូបិយវត្ថុមានន័យថាការកើនឡើងប្រាក់ ១,៧០ ដុល្លា រក្នុងរូបិយវត្ថុ M1 ។ នេះគឺជា "មេគុណរូបិយវត្ថុ" ។ វាមិនស្ថិតស្ថេរទេ ដោយសារមូលហេតុជាច្រើន។ ពេលខ្លះ សហព័ន្ធផ្លាស់ប្តូរសមាមាត្រតម្រូវការធនបម្រុង។ ធនាគារជួនកាលមានធនបម្រុងលើស ហើយពេលខ្លះខ្ចីប្រាក់បម្រុងពីធនាគារកណ្តាល។ តម្រូវការរបស់សាធារណជនចំពោះប្រាក់កម្ចីធៀបនឹងប្រាក់ បញ្ញើមានភាពខុសគ្នាតាមរដូវកាល ជាទៀងទាត់ និងដោយចៃដន្យ។ ជាការពិត តម្រូវការរបស់សាធារណៈ ចំពោះរូបិយបណ្ណធៀបនឹងតម្រូវការប្រាក់បញ្ញើមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលដប់ប្រាំឆ្នាំ កន្លងមក។ នៅឆ្នាំ ១៩៩០ មេគុណរូបិយវត្ថុគឺ ២,៧១ ដុល្លារក្នុងប្រាក់មួយដុល្លារនៃមូលដ្ឋានរូបិយវត្ថុថ្មី។ ក្នុងឆ្នាំ ២០០៣ វាមានទំហំតូចជាង ៤០ ភាគរយ។ នេះឆ្លុះបញ្ចាំងពីការវិវត្តនៃបច្ចេកវិទ្យាប្រតិបត្តិការ និងស្ថាប័នហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យប្រជាជន និងក្រុមហ៊ុនសហគ្រាសរក្សាទុកមូលនិធិសាច់ប្រាក់ងាយស្រួលរបស់ពួកគេបានច្រើន ក្នុងទម្រង់ផ្សេងៗក្រៅពីប្រាក់កម្ចីដែលអាចដកជាមូលប្បទានបត្របាន ហើយនៅតែអាចទូទាត់វិក្កយបត្ររបស់ពួកគេយ៉ាងងាយ ស្រួល។ ដូច្នេះការគ្រប់គ្រងរូបិយវត្ថុ M1 របស់សហព័ន្ធ គឺមិនមានភាពប្រាកដប្រជាទេ ហើយការគ្រប់គ្រងរបស់សហព័ន្ធមកលើរូបិយវត្ថុសរុបលើសពីនេះនៅតែមានភាពធូរលុង។

ក្រុមរូបិយវត្ថុនិយមបានជំរុញឱ្យសហព័ន្ធត្រៀមប្រឡងប្រតិបត្តិការរបស់ខ្លួន ដើម្បីឱ្យមានកំណើន-នថេរនូវរូបិយវត្ថុសរុប M1 ឬ M2 ។ យោងតាមអាណត្តិរបស់សភាសហព័ន្ធ បានធ្វើការប្រកាសពីរដងក្នុងមួយឆ្នាំ នូវទំហំគោលដៅនៃកំណើនរូបិយវត្ថុសរុបរយៈពេលជាច្រើនត្រីមាសខាងមុខ។ នៅទសវត្សរ៍ឆ្នាំ ១៩៧០ FOMC បានព្យាយាមរក្សាឱ្យនៅចន្លោះទាំងនេះ ប៉ុន្តែជារឿយៗត្រូវបានបរាជ័យ។ ក្រុមរូបិ-យវត្ថុនិយមបានទិតៀនជាប្រចាំជាពិសេស នៅពេលកំណើនរូបិយវត្ថុលើសពីគោលដៅរបស់សហព័ន្ធ ក្នុងអំឡុងពេលមានវិបត្តិប្រេង។ នៅខែតុលា ឆ្នាំ ១៩៧៩ ប្រធានក្រុមហ៊ុន Volcker បានព្រមានដល់សាធារណជនថាសហព័ន្ធនឹងប្រកាន់ខ្ជាប់នូវការរឹតត្បិតលើគោលដៅរបស់ខ្លួនសម្រាប់រូបិយវត្ថុសរុបរហូតទាល់តែមានជ័យជំនះលើអតិផរណា។ ទោះជាយ៉ាងណា បីឆ្នាំក្រោយមក សហព័ន្ធលែងមានការយកចិត្តទុកដាក់ខ្លាំងទៅលើរូបិយវត្ថុសរុប។

រូបិយវត្ថុសរុបផ្ទាល់គឺមិនសំខាន់ទេ។ អ្វីដែលសំខាន់គឺដំណើរការម៉ាក្រូសេដ្ឋកិច្ចដូចដែលបានចង្អុលបង្ហាញដោយផលិតផលក្នុងស្រុកសរុប កម្លាំងពលកម្ម និងតម្លៃ។ គោលនយោបាយរូបិយវត្ថុ

និយម គឺផ្អែកទៅលើការភ្ជាប់យ៉ាងស្អិតរមួតរវាងស្តុករូបិយវត្ថុជាប្រាក់ដុល្លារ គឺ MI និងលំហូរនៃការចំណាយ ផលិតផលក្នុងស្រុកសរុបគិតជាដុល្លារក្នុងមួយឆ្នាំ។ ទំនាក់ទំនងរបស់វាគឺជាសន្ទុះរូបិយវត្ថុចំនួនដង ជាមធ្យមដែលប្រាក់ដុល្លារធ្វើចរាចរណ៍វិលជុំក្នុងមួយឆ្នាំ និងចំណាយលើផលិតផលក្នុងស្រុកសរុប។ តាមនិយមន័យនៃពាក្យ *សន្ទុះ* ផលិតផលក្នុងស្រុកសរុបស្មើនឹងស្តុករូបិយវត្ថុគុណនឹងសន្ទុះរបស់វា។ សន្ទុះ MI ស្មើនឹង ៨.៥ ក្នុងឆ្នាំ ២០០៣។ ប្រសិនបើអាចព្យាករណ៍បានការត្រួតពិនិត្យ MI ក៏អាចគ្រប់គ្រងផលិតផលក្នុងស្រុកគិតជាដុល្លារផងដែរ។ ប៉ុន្តែសន្ទុះ MI គឺងាយនឹងប្រែប្រួល។ នៅចន្លោះឆ្នាំ ១៩៦១ ដល់ឆ្នាំ ១៩៩០ សន្ទុះកំណើនប្រចាំឆ្នាំជាមធ្យមគឺ ២,២ ភាគរយជាមួយនឹងគម្លាតបទដ្ឋានស្មើនឹង ៣,៦ ភាគរយ។ នោះ ប្រហែលជាអាចមានឱកាសមួយក្នុងចំណោមបីដែលសន្ទុះនឹងកើនឡើងលើសពី ៥,៨ ភាគរយ ឬធ្លាក់ចុះ ជាង ១,៤ ភាគរយនៅឆ្នាំណាមួយ។ សម្រាប់អំឡុងឆ្នាំ ១៩៩១-២០០៣ កំណើនប្រចាំឆ្នាំជាមធ្យមគឺ ១,៦ ភាគរយជាមួយនឹងគម្លាតបទដ្ឋានស្មើនឹង ៥,៩ ភាគរយ។ (សន្ទុះ M2 មិនសូវមានការប្រែប្រួលទេ ប៉ុន្តែមានការគ្រប់គ្រងតិចតួចលើ M2)។

សន្ទុះជាក់ស្តែងគឺអាស្រ័យទៅលើទម្លាប់នៃការគ្រប់គ្រងប្រាក់របស់គ្រួសារ និងសហគ្រាសអាជីវកម្មនៅក្នុងសេដ្ឋកិច្ចទាំងមូល។ នៅពេលបច្ចេកវិទ្យាប្រតិបត្តិការ និងស្ថាប័នហិរញ្ញវត្ថុមានការវិវត្តហើយមានមធ្យោបាយជំនួសប្រាក់កាន់តែច្រើនឡើង នោះសន្ទុះនឹងមិនសូវមានស្ថេរភាព ហើយរូបិយវត្ថុសរុបនឹងក្លាយជាមធ្យោបាយជំនួសមួយដែលលែងមានការជឿជាក់ដូចមុនសម្រាប់ការចំណាយសរុប និងសកម្មភាពសេដ្ឋកិច្ច។ វិបត្តិសេដ្ឋកិច្ចក្នុងអំឡុងឆ្នាំ ១៩៨១-១៩៨២ គឺមានទំហំជ្រៅជ្រៅជាងអ្វីដែលសហព័ន្ធបានគ្រោងទុក ព្រោះ FOMC បានរក្សាជំហរវិងមាំចំពោះគោលដៅរូបិយវត្ថុសរុបរបស់ខ្លួន ខណៈដែលសន្ទុះបានធ្លាក់ចុះយ៉ាងឆាប់រហ័ស។

ការគណនានូវតម្រូវការសរុបជាផលនៃស្តុករូបិយវត្ថុ និងសន្ទុះរបស់វាគឺជាវិធីផ្លូវកាត់មួយដែលមិនគ្រប់គ្រាន់សម្រាប់ដំណើរការដ៏ស្មុគស្មាញដែលតាមរយៈនោះការបញ្ជូនសារគោលនយោបាយរូបិយវត្ថុត្រូវបានធ្វើឡើង ពោលគឺ តាមរយៈអត្រាការប្រាក់ធនាគារ និងទីផ្សារទ្រព្យសម្បត្តិរហូតដល់ការចំណាយលើផលិតផលក្នុងស្រុកសរុបតាមរយៈគ្រួសារ សហគ្រាសអាជីវកម្ម និងជនបរទេស។ សហព័ន្ធធ្វើបានល្អប្រើសរជាងនេះ ដោយផ្តោតការយកចិត្តទុកដាក់ដោយផ្ទាល់ទៅលើលទ្ធផលម៉ាក្រូសេដ្ឋកិច្ចដែលចង់បានជាជាងទៅលើការផ្សារភ្ជាប់ទៅនឹងគោលដៅបន្ទាប់បន្សំ។

៦.៤.៥-សសរស្តម្ភនៃគោលនយោបាយរូបិយវត្ថុ (QUOINS OF MONETARY POLICY)

ឥឡូវនេះ អ្នកនឹងបានយល់ច្បាស់អំពីខ្លឹមសារសំខាន់នៃគោលនយោបាយរូបិយវត្ថុ។ វាជាគោលនយោបាយស្តីពីការបង្កើតរូបិយវត្ថុ ជាពិសេសអត្រាកំណើននៃការបង្កើតរូបិយវត្ថុ។ គ្មានធនាគារកណ្តាលណាមួយចង់បង្កើតឱ្យមានកំណើនរូបិយវត្ថុអវិជ្ជមាននោះទេ ពីព្រោះបញ្ហានេះអាចនាំឱ្យមានបរិត្តផរណា ហើយបរិត្តផរណាមានន័យថាការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្ម ពោលគឺការធ្លាក់ចុះនូវទ្រព្យធន។ ការធ្លាក់ចុះនូវទ្រព្យធនមានន័យថាការធ្លាក់ចុះនូវការប្រើប្រាស់ និងការចំណាយវិនិយោគដែល

ជាកត្តាចលករដ៏ចម្បងនៃកំណើនសេដ្ឋកិច្ច។ ដូច្នេះ គោលនយោបាយនេះ មានគោលបំណងជានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពដែលទាមទារឱ្យមានស្ថិរភាពថ្លៃ និងអតិផរណាទាប។ ដូច្នេះ បើនិយាយពីអត្តសញ្ញាណគឺ DM x DV = DP x Deal GDP (សន្មតថា V ថេរ) DM3 មិនគួរលើសពីសមត្ថភាពពង្រីកសេដ្ឋកិច្ចក្នុងអត្រាមួយទេ ពោលគឺផលិតផលក្នុងស្រុកដុល Deal ដែលនឹងផ្តល់នូវ DP មិនលើសពីគោលដៅអតិផរណា (ករណីភាគច្រើនគឺ ២% ក្នុងមួយឆ្នាំ) ។ ដូច្នេះ ការអនុវត្តគោលនយោបាយរូបិយវត្ថុ ត្រូវរួមមានគោលដំហរមួយស្តីពីភាពបត់បែននៃការផ្គត់ផ្គង់របស់សេដ្ឋកិច្ច។

អ្នកដឹងស្រាប់ហើយថា រូបិយវត្ថុត្រូវបានបង្កើតឡើងតាមរយៈប្រាក់កម្ចីធនាគារដែលផ្តល់ដល់រដ្ឋាភិបាល និង NBPS ហើយការទិញរបស់ធនាគារនូវមូលបត្រនៅផ្សារហ៊ុនក៏បង្កើតបានជារូបិយវត្ថុផងដែរ។ ដូច្នេះ កត្តាចលកនៃកំណើនរូបិយវត្ថុ គឺជាតម្រូវការប្រាក់កម្ចីរបស់រដ្ឋ និង NBPS និងការសម្រេចចិត្តរបស់ធនាគារ ដើម្បីទិញមូលបត្រពីផ្សារហ៊ុន (=ជាទូទៅ គឺជាកត្តាតូចតាច)។ តើអ្នកដឹងទេថា ធនាគារកណ្តាលមានឧបករណ៍ក្នុងដៃក្នុងការគ្រប់គ្រងលើការបង្កើតរូបិយវត្ថុ ហើយទាំងនេះគឺជាលក្ខខណ្ឌទុនបម្រុងពោលគឺ KIR និង OMO (r ក៏អាចផ្លាស់ប្តូរដែរ ប៉ុន្តែគេកម្រប្រើណាស់)។

ផ្អែកតាមគំរូសហគ្រាសរបស់ RR លក្ខខណ្ឌទុនបម្រុងត្រូវបានប្រើ ដើម្បីទប់ស្កាត់កំណើន M3 លើបរិមាណតាមរយៈការបង្កើតបរិមាណធនបម្រុងដែលត្រូវការទុនបម្រុងលើស(ER)តាម រយៈការទិញពី OMO ។ កម្រិតអត្រាការប្រាក់ គឺអាចរកឃើញដោយផ្ទាល់ (ឬគួរតែដូច្នោះ ពីព្រោះធនាគារកណ្តាលមិនអាចគ្រប់គ្រងទាំងពីរបានដោយមិនបង្កើតនូវអនិរន្តរភាពក្នុងការការបង្វែរនោះទេ)។

ផ្អែកតាមគំរូសហគ្រាសធនាគារ RR ឧបករណ៍ប្រតិបត្តិការសំខាន់ គឺអត្រាការប្រាក់កម្ចី របស់ធនាគារកណ្តាល(KIR-L)ដែលផ្តល់ទៅដល់ធនាគារប្រកបដោយប្រសិទ្ធភាព ដោយធានាឱ្យមានកង្វះខាតសាច់ប្រាក់ងាយស្រួលតាមរយៈ OMO គ្រប់ពេលវេលា(ពោលគឺធនាគារកណ្តាលរក្សាបើកចំហឱ្យមានប្រាក់កម្ចីដល់ធនាគារគ្រប់ពេល)។ "ការធ្វើឱ្យមានប្រសិទ្ធភាព" នូវប្រព័ន្ធឆ្លងកាត់ KIR តាមអត្រាគោលរបស់ធនាគារ (និងរាល់អត្រាផ្សេងទៀត និងអត្រាប្តូរប្រាក់ ដែលជះឥទ្ធិពលលើតម្រូវការប្រាក់កម្ចី (ជាកត្តាចលករដ៏ចម្បងក្នុងការបង្កើតរូបិយវត្ថុ)។

គំរូ IBR គឺស្រដៀងនឹងគំរូសហគ្រាសធនាគារ BR ដែរ។ ប៉ុន្តែវាផ្តោតទៅលើអត្រាអន្តរធនាគារ របស់ធនាគារ និងជះឥទ្ធិពលលើវានៅត្រង់លក្ខខណ្ឌទាំងលើអតិរេកសាច់ប្រាក់ងាយស្រួលរបស់ធនាគារទុនបម្រុងលើស (ER) និងកង្វះសាច់ប្រាក់ងាយស្រួលរបស់ធនាគារបម្រុង។ ដូចករណីមុនដែរ គំរូនេះក៏មានគោលបំណងជាអវសាន្ត គឺដើម្បីធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើអត្រាប្រាក់កម្ចីរបស់ធនាគារ (និងអត្រាប្តូរប្រាក់ និងអត្រាផ្សេងទៀត) និងជះឥទ្ធិពលលើតម្រូវការ។ មានកស្តុតាងបង្ហាញថា ផ្អែកតាមគំរូពីរចុងក្រោយលក្ខខណ្ឌទុនបម្រុង (ដូចដែលយើងបានឃើញស្រាប់ហើយវាមិនមាននៅគ្រប់ករណីទាំងអស់) គឺជាធាតុ*មិនសំខាន់* មួយនៅក្នុងការបង្កើតរូបិយវត្ថុ។ វាគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលជះឥទ្ធិពលលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារដូចដែលបានរៀបរាប់លម្អិតពីខាងដើមប៉ុណ្ណោះ។

ជាចុងក្រោយ មុនពេលដែលយើងឈានដល់យន្តការនៃការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM)ដែលកាន់តែមានសារសំខាន់(ជាងមុន)នោះ អាជ្ញាធររូបិយវត្ថុ (ធនាគារកណ្តាល និងរតនាគារ) មិនតែងតែដោះស្រាយបញ្ហាបានត្រឹមត្រូវជានិច្ចទេ។ គេសន្មតថាធនាគារនឹងផ្តល់ប្រាក់កម្ចីដល់អតិថិជនដែលអាចជឿទុកចិត្តបាន និងសម្រាប់គម្រោងដែលអាចដំណើរការបាន។ ធនាគារកណ្តាល មានឧបករណ៍គ្រប់យ៉ាងដើម្បីទប់ស្កាត់កំណើនរូបិយវត្ថុហួសកម្រិត។ ប្រព័ន្ធនេះ គឺជាប្រព័ន្ធមួយដ៏ល្អប្រសើរមួយ ពីព្រោះវាតែងមានរូបិយវត្ថុជានិច្ចដែលបានរំដោះសេដ្ឋកិច្ចចេញពីបញ្ហាកង្វះខាតរូបិយវត្ថុយ៉ាងតឹងតែង (កាក់មាស និងមាសគីឡូ) កាលពីមុន ប៉ុន្តែមាន ភស្តុតាងជាច្រើនដែលបង្ហាញថាអាជ្ញាធរមិនមានការទទួលខុសត្រូវគ្រប់គ្រាន់...ផលវិបាក គឺជារឿងមួយដ៏ឈឺចាប់។ ថាតើត្រូវមានគំរូអនុវត្តថ្មីមួយ ដែលត្រូវគិតគូរពីភាពបត់បែនសេដ្ឋកិច្ចដែរឬទេ? គំរូមួយទាក់ទងនឹងការខ្ចីប្រាក់របស់ធនាគារពីរដ្ឋាភិបាលនៃបណ្តាប្រទេសក្រីក្រសម្រាប់គម្រោងអភិវឌ្ឍន៍អាចកើតឡើងក្នុងទំហំមួយ ដែលប្រាក់កម្ចីបង្កើតឱ្យមានប្រាក់ចំណូលសម្រាប់ចំណាយលើអត្រាការប្រាក់កម្ចីដោយសន្មតថាសេដ្ឋកិច្ចក្នុងស្រុកអាចផលិតទំនិញបាន(សម្រាប់តម្រូវការអភិវឌ្ឍ?)

៦.៥- ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ: អត្រាការប្រាក់ និងអតិផរណា

(MONETARY POLICY: FROM INTEREST TO INFLATION)


យើងអាចចូលមើលគេហទំព័ររបស់ធនាគារកណ្តាល វានឹងបង្ហាញអំពីគោលបំណងនៃគោលនយោបាយរូបិយវត្ថុ ត្រូវបានអនុវត្តឡើងជាមួយនឹងការកំណត់គោលដៅសំខាន់ គឺថាអតិផរណាគួរតែត្រូវបានកាត់បន្ថយ។ ហេតុផលនៃគោលបំណងនេះ គឺការកំណត់គោលដៅអតិផរណា (inflation tar-geting) ពេលគឺរក្សារកម្រិតអតិផរណាឱ្យទាបពី ២% ទៅ ៣% ក្នុង១ឆ្នាំ អាចជួយដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ កម្រិតអតិផរណាខ្ពស់ អាចបំផ្លិចបំផ្លាញដល់កំណើនសេដ្ឋកិច្ច ពីព្រោះអាចធ្វើឱ្យមានការប្រែប្រួលក្នុងការសម្រេចចិត្តប្រើប្រាស់ និងវិនិយោគរបស់ភ្នាក់ងារគ្រួសារដែលប្រាស់ចាកពីប្រសិទ្ធភាពកត្តាផលិតកម្ម។ ជារឿយៗអតិផរណាតែងតែពង្រីកខ្លួនរបស់វា ហើយវាពិតជាលំបាកខ្លាំងណាស់ក្នុងការលុបវា។ ដើម្បីផ្តល់សារប្រយោជន៍ដល់គោលបំណងប្រទេសអភិវឌ្ឍន៍ភាគច្រើនលើពិភពលោកមានគោលដៅអតិផរណាដែលពួកគេត្រូវបានកំណត់ត្រឹម ២% ឬមានកម្រិត ២-៣% ប្រចាំឆ្នាំ (ឬមានគោលដៅបត់បែនដូចក្នុងករណីសហរដ្ឋអាមេរិក)។ ជាទូទៅ គោលដៅអតិផរណាត្រូវបានកំណត់ដោយរដ្ឋាភិបាល និងប្រតិបត្តិដោយធនាគារកណ្តាល ក្នុងករណីភាគច្រើនប្រតិបត្តិការឯករាជ្យពីរដ្ឋាភិបាល។ ការបែងចែកនេះជាមុខងាររវាងរដ្ឋាភិបាល និងធនាគារកណ្តាលត្រូវបានគេទទួលស្គាល់ជាទូទៅថាមានសារសំខាន់ពីរដ្ឋាភិបាល ពីព្រោះធនាគារកណ្តាល ត្រូវតែចាត់វិធានការគោល នយោបាយរូបិយវត្ថុប្រឆាំងនឹងសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាល (និងផ្សេងទៀត)។ ចំពោះប្រទេសមួយមានធនាគារកណ្តាល ធ្វើប្រតិបត្តិការមិនឯករាជ្យជាមួយរដ្ឋាភិបាលមិនត្រូវបានគេទទួលស្គាល់នេះទេ។ កម្រិតអតិផរណាចន្លោះពី ២-៣% ប្រចាំឆ្នាំត្រូវបានគេចាត់ទុកថាអាចទទួលយកបាន ពីព្រោះក្នុងកម្រិតនេះកំណើនសេដ្ឋកិច្ច និងការពឹងទុកក្នុងការបង្កើតទ្រព្យសម្បត្តិមានភាព


ល្អប្រសើរបំផុត។ នៅក្នុងកម្រិតខ្ពស់ និងកម្រិតទាបនៃផលប៉ះពាល់នៃការការពារ ឬការការពារទ្រព្យសម្បត្តិប្រជាជាតិចូលបានបញ្ចូលក្នុងសមីការផលិតផលជាតិសរុប។ មូលហេតុចម្បងនៃអតិផរណាខ្ពស់ដែលមិនអាចទទួលយកបាន គឺតម្រូវការសរុប [C + I + x - M = GDP (ចំណាយ)] ហួសសមត្ថភាពសេដ្ឋកិច្ចដើម្បីផ្តល់ (ការផ្គត់ផ្គង់សរុប)។ ផ្អែកលើកំណើនតម្រូវការនិងការផ្គត់ផ្គង់ គឺជាសមត្ថភាពរបស់ប្រព័ន្ធធនាគារក្នុងការបង្កើតរូបិយវត្ថុ។ មូលហេតុចម្បងបរិត្តផរណាគឺនៅទ្រឹង ឬបង្កើតរូបិយវត្ថុអវិជ្ជមាន។ ការកើនឡើងការបង្កើតរូបិយវត្ថុ គឺជាតម្រូវការប្រាក់កម្ចីរបស់រដ្ឋាភិបាលវិស័យនិយោគ និងភ្នាក់ងារគ្រួសារ ហើយការកើនឡើងនៃតម្រូវការប្រាក់កម្ចី គឺជាអត្រាការប្រាក់គោលរបស់ធនាគារ។ សម្រាប់វិស័យសាជីវកម្ម និងភ្នាក់ងារគ្រួសារមានអត្រាការប្រាក់របស់ធនាគារពិសេស។

អត្រាការប្រាក់កម្ចីរបស់ធនាគារ (lending rate of bank) ត្រូវបានកំណត់ (ក្នុងករណីភាគច្រើន) ជាប្រតិបត្តិការទីផ្សារបើកចំហ(OMO) ដើម្បីមានឥទ្ធិពលទៅលើសាច់ប្រាក់ងាយស្រួលធនាគារ និងអត្រាការប្រាក់ដែលបានកំណត់ដោយធនាគារកណ្តាល សម្រាប់ប្រាក់កម្ចីរបស់ពួកគេទៅឱ្យធនាគារ (KIR-L) ឬសម្រាប់ប្រាក់បម្រុងលើស(KIR-D)។ អ្វីដែលសំខាន់ខាងលើ គឺជាមាគ៌ានៃគោលនយោ- បាយរូបិយវត្ថុបញ្ច្រាស។ ឥឡូវនេះ យើងពិពណ៌នាសង្ខេបនូវអ្វីដែលគេហៅថាយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ(MPTM) ចាប់ផ្តើមពីអត្រារបស់ធនាគារកណ្តាល និងបញ្ចប់ដោយអត្រាអតិផរ-ណា។

នៅលើគេហទំព័ររបស់ធនាគារកណ្តាល នឹងបង្ហាញពីយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM) ភាគច្រើន ហើយមានរូបភាពបង្ហាញពីទស្សនៈរបស់ពួកគេអំពី MPTM ពោលគឺជាមាគ៌ាពីអត្រារបស់ធនាគារកណ្តាលទៅការអភិវឌ្ឍកម្រិតថ្លៃ (=អតិផរណា ឬបរិត្តផរណា)។ សូមមើលរូបភាពទី៥ គឺជាការបញ្ចូលគ្នានៃចំណុចខ្លះក្នុងចំណោមពួកគេ។ មុននឹងយើងចាប់ផ្តើមជាមួយនឹងការពន្លឿនយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM) យើងត្រូវតែបញ្ជាក់ពីតថភាពជាក់ស្តែងដែលការបញ្ជូនមានការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុអាចចំណាយពេលពី១ទៅ២ឆ្នាំ ដើម្បីឱ្យមានឥទ្ធិពលលើការអភិវឌ្ឍតម្លៃ។

គំនូសតាងទី១០ បង្ហាញពីៈ យន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM)





លោកុប្បត្តិនៃអត្រាការប្រាក់ គឺអត្រាកំណត់គ្រប់គ្រងដោយធនាគារកណ្តាល[៨៣]។ ដូចយើងបានឃើញហើយថា ធនាគារកណ្តាលមួយចំនួនមានអត្រាផ្លូវការមួយគឺ KIR-L ត្រូវបានអនុវត្តចំពោះកង្វះខាតសាច់ប្រាក់ងាយស្រួល ហើយធនាគារកណ្តាលខ្លះទៀតមានអត្រាផ្លូវការចំនួនពីរ គឺអត្រាដែលត្រូវបានបញ្ជាក់ និងអត្រាប្រាក់បញ្ញើសម្រាប់ផ្នែកបន្ថែម KIR-D។ គំរូម៉ូដែលទាំងពីរនេះ មានឥទ្ធិពលដោយផ្នាល់លើអត្រា b2b-IBM ដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់អត្រាការប្រាក់របស់ធនាគារ (ជាពិសេសអត្រាការប្រាក់បញ្ញើប្រចាំថ្ងៃ)។ អត្រាប្រាក់បញ្ញើផ្សេងទៀតរបស់ធនាគារ ក៏មានប៉ះពាល់ដោយសារតែអត្រានេះដែរ។ កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារ ដើម្បីស្វែងរកប្រាក់ចំណេញឱ្យបានច្រើនបំផុតសម្រាប់ម្ចាស់ភាគហ៊ុន ដោយព្យាយាមរក្សាកម្រិតមធ្យមភាគរវាងថ្លៃដើមនៃប្រាក់បញ្ញើ ឬប្រាក់កម្ចី និងប្រាក់ចំណូលលើទ្រព្យសកម្ម។ ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់ផ្លូវការមានផលប៉ះពាល់យ៉ាងខ្លាំងដល់អត្រាការប្រាក់កម្ចីរបស់ធនាគារ។

អត្រាពង្រីកប្រាក់កម្ចីប្រាក់ចំណេញខ្ពស់របស់ធនាគារ គឺជាអត្រាការប្រាក់គោលរបស់ធនាគារ។ រាល់អត្រាប្រាក់កម្ចីរបស់ធនាគារសម្រាប់ NMD ត្រូវបានកំណត់ជាមូលដ្ឋាននៅលើអត្រាការប្រាក់គោលរបស់ធនាគារ(PR)។ អត្រាបំណុលដែលអាចលក់បាន (ដូចជាវិក្កយបត្ររតនាគារ និងប័ណ្ណពាណិជ្ជ) ក៏មានឥទ្ធិពលគួរឱ្យកត់សម្គាល់ផងដែរ។ ជាទូទៅការផ្លាស់ប្តូរ KIR របស់ធនាគារកណ្តាលត្រូវបាន ផ្តួផ្តងដោយការផ្លាស់ប្តូរអត្រាការប្រាក់កម្ចីរបស់ធនាគារ។ អត្រាប្រាក់កម្ចីធនាគារ គឺជាធាតុចូលដ៏សំខាន់ក្នុងការសម្រេចចិត្តក្នុងការខ្ចីប្រាក់។ បុគ្គលខ្ចីប្រាក់ពីធនាគារ និងអ្នកប្រើប្រាស់ក្នុងការរំពឹងទុកនៃប្រាក់ចំណូលរបស់ពួកគេនាពេលអនាគត។ ក្រុមហ៊ុនខ្ចីប្រាក់សម្រាប់គោលបំណងពង្រីកអាជីវកម្ម (ស្តុក ទំនិញ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធអាជីវកម្ម)។

វិស័យធនាគារឆ្លើយតបទៅនឹងតម្រូវការប្រាក់កម្ចី និងបង្កើតរូបិយវត្ថុ(ប្រាក់បញ្ញើ) ផ្តល់ជូនដល់បុគ្គលដែលគួរឱ្យកម្ចី (មានការងារធ្វើនឹងអាចសងបំណុលបាន) ហើយក្រុមហ៊ុនកំពុងខ្ចីប្រាក់សម្រាប់គម្រោងថ្មីៗដែលលំហូរសាច់ប្រាក់ ឬត្រឡប់មកវិញ(FVs) នាពេលអនាគតលើសពីតម្លៃនៃកម្ចីប្រាក់។

ការកើនឡើងអត្រាការប្រាក់នឹងធ្វើឱ្យបុគ្គលកាន់តែច្រើនមិនសម្រេចចិត្តខ្ចីប្រាក់ និងគម្រោងជាច្រើនទៀត ដែលមិនអាចទទួលយកបានត្រូវបានកាត់បន្ថយអត្រាកំណើនវិនិយោគខណៈពេលអត្រាការប្រាក់ធ្លាក់ចុះនឹងធ្វើឱ្យមានកើនឡើងគម្រោងវិនិយោគ។ ការខ្ចីប្រាក់ឬការបង្កើតប្រាក់ គឺកត្តាចម្បងក្នុងការផ្លាស់ប្តូរតម្រូវការក្នុងស្រុក។

មិនមែនសុទ្ធតែបុគ្គល និងក្រុមហ៊ុនទាំងអស់ខ្ចីប្រាក់ពីវិស័យធនាគារនោះទេ។ សាធារណជនមួយចំនួនធំ គឺក៏ជាអ្នកផ្តល់កម្ចី ឬអ្នកសន្សំ និងអត្រាការប្រាក់សម្រាប់ពួកគេក៏មានសារសំខាន់សម្រាប់អ្នកខ្ចីផងដែរ។ អត្រាការប្រាក់ទាបធ្វើឱ្យការសន្សំមិនសូវមានការទាក់ទាញទេ រីឯការចំណាយកាន់តែមានភាពទាក់ទាញខ្លាំង។ ការនិយាយគ្នាក៏អនុវត្តនេះដែរ។ ការផ្លាស់ប្តូរអត្រាផ្លូវការមានផលប៉ះពាល់

[៨៣] *Here we ignore the firm_RR model, where is essentially a theoreticsl model rarely applied today*

ភ្លាមៗទៅលើតម្លៃទ្រព្យផ្សេងទៀត។ ទាំងនេះជាអ្វី? ទាំងនេះ គឺជាតម្លៃនៃទ្រព្យសកម្មក្រៅពីតម្លៃទ្រព្យសម្បត្តិរបស់ធនាគារមានដូចជាសញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន (ភាគហ៊ុន) ទ្រព្យសម្បត្តិ និងទំនិញ។ លើកលែងតែប្រភេទទំនិញបានលើកឡើងនេះ (សញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន និងទ្រព្យសម្បត្តិ) ដែលប្រភេទទំនិញទាំងនេះមានលំហូរសាច់ប្រាក់នាពេលអនាគត។ អ្នកនឹងចាំបានថាតម្លៃបច្ចុប្បន្ន (= PV) លំហូរសាច់ប្រាក់នាពេលអនាគត (FV) ត្រូវបានបញ្ចុះអប្បហារដោយអត្រាការប្រាក់ជាក់លាក់ដែលទាក់ទងទៅនឹង (PV)។ ដូច្នេះនៅពេលដែលអត្រាការប្រាក់កើនឡើង នោះធ្វើឱ្យតម្លៃទ្រព្យសកម្មមានការធ្លាក់ចុះ ហើយករណីនេះបញ្ច្រាស់គ្នាវិញ។

ប្រភេទទំនិញដូចជា (សញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន និងទ្រព្យសម្បត្តិ) មិនមានលំហូរសាច់ប្រាក់នាពេលអនាគតទេ។ ប៉ុន្តែអត្រាការប្រាក់ខ្ពស់ធ្វើឱ្យវាមិនសូវទាក់ទាញការវិនិយោគ ហើយផ្ទុយទៅវិញអត្រាទាបធ្វើឱ្យមានការទាក់ទាញវិនិយោគ។ ដោយសារតែបុគ្គល និងក្រុមហ៊ុនគឺជាម្ចាស់ទ្រព្យសម្បត្តិនៃប្រព័ន្ធហិរញ្ញវត្ថុ (ដោយផ្ទាល់ឬដោយប្រយោលតាមរយៈវិស័យធនាគារ និងវិស័យវិនិយោគ) តម្លៃនៃទ្រព្យសកម្មមានឥទ្ធិពលយ៉ាងខ្លាំងទៅលើតម្រូវការក្នុងស្រុក (C + I)។

ការផ្លាស់ប្តូរអត្រាផ្លូវការរបស់ធនាគារកណ្តាលក៏ជះឥទ្ធិពលដល់ការរំពឹងទុក និងកម្រិតទំនុកចិត្តរបស់ក្រុមហ៊ុន និងបុគ្គល ដែលមានឥទ្ធិពលលើតម្រូវការក្នុងស្រុក។ ផលប៉ះពាល់ទាំងនេះ ក៏មានជះឥទ្ធិពលដល់វិស័យបរទេសផងដែរ។ ដូច្នេះ អត្រាប្តូរប្រាក់ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើតម្រូវការខាងក្រៅសុទ្ធ (X - M) និងតម្លៃការនាំចូល។ ការផ្លាស់ប្តូរតម្រូវការក្នុងស្រុកមានផលប៉ះពាល់ដល់វិស័យការងារ។ ប្រសិនបើ មានសម្ពាធទៅលើការផ្គត់ផ្គង់ផ្នែកជំនាញ វាមានសម្ពាធលើប្រាក់ឈ្នួលពលកម្មដែលជាផលប៉ះពាល់ដល់តម្លៃរបស់អ្នកប្រើប្រាស់។

ដូចដែលបានឃើញហើយចំណុចទាំងអស់ខាងលើ គឺជាកត្តាសំខាន់នៃតម្រូវការក្នុងស្រុក ហើយប្រព័ន្ធធនាគារ ជួយដល់តម្រូវការតាមរយៈការផ្តល់ប្រាក់កម្ចី [ការពេញចិត្តប្រាក់កម្ចីគឺសមភាគីនៃប្រាក់បញ្ញើធនាគារថ្មី (=ប្រាក់)]។ សមត្ថភាពសេដ្ឋកិច្ចក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាកម្មថ្មីៗ ដើម្បីបំពេញតម្រូវការកើនឡើងគឺជាកត្តាដ៏សំខាន់។

គម្លាតកាន់តែធំរវាងតម្រូវការសរុប(=សរុប) និងការផ្គត់ផ្គង់សរុប គឺជាកត្តាចម្បងក្នុងការអភិវឌ្ឍតម្លៃ (price developments)។ ការប្រែប្រួលតម្លៃទំនិញនាំចូលទៅមុខងារមួយនៃអត្រាប្តូរប្រាក់ គឺជាកត្តាដ៏សំខាន់មួយ ប៉ុន្តែកត្តានេះ អាស្រ័យលើទំហំតម្រូវការខាងក្រៅសុទ្ធទាក់ទងងតម្រូវការក្នុងស្រុក។ រង្វិលជុំសេដ្ឋកិច្ច ត្រូវបានបញ្ចប់នៅពេលដែលមនុស្សម្នាក់ពិចារណាថា ការអភិវឌ្ឍតម្លៃជាផលប៉ះពាល់ដល់ការសម្រេចចិត្តគោលនយោបាយរូបិយវត្ថុ។

ពាក្យចុងក្រោយ ក្នុងខែសីហា ឆ្នាំ២០០៧ យើងបានឃើញផ្នែកដ៏អាក្រក់នៃប្រព័ន្ធរូបិយវត្ថុ។ ការបង្កើតរូបិយវត្ថុ គឺមានច្រើនពេកហើយយើងបានឃើញអតិផរណាកើនឡើងនៅទូទាំងពិភពលោកដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃតម្លៃទំនិញអន្តរជាតិ ដូចជា ប្រេង ចំណីអាហារ ដែកថែប ជាដើម។

អ្នកបានដឹងហើយថា វាមានទំហំធំ (នៅសហរដ្ឋអាមេរិក) ដោយផ្អែកលើការផ្តល់ប្រាក់កម្ចីរបស់ធនាគារឱ្យដល់អ្នកខ្ចីដែលមិនគួរឱ្យគោរព។ នេះគឺការបរាជ័យមិនត្រឹមតែជំហរនៃការជឿទុកចិត្តដែល

ធនាគារកាន់កាប់ប្រាក់នោះទេ ដោយសារតែសមត្ថភាពរបស់ធនាគារក្នុងការបង្កើតរូបិយវត្ថុ ពីព្រោះសាធារណជនជាទូទៅទទួលយកប្រាក់បញ្ញើធនាគារដោមធ្យោបាយទូទាត់ប្រាក់ដ៏សំខាន់ ប៉ុន្តែក៏ជាការបារាជ័យរបស់អ្នកចូលរួមសម្ព័ន្ធភាពមួយចំនួននៅក្នុងប្រព័ន្ធរូបិយវត្ថុ៖

ធនាគារកណ្តាល នៅក្នុងការអនុវត្តមិនមានប្រសិទ្ធិភាពនៃគោលនយោបាយរូបិយវត្ថុ និយតករធនាគារដែលមិនបានត្រួតពិនិត្យធនាគារឱ្យមានប្រសិទ្ធភាព និងទីភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់ប្រាក់កម្ចីមួយចំនួនធំ ដែលត្រូវបានបិទបាំងដោយប្រាក់ចំណូល ដែលបានមកពីការវាយតម្លៃបំណុលទ្រព្យសម្បត្តិ ឬអង្គភាព ដែលមានគោលបំណងពិសេស (SPVs/SPEs) ហើយភ្លេចទំនាស់ផលប្រយោជន៍ដែលពួកគេមាន។ ជាក់ស្តែងនេះ មិនបានអនុវត្តចំពោះប្រទេសទាំងអស់ទេ។ ប៉ុន្តែយើងមិនត្រូវភ្លេចពីពេលវេលាល្អៗ មុនសម័យកាលនេះទេ នៅពេលដែលការបង្កើតទ្រព្យសម្បត្តិមិនធ្លាប់មានពីមុនមក។ នេះ គឺជាផ្នែកដ៏ប្រណិតនៃប្រព័ន្ធរូបិយវត្ថុដែលអាចធ្វើទៅបានដោយអព្ភូតហេតុនៃការបង្កើតរូបិយវត្ថុ។

សរុបរួម គោលនយោបាយរូបិយវត្ថុចាំបាច់ត្រូវបានគិតទុកជាមុន៖សម្រាប់ហេតុផលនេះធនាគារ កណ្តាលប្រើគំរូអេកូណូមេទ្រីក ដែលមានលក្ខណៈទំនើបសម្រាប់ការត្រួតពិនិត្យឡើងវិញ។ គោលនយោបាយរូបិយវត្ថុ គឺដំណើរការគ្រប់គ្រងបរិមាណការផ្គត់ផ្គង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ច ដើម្បីសម្រេចបាននូវគោលដៅម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជាការបន្ទាបអត្រាអតិផរណា ការបង្កើនកម្មភាពនិងកំណើនសេដ្ឋកិច្ច។ សម្រាប់គោលដៅមួយផ្សេងទៀតនៃគោលនយោបាយរូបិយវត្ថុ គឺជាការបង្កើនបរិ-មាណរូបិយវត្ថុ អត្រាប្តូរប្រាក់ បរិមាណរូបិយវត្ថុ និងគុណភាពនៃការឱ្យខ្ចី ស្ថានភាពនៅលើទីផ្សារមូលបត្រ តម្រូវការសរុបរបស់សេដ្ឋកិច្ច និងលំហូរមូលនិធិឆ្លងដែន។ល។

៦.៦-ការវិនិយោគ(INVESTING)

ការវិនិយោគ គឺជាអថេរសំខាន់បំផុតមួយក្នុងសេដ្ឋកិច្ច។ នៅពីក្រោយការវិនិយោគមនុស្សបានធ្វើដំណើរចេញពីរូងភ្នំរហូតដល់អាគារខ្ពស់ៗ។ ការកើនឡើង និងការដួលរលំនៃការវិនិយោគនៅតែជាបុព្វហេតុចម្បងនៃវិបត្តិសេដ្ឋកិច្ច។ ការវិនិយោគបានធ្លាក់ចុះយ៉ាងខ្លាំងស្ទើរតែក្នុងអំឡុងពេលទាំងមូលនៃវិបត្តិសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក។

តើការវិនិយោគគឺជាអ្វី?

តាមរយៈការវិនិយោគ សេដ្ឋវិទូមានន័យថាការផលិតទំនិញសម្រាប់ប្រើប្រាស់ដើម្បីផលិតទំនិញមួយទៀត។ និយមន័យនេះគឺខុសគ្នាពីការប្រើប្រាស់ដែលកំពុងមានការពេញនិយម ដែលក្នុងនោះការសម្រេចចិត្តក្នុងការទិញហ៊ុន (សូមមើល**ផ្សារហ៊ុន**) ឬ**សញ្ញាបណ្ណ**ត្រូវបានគិតថាជាការវិនិយោគ។

ការវិនិយោគជាធម្មតា គឺជាផលពីការប្រើប្រាស់មុនៗ។ នៅក្នុងសង្គមកសិកម្មសុទ្ធសាធមនុស្សសម័យដើមត្រូវជ្រើសរើសថាតើត្រូវបរិភោគគ្រាប់ធញ្ញជាតិប៉ុន្មានក្រោយពេលប្រមូលផល ហើយត្រូវសន្សំ ទុកប៉ុន្មានសម្រាប់ដាំដុះនាពេលអនាគត។ ជម្រើសចុងក្រោយគឺជាការវិនិយោគ។ នៅក្នុងសង្គមសម័យទំនើបខ្លាំង យើងបែងចែកសមត្ថភាពផលិតរបស់យើងដើម្បីផលិតទំនិញប្រើប្រាស់សុទ្ធ ដូចជា

នំហាំប៊ឺហ្គឺ និងសាច់ក្រក hot dogs រួមទាំងទំនិញវិនិយោគនានា ដូចជារោងសិប្បកម្មផលិតគ្រឿងអេឡិចត្រូនិក។ ប្រសិនបើយើងផលិតនំហាំប៊ឺហ្គឺមានតម្លៃមួយដុល្លារនៅថ្ងៃនេះ នោះផលិតផលជាតិសរុបរបស់យើងគឺខ្ពស់ជាងប្រាក់មួយដុល្លារ។ ប្រសិនបើយើងបង្កើតរោងសិប្បកម្មផលិតគ្រឿងអេឡិចត្រូនិកមានតម្លៃមួយដុល្លារនៅថ្ងៃនេះ នោះផលិតផលជាតិសរុបគឺខ្ពស់ជាងប្រាក់មួយដុល្លារ ប៉ុន្តែវាក៏នឹងខ្ពស់ជាងនៅឆ្នាំក្រោយដែរ ពីព្រោះរោងសិប្បកម្មផលិតគ្រឿងអេឡិចត្រូនិកនេះនឹងនៅតែផលិតបន្ទះឈីបកុំព្យូទ័របន្ទាប់ពីហាំប៊ឺហ្គឺលែងមានជាយូរមកហើយ។ នេះជារបៀបដែលការវិនិយោគនាំទៅរក**កំណើនសេដ្ឋកិច្ច**។ បើគ្មានការវិនិយោគ ការរីកចម្រើនរបស់មនុស្សនឹងត្រូវបញ្ឈប់ជាក់ជាពុំខាន។

តើធនធានសម្រាប់វិនិយោគបានមកពីណា?

នៅក្នុងសេដ្ឋកិច្ចបិទខ្ទប់មួយពីពិភពខាងក្រៅ ការវិនិយោគអាចកើតចេញពីការប្រើប្រាស់ដែលត្រូវបានមើលរំលង នោះគឺ**ការសន្សំ**របស់បុគ្គលឯកជន ក្រុមហ៊ុនសហគ្រាសឯកជន ឬរដ្ឋាភិបាល។ ទោះយ៉ាងណានៅក្នុងសេដ្ឋកិច្ចបើកចំហ ការវិនិយោគអាចកើនឡើងក្នុងពេលតែមួយដែលការសន្សំរបស់ប្រទេសមួយមានកម្រិតទាប ពីព្រោះប្រទេសមួយអាចខ្ចីធនធានសម្រាប់វិនិយោគចាំបាច់ពីប្រទេសជិតខាង។ វិធីសាស្ត្រនៃការវិនិយោគហិរញ្ញប្បទាននេះមានសារសំខាន់ណាស់នៅសហរដ្ឋអាមេរិក។ មូលដ្ឋានឧស្សាហកម្មរបស់សហរដ្ឋអាមេរិកនៅសតវត្សរ៍ទី ១៩ ដូចជាផ្លូវដែក រោងចក្រ និងអ្វីផ្សេងទៀតត្រូវបានសាងសង់ដោយប្រើហិរញ្ញប្បទានពីបរទេស ជាពិសេសពីប្រទេសអង់គ្លេស។ ថ្មីៗនេះ សហរដ្ឋអាមេរិកបានប្រកាសផ្តួនៗនូវកំណើនវិនិយោគគួរឱ្យកត់សម្គាល់ និងការសន្សំទាបបំផុត។ ទោះយ៉ាងណា នៅពេលការវិនិយោគទទួលមូលនិធិពីខាងក្រៅ នោះផលទុនពីការវិនិយោគក៏ត្រូវបានផ្ទេរទៅខាងក្រៅផងដែរ។ ប្រទេសមួយដែលពឹងផ្អែកទាំងស្រុងលើហិរញ្ញប្បទានវិនិយោគបរទេសអាចកត់សម្គាល់ឃើញបន្តិចម្តងៗថាខ្លួនមាន ចំណូលមូលធនតិចតួចសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការប្រើប្រាស់នាពេលអនាគត។ ដូច្នេះ ប្រភពហិរញ្ញប្បទានវិនិយោគគឺជាក្តីកង្វល់ដ៏សំខាន់មួយ។ ប្រសិនបើហិរញ្ញប្បទានបានមកពីការសន្សំក្នុងស្រុក នោះផលទុនពីការវិនិយោគនឹងរក្សានៅក្នុងស្រុកនាពេល អនាគត។ ប្រសិនបើហិរញ្ញប្បទានបានមកពីការសន្សំបរទេស នោះផលទុនពីការវិនិយោគនាពេលអនាគតនឹងហូរចេញទៅក្រៅប្រទេស ហើយប្រទេសនេះនៅសល់ទ្រព្យសម្បត្តិតិចតួចប៉ុណ្ណោះ។

តើអ្វីដែលធ្វើឱ្យការវិនិយោគកើនឡើង និងធ្លាក់ចុះ?

ទ្រឹស្តីនៃការវិនិយោគមានតាំងពីដំនាន់មហាសេដ្ឋកិច្ច។ IRVING FISHER, ARTHUR CECIL PIGOU និង ALFRED MARSHALL សុទ្ធតែបានចូលរួមវិភាគទានទាំងអស់ ដូច JOHN MAYNARD KEYNES ដែរ ដែលទ្រឹស្តី Marshallian នៃការចំណាយរបស់អ្នកប្រើប្រាស់របស់គាត់មានលក្ខណៈពិសេសដ៏សំខាន់មួយនៅក្នុងទ្រឹស្តីទូទៅរបស់គាត់។ លើសពីនេះទៀត ការវិនិយោគគឺជាអថេរមួយក្នុងចំណោមអថេរដំបូងដែលបានសិក្សាជាមួយបច្ចេកទេសទំនើប។ ដូចដែលបានកើតឡើងរួចហើយនៅឆ្នាំ ១៩០៩ Albert Aftalion បានកត់សម្គាល់ថាការវិនិយោគមានទំនោរទៅរកវដ្តអាជីវកម្ម។

មានអ្នកនិពន្ធជាច្រើន រួមទាំងម្ចាស់ជ័យលាភីពានរង្វាន់ណូបែល TRYGVE HAAVELMO បានចូលរួមចំណែកក្នុងការលើកកម្ពស់ស្នាដៃស្រាវជ្រាវផ្នែកវិនិយោគបន្ទាប់ពីសង្គ្រាម។ លោក Dale Jorgenson បានបោះពុម្ពផ្សាយស្នាដៃសំយោគនេះដែលមានឥទ្ធិពលខ្ពស់ និងស្នាដៃមុនៗនៅឆ្នាំ ១៩៦៣ ។ ទ្រឹស្តីការវិនិយោគបែបនេអូក្លាស៊ិករបស់គាត់បានឆ្លងកាត់នឹងការធ្វើតេស្តសាកល្បងតាមពេលនីមួយៗ ពីព្រោះវាអនុញ្ញាតឱ្យអ្នកវិភាគគោលនយោបាយព្យាករណ៍ថាតើការកែប្រែគោលនយោបាយរបស់រដ្ឋាភិបាលមានផលប៉ះពាល់ដល់ការវិនិយោគយ៉ាងដូចម្តេច។ លើសពីនេះទៀត ទ្រឹស្តីនេះមានការទាក់ទាញខាងវិចារណញ្ញាណ និងជាឧបករណ៍ចាំបាច់សម្រាប់សេដ្ឋវិទូទាំងអស់។

សេចក្តីសន្និដ្ឋាន៖

គោលបំណងគោលនយោបាយសារពើពន្ធ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច រក្សាស្ថិរភាពថ្លៃ យុត្តិធម៌សង្គម និងរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចជាដើម។ គោលនយោបាយសារពើពន្ធនេះ អាចសម្រេចទៅបាន លុះត្រាតែយន្តការនៃគោលនយោបាយសារពើពន្ធដូចជា ការចំណាយសា-ធារណៈ ការកម្រិតពន្ធ ការខ្ចីប្រាក់ និងការផ្តល់នូវហិរញ្ញប្បទានឱនភាពថវិកា ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ភាពជោគជ័យនៃគោលនយោបាយសារពើពន្ធ អាស្រ័យលើការចាត់វិធានការទាន់ពេលវេលា និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការអនុវត្តនូវគោលនយោ-បាយនេះ។ ដូច្នេះ គោលនយោបាយសារពើពន្ធ រួមបញ្ចូលនូវសេចក្តីសំរេចពីរផ្សេងគ្នា គឺពាក់ព័ន្ធការចំណាយសាធារណៈ និងរចនាសម្ព័ន្ធពន្ធរបស់រដ្ឋាភិបាល។ ជាកត្តាសំខាន់ គឺសម្រាប់រក្សាការងារធ្វើពេញលេញដល់សង្គម ដើម្បីរក្សាមិនឱ្យមានកម្លាំងចលករនៅក្នុងសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះដែរ យន្តការនៃគោលនយោបាយសារពើពន្ធ មិនគ្រប់គ្រាន់ដើម្បីរក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែងនោះទេ ប៉ុន្តែចាំបាច់ត្រូវមានគោលនយោបាយរូបិយវត្ថុ ជាយន្តការបញ្ជាសពីគោលនយោបាយសារពើពន្ធ ដើម្បីកែខែកម្រិតអតិផរណាឡើងខ្ពស់។ ជាមួយនឹងយន្តការផ្សេងៗទៀត គោលនយោបាយសារពើពន្ធ ក៏មានឥទ្ធិពលលើស្ថិរភាពសេដ្ឋកិច្ច។

ឧទាហរណ៍៖ គោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលឥណ្ឌា បានទទួលជោគជ័យខ្លាំងក្នុងវិស័យសេវាកម្ម ដូចជាការកៀរគរធនធានសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយបង្កើនកម្រិតអត្រាសន្សំ ការបង្កើតដើមទុន ដើម្បីការអភិវឌ្ឍន៍ឧស្សាហកម្មខ្នាតតូច និងកាត់បន្ថយ អត្រានៃភាពក្រីក្រជាដើម។ ចំណែកឯ នៅប្រទេសម៉ាឡេស៊ី គេជឿជាក់ថាគោលនយោបាយ ពហុពន្ធភាព ដែលមានការពង្រីកកាន់តែច្រើន នឹងមិនបង្កឱ្យមានឱនភាពថវិកានោះទេ ប៉ុន្តែក៏មានឥទ្ធិពលកម្រិតមធ្យមទៅលើផលទុនជាតិសរុប ក្នុងសេដ្ឋកិច្ចរយៈពេលវែងដែរ។ ដូច្នេះ គេអាចនិយាយបានថា ទំហំនៃវិស័យសាធារណៈរបស់រដ្ឋាភិបាលកម្រិតខ្ពស់ជាង បើប្រៀបធៀបទៅនឹងវិស័យឯកជន។ គោលនយោបាយសារពើពន្ធ ក៏បានបញ្ជាក់ផងដែរថា រដ្ឋាភិបាល គួរតែធ្វើឱ្យមានការគ្រប់គ្រងកាន់តែប្រសើរឡើងលើវិស័យសាធារណៈ ដើម្បីគាំពារពន្ធ និងការចំណាយលើគោលការណ៍ហិរញ្ញវត្ថុ។ កំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ ក៏នឹងជះឥទ្ធិពលដល់តម្រូវការសរុបកាន់តែខ្ពស់នៃទំនិញសាធារណៈដែលត្រូវបានផ្តល់ឱ្យកាន់

តែមានប្រសិទ្ធភាពដោយរដ្ឋាភិបាល។ រដ្ឋាភិបាលប្រើគោលនយោបាយសារពើពន្ធ ដើម្បីមានឥទ្ធិពលលើតម្រូវការសរុបក្នុងសេដ្ឋកិច្ច ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវស្ថិរភាពថ្លៃ ភាពមានការងារពេញលេញ និងកំណើនសេដ្ឋកិច្ច។ តាមទស្សនៈសេដ្ឋវិទូលោក កេនស៍ បានណែនាំថា កំណើនការចំណាយរបស់រដ្ឋាភិបាល និងតំហយអត្រាពន្ធ គឺជាវិធីល្អបំផុតសម្រាប់ជំរុញតម្រូវការសរុប។ សេចក្តីណែនាំនេះ អាចអនុវត្តបានក្នុងពេលមានវិបត្តិសេដ្ឋកិច្ចឬសកម្មភាពសេដ្ឋកិច្ចរីកចម្រើនតិចតួច គោលនយោបាយសារពើពន្ធ ជាយន្តការដ៏សំខាន់មួយ សម្រាប់បង្កើតរចនាសម្ព័ន្ធ សម្រាប់កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងផ្តល់ភាពមានការងារពេញលេញ។ រដ្ឋាភិបាល អាចនឹងប្រើភាពលើសកញ្ចប់ថវិកា ដើម្បីកាត់បន្ថយល្បឿននៃកំណើនសេដ្ឋកិច្ចខ្លាំងក្លា និងធ្វើឱ្យមានស្ថិរភាពថ្លៃ ពេលមានអតិផរណាឡើងខ្ពស់។ តាមទ្រឹស្តីរបស់លោក កេនស៍ បានចែងបន្ថែមថា ការកាត់បន្ថយចំណាយក្នុងសេដ្ឋកិច្ចមួយនឹងនាំដល់ការថយចុះកម្រិតនៃតម្រូវការសរុប និងធ្វើឱ្យមានស្ថិរភាពថ្លៃ។

ទន្ទឹមនោះ មានសេដ្ឋវិទូជាច្រើន បានធ្វើការដកស្រង់ពីប្រសិទ្ធភាពនៃកម្លាំងជំរុញសារពើពន្ធ។ នៅពេលដែលរដ្ឋាភិបាលជួបនឹងឱនភាពថវិកា ផលទុនជាតិប្រមូលបានតាមរយៈកម្ចីសាធារណៈ(ការបង្កើតមូលបត្ររបស់រដ្ឋាភិបាល) ឬកម្ចីពីបរទេស។ រដ្ឋាភិបាលទប់ទល់នឹងឱនភាពតាមរយៈការបង្កើតនូវមូលបត្ររដ្ឋាភិបាល អត្រាការប្រាក់ អាចត្រូវបង្កើនឡើងនៅតាមទីផ្សារ ពីព្រោះកម្ចីរបស់ រដ្ឋាភិបាលបង្កើតតម្រូវការខ្ពស់ជាង សម្រាប់ឥណទានក្នុងទីផ្សារហិរញ្ញវត្ថុ។ បណ្តាលឱ្យតម្រូវការទំនិញនិងសេវាសរុបថយចុះ ដែលផ្ទុយទៅនឹងកម្លាំងជំរុញសារពើពន្ធ។

រដ្ឋាភិបាលប្រើគោលនយោបាយរូបិយវត្ថុ ដើម្បីមានឥទ្ធិពលលើតម្រូវការសរុបក្នុងសេដ្ឋកិច្ចក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវស្ថិរភាពថ្លៃ ភាពមានការងារពេញលេញ និងកំណើនសេដ្ឋកិច្ច។ *តាមទស្សនៈសេដ្ឋវិទូលោក កេនស៍ បានណែនាំថាកំណើនការចំណាយរបស់រដ្ឋាភិបាល និងតំហយអត្រាពន្ធ គឺជាវិធីល្អបំផុតសម្រាប់ជំរុញតម្រូវការសរុប*។ សេចក្តីណែនាំនេះ អាចអនុវត្តបានក្នុងពេលមានវិបត្តិសេដ្ឋកិច្ច ឬសកម្មភាពសេដ្ឋកិច្ចរីកចម្រើនតិចតួច គោលនយោបាយសារពើពន្ធជាយន្តការដ៏សំខាន់មួយ សម្រាប់បង្កើតរចនាសម្ព័ន្ធសម្រាប់កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងផ្តល់ភាពមានការងារពេញលេញ។ រដ្ឋាភិបាលអាចនឹងប្រើភាពលើសកញ្ចប់ថវិកា ដើម្បីកាត់បន្ថយល្បឿននៃកំណើនសេដ្ឋកិច្ចខ្លាំងក្លា និងធ្វើឱ្យមានស្ថិរភាពថ្លៃ ពេលមានអតិ-ផរណាឡើងខ្ពស់។ *តាមទ្រឹស្តីរបស់លោក កេនស៍ បានចែងបន្ថែមថា ការកាត់បន្ថយចំណាយក្នុងសេដ្ឋកិច្ចមួយ នឹងនាំដល់ការថយចុះកម្រិតនៃតម្រូវការសរុប និងធ្វើឱ្យមានស្ថិរភាពថ្លៃ*។

ទន្ទឹមនឹងនោះ មានសេដ្ឋវិទូជាច្រើន បានធ្វើការដកស្រង់ពីប្រសិទ្ធភាពនៃកម្លាំងជំរុញសារពើពន្ធ។ នៅពេលដែលរដ្ឋាភិបាលជួបនឹងឱនភាពថវិកា ផលទុនជាតិប្រមូលបានតាម រយៈកម្ចីសាធារណៈឬកម្ចីពីបរទេស។ រដ្ឋាភិបាលទប់ទល់នឹងឱនភា (ការបង្កើតមូលបត្ររបស់រដ្ឋាភិបាល) តាមរយៈការបង្កើតនូវមូលបត្ររដ្ឋាភិបាល អត្រាការប្រាក់ អាចត្រូវបង្កើនឡើងនៅតាមទីផ្សារ ពីព្រោះកម្ចីរបស់រដ្ឋាភិបាលបង្កើតតម្រូវការខ្ពស់ជាង សម្រាប់ឥណទានក្នុងទីផ្សារ ហិរញ្ញវត្ថុ។ បណ្តាលឱ្យតម្រូវការទំនិញនិងសេវាសរុបថយចុះ ដែលផ្ទុយទៅនឹងកម្លាំងជំរុញសារពើពន្ធ។

បណ្ណាល័យសាស្ត្រ

Ando, Albert, H. Eguchi, R. Farmer, and Y. Suzuki, eds. Monetary Policy in Our Times. Cambridge: MIT Press, 1985.

Bank of Canada. [Online.] available: www.bankofcanada.ca [Accessed: various dates].

Bank of England. [Online.] Available: www.bankofengland.co.uk [Accessed: various dates]

Bernstein, Michael. The Great Depression: Delayed Recovery and Economic Change in America, 1929-1939. New York: Cambridge University Press, 1987.

Best, Gary Dean. Pride, Prejudice, and Politics: Roosevelt Versus Recovery, 1933-1938. New York: Praeger, 1991.

Blake, D, 2000. Financial market analysis. Chichester: John Wiley & Sons Limited.

Bordo, Michael D. "Financial Crises, Banking Crises, Stock Market Crashes, and the Money Supply: Some International Evidence, 1870-1933." In Forrest Capie and Geoffrey E. Wood, eds., Financial Crises and the World Banking System. London: Macmillan, 1986.

Bordo, Michael D. "The Classical Gold Standard—Some Lessons for Today." Federal Reserve Bank of St. Louis Review 63, no. 5 (1981): 2-17.

Bordo, Michael D., and A. J. Schwartz, eds. "Transmission of Real and Monetary Disturbances Under Fixed and Floating Rates." Cato Journal 8, no. 2 (1988): 451-472.

Bordo, Michael D., and A. J. Schwartz, eds. A Retrospective on the Classical Gold Standard, 1821-1931. Chicago: University of Chicago Press, 1984. Especially "The Gold Standard and the Bank of England in the Crisis of 1847," by R. Dornbusch and J. Frenkel.

Bordo, Michael D., Claudia Goldin, and Eugene N. White, eds. The Defining Moment: The Great Depression and the American Economy in the Twentieth Century. Chicago: University of Chicago Press, 1998.

Brown, E. Cary. "Fiscal Policy in the Thirties: A Reappraisal." American Economic Review 46 (December 1956): 857-879.

Brunner, Karl, and Allan H. Meltzer. "An Aggregate Theory for a Closed Economy." In Jerome L. Stein, ed., Monetarism. New York: American Elsevier, 1976.

Brunner, Karl, ed. The Great Depression Revisited. Boston: Martinus Nijhoff, 1981.

Cole, Harold L., and Lee E. Ohanian. "New Deal Policies and the Persistence of the Great Depression: A General Equilibrium Analysis." Journal of Political Economy 112 (August 2004): 779-816.

Davies, G, 2002. History of money. Cardiff: University of Wales Press.

De Kock, MH, 1946. Central banking. London: Staples Press.

Eichengreen, Barry. Golden Fetters: The Gold Standard and the Great Depression, 1919-1939. New York: Oxford University Press, 1992.

European Central Bank. [Online.] Available: www.ecd.int. [Accessed: various dates].

Faura, AP, 1977. A money market analysis, South African Reserve Bank Quarterly Bulletin. September. Pretoria: South African Reserve Bank.

Faure, AP, 1995. Understanding the money market shortage. Paper written for clients of Alexander Securities (Pty) Limited. March. Stellenbosch: Alexander Securities (Pty) Limited.

Faure, AP, 2005. The financial system. Cape Town: Quoin Institute (Pty) Limited.

Faure, AP, 2008. Monetary policy: bank liquidity management. Cape Town: Quoin Institute.

Faure, AP, 2008. Monetary policy: money, its statistical causes and its real drivers. Cape Town: Quoin Institute.

Faure, AP, 2008. Monetary policy: transmission. Cape Town: Quoin Institute.

Federal Reserve Board. [Online.] Available: www.federalreserve.gov/fomc/ [Accessed: various dates].

Feldstein, Martin. "The Economics of the New Unemployment." Public Interest 33 (Fall 1973): 3–42.

Feldstein, Martin. "Why Is Productivity Growing Faster?" NBER Working Paper no. 9530. National Bureau of Economic Research, Cambridge, Mass., 2003.

Field, Alexander J. "Uncontrolled Land Development and the Duration of the Depression in the United States." Journal of Economic History 52 (June 1992): 785-805.

Fisher, Irving. The Theory of Interest. 1930. Reprint. Brookfield, Vt.: Pickering and Chatto, 1997. Available online at: http://www.econlib.org/library/YPDBooks/Fisher/fshToI.html

Ford, A. The Gold Standard, 1880-1914: Britain and Argentina. Oxford: Clarendon Press, 1962.

Friedman, M., and A. J. Schwartz. A Monetary History of the United States, 1867–1960. Princeton: Princeton University Press and National Bureau of Economic Research, 1963.

Friedman, Milton, and Anna Jacobson Schwartz. A Monetary History of the United States, 1867-1960. Princeton: Princeton University Press, 1963.

Friedman, Milton. "The Role of Monetary Policy." Presidential address at the Eightieth Annual Meeting of the American Economic Association, December 1967. American Economic Review 58, no. 1 (March 1968): 1–17.

Friedman, Milton. A Program for Monetary Stability. New York: Fordham University Press, 1959.

Further Reading

Glasner, David. Free Banking and Monetary Reform. New York: Cambridge University Press, 1989.

Goodhart, C. A. E. The Evolution of Central Banks. Cambridge: MIT Press, 1988.

Gowland, D, 1991. Money, inflation and unemployment. Herefordshire: Harvester Whealsheaf.

Greider, William. Secrets of the Temple: How the Federal Reserve Runs the Country. New York: Simon and Schuster, 1987.

Hall, Robert. "Employment Fluctuations and Wage Rigidity." Brookings Papers on Economic Activity 1 (1980): 91–141.

Hall, Thomas, and J. David Ferguson. The Great Depression: An International Disaster of Perverse Economic Policies. Ann Arbor: University of Michigan Press, 1998.

Hansen, Alvin. Full Recovery or Stagnation? New York: Norton, 1938.

Harrod, RD,1969. Money. London: Macmillan and Company Limited.

Higgs, Robert. "Regime Uncertainty: Why the Great Depression Lasted So Long and Why Prosperity Returned After the War." Independent Review 1 (Spring 1997): 561-590.

Higgs, Robert. "Wartime Prosperity? A Reassessment of the U.S. Economy in the 1940s." Journal of Economic History 52 (March 1992): 41-60.

Higgs, Robert. Crisis and Leviathan: Critical Episodes in the Growth of American Government. New York: Oxford University Press, 1987.

Howells, P. and Bain, K., 2002. The economics of money, banking and finance. Harlow, Essex: Reason Education Limited.

Humphrey, T. "The Choice of a Monetary Policy Framework: Lessons from the 1920s." Cato Journal 21, no. 2 (2001): 285–313.

Jevons, WS, 1875. Money and the mechanism of exchange. London: Kegan Paul, Trench & Co.

McCallum, Bennett T. Monetary Economics: Theory and Policy. New York: Macmillan, 1989.

Meijer, JH, 1992. Instrument of monetary policy. In Falkena, HB et al. (eds). Fundamentals of the South African financial system. Halfway house: Southern Book Publishers (Pty) Limited.

Meulendyke, Ann-Marie. U.S. Monetary Policy and Financial Markets. 1989. New York: Federal Reserve Bank of New York, 1998.

Mishin, FS, 2004. The economics of money, banking, and financial markets. Boston: pearson Addison-Wesley.

Morgan, EV, 1965. A history of money. Middlesex, England: Penguin Books.

Newlyn, WT, 1971. Theory of money. London: Oxford University Press.

O'Brien, Anthony Patrick. "A Behavioral Explanation for Nominal Wage Rigidity During the Great Depression." Quarterly Journal of Economics 104 (November 1989): 719-735.

Officer, L. “The Efficiency of the Dollar-Sterling Gold Standard, 1890-1908.” Journal of Political Economy 94 (1986): 1038-1073.

Patinkin, Don. “Interest.” In International Encyclopedia of the Social Sciences. Vol. 7. New York: Macmillan, 1968.

Peppers, Larry. “Full-Employment Surplus Analysis and Structural Change: The 1930s.”
, PJ, 1985. Monetary economics. London: Butterworth.

Pilbeam, K, 1998. Finance and financial market. London: Macmillan Press Limited.
Explorations in Economic History 10 (Winter 1973): 197-210.

Pierce, DG and Tysome Renaghan, Thomas. “A New Look at Fiscal Policy in the 1930s.” Research in Economic History 11 (1988): 171-183.

Reprinted as The Rationale of Central Banking and the Free Banking Alternative. Indianapolis: Liberty Fund, 1990. Available online at: http://www.econlib.org/library/LFBooks/SmithV/smvRCB.html

Rose, PR, 2000. Money and capital markets. Boston: Irwin McGraw-Hill.

Saint-Etienne, Christian. The Great Depression, 1929-1938: Lessons for the 1980s. Stanford: Hoover Institution Press, 1984.

Samuelson, Paul A. “Money, Interest Rates and Economic Activity: Their Interrelationship in a Market Economy.” In Robert C. Merton, ed., The Collected Scientific Papers of Paul A. Samuelson. Vol. 3. Cambridge: MIT Press, 1972. Originally published in American Bankers Association, Proceedings of a Symposium on Money, Interest Rates, and Economic Activity. New York, 1967.

Smal, MM and De Jager, S, 2001. The monetary transmission mechanism in South Africa. Occasional Paper No. 16, September. Pretoria: South African Reserve Bank.

Smiley, Gene. Rethinking the Great Depression: A New View of Its Causes and Consequences. Chicago: Ivan R. Dee, 2002.

Smith, V. C. The Rationale of Central Banking. Westminster: P. S. King and Son, 1936.

South Africa Reserve Bank, 2010. Quarterly Bulletin. Various.

South African Reserve Bank, 2004c. A consultative paper on: modifications to the money market operations of the South African Reserve Bank. Financial Markets Development. December. Pretoria: South African Reserve Bank.

South African Reserve Bank. [Online.] Available: www.reservebank.co.za. [Accessed: various dates].

Statues of the Republic of south Africa, 1989. South African Reserve Bank Act 90 of 1989. Pretoria: Government Printer.

Statues of The Republic South Africa, 1989. Constitution of the Republic of South Africa Third Amendment Act 26 of 1996. Pretoria: Government Printer.

Stein, ed., Monetarism. New York: American Elsevier, 1976.

Summers, Lawrence H. “Why Is the Unemployment Rate So Very High Near Full Employment?” Brookings Papers on Economic Activity 2 (1986): 339–383.

Summers, Lawrence H. Understanding Unemployment. Cambridge: MIT Press, 1990.

Summers, Lawrence H., and Kim B. Clark. “Labor Market Dynamics and Unemployment: A Reconsideration.” Brookings Papers on Economic Activity 1 (1979): 13–60.

Symposium: “Monetarism: Lessons from the Post-1979 Experiment.” American Economic Review Papers and Proceedings 74 (May 1984): 382–400.

Taylor, John B., ed. Monetary Policy Rules. Chicago: University of Chicago Press, 1999.

Temin, Peter, and Barrie Wigmore. “The End of One Big Deflation.” Explorations in Economic History 27 (October 1990): 483-502.

Temin, Peter. “Socialism and Wages in the Recovery from the Great Depression in the United States and Germany.” Journal of Economic History 50 (June 1990): 297-308.

Temin, Peter. Did Monetary Forces Cause the Great Depression? New York: Norton, 1976.

Temin, Peter. Lessons from the Great Depression. Cambridge: MIT Press, 1989.

Timberlake, R. H. Monetary Policy in the United States: An Intellectual and Institutional History. Chicago: University of Chicago Press, 1993.

Van der Merwe, EJ, 2004. Inflation targeting in South Africa. Occasional Paper No. 18, July. Pretoria: South African Reserve Bank.

Van Staden, B 1996. A new monetary analysis for South Africa. Pretoria: South African Reserve bank Quarterly Bulletin, Bulletin, March.

Van Staden, B, 1963. A monetary analysis for South A new analysis for South Africa.

Vedder, Richard K., and Lowell P. Gallaway. Out of Work: Unemployment and Government in Twentieth-Century America. New York: Holmes and Meier, 1993.

Walsh, Carl E. Monetary Theory and Policy. Cambridge: MIT Press, 1998.

Walton, Gary M., ed. Regulatory Change in an Atmosphere of Crisis: Current Implications of the Roosevelt Years. New York: Academic Press, 1979.

Warburton, Clark. Depression, Inflation, and Monetary Policy: Selected Papers, 1945–1953. Baltimore: Johns Hopkins University Press, 1966.

Weinstein, Michael. Recovery and Redistribution Under the NIRA. Amsterdam: North-Holland, 1980.

Wright, Gavin. “The Political Economy of New Deal Spending: An Econometric Analysis.” Review of Economics and Statistics 56 (February 1974): 30-38.